# បរិបទសង្គមនៃការបង្រៀននិងរៀន



**រៀបរៀងដោយ៖** គាំទ្រថវិកាលើការរៀបរៀង និពន្ធ និងកែលម្អដោយ៖

**“មូលនិធិការស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍”**

**២០២២**

**គណៈកម្មការនិពន្ធ៖**

១. លោកបណ្ឌិត សាំង មាសសួន

២. លោកស្រី អ៊ូ ស៊ីថា

៣. លោកស្រី ធុំ គន្ធី

៤. លោកស្រី ជិន ភីនី

៥. លោកស្រី អ៊ុយ វណ្ណៈ

៦. លោកស្រី គង់ ស្រីលីន

**គណៈកម្មការរចនាទំព័រ៖** លោកស្រី សំបាត់ អ៊ាត លោកស្រី ឈុំ ពៅ

**គណៈកម្មការត្រួតពិនិត្យ៖**

១. លោកបណ្ឌិត សំ ច័ន្ទកិរុណា

# បុព្វកថា

ដំណើរអភិវឌ្ឍនៃព្រះរាជាណាចក្រកម្ពុជានៅក្នុងយុគសម័យទំនើបនេះ ជាមេរៀនដ៏ជោគជ័យបំផុតមួយដែលចាប់ឬសគល់ចេញពីការបញ្ចប់របបប្រល័យពូជសាសន៍ ការបញ្ចប់សង្គ្រាម ការផ្សះផ្សារជាតិ ការកសាងមូលដ្ឋានរឹងមាំនៃសន្តិភាពនិងស្ថេរភាព និងការអភិវឌ្ឍសេដ្ឋកិច្ច។ នៅក្រោយពេលដែលសន្តិភាពត្រូវបានកើតឡើងដោយបរិបូរណ៍នៅឆ្នាំ១៩៩៨ កម្ពុជាទទួលកំណើនសេដ្ឋកិច្ចខ្ពស់ គឺប្រមាណ ៨%ក្នុងមួយឆ្នាំ។ លើសពីនេះទៀតអត្រានៃភាពក្រីក្រត្រូវបានកាត់បន្ថយពីប្រមាណ៥៣% នៅឆ្នាំ ២០០៤មកនៅទាបជាង១០% នៅឆ្នាំ២០១៩។ ដំណើរនៃការអភិវឌ្ឍជាតិជាសកម្មភាពដែលបន្តទៅមុខជាប់ជានិច្ច ហើយគោលនយោបាយថ្មីៗដែលមានលក្ខណៈអន្តរវិស័យគ្របដណ្តប់ ក៏កំពុងលេចរូបរាងឡើងដើម្បីតម្រង់ទិសកម្ពុជាឆ្ពោះទៅកាន់ប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងឈានឡើងជាប្រទេសមានប្រាក់ចំណូលខ្ពស់ នៅឆ្នាំ២០៥០។ ការប្រែប្រួលឆាប់រហ័សនៃនិម្នាបនកម្មពិភពលោក និងតំបន់រួមទាំងទំនាក់ទំនងភូមិសាស្រ្តនយោបាយ បានផ្តល់កាលានុវត្តភាពសម្រាប់ការអភិវឌ្ឍឧស្សាហកម្មនៅកម្ពុជា ដែលត្រូវបានរាជរដ្ឋាភិបាលចាត់ទុកជាមូលដ្ឋានគ្រឹះនៃកំណើនសេដ្ឋកិច្ចកម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជាបានកំពុងបន្តពង្រឹង និងអភិវឌ្ឍវិស័យអប់រំឆ្ពោះទៅរកការស្រាវជ្រាវ និងនវានុវត្តន៍ដើម្បីពង្រឹងសមត្ថភាពនិងជំនាញរបស់ធនធានមនុស្សនៅកម្ពុជាឱ្យស្របទៅនឹងបរិបទថ្មីនៃការអភិវឌ្ឍ ជាពិសេសការពង្រឹងសហគ្រិនភាពក្នុងការរៀបចំម៉ូដែលធុរកិច្ចថ្មីៗ។ ដើម្បីចាប់យកកាលានុវត្តភាពពីបដិវត្តន៍ឧស្សាហកម្មទី៤ និងសេដ្ឋកិច្ចឌីជីថលដែលកំពុងផុសផុលឡើង ប្រព័ន្ធអេកូឡូហ្ស៊ីដែលបង្កលក្ខណៈអំណោយផលដល់ការបង្កើតថ្មី នវានុវត្តន៍ ការស្រាវជ្រាវ និងអភិវឌ្ឍន៍ ត្រូវតែមានការកែលម្អ។

បណ្តាប្រទេសនៅទ្វីបអាស៊ីកំពុងនាំមុខក្នុងការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍ ដោយមានភាគហ៊ុនប្រមាណ៤៤% នៃការវិនិយោគទាំងមូលរបស់ពិភពលោក។ ប្រទេសចិនកំពុងបន្តកសាងហេដ្ឋារចនាសម្ព័ន្ធនៃការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍ ក៏ដូចជាសមត្ថភាពមនុស្ស។ ផ្ទុយទៅវិញ ប្រទេសនៅទ្វីបអាមេរិកខាងត្បូង និងអាហ្វ្រិក កំពុងស្ថិតនៅឆ្ងាយពីការវិនិយោគនេះ ហើយជាលទ្ធផល ប្រទេសទាំងនោះក៏ពុំមានកំណើនសេដ្ឋកិច្ចគួរឱ្យកត់សម្គាល់ដែរ។ ទុនវិនិយោគសរុបលើការស្រាវជ្រាវនិងអភិវឌ្ឍរបស់ប្រទេសនៅទ្វីបអាមេរិកខាងត្បូវនិងអាហ្វ្រិក មានប្រមាណ៥%នៃការវិនិយោគទាំងមូលរបស់ពិភពលោក ក្នុងពេលដែលតំបន់ទាំង២នេះមានប្រជាជនប្រមាណ២០%នៃប្រជាជនពិភពលោក។ ប្រទេសចំនួន៦ដែលមានលំដាប់ខ្ពស់ជាងគេនៅក្នុងការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍ រួមមានសហរដ្ឋអាមេរិក ចិន ជប៉ុន អាល្លឺម៉ង់ ឥណ្ឌា និងកូរ៉េខាងត្បូង ដែលស្មើនឹងប្រមាណ ៧០%នៃទុនវិនិយោគសរុបរបស់ពិភពលោក។

តើចំណេះដឹង ផលិតផល និងសេវាកម្មថ្មីទាំងនេះកើតឡើងពីអ្វី? ហើយកើតឡើងដោយរបៀបណា? ព្រះរាជាណាចក្រកម្ពុជាកំពុងតែកសាងមូលដ្ឋានសម្រាប់ការត្រៀមខ្លួនទទួល និងប្រកួតប្រជែងក្នុងយុគសម័យបដិវត្តឧស្សាហកម្មទី៤ នៅក្នុងសេដ្ឋកិច្ចដែលផ្អែកលើពុទ្ធិ ហើយដែលប្រការនេះចាំបាច់តម្រូវឱ្យពលរដ្ឋកម្ពុជា ត្រូវក្លាយខ្លួនជាពលរដ្ឋឌីជីថល ពលរដ្ឋសកល និងពលរដ្ឋដែលប្រកបដោយការទទួលខុសត្រូវ ដែលមានសមត្ថភាពក្នុងការផលិត ចែកចាយ និងប្រើប្រាស់ពុទ្ធិដើម្បីទទួលមនុញ្ញផល និងរួមចំណែកក្នុងកំណើន។ ធនាគារពិភពលោកបានធ្វើការកត់សម្គាល់តាំងពីឆ្នាំ២០០២នូវបម្លាស់ប្តូរនៃមូលដ្ឋានសេដ្ឋកិច្ច ពីសេដ្ឋកិច្ចដែលពឹងផ្អែកលើកម្លាំងពលកម្ម និងធនធានអតិកម្ម (Labour and Resource Based Economy) ទៅកាន់សេដ្ឋកិច្ចដែលពឹងផ្អែកលើពុទ្ធិ (Knowledge Based-Economy) ដែលក្នុងន័យនេះ ពុទ្ធិគឺជាគន្លឹះនៃការអភិវឌ្ឍ។ អាស្រ័យហេតុនេះ នៅលើគន្លងដែលកម្ពុជាកំពុងធ្វើដំណើរឆ្ពោះទៅកាន់សេដ្ឋកិច្ចឌីជីថល សង្គមកម្ពុជាត្រូវតែមានសមត្ថភាពក្នុងការផលិត ជ្រើសរើស បន្សាំ បង្កើតមុខរបរ និងប្រើប្រាស់ពុទ្ធិ ដើម្បីរក្សានិរន្តរភាពនៃកំណើន និងកែលម្អជីវភាពរស់នៅ។ សមត្ថភាពទាំងនេះ អាចកើតឡើងនៅពេលពលរដ្ឋកម្ពុជាមានឱកាសក្នុងការទទួលបានបទពិសោធន៍ពីការស្រាវជ្រាវ ការបណ្តុះគំនិតច្នៃប្រឌិត និងការស្វែងរកនវានុវត្តន៍។

កំណែទម្រង់វិស័យអប់រំ គឺជាការត្រួសត្រាយមាគ៌ាសម្រាប់ដំណើរឆ្ពោះទៅកាន់សង្គមប្រកបដោយពុទ្ធិ និងប្រជាពលរដ្ឋប្រកបដោយភាពរស់រវើក។ តាមរយៈមូលដ្ឋានអប់រំ សង្គមប្រកបដោយពុទ្ធិនឹងប្រមូលផ្តុំ បង្កើត និងចែករំលែក ទៅកាន់សមាជិកក្នុងសង្គមនូវសម្បទាអប់រំ ពិសេសគឺពុទ្ធិសម្បទាក្នុងបុព្វហេតុនៃមនុស្សជាតិនិងឧត្តមប្រយោជន៍នៃប្រទេស។ សង្គមប្រកបដោយពុទ្ធិ គឺពុំគ្រាន់តែជាសង្គមដែលសម្បូរព័ត៌មានប៉ុណ្ណោះទេ តែជាសង្គមដែលប្រជាពលរដ្ឋអាចធ្វើបរិវត្តកម្មពីព័ត៌មានទៅជាមូលធនប្រកបដោយប្រសិទ្ធភាព។ ការរីកចម្រើនទៅមុខជាលំដាប់នៃបច្ចេកវិទ្យានិងតំណភ្ជាប់ បានពង្រីកព្រំដែននៃការចូលទៅកាន់ និងការទទួលបានព័ត៌មានជាសកល ហើយដែលក្នុងន័យនេះ ការអប់រំនឹងបន្តវិវត្តទៅមុខនិងមានការផ្លាស់ប្តូរ។ សង្គមមួយដែលមានអំណាន និងរបាប់ជាបុរេលក្ខខណ្ឌនៃជីវភាពប្រចាំថ្ងៃនៃប្រជាពលរដ្ឋ ពេលនោះបំណិននៃអំណាន និពន្ធ និងការគណនាលេខនព្វន្ត គឺជាចលករនៃការរៀនរបស់សិស្ស។ ជាតុដ៏ចម្បងមួយដែលស្ថិតនៅក្នុងការកសាងសង្គមដែលប្រកបដោយពុទ្ធិគឺសៀវភៅសិក្សា ហើយការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សាជាប្រចាំ គឺជានវានុវត្តន៍នៃវិស័យអប់រំដែលនាំទៅរកការសិក្សាពេញមួយជីវិត ការអភិវឌ្ឍសម្បទាអប់រំ និងការចែករំលែកចំណេះដឹង។ មូលដ្ឋានអប់រំ ជាពិសេសគឺគ្រឹះស្ថានឧត្តមសិក្សាត្រូវមានតួនាទីដែលប្រកបដោយការឆ្លើយតបចំពោះតម្រូវការខាងលើនេះ។ សាស្ត្រាចារ្យ អ្នកស្រាវជ្រាវ និងបុគ្គលិកអប់រំត្រូវបន្តសិក្សាជាប់ជានិច្ចតាមរយៈការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ហើយដែលសៀវភៅសិក្សាទាំងនេះនឹងក្លាយជាស្ពាននៃទំនាក់ទំនងរវាងនវានុវត្តន៍នៃបច្ចេកវិទ្យា និងការរៀននិងបង្រៀននៅក្នុងថ្នាក់រៀន។

សង្គមដែលប្រកបពុទ្ធិ ក៏ជាសង្គមដែលបណ្តុះឱ្យមានរចនាសម្ព័ន្ធទន់នៃសេដ្ឋកិច្ចដែលពឹងផ្អែកលើពុទ្ធិដែរ។ ឧទាហរណ៍ជាក់ស្តែងនៃបែបផែននេះរួមមាន Silicon Valley នៃសហរដ្ឋអាមេរិក

សួនឧស្សាហកម្មវិស្វកម្មអាកាសយានយន្តនិងយានយន្តនៅទីក្រុង Munich ប្រទេសអាល្លឺម៉ង់ តំបន់ដីវបច្ចេកវិទ្យានៅក្រុង Hyderabad ប្រទេសឥណ្ឌា តំបន់ផលិតគ្រឿងអេឡិចត្រូនិក និងសារគមនាគមន៍ ឌីជីថលនៅទីក្រុង Seoul ប្រទេសកូរ៉េខាងត្បូង ក៏ដូចជាសួនឧស្សាហកម្មថាមពល និងឥន្ធនគីមីសាស្ត្រនៃប្រទេសប្រេស៊ីល ហើយក៏នៅមានទីក្រុងនៃប្រទេសជាច្រើនទៀតនៅលើពិភពលោក លក្ខណៈសម្បត្តិនៃទីក្រុងទាំងនេះគឺការប្រើប្រាស់និន្នាការនៃការអភិវឌ្ឍដែលជំរុញ និងតម្រង់ទិសដោយចំណេះដឹង ហើយដែលចំណេះដឹងទាំងនោះកើតចេញជាដំបូងពីការវិនិយោគទៅលើគ្រឹះស្ថានឧត្តមសិក្សា ស្ថាប័នស្រាវជ្រាវ មជ្ឈមណ្ឌលឧត្តមភាពនៃជំនាញជាន់ខ្ពស់ ការប្រកួតប្រជែងដោយគុណាធិបតេយ្យ និង ជាពិសេសគឺការបណ្តុះវប្បធម៌អំណាននិងនិពន្ធសៀវភៅ។ ល្បឿននៃការរីកចម្រើនផ្នែកពុទ្ធិ និងបច្ចេកវិទ្យាកំពុងមានសន្ទុះលឿនជាងអ្វីដែលសិស្ស និងនិស្សិតអាចទទួលបានពីគ្រូនៅគ្រឹះស្ថានសិក្សា ដែលធ្វើឱ្យគោលដៅនៃការអប់រំនៅពេលបច្ចុប្បន្ននេះ មានការប្រឈមខ្លាំងជាងពេលណាទាំងអស់។ ឧទាហរណ៍ ក្នុងមួយឆ្នាំ មានសៀវភៅជាង២,២លានចំណងជើង ត្រូវបានសរសេរ និងបោះពុម្ព ដែលក្នុងនោះប្រទេសចិនមាន៤៤០ពាន់ ចំណែកឯសហរដ្ឋអាមេរិកមាន ៣០៥ ពាន់ និងប្រទេសរុស្ស៊ីមាន ១២០ពាន់ចំណងជើង។

ខណៈពេលដែលបច្ចេកវិទ្យាកំពុងរីកចម្រើនជារៀងរាល់ថ្ងៃ មធ្យោបាយសម្រាប់អំណានក៏មានច្រើនជម្រើសសម្រាប់សិស្ស និស្សិត និងសាធារណៈជនរួមមានការអានសៀវភៅ ការអានលើឧបករណ៍អេឡិចត្រូនិក ការអានដោយប្រើទូរសព្ទវៃឆ្លាត និងការអានលើកុំព្យូទ័រ ដែលសុទ្ធសឹងជាមធ្យោបាយសំខាន់ៗដែលនាំអ្នកអានទាំងឡាយឱ្យសម្រេចគោលបំណងអានរបស់ខ្លួន។ ម្យ៉ាងវិញទៀត អំណានដោយប្រើមធ្យោបាយបច្ចេកវិទ្យាទំនើប ចំណាយពេលតិច ងាយស្រួលអាន និងជួយដល់បរិស្ថានមួយកម្រិតទៀត។ នាពេលបច្ចុប្បន្ន សិស្ស និស្សិត និងសាធារណៈជនកម្ពុជាដែលស្រឡាញ់អំណានកំពុងតែប្រើប្រាស់មធ្យោបាយអំណានទាំងនេះ។ បើយើងក្រឡេកមើលទៅប្រទេសជឿនលឿន ទោះបីជាបច្ចេកវិទ្យារីកចម្រើនខ្លាំងយ៉ាងណា អំណានតាមរយៈសៀវភៅនៅតែមានសន្ទុះដដែល។ ម្យ៉ាងវិញទៀត បច្ចេកវិទ្យាអានបែបទំនើបតាមរយៈឧបករណ៍ទំនើប អាស្រ័យលើលទ្ធភាពនៃធនធានអប់រំឌីជីថល និងមាតិកាឌីជីថលគ្រប់គ្រាន់ដែលបានផលិត និងបង្ហោះចែកចាយសម្រាប់អំណាន។

ក្នុងបរិបទកម្ពុជា ជាពិសេសក្នុងបរិការណ៍នៃការផ្ទុះរីករាលដាលនៃជំងឺកូវីដ-១៩ ក្រសួងអប់រំ យុវជន និងកីឡា បានជំរុញឱ្យមានបរិវត្តកម្មឌីជីថលនៅក្នុងអេកូស៊ីស្តែមនៃការអប់រំ ជាពិសេសការអប់រំតាមប្រព័ន្ធអេឡិចត្រូនិកនិងការអប់រំពីចម្ងាយដើម្បីលើកកម្ពស់អំណានតាមរយៈការផលិតមាតិកាឌីជីថលដែលមានភាពចំរុះ ការកសាងសមត្ថភាពផ្នែកតំណភ្ជាប់និងវេទិកាឌីជីថល ការពង្រីកវិសាលភាពនៃមជ្ឈមណ្ឌលទិន្នន័យ និងការលើកកម្ពស់គុណភាពនៃការផលិតធនធានអប់រំឌីជីថល គួបផ្សំជាមួយការចែកសន្លឹកកិច្ចការឱ្យសិស្សយកទៅរៀននៅផ្ទះ និងការចុះទៅជួបជាមួយសិស្សជាបណ្តុំនៅតាមសហគមន៍។ ក្នុងន័យលើកកម្ពស់អំណាន និងភាពសម្បូរបែបនៃធនធានសៀវភៅសិក្សាឱ្យកាន់តែមានប្រសិទ្ធភាពនិងភាពសក្តិសិទ្ធិ និងផ្តល់ឱកាសអំណានកាន់តែច្រើនថែមទៀតដល់សិស្សានុសិស្ស

និស្សិត និងសាធារណៈជន ក្រសួងអប់រំ យុវជន និងកីឡាលើកទឹកចិត្តនូវចំណុចមួយចំនួនដូចខាងក្រោម៖

1. សាស្ត្រាចារ្យ អ្នកស្រាវជ្រាវ និងបុគ្គលិកអប់រំ សូមបន្តនិងបង្កើនការបោះពុម្ពស្នាដៃបន្ថែមទៀត ដើម្បីធ្វើឱ្យធនធានសម្រាប់អំណានកាន់តែសម្បូរបែប ជាពិសេសធនធានអំណានជាខេមរភាសា
2. គ្រឹះស្ថានឧត្តមសិក្សា សូមផ្តល់លទ្ធភាពគ្រប់បែបយ៉ាង ដើម្បីឱ្យបុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់ និង និស្សិតគ្រប់កម្រិតសិក្សាអាចចូលរួមអាន និងសិក្សាស្រាវជ្រាវតាមគ្រប់លទ្ធភាពជាមួយធនធានអំណាន ជាពិសេសការរៀបចំឱ្យមានពេលវេលាសម្រាប់សហសិក្សា និងអំណានក្នុងបណ្ណាល័យ
3. សាស្ត្រាចារ្យតាមមុខវិជ្ជា និងអ្នកស្រាវជ្រាវតាមជំនាញឬវិស័យ ត្រូវរៀបចំដំណើរការរៀនបង្រៀន និងស្រាវជ្រាវដែលមានដាក់បញ្ចូលកិច្ចការស្វ័យសិក្សា សហសិក្សា ឬការស្រាវជ្រាវបណ្ណាល័យដែលតម្រូវឱ្យនិស្សិត ត្រូវអាននិងស្រាវជ្រាវជាមួយធនធានអំណាន
4. គ្រឹះស្ថានឧត្តមសិក្សា និងមជ្ឈមណ្ឌលស្រាវជ្រាវ ត្រូវខិតខំឱ្យអស់លទ្ធភាពក្នុងការបង្កើតបណ្ណាល័យ មជ្ឈមណ្ឌលរក្សាឯកសារ ឬមជ្ឈមណ្ឌលអប់រំឌីជីថល ជាដើម ដើម្បីឱ្យបុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់និងនិស្សិតគ្រប់កម្រិតសិក្សា អាចទទួលបាន និងស្វែងរកប្រភពសម្រាប់អំណាន កាន់តែសម្បូរបែប និងមានភាពបត់បែន ឆ្លើយតបតាមតម្រូវការអ្នកអាន
5. និស្សិតគ្រប់កម្រិតសិក្សា ត្រូវខិតខំនិងចំណាយពេលអាន និងចាត់ទុកវប្បធម៌ និងអកប្បកិរិយាអំណានជាផ្នែកមួយ នៃពេលវេលានិងភាពស៊ីវិល័យនៃជីវិតប្រចាំថ្ងៃ
6. បងប្អូនជនរួមជាតិ ដែលជាមាតាបិតា ឬអ្នកអាណាព្យាបាល សូមជួយជំរុញនិងបង្កលក្ខណៈកាន់តែ ច្រើនថែមទៀត ជាពិសេសការលៃលកចំណាយនៅក្នុងគ្រួសារសម្រាប់ការទិញសម្ភារៈសិក្សា សៀវភៅអាន និងឧបករណ៍សម្រាប់អំណានដល់កូនៗ ដែលចាត់ទុកជាការវិនិយោគមួយដ៏សំខាន់ សម្រាប់ បង្កើនចំណេះដឹង និងអនាគតរបស់ពួកគេ។

ដោយមានការគាំទ្រពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅឆ្នាំ២០២០ ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ ដែលហៅកាត់ថា"មូលនិធិ ស.គ.ន" និងហៅជាភាសាអង់គ្លេសថា The Research Creativity and Innovation Fund ដែលហៅកាត់ជាភាសាអង់គ្លេសថា "RCI Fund"។ គោលដៅចម្បងនៃមូលនិធិនេះ គឺរួមចំណែកលើកកម្ពស់វប្បធម៌នៃការស្រាវជ្រាវ បំផុសគំនិតច្នៃប្រឌិត និងជំរុញការធ្វើនវានុវត្ត ដើម្បីជាប្រយោជន៍ដល់វិស័យអប់រំ យុវជន និងកីឡា ដែលឆ្លើយតបទៅនឹងទីផ្សារពលកម្ម និងសាកលភាវូបនីយកម្ម។ មូលនិធិ ស.គ.ន បានសម្រេចកំណត់ប្រធានបទ ជាអាទិភាពសម្រាប់ការគាំទ្រដោយមូលនិធិចំនួន៣ រួមមាន ឌីជីថលនីយកម្មសម្រាប់បដិវត្តឧស្សាហកម្ម៤.០ ( Digitalization for IR.4.0 ) ការស្រាវជ្រាវអនុវត្តលើវិស័យកសិកម្ម ( Applied Agricultural Research ) និងការស្រាវជ្រាវគរុកោសល្យសតវត្សទី២១ (21st Century Pedagogy Research )។

ដោយមានការធ្វើអាទិភាពរូបនីយកម្មទៅលើទិសដៅនៃការប្រើប្រាស់ថវិកាមូលនិធិសម្រាប់ឆ្នាំ២០២០ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា បានផ្តល់ការគាំទ្រដល់ **ការរៀបរៀង និពន្ធ និងកែលម្អ សៀវភៅសិក្សា(Text book) ដែលនឹងត្រូវប្រើប្រាស់នៅកម្រិតឧត្តមសិក្សា។** គោលបំណងនៃការរៀបរៀង និពន្ធ និងកែលម្អ សៀវភៅសិក្សានៅកម្រិតឧត្តមសិក្សាគឺដើម្បីបង្កើនបរិមាណ លើកកម្ពស់គុណភាព និងពង្រីកសមធម៌នៃធនធានសិក្សាជាខេមរភាសា ជូនដល់និស្សិតដែលកំពុងបន្តការសិក្សា និងត្រៀមខ្លួនធ្វើការស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។ លើសពីនេះទៀតការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា មានគោលដៅដូចខាងក្រោម ៖

- ឆ្លើយតបជាបន្ទាន់ចំពោះការខ្វះខាតធនធានសិក្សា ដែលជាតម្រូវការសិក្សារបស់និស្សិតនៅកម្រិតឧត្តមសិក្សា
- លើកកម្ពស់ទំនើបភាវូបនីយកម្ម និងឧត្តមានុវត្តន៍នៃការរៀននិងបង្រៀន និងការស្រាវជ្រាវនៅលើមុខវិជ្ជា កម្មវិធីសិក្សា ឬមុខជំនាញជាក់លាក់
- បង្កើនភាពស៊ីជម្រៅក្នុងការកសាងវិជ្ជាជីវៈនិងបទពិសោធន៍សម្រាប់បានៈសាស្ត្រាចារ្យ និងអ្នកស្រាវជ្រាវ
- រួមចំណែកដល់ការកសាងភាពជាសហគមន៍វិជ្ជាជីវៈ ការចែករំលែកបទពិសោធន៍ និងវប្បធម៌នៃការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា។

ក្រសួងអប់រំ យុវជន និងកីឡា បានវាយតម្លៃខ្ពស់ចំពោះការបោះជំហានប្រកបដោយមនសិការវិជ្ជាជីវៈនៃគ្រឹះស្ថានឧត្តមសិក្សា និងបុគ្គលិកអប់រំទាំងអស់ ក្នុងការរៀបចំ រៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ដើម្បីបង្កើនបរិមាណ លើកកម្ពស់គុណភាព និងពង្រឹងសមធម៌នៃធនធានសិក្សាជាខេមរភាសា ជូននិស្សិតដែលកំពុងបន្តការសិក្សា និងត្រៀមខ្លួនធ្វើការស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។ សៀវភៅសិក្សាជាផ្នែកមួយនៃការទទួលស្គាល់គុណភាពអប់រំនៃគ្រឹះស្ថានឧត្តមសិក្សា និងជាធនធានសិក្សាដែលជាមូលដ្ឋានមួយដ៏សំខាន់ ក្នុងការគាំទ្រដល់ការបង្រៀន និងរៀន ហើយត្រូវមានបរិមាណគ្រប់គ្រាន់ ឆ្លើយតបទៅនឹងកម្មវិធីអប់រំ និងតម្រូវការសិក្សាស្រាវជ្រាវ។ ជាគោលការណ៍ គ្រឹះស្ថានឧត្តមសិក្សាទាំងអស់ ត្រូវមានសៀវភៅសិក្សាដែលប្រើជាគោលសម្រាប់មុខវិជ្ជានីមួយៗ។ ចំនួនសៀវភៅសិក្សាដែលគ្រប់គ្រាន់សម្រាប់ការស្រាវជ្រាវ និងការសិក្សារបស់និស្សិត ត្រូវមានយ៉ាងតិចមួយចំណងជើងក្នុងមួយមុខវិជ្ជា ហើយត្រូវតម្កល់យ៉ាងតិច២ច្បាប់ នៅក្នុងបណ្ណាល័យ ឬអាចរកបានតាមប្រព័ន្ធអេឡិចត្រូនិក។ ក្រសួងអប់រំ យុវជន និងកីឡា លើកទឹកចិត្តបន្ថែមទៀតជូនដល់គ្រឹះស្ថានឧត្តមសិក្សារដ្ឋ និងឯកជនដែលបានស្នើសុំថវិកាមូលនិធិរួច សូមចូលរួមបន្ថែមទៀតដើម្បីបង្កើនចំនួនចំណងជើងសៀវភៅ។ ចំណែកគ្រឹះស្ថានឧត្តមសិក្សារដ្ឋនិងឯកជនដែលពុំទាន់បានដាក់ពាក្យស្នើសុំ សូមចូលរួមដើម្បីជាគុណប្រយោជន៍ដល់តម្រូវការដ៏ទទូច និងថ្លៃថ្លានៃនិស្សិតកម្ពុជាក្នុងការសិក្សា និងស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។

# សេចក្តីបញ្ជាក់
# នៃមូលនិធិការស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍

សៀវភៅសិក្សានេះជាលទ្ធផលនៃការស្នើសុំអនុវត្តថវិកាមូលនិធិការស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ ក្នុងគម្រោង**រៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ដែលនឹងត្រូវប្រើប្រាស់នៅកម្រិតឧត្តមសិក្សា។** សៀវភៅសិក្សានេះ ត្រូវបានរៀបរៀង និពន្ធ ឬកែលម្អដោយមានការធានាអះអាងថាជាស្នាដៃរបស់អ្នកនិពន្ធផ្ទាល់ និងបានឆ្លងកាត់ត្រួតពិនិត្យ ផ្តល់យោបល់ និងវាយតម្លៃដោយក្រុមប្រឹក្សាអប់រំ ក្រុមប្រឹក្សាស្រាវជ្រាវ ឬក្រុមប្រឹក្សាដែលមានតម្លៃស្មើនៃគ្រឹះស្ថានឧត្តមសិក្សា និងតាមរយៈកិច្ចសន្យាដែលបានធ្វើឡើង និងដែលបានតម្កល់ទុកនៅមូលនិធិការស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍។ រាល់ខ្លឹមសារ ការបកស្រាយ និងរូបភាព គឺជាជំហរនិងទស្សនៈផ្ទាល់របស់អ្នកនិពន្ធ ហើយ ពុំឆ្លុះបញ្ចាំង ឬជាតំណាងដល់មូលនិធិការស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ នៃក្រសួងអប់រំ យុវជន និងកីឡា ឡើយ។

# បញ្ជីតារាងរូបភាព


រូបភាព 1 ៖ ថ្នាក់រៀនសម័យបុរាណ ........................................ 2
រូបភាព 2 ថ្នាក់រៀនស.វ. ទី២១ ........................................ 3
រូបភាព 3 ៖ ការអប់រំ១.០ ........................................ 3
រូបភាព 4 ៖ ២.០.ទំនាក់ទំនងបង្កើតបណ្ដាញ កិច្ចសហការ(គ្រូបង្រៀនភ្លេង) ........................................ 3
រូបភាព 5៖ ៣.០.បដិវត្តន៍ក្នុងការអប់រំ ........................................ 3
រូបភាព 6៖ ជំនាញស.វ.ទី២១ ........................................ 5
រូបភាព 7៖ បំណិនស.វ.ទី២១ ........................................ 5
រូបភាព 8 ៖ បំណិនច្នៃប្រឌិត ........................................ 6
រូបភាព 9៖បំណិនក្នុងការសិក្សា ........................................ 6
រូបភាព 10៖ បំណិនព័ត៌មាន ........................................ 7
រូបភាព 11៖ ចំណេះនិងជំនាញត្រូវការនៅស.វ.២១ ........................................ 7
រូបភាព 12 ៖ គ្រូបង្រៀនស.វទី២១ ........................................ 9
រូបភាព 13៖ បរិស្ថានមនុស្ស ធម្មជាតិ និងសង្គម វប្បធម៌ ........................................ 15
រូបភាព 14 ៖ បរិស្ថានធម្មជាតិ ........................................ 15
រូបភាព 15 ៖ ការបំផ្លាញព្រៃឈើ ........................................ 16
រូបភាព 16៖ សកម្មភាពរបស់មនុស្ស ........................................ 16
រូបភាព 17៖ កង្វក់ឬការបំពុលទឹក ........................................ 16
រូបភាព 18 ៖ ការអប់រំសម្រាប់កាអភិវឌ្ឍប្រកបដោយចីរភាព ........................................ 22
រូបភាព 19 ៖ តម្រូវការមនុស្ស ........................................ 23
រូបភាព 20 ៖ ការចូលរួមពីអ្នកពាក់ព័ន្ធ ........................................ 23
រូបភាព 21៖ ការអប់រំបរិយាបន្ន ........................................ 23
រូបភាព 22 ៖ សិទ្ធិមនុស្ស ........................................ 24
រូបភាព 23៖ សន្តិសុខ និងសន្តិភាព ........................................ 25
រូបភាព 24៖ សមភាពយេនឌ័រ ........................................ 25
រូបភាព 25៖ វិសមភាពយេនឌ័រ ........................................ 25
រូបភាព 26៖ សុខភាពនិងសុខមាលភាព ........................................ 25
រូបភាព 27៖ អភិបាលកិច្ចល្អ ........................................ 26
រូបភាព 28៖ ទំនួលខុសត្រូវ ........................................ 26

រូបភាព 29៖ ការកាត់បន្ថយភាពក្រីក្រ ...................................................................... 26
រូបភាព 30៖ សេដ្ឋកិច្ចទីផ្សារ ............................................................................................ 27
រូបភាព 31៖ការផ្លាស់ប្តូរ................................................................................................... 28
រូបភាព 32៖ ................................................................................................................... 44
រូបភាព 33 ..................................................................................................................... 46
រូបភាព 34 ..................................................................................................................... 49
រូបភាព 35 ..................................................................................................................... 51
រូបភាព 36 ..................................................................................................................... 51
រូបភាព 37 ..................................................................................................................... 52
រូបភាព 38៖ UNICEF Cambodia/2018/Todd Brown ...................................................... 54
រូបភាព 39 ..................................................................................................................... 56
រូបភាព 40 ..................................................................................................................... 57
រូបភាព 41 ..................................................................................................................... 60
រូបភាព 42 ..................................................................................................................... 68
រូបភាព 43៖ How do we teach 21st century skills in classrooms? ................................. 69
រូបភាព 44៖ 21st century classrooms design ................................................................ 69
រូបភាព 45 ..................................................................................................................... 70
រូបភាព 46៖ភាពជាដៃគូ ................................................................................................. 75
រូបភាព 47 ..................................................................................................................... 76
រូបភាព 48៖ ការច្នៃប្រឌិតឬបង្កើតថ្មី .................................................................................. 77
រូបភាព 49 ..................................................................................................................... 83
រូបភាព 50 ..................................................................................................................... 91
រូបភាព 51 ..................................................................................................................... 92
រូបភាព 52 ..................................................................................................................... 92
រូបភាព 53 ..................................................................................................................... 93
រូបភាព 54 ..................................................................................................................... 94
រូបភាព 56 ..................................................................................................................... 96

# មាតិកា


បុព្វកថា ................................................................................ i

សេចក្ដីបញ្ជាក់ ................................................................................ vi

អារម្ភកថា ................................................................................ i

សេចក្ដីថ្លែងអំណរគុណ ................................................................................ i

ការបរិយាយលើមុខវិជ្ជា ................................................................................ ii

មូលន័យសង្ខេប ................................................................................iii

មេរៀនទី១ គ្រូបង្រៀនសតវត្សរ៍ទី២១ ................................................................................ 1

១.១. សេចក្ដីផ្ដើម ................................................................................ 1

១.១.១.ថ្នាក់រៀនកាលពីសម័យមុន ................................................................................ 1

១.១.២.ថ្នាក់រៀននៅសតវត្សរ៍ទី២១ ................................................................................2

១.២. បំណិនសតវត្សរ៍ទី២១................................................................................3

១.២.១. ការគិតស៊ីជម្រៅ (Critical Thinking ) ................................................................................5

១.២.២.ការសហការ (Collaboration ) ................................................................................5

១.២.៣.ការទំនាក់ទំនង (Communication )................................................................................5

១.២.៤.ការបង្កើតថ្មី (Creativity )................................................................................6

១.៣.បំណិនទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព ................................................................................6

១.៤.បំណិនក្នុងការសិក្សានិងច្នៃប្រឌិត ................................................................................6

១.៥ .បំណិនផ្នែកព័ត៌មានមេឌា និងបច្ចេកវិទ្យា ................................................................................7

១.៦ .បំណិនជីវិតនិងការងារ ................................................................................7

១.៦.១.ចំណេះដឹងនិងជំនាញត្រូវការនៅក្នុងសតវត្សរ៍ទី២១ ................................................................................7

១.៦.២.ជំនាញសំខាន់ទាំង ១០ ក្នុងឆ្នាំ ២០១៥ ធៀបនឹងឆ្នាំ ២០២០................................................................................8

១.៦.៣.ភាពខុសគ្នារវាងតម្រូវការរបស់សិស្សនិងគ្រូនៅសតវត្សរ៍ទី២១................................................................................8

១.៦.៤.គ្រូបង្រៀននៅសតវត្សរ៍ទី២១................................................................................9

១.៧ . វិធីបង្រៀននិងរៀនបំណិនសតវត្សរ៍ទី២១ ................................................................................9

១.៧.១. ធ្វើឱ្យវាពាក់ព័ន្ធ (Make it relevant) ........................................................ 9
១.៧.២.បង្រៀនឱ្យគោរពច្បាប់ ឬបទដ្ឋាន(Teach through the disciplines) .................. 10
១.៧.៣.អភិវឌ្ឍន៍បំណិនការគិតកម្រិតខ្ពស់និងការគិតកម្រិតទាបក្នុងពេលដំណាលគ្នា.......... 10
១.៧.៤ លើកទឹកចិត្តដល់ការផ្ទេរការសិក្សា ................................................................ 10
១.៨. តួនាទីរបស់គ្រូក្នុងការធ្វើឱ្យសម្រេចបំណិនសតវត្សទី ២១ ........................................ 11
១.៩.តួនាទី៧ចំណុចរបស់គ្រូបង្រៀននៅក្នុងយុគ្គសម័យទំនើប ........................................ 11
មេរៀនទី២ គោលដៅអភិវឌ្ឍប្រកបដោយចីរភាព ...................................................... 14
២.១. សេចក្តីផ្តើម ........................................................................................ 14
២.២. សញ្ញាណទូទៅនៃបរិស្ថាន......................................................................... 14
២.២.១.បរិស្ថានធម្មជាតិ .................................................................................. 15
២.២.២.បរិស្ថានសង្គមវប្បធម៌ ........................................................................... 15
២.២.៣.បរិស្ថានមនុស្ស ................................................................................... 15
២.៣. ការអភិវឌ្ឍប្រកបដោយចីរភាពនិងគោលដៅនៃ SDGs ........................................ 17
២.៣.១.គោលដៅនៃការអភិវឌ្ឍប្រកបដោយចីរភាព ៖.................................................. 17
២.៣.២.គោលបំណងសំខាន់ៗចំនួន១៧ចំណុចដូចជា៖ ................................................ 18
២.៤. សារតារ នៃការអភិវឌ្ឍប្រកបដោយនិរន្តភាព .................................................... 19
២.៥. ការអប់រំដើម្បីអភិវឌ្ឍប្រកបដោយនិរន្តរភាព...................................................... 20
មេរៀនទី៣ បញ្ញាត្តិនៃការអប់រំសម្រាប់ការអភិវឌ្ឍ ................................................... 22
ប្រកបដោយចីរភាព.......................................................................................... 22
៣.១. ការអប់រំសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព .................................................. 22
៣.១.១.គោលបំណង ESD (Global concept) ........................................................ 23
៣.១.២.វិធីសាស្រ្តគរុកោសល្យសម្រាប់ការអប់រំប្រកបដោយចីរភាព ៖ ................................ 23
អ្វីខ្លះ?...................................................................................................... 23
២.៣. ជាតុសំខាន់ៗនៃការអប់រំសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព ................................ 24
២.៣.១.សង្គម(Society) ................................................................................. 24

២.៣.២.សិទ្ធិមនុស្ស ........ 24
២.៣.៣.សន្តិភាព និងសន្តិសុខ ........ 24
២.៣.៤.សមភាពយេនឌ័រ ........ 25
២.៣.៥.អភិបាលកិច្ចល្អ ........ 26
២.៣.៦.សេដ្ឋកិច្ច ( Economy ) ........ 26
២.៣.៧.បរិស្ថាន ( Environment ) ........ 27
មេរៀនទី៤ គោលការណ៍ចម្បងនៃការអប់រំសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព ........ 28
៤.១.សេចក្តីផ្តើម ........ 28
៤.២.និយមន័យ ........ 28
៤.៣.គោលការណ៍នៃការអប់រំសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព ........ 28
៤.៣.១. ការផ្លាស់ប្តូរនិងការផ្លាស់ប្តូរ ........ 28
៤.៣.២. ការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា ........ 28
៤.៣.៣.ការគិតជាប្រព័ន្ធ ........ 28
៤.៣.៤. អនាគតល្អប្រសើរ ........ 29
៤.៣.៥. ការត្រិះរិះពិចារណា ........ 29
៤.៣.៦. ការចូលរួម ........ 29
៤.៣.៧. ភាពជាដៃគូរសម្រាប់ការផ្លាស់ប្តូរ ........ 29
៤.៤.វិធីបង្រៀនការអប់រំដើម្បីការអភិវឌ្ឍន៍ប្រកបដោយចីរភាព ........ 29
៤.៤.១.ការឆ្លុះបញ្ចាំង ........ 29
៤.៤.២.ការគិតជាប្រព័ន្ធ ........ 29
៤.៤.៣. ការរៀនសូត្រដែលមានការចូលរួម ........ 29
៤.៤.៤.ការគិតប្រកបដោយច្នៃប្រឌិត ........ 29
៤.៤.៥.ការសិក្សារួមគ្នា ........ 29
៤.៥.ឱកាសនិងបញ្ហាប្រឈមនៃESD ........ 29
៤.៥.១. អត្ថប្រយោជន៍និងឱកាស ........ 29

៤.៥.២.បញ្ហាប្រឈម....30
៤.៦.សាវតាបរិស្ថាន....30
៤.៧.ការបញ្ជ្រាប ESD ទៅក្នុងកម្មវិធីសិក្សាអប់រំគ្រូបង្រៀន....30
៤.៧.១.សិក្សាកសិកម្ម (Agricultural Studies)....33
៤.៨.ការអភិវឌ្ឍខ្លួនឯងប្រកបដោយចីរភាព(The Sustaninable Self)....39
មេរៀនទី ៥ ទ្រឹស្តីនៃការអប់រំ....43
៥.១.សេចក្តីផ្តើម....43
៥.២ . និយមន័យ....43
៥.៣. របៀបនៃការរៀន....43
៥.៤.១. ទ្រឹស្តីនៃអាកប្បកិរិយា(Behaviorism)....44
៥.៤.២ ទ្រឹស្តីនៃការយល់ដឹង(Cognitivism)....45
៥.៤.៣ ទ្រឹស្តីស្ថាបនានិយម(Constructivism)....46
មេរៀនទី៦ ការប្រៀបធៀបការអប់រំអន្តរជាតិ....47
៦.១.សេចក្តីផ្តើម....47
៦.២. និយមន័យ....47
៦.៣. គោលបំណងនៃការសិក្សាប្រៀបធៀបការអប់រំ....48
៦.៤. សារៈសំខាន់នៃការប្រៀបធៀបអប់រំ....48
៦.៥. វិសាលភាពនៃការប្រៀបធៀបអប់រំ....49
៦.៦. បញ្ហាប្រឈម....49
៦.៧.ដំណោះស្រាយ....50
មេរៀនទី៧ ផែនការយុទ្ធសាស្រ្តវិស័យអប់រំ ឆ្នាំ២០១៩-២០២៣(ផ្នែក១)....58
៧.១. សេចក្តីផ្តើម....58
៧.២. និយមន័យ....58
៧.៣.គោលបំណងនៃការសិក្សា....58
៧.៤.កំណែទម្រង់សំខាន់ៗនៅក្នុងផែនការយុទ្ធសាស្រ្តអប់រំសម្រាប់ឆ្នាំ២០១៩-២០២៣....58

មេរៀនទី៨ ផែនការយុទ្ធសាស្ត្រចក្ខុវិស័យអប់រំឆ្នាំ២០១៩_២០២៣(ផ្នែកទី២) ..................60
៨.១.សេចក្តីផ្តើម ..................60
៨.២.គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពសម្រាប់ឆ្នាំ២០៣០ ..................60
៨.២.១.គោលដៅអប់រំជាតិ ..................64
៨.២.២.គោលដៅយុទ្ធសាស្ត្រសម្រាប់សម្រេចគោលដៅអប់រំឆ្នាំ២០៣០..................65
៨.៣.កំណែរទម្រង់សាលារៀន ..................65
៨.៤.ការលើកកម្ពស់ការអប់រំឱីជីថល ..................66
៨.៥.វិធីសាស្ត្របង្រៀនដើម្បីឆ្លើយតបទៅនឹងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ..................66
ឆ្នាំ ២០១៩-២០២៣ ..................66
មេរៀនទី៩ សាលារៀនជំនាន់ថ្មី (ផ្នែកទី ១) ..................68
៩.១.សេចក្តីផ្តើម ..................68
៩.២.បញ្ញត្តិសាលាជំនាន់ថ្មី..................68
៩.៣.មូលហេតុនៃការបង្កើតសាលាជំនាន់ថ្មី ..................69
៩.៤.ចក្ខុវិស័យ និងគោលដៅនៃសាលាជំនាន់ថ្មី..................69
៩.៥.គោលបំណងរបស់សាលាជំនាន់ថ្មី ..................70
មេរៀនទី១០ សាលារៀនជំនាន់ថ្មី (ផ្នែកទី២) ..................72
១០.១.សេចក្តីផ្តើម ..................72
១០.២.កំណែទម្រង់ប្រព័ន្ធអប់រំ ..................72
១០.៣.ផែនការសកម្មភាព ..................74
១០.៤.យុទ្ធសាស្ត្រសំខាន់ៗក្នុងការធ្វើឱ្យសម្រេចគោលដៅ និងគោលបំណងនៃសាលាជំនាន់ថ្មី..75
១០.៤.១.ការជ្រើសរើសសាលាយ៉ាងហ្មត់ចត់..................75
១០.៤.២.ភាពជាដៃគូ..................75
១០.៤.៣.គណនេយ្យភាពសាលារៀន៖..................75
១០.៤.៤.ការគ្រប់គ្រងដោយផ្ទាល់ពីថ្នាក់ជាតិចំពោះសាលាជំនាន់ថ្មី៖ ..................76
១០.៤.៦.ការទទួលខុសត្រូវរបស់សាលារៀនជំនាន់ថ្មី ..................76

១០.៤.៧.ការត្រួតពិនិត្យសាលារៀនជំនាន់ថ្មីដោយផ្ទាល់ពីថ្នាក់ជាតិ.................................76
១០.៤.៨.ការលើកទឹកចិត្តគ្រូ.........................................................................................76
១០.៤.៦.ដំណើរការស្វ័យភាពផ្សារភ្ជាប់នឹងការច្នៃប្រឌិតថ្មី..................................................77
១០.៤.៧.ការប្រើប្រាស់បច្ចេកវិទ្យាឱ្យបានទូលំទូលាយដើម្បីជំរុញការច្នៃប្រឌិតថ្មី...............77
១០.៤.៨.ការពង្រឹងសិទ្ធិអំណាចយុវជន .............................................................................78
១០.៤.៩.ការបង្កើនម៉ោងបង្រៀននិងរៀន ...........................................................................78
១០.៤.១០.ការដាក់ឱ្យអនុវត្តប្រភេទមុខវិជ្ជា .......................................................................78
១០.៤.១១.មូលនិធិសមធម៌សង្គម ........................................................................................78
១០.៤.១២.សាលារៀននៅក្នុងសាលារៀនគំរូ..........................................................................78
១០.៤.១៣.ការកាត់បន្ថយផលធៀបគ្រូ-សិស្ស.........................................................................78
១០.៤.១៤.ការផ្លាស់ប្តូរផ្នត់គំនិតជាបុគ្គល.............................................................................79
១០.៤.១៥.ការធ្វើទំនើបកម្មបរិស្ថានសិក្សា...........................................................................79
មេរៀន១១ ការគ្រប់គ្រងសាលារៀន ( ផ្នែកទី ១ )..........................................................80
១១.១.សេចក្តីផ្តើម ............................................................................................................80
១១.២.សាវតានិងនិយមន័យការគ្រប់គ្រងសាលារៀន(SBM)...................................................80
១១.២.១.សាវតាសង្ខេបរបស់SBM.......................................................................................80
១១.២.២.និយមន័យផ្សេងៗរបស់ SBM................................................................................ 81
១១.៣.សារៈសំខាន់នៃការគ្រប់គ្រងសាលារៀន .....................................................................82
១១.៤.យុទ្ធសាស្រ្តអនុវត្តកម្មវិធីការគ្រប់គ្រងតាមសាលារៀន ប្រព័ន្ធ៣ អាបិតជិត...................82
មេរៀនទី ១២ ការគ្រប់គ្រងសាលារៀន (ផ្នែកទី ២).........................................................84
១២.១.និយមន័យ ................................................................................................................84
១២.២.ភាពខុសគ្នារវាងការដឹកនាំ និងការគ្រប់គ្រង .............................................................84
១២.៣. យល់ដឹងអំពីសមាសភាគទាំង៤ នៃការគ្រប់គ្រងតាមសាលារៀន ...............................84
១២.៤.គោលបំណងនៃការគ្រប់គ្រងសាលារៀន ....................................................................87
១២.៥.តួនាទីអាជ្ញាធរចូលរួមក្នុងការគ្រប់គ្រងសាលារៀន ....................................................87

មេរៀនទី១៣ សាលារដ្ឋ និងសាលាឯកជន ........ 89
១៣.១. សេចក្តីផ្តើម ........ 89
១៣.២. ចំនួនសាលារដ្ឋ និងសាលាឯកជននៅកម្ពុជា ........ 89
១៣.៣. និយមន័យ ........ 91
១៣.៣.១.សាលារដ្ឋ ( Public School ) ........ 91
១៣.៣.២. សាលាឯកជន ( Private School ) ........ 92
១៣.៤.ការប្រៀបធៀបពីភាពខុសគ្នារវាងសាលារដ្ឋនិងសាលាឯកជន ........ 92
១៣.៤.១.ការអនុវត្តភាពជាអ្នកដឹកនាំ ( leadership Performance ) ........ 92
១៣.៤.២.កម្មវិធីសិក្សា ( Curriculum ) ........ 93
១៣.៤.៣.ប្រាក់ខែគ្រូបង្រៀន ( Teacher's Salary ) ........ 93
១៣.៤.៤.លទ្ធផលរំពឹងទុករបស់សិស្ស ( Student Outcome ) ........ 94
១៣.៤.៥.គណនេយ្យភាព ( ACCOUNTING ) ........ 94
មេរៀនទី ១៤ គោលនយោបាយគ្រូបង្រៀន ........ 96
១៤.១.សេចក្តីផ្តើម ........ 96
១៤.២.គោលនយោបាយគ្រូបង្រៀន ........ 97
១៤.៣.ចក្ខុវិស័យ ........ 98
១៤.៤.គោលបំណង និងគោលដៅ ........ 98
១៤.៤.១.គោលបំណង ........ 98
១៤.៤.២.គោលដៅ ........ 98
១៤.៥.យុទ្ធសាស្ត្រសំខាន់ៗក្នុងការធ្វើឱ្យសម្រេចគោលដៅ ........ 99
១៤.៦.ផែនការសកម្មភាព ........ 100
ឯកសារយោង ........ 104

## អារម្ភកថា

សៀវភៅនេះបានបង្កើតឡើងក្នុងគោលបំណងជួយសម្រួលដល់ការសិក្សាស្រាវជ្រាវរបស់គរុនិស្សិត ១២ + ៤ ជំនាន់នេះ និងជំនាន់ក្រោយៗទៀតងាយសិក្សាស្វែងយល់នូវខ្លឹមសារក្នុងនោះរួមមានមូលដ្ឋានចំណេះដឹងនៃបរិបទសង្គមសម្រាប់ការបង្រៀននិងរៀនសិក្សាពីជំនាញសតវត្សរ៍ទី២១និងអ្វីដែលសំខាន់ចំពោះការបង្រៀននិងរៀនគោលដៅនៃការអភិវឌ្ឍប្រកបដោយចីរភាពនិងទ្រឹស្តីនៃការអប់រំនៃនាំពីសញ្ញាណនៃសាលាជំនាន់ថ្មីនៅកម្ពុជានិងរបៀបផ្តល់ដល់សិស្សនូវបំណិនសតវត្សរ៍ទី ២១ កំណែទម្រង់នៃការគ្រប់គ្រងសាលារៀននិងគោលនយោបាយគ្រូប (ផ្តល់ដល់សាលានូវស្វ័យភាព) ង្រៀន។ មុខវិជ្ជាបរិបទសង្គមនៃការបង្រៀននិងរៀនជាមុខវិជ្ជារង១នៅក្នុងមុខវិជ្ជាការសិក្សាអប់រំគរុនិស្សិតត្រូវរៀននៅឆ្នាំទី៣ ឆមាសទី ១ មានចំនួន ១ ក្រេឌីត ស្មើនឹង ១៥ ម៉ោង។

ការអភិវឌ្ឍន៍ឯកសារនេះយើងខ្ញុំបានខិតខំស្វែងរកនូវប្រភពទិន្នន័យជាច្រើនដែលទាក់ទងនឹងខ្លឹមសារប្រធានបទខាងលើមករួមបញ្ចូលគ្នាដោយប្រភពឯកសារដែលពាក់ព័ន្ធនោះរួមមាន ឯកសាររបស់ក្រសួងអប់រំយុវ ជន និងកីឡា ឯកសារក្នុងបណ្ណាល័យវិទ្យាស្ថានគរុកោសល្យ និងទិន្នន័យខ្លះទៀតប្រមូលពីអ៊ីនធើណែតដែលជាប្រព័ន្ធផ្សព្វផ្សាយមួយមានភាពទូលំទូលាយសម្រាប់សតវត្សទី២១នេះដើម្បីបណ្តុះបណ្តាលគ្រូបង្រៀនប្រកបដោយប្រសិទ្ធភាព និងទទួលបានលទ្ធផលល្អ។

ទោះបីយ៉ាងណាក៏ដោយ យើងខ្ញុំគិតថាឯកសារនេះនៅមិនទាន់ល្អឥតខ្ចោះនោះទេ ប្រាកដជានូវមានចំណុចខ្វះខាតជាច្រើនទៀតនឹងត្រូវកែសម្រួលបន្ថែមទៀតទៅតាមពេលវេលា និងការរីកចម្រើនរបស់វិស័យ អប់រំ។

យើងខ្ញុំរង់ចាំទទួលនូវយោបល់រិះគន់ក្នុងន័យស្ថាបនាពីមិត្តអ្នកអាន និងអ្នកប្រើប្រាស់ទាំងអស់ដោយក្តីរីករាយដើម្បីជាទុនសម្រាប់កែលម្អឯកសារនេះឱ្យកាន់តែប្រសើរឡើងថែមទៀត។

# សេចក្តីថ្លែងអំណរគុណ

ជាការពិតសៀវភៅ «បរិបថសង្គមនៃការបង្រៀននិងរៀន» ដែលលេចចេញជារូបរាងនៅពេលនេះគឺបានកើតឡើងពីការខិតខំ និងយកចិត្តទុកដាក់ចូលរួមពីភាគី និងស្ថាប័នពាក់ព័ន្ធជាច្រើន។

យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតដល់ភាគីនិងស្ថាប័នពាក់ព័ន្ធទាំងអស់ដូចជា ៖

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលបានគាំទ្រយ៉ាងពេញទំហឹងដល់ក្រសួងអប់រំ យុវជន និងកីឡាឱ្យបង្កើតមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ ហៅកាត់ថា «មូលនិធិ ស.គ.ន»។

- ក្រសួងអប់រំ យុវជន និងកីឡាដែលបានបង្កើតមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ ដែលហៅកាត់ថា «មូលនិធិ ស.គ.ន» ដើម្បីរួមចំណែកលើកកម្ពស់វប្បធម៌នៃការស្រាវជ្រាវ បំផុសគំនិតច្នៃប្រឌិត និងជំរុញការធ្វើនវានុវត្ត ដើម្បីជាប្រយោជន៍ដល់វិស័យអប់រំ យុវជន និងកីឡា ដែលឆ្លើយតបទៅនឹងទីផ្សារពលកម្ម និងសាកលភាវូបនីយកម្ម។

- មូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ ដែលបានគាំទ្រដល់ការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា (Text book) ដែលនឹងត្រូវប្រើប្រាស់នៅកម្រិតឧត្តមសិក្សា ដើម្បីបង្កើនបរិមាណ លើកកម្ពស់គុណភាព និងពង្រីកសមធម៌នៃធនធានសិក្សាជាខេមរភាសាជូនដល់និស្សិតដែលកំពុងបន្តការសិក្សា និងត្រៀមខ្លួនធ្វើការស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។

- ឯកឧត្តមបណ្ឌិតនាយកវិទ្យាស្ថានគរុកោសល្យភ្នំពេញដែលបានចាត់តាំងជាគណៈកម្មការនិពន្ធចូលរួមការរៀបរៀង និពន្ធ និងកែលម្អសៀវភៅនៅកម្រិតឧត្តមសិក្សានេះ។

- នាយកដ្ឋានបណ្តុះបណ្តាលដែលបានចាត់តាំងជាគណៈកម្មការនិពន្ធ និងគណៈកម្មការត្រួតពិនិត្យ លើស្នាដៃនៃការចូលរួមការរៀបរៀង និពន្ធ និងកែលម្អសៀវភៅនៅកម្រិតឧត្តមសិក្សានេះ។

- លោកប្រធាន នាយកដ្ឋានបណ្តុះបណ្តាលដែលព្រមព្រៀងទទួលសិទ្ធិជាតំណាងអ្នករៀបរៀងក្នុងការចាត់ចែង និងសម្របសម្រួលជាមួយក្រសួងអប់រំ យុវជន និងកីឡា ចុះហត្ថលេខាលើកិច្ចព្រមព្រៀង និងកិច្ចដំណើការទូទាត់ថវិកាតាមរយៈការស្នើសុំ និងទទួលថវិកា បោះពុម្ព និងផ្សព្វផ្សាយបន្តនូវស្នាដៃរៀបរៀង និពន្ធ និងកែលម្អរបស់អ្នករៀបរៀងក្នុងការរៀន និងបង្រៀនក្នុងគ្រឹះស្ថានសិក្សា និងប្រគល់សិទ្ធិស្របតាមការកំណត់នៃកិច្ចព្រមព្រៀង ស្តីពីការរៀបរៀង និពន្ធ និងកែលម្អសៀវភៅនៅកម្រិតឧត្តមសិក្សា ក្រោមការគាំទ្រនៃមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍។

- គ្រូឧទ្ទេសមុខវិជ្ជាចិត្ត-គរុកោសល្យដេប៉ាតឺម៉ង់គរុកោសល្យនៃវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ ដែលបានផ្តល់មតិកែលម្អលើខ្លឹមសារ នៃមេរៀននីមួយៗឱ្យកាន់តែមានភាពសុក្រឹត និងមានលក្ខណៈវិទ្យាសាស្ត្រ។

យើងខ្ញុំសង្ឃឹមថា សៀវភៅនេះនឹងឆ្លើយតបជាបន្ទាន់ចំពោះការខ្វះខាតធនធានសិក្សា ដែលជាតម្រូវការសិក្សារបស់សិស្ស និស្សិត នៅកម្រិតវិទ្យាល័យ និងឧត្តមសិក្សា។

# ការបរិយាយលើមុខវិជ្ជា

មុខវិជ្ជានេះនឹងផ្តល់ឱ្យសិស្សនូវចំណេះដឹងជាមូលដ្ឋាននៃបរិបទសង្គមសម្រាប់ការបង្រៀន និងការរៀន។ ពួកគេនឹងចាប់ផ្តើមជាមួយនឹងការប្រឡងជំនាញសតវត្សទី 21 និងខ្លឹមសារសំខាន់ៗ សម្រាប់ការបង្រៀន និងការរៀន ។ មុខវិជ្ជានេះដែលនឹងត្រូវដាក់បញ្ចូលទាំងគោលដៅអភិវឌ្ឍន៍ ប្រកបដោយចីរភាព ក៏ដូចជាទ្រឹស្តីអប់រំផ្សេងៗ និងការអប់រំប្រៀបធៀប ដើម្បីផ្តោតលើផែនការយុទ្ធសាស្ត្រអប់រំដែលមានស្រាប់ ២០២២-២០២៣។

បន្ទាប់មក គរុនិស្សិតនឹងត្រូវបានណែនាំអំពីសញ្ញាណនៃសាលាជំនាន់ថ្មី (NGS) នៅកម្ពុជា និងរបៀបក៏ដូចជាការអនុវត្តន៍ជាក់ស្តែងដើម្បីជាបទពិសោធន៍ក្នុងការបង្រៀនឆ្លើយតបជំនាញសតវត្សទី 21 ។ លើសពីនេះ គរុនិស្សិតក៏នឹងសិក្សាអំពីកំណែទម្រង់ការគ្រប់គ្រងតាមសាលារៀនដែលកំពុងត្រូវបានអនុវត្ត ដើម្បីជួយគាំទ្រសាលារៀនជាមួយនឹងស្វ័យភាពសម្រាប់ដំណើរការប្រកបដោយគុណភាព និងការរៀនសូត្រល្អបំផុតរបស់សិស្សនាពេល អនាគត។

មុខវិជ្ជានេះនឹងបញ្ជាក់អំពីគោលនយោបាយគ្រូបង្រៀនដើម្បីឱ្យគរុនិស្សិតដឹងពីរបៀបដែលពួកគេអាចកំណត់ការបង្រៀនរបស់ពួកគេ និងការសិក្សារបស់សិស្សរបស់ពួកគេដើម្បីទទួលបានលទ្ធផលប្រកបដោយគុណភាពបំផុតសម្រាប់ប្រទេសកម្ពុជា។

# មូលន័យសង្ខេប

បរិបទសង្គមនៃការបង្រៀននិងរៀនជាមុខវិជ្ជាផ្តោតលើខ្លឹមសារសំខាន់ៗដូចជា គ្រូបង្រៀនសតវត្សរ៍ទី២១ គោលដៅអភិវឌ្ឍប្រកបដោយចីរភាព បញ្ញត្តិនៃការអប់រំសម្រាប់ការអភិវឌ្ឍ គោលការណ៍ចម្បងនៃការអប់រំសម្រាប់ការអភិវឌ្ឍនប្របកដោយចីរភាព ទ្រឹស្តីនៃការអប់រំ ការប្រៀបធៀបការអប់រំអន្តរជាតិ ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៩-២០២៣ សាលារៀនជំនាន់ថ្មី ការគ្រប់គ្រងសាលារៀន សាលារដ្ឋនិងសាលាឯកជន គោលនយោបាយគ្រូបង្រៀន។ ខ្លឹមសារទាំងអស់នេះនឹងជួយពង្រឹងសមត្ថភាពមូលដ្ឋានសម្រាប់គរុនិស្សិតពិសេសជាកញ្ចក់ឆ្លុះបញ្ចាំងពីបទពិសោធន៍នៃការអប់រំនាសតវត្សទី២១ដែលកំពុងប្រឈម ដើម្បីជួយគ្នារកដំណោះស្រាយក្នុងវិជ្ជាជីវៈជា គ្រូបង្រៀននេះ។

ការបង្រៀននៅសតវត្សរ៍ទី ២១ មានន័យថាការបង្រៀនដូចដែលអ្នកបានបង្រៀនតែជាមួយនឹងឧបករណ៍និងបច្ចេកវិទ្យាសព្វថ្ងៃ។ វាមានន័យថាប្រើប្រាស់អ្វីគ្រប់យ៉ាងដែលមានសារៈសំខាន់នៅក្នុងពិភពលោកសព្វថ្ងៃនេះដើម្បីឱ្យសិស្សអាចមានលទ្ធភាពរស់នៅនិងរីកចម្រើននៅក្នុងសេដ្ឋកិច្ចនាពេលបច្ចុប្បន្នក៏ដូចជាមានសមត្ថភាពណែនាំនិស្សិតនិងរៀបចំពួកគេសម្រាប់ពេលអនាគត។

គោលដៅអភិវឌ្ឍប្រកបដោយចីរភាព (ESD) គឺផ្តោតលើការអប់រំ និងការរៀនសូត្រដែលទាមទារឱ្យប្រជាជនចូលរួមគិតពីបញ្ហានៃការអភិវឌ្ឍប្រកបដោយចីរភាពនិរន្តរភាព ដោយអភិវឌ្ឍន៍សមត្ថភាពរបស់ពួកគេតាមរយៈការអប់រំ។

ការអប់រំដែលលើកទឹកចិត្តឱ្យមានការផ្លាស់ប្តូរចំណេះដឹង ជំនាញ គុណតម្លៃ និងឥរិយាបថដើម្បីធ្វើឱ្យសង្គមមាននិរន្តភាព និងយុត្តិធម៌ សម្រាប់មនុស្សទាំងអស់។ ESD លើកកម្ពស់ប្រជាជនដើម្បីផ្លាស់ប្តូរវិធីគិតនិងអនុវត្តរបស់ប្រជាពលរដ្ឋឆ្ពោះទៅរកអនាគតប្រកបដោយនិរន្តភាព(អង្គការសហប្រជាជាតិ)។ពេលដែលយើងពង្រីកចំណេះដឹងអំពីទ្រឹស្តីអប់រំ យើងផ្តោតសំខាន់ទៅលើមូលដ្ឋានគ្រឹះនៃទ្រឹស្តីការអប់រំមួយចំនួនដូចជា៖ ទ្រឹស្តីអាកប្បកិរិយា ទ្រឹស្តីនៃការយល់ដឹង ទ្រឹស្តីស្ថាបនានិយម និងការលើកទឹកចិត្ត ឬទ្រឹស្តីមនុស្សនិយម។ប្រៀបធៀបប្រព័ន្ធអប់រំរវាងប្រទេសកំពុងអភិវឌ្ឍនិងប្រទេសអភិវឌ្ឍដូចជា៖ កម្មវិធីសិក្សា ការអប់រំគ្រូ និងលក្ខខ័ណ្ឌនៃការជ្រើសរើស។ ចំណេះដឹងអំពីប្រព័ន្ធអប់រំនៃប្រទេសផ្សេងៗជួយដល់អ្នកធ្វើគោលនយោបាយក្នុងការឆ្លុះបញ្ចាំងពីការអប់រំនៅក្នុងបរិបទនៃការប្រកួតប្រជែងនិងឧត្តមភាព។

ដើម្បីសម្រេចតាមគោលដៅនេះ ក្រសួងអបរំ យុវជន និងកីឡា បានអនុម័តផែនទីបង្ហាញផ្លូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ស្តីពីការអបរំនៅកម្ពុជានៅដើមឆ្នាំ២០១៩ ដើម្បីធានាឱ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា។

ដោយហេតុថា សៀវភៅមួយនេះជាការរៀបចំចងក្រងលើកដំបូង វាមិនទាន់មានលក្ខណៈល្អប្រសើរនៅ ឡើយទេវាប្រាកដណាស់នៅមានចន្លោះខ្វះខាត ឬល្អៀងខ្លះៗ ដែលទាមទារការអភិវឌ្ឍជាបន្តបន្ទាប់។

# មេរៀនទី១ គ្រូបង្រៀនសតវត្សរ៍ទី២១

## វត្ថុបំណង

បន្ទាប់ពីរៀនមេរៀននេះចប់គរុនិស្សិតអាចៈ

- ពន្យល់បានពីបំណិនសតវត្សទី២១តាមរយៈកិច្ចការស្រាវជ្រាវបានត្រឹមត្រូវ
- ពន្យល់បានពីការបង្រៀនដែលផ្តល់ដល់សិស្សនូវបំណិនសតវត្សទី២១
- អនុវត្តបំណិនសតវត្សទី២១ក្នុងការបង្រៀននិងរៀន

## ១.១. សេចក្តីផ្តើម

ជំនាញដែលសិស្សត្រូវការដើម្បីរួមចំណែកក្នុងការអភិវឌ្ឍសង្គមមានការផ្លាស់ប្តូរឥតឈប់ឈរ ប៉ុន្តែប្រព័ន្ធអប់រំរបស់ពួកយើងមិនមានការប្រែប្រួលខ្លាំងទេ។សាលាភាគច្រើនមើលទៅដូចគ្នានឹងសាលាជំនាន់មុនដែរហើយគ្រូខ្លួនឯងច្រើនតែមិនអភិវឌ្ឍនូវការអនុវត្តនិងបំណិនដែលត្រូវការដើម្បីបំពេញតម្រូវការរបស់អ្នកសិក្សានាពេលបច្ចុប្បន្ន ។ តើបំណិនអ្វីខ្លះដែលយុវជនត្រូវការដើម្បីចូលរួមយ៉ាងសកម្មនៅក្នុងពិភពលោកដែលមានការផ្លាស់ប្តូរយ៉ាងឆាប់រហ័សនេះ? ហើយប្រព័ន្ធអប់រំអាចគាំទ្រយ៉ាងដូចម្តេចទៅនឹងប្រភេទនៃការបង្រៀនដែលអភិវឌ្ឍបំណិនទាំងនោះ? តើគ្រូមានតួនាទីអ្វីខ្លះក្នុងការដឹកនាំច្នៃប្រឌិតថ្មីទាំងក្នុងនិងក្រៅថ្នាក់រៀន?

ការបង្រៀននៅសតវត្សរ៍ទី 21 មានន័យថាការបង្រៀនដូចដែលអ្នកបានបង្រៀនតែជាមួយនឹងឧបករណ៍និងបច្ចេកវិទ្យាសព្វថ្ងៃ។ វាមានន័យថាប្រើប្រាស់អ្វីគ្រប់យ៉ាងដែលមានសារៈសំខាន់នៅក្នុងពិភពលោកសព្វថ្ងៃនេះដើម្បីឱ្យសិស្សអាចមានលទ្ធភាពរស់នៅនិងរីកចម្រើននៅក្នុងសេដ្ឋកិច្ចនាពេលបច្ចុប្បន្នក៏ដូចជាមានសមត្ថភាពណែនាំនិស្សិតនិងរៀបចំពួកគេសម្រាប់ពេលអនាគត។

### ១.១.១.ថ្នាក់រៀនកាលពីសម័យមុន

តាំងពីបុរាណកាលមកនៅសតវត្សទី១៣មកព្រះពុទ្ធសាសនាបានដើរតួនាទីយ៉ាងសំខាន់ក្នុងការអប់រំនៅក្នុងសង្គមខ្មែរ សូម្បីតែក្នុងសម័យបារាំងគ្រប់គ្រងចាប់ទាំងពីឆ្នាំ១៨៦៣មកក៏ដោយ។ បន្ទាប់ពីមានការមកដល់នៃប្រព័ន្ធអប់រំបែបបារាំងមានជាបន្តបន្ទាប់មកក្តី ក៏តួនាទីរបស់វត្តនៃព្រះពុទ្ធសាសនាក្នុងការគាំទ្រដល់ការអប់រំនៅកម្ពុជានៅតែមានសារៈសំខាន់។ បន្ទាប់ពីសាលាទំនើបថ្មីដំបូងគេបានបង្កើតឡើងនៅស្រុកខ្មែរហៅថាសាលា"ភាសាបារាំង"ដែរអាណាព្យាបាលបារាំងបានសាងសង់ឡើងនៅឆ្នាំ១៨៧៣ ហើយបន្ទាប់ពីនោះមកទៀតសាលារៀនជាច្រើនទៀតក៏ត្រូវបានបង្កើតឡើងនៅតាមទីក្រុងនានាៗពាសពេញប្រទេសកម្ពុជាផងដែរ។

យោងតាមក្រសួងអប់រំយុវជននិងកីឡាបានបង្ហាញថាមានសាលារដ្ឋចំនួន ១២,៨៨៩ ក្នុងនោះមានសាលាបឋមសិក្សា អនុវិទ្យាល័យ វិទ្យាល័យត្រូវបានសាងសង់នៅក្នុងព្រះរាជាណាចក្រ (MoEYS, ឯកសារឆ្នាំ២០១៧)។ ប្រសិនបើយើងស្វែងយល់ និងយកចិត្តទុកដាក់គ្រប់គ្រាន់ពីរឿងនេះ

វាក៏ជាវិធីមួយដែលជួយរំដោះសិស្សចេញពីភាពល្ងង់ខ្លៅនិងជាបំណងប្រាថ្នារបស់ពិភពលោកដែលនៅទីបំផុតការសិក្សាទាំងនោះបានជួយពួកគេឱ្យមានពន្លឺ។

តើថ្នាក់នៅសម័យមុនគេបង្រៀនសិស្សយ៉ាងដូចម្ដេចខ្លះ ?

- សិស្សទទួលយកខ្លឹមសារមេរៀនដោយគ្រូបង្រៀននៅក្នុងថ្នាក់
- គ្រូប្រើវិធីឧទ្ទេសនិងការអានសៀវភៅគោល
- សិស្សត្រូវបានវាយតម្លៃដោយផ្ដោតជាបឋមលើចំណេះដឹងដែលបានសិក្សានៅក្នុងថ្នាក់។



*រូបភាព ទី 1 ការបង្រៀនសម័យមុន*

## ១.១.២.ថ្នាក់រៀននៅសតវត្សរ៍ទី២១

អ្នកអប់រំសតវត្សរ៍ទី 21 ដែលមានប្រសិទ្ធិភាពគិតអំពីអនាគតរបស់សិស្សពួកគេហើយយល់ដឹងពីឱកាសការងារដែលអាចកើតឡើងពីពួកគេ។ ពួកគេតែងតែមានគម្រោងដើម្បីធានាថាគ្មានកុមារណាម្នាក់ត្រូវបានគេទុកឱ្យនៅសល់ឡើយដូច្នេះពួកគេផ្ដោតលើការរៀបចំកុមារថ្ងៃនេះសម្រាប់អ្វីដែលនឹងមកនាពេលអនាគត។

អ្នកអប់រំដែលមានប្រសិទ្ធិភាពក្នុងសតវត្សរ៍ទី 21 ត្រូវតែមានលទ្ធភាពសហការនិងធ្វើការបានល្អនៅក្នុងក្រុម។ ជាងមួយទសវត្សរ៍កន្លងមកនេះជំនាញដ៏សំខាន់នេះបានកើនឡើងយ៉ាងឆាប់រហ័សនៅក្នុងសាលារៀន។ ការសិក្សារៀនសូត្រត្រូវបានចាត់ទុកថាមានប្រសិទ្ធភាពជាងនៅពេលដែលអ្នកអាចចែករំលែកគំនិតនិងចំណេះដឹងរបស់អ្នកជាមួយអ្នកដទៃ។ ការចែករំលែកជំនាញនិងបទពិសោធន៍របស់អ្នកហើយការប្រាស្រ័យទាក់ទងនិងការរៀនសូត្រពីអ្នកដទៃគឺជាផ្នែកសំខាន់នៃដំណើរការសិក្សានិងបង្រៀន។

បច្ចេកវិទ្យាកំពុងផ្លាស់ប្ដូរក្នុងល្បឿនយ៉ាងឆាប់រហ័សហើយនោះមានន័យថាគ្រូបង្រៀនសតវត្សទី 21 មានសិទ្ធិក្នុងការធ្វើដំណើរ។ បច្ចេកវិជ្ជាចុងក្រោយបង្អស់មិនថាសម្រាប់ មេរៀន ឬ ចំណាត់ថ្នាក់ នឹងអនុញ្ញាតឱ្យគ្រូនិងសិស្សអាចរៀនបានល្អប្រសើរនិងលឿនជាងមុន។ គ្រូបង្រៀនដែលមានប្រសិទ្ធិភាពដឹងថាការរៀនសូត្រពីឧបករណ៍អេឡិចត្រូនិចចុងក្រោយបង្អស់ពិតជាអាចផ្លាស់ប្ដូរការអប់រំរបស់សិស្សពួកគេបានដូច្នេះវាមិនត្រឹមតែមានចរិតលក្ខណៈថ្មីៗប៉ុណ្ណោះទេតែថែមទាំងចេះធ្វើជំនួញ។

ក្នុងនាមជាគ្រូបង្រៀននៅក្នុងពិភពលោកនាពេលបច្ចុប្បន្ននេះមានន័យថាអ្នកត្រូវសម្របខ្លួនទៅនឹងឧបករណ៍និងការផ្លាស់ប្ដូរដែលកំពុងផ្លាស់ប្ដូរដែលកំពុងអនុវត្តនៅក្នុងសាលារៀ

ន។ Smartboards ត្រូវបានជំនួសខ្ទង់សៀវភៅនិង Tablet កំពុងជំនួសសៀវភៅសិក្សាហើយគ្រូបង្រៀនសតវត្សរ៍ទី 21 ត្រូវការមិនអីទេ។

តើថ្នាក់រៀននៅសតវត្សរ៍ទី២១ គេបង្រៀនសិស្សយ៉ាងដូចម្តេច?

- គ្រូបង្រៀនជាអ្នកសម្របសម្រួល
- បង្រៀនសិស្សដោយប្រើវិធីចម្រុះដែលបង្កើតបានជាបរិស្ថានសិក្សាកុមារមេត្រី នឹងផ្តល់ដល់សិស្សក្នុងការជ្រើសរើសបែបផែនសិក្សាសមស្របណាមួយសម្រាប់ពួកគេ
- ផ្តល់ឱកាសដល់សិស្សបង្ហាញពីអ្វីដែលគេចេះនិងមានសមត្ថភាពក្នុងការធ្វើអ្វីមួយ ។



*រូបភាព 2 ថ្នាក់រៀនស.វ. ទី២១*




*រូបភាព 3 ៖ ការអប់រំ១.០*




*រូបភាព 4 ៖ ២.០.ទំនាក់ទំនងបង្កើតបណ្តាញ កិច្ចសហការ(គ្រូបង្រៀនភ្លេង)*




*រូបភាព 5៖ ៣.០.បដិវត្តន៍ក្នុងការអប់រំ*

បដិវត្តន៍ក្នុងការអប់រំ ៣.០ ភ្ជាប់ទំនាក់ទំនង នវានុវត្ត អនុវត្តទ្រឹស្តីកសាងនិយម(អ្នកសិក្សាបង្កើតពេលវេលាសិក្សាផ្ទាល់ខ្លួន គ្រូបង្រៀនជាអ្នកសម្របសម្រួលតាមរយៈ Fb,Tweeter,and Instagram)

## ១.២. បំណិនសតវត្សរ៍ទី២១

ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា មានប្រសាសន៍ថា បំណិនសតវត្សទី២១ និងបំណិនឌីជីថលសំខាន់សម្រាប់យុវជនកម្ពុជា ហើយកម្មវិធីប្រកួតប្រជែងដេញដោលយុវជនថ្នាក់ជាតិ បានចូលរួមពង្រឹងសមត្ថភាពយុវជនឱ្យរៀនសូត្រពីបំណិនសតវត្សទី២១ ។ ដើម្បីឆ្លើយតបបំណិនសតវត្សទី២១ សិស្សានុសិស្សត្រូវស្វ័យសិក្សាជាប្រចាំ មានបំណិនសិក្សាពេញមួយជីវិត មានវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា និងមានបំណិនល្អក្នុងការរស់នៅ ។ លើសពីនេះ បុគ្គលដែលសុខភាពល្អអាស្រ័យលើមានបំណិនរស់នៅល្អ ចរិយាសម្បទា សីលធម៌ ជាទុនមួយនាំឱ្យមនុស្សក្លាយជាអ្នកដឹកនាំល្អ ។

បុគ្គលដែលមានជំនាញខ្ពស់ទាមទារឱ្យមានចំណេះដឹងឌីជីថល អក្ខរកម្មឌីជីថល ហើយចង់បានសង្គមឌីជីថលត្រូវមានពលរដ្ឋឌីជីថល ។សង្គមឌីជីថលជាគោលដៅយូរអង្វែងរបស់កម្ពុជាដែលត្រូវការពេលយូរដើម្បីទៅដល់។ ទន្ទឹមនឹងនេះ យុវជនឌីជីថលត្រូវរៀនសម្របខ្លួនជាមួយបច្ចេកវិទ្យា មានផ្នត់គំនិតប្រកបដោយ សីលធម៌ មានវិន័យ ខិតខំរៀនសូត្រ ខិតខំធ្វើការ ឱ្យតម្លៃទៅលើការងារ និងមានទំនាក់ទំនងល្អក្នុងសង្គម ។

ការអភិវឌ្ឍឌីជីថលជារឿងសំខាន់របស់ប្រទេសជាតិ ។ ទន្ទឹមនឹងនេះ យុវជនមានបំណិនជីថលជាជោគជ័យមួយក្នុងជីវិត ខ្លាំងទាំងចំណេះដឹង ខ្លាំងទាំងសេដ្ឋកិច្ច និងចេះផ្សារភ្ជាប់ឌីជីថលជាមួយរបៀបរស់នៅ ។

បំណិនសតវត្សទី២១ មានបីសំខាន់ៗ រួមមាន ទី១-បំណិននៃការសិក្សារៀនសូត្រ ផ្តោតលើការត្រិះរិះពិចារណា ការគិតដោយមានភាពច្នៃប្រឌិត ការសហការ និងការទំនាក់ទំនង ។ ទី២-បំណិននៃការទទួលព័ត៌មានថ្មីៗ ដូចជាសិស្សត្រូវមានចំណេះដឹងផ្នែកព័ត៌មានវិទ្យា ចំណេះដឹងផ្នែកប្រព័ន្ធផ្សព្វផ្សាយ និងចំណេះដឹងផ្នែក បច្ចេកវិទ្យា ។ ទី៣-បំណិនជីវិត ផ្តោតលើការចេះរស់នៅចុះសម្រុងជាមួយអ្នកដទៃ ការចេះផ្តួចផ្តើមគំនិត ភាពជាអ្នកដឹកនាំ និងផលិតភាពការងារ ។ បំណិនទាំងនេះសំខាន់សម្រាប់សិស្សានុសិស្សក្នុងសម័យសេដ្ឋកិច្ចពឹងផ្អែកលើបច្ចេកវិទ្យាព័ត៌មាន ។ គួរបញ្ជាក់ថា រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញគោលនយោបាយជំរុញឱ្យប្រទេសកម្ពុជាក្លាយជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់ឆ្នាំ២០៣០ និងក្លាយជាប្រទេសអភិវឌ្ឍន៍ នៅឆ្នាំ២០៥០ ។ ទន្ទឹមមគ្នានេះទាមទារឱ្យយុវជនមានបំណិនសតវត្សទី២១ និងបំណិនឌីជីថល មានការអប់រំទូលំទូលាយ ដើម្បីអាចឆ្លើយតបការដាក់ចេញជាខ្សែបន្ទាត់គោលនយោបាយ ។ ស្របគ្នានេះក្រសួងអប់រំបង្កើតឱ្យមានសាលាជំនាន់ថ្មី សាលាអ៊ីធូស្មែម គម្រោងគ្រប់គ្រង SBM ប្រកបដោយប្រសិទ្ធភាព សាលាធនធាន និងសាលាផ្សេងៗទៀតជួយគាំទ្រសិស្ស និងគ្រូបង្រៀនមានសមត្ថភាពដោះស្រាយបញ្ហាសតវត្សទី២១ ៕

យោងតាមឯកសារកំណែទម្រង់វិធីសាស្ត្របង្រៀនដើម្បីលើកម្ពស់បំណិនសតវត្សទី២១ (បណ្ឌិតសភាចារ្យ ហង់ ជួនណារ៉ុន ២០២១) បំណិនសតវត្សទី២១គឺសំដៅលើបំណិនទន់និងបំណិនបុរេវិជ្ជាជីវៈដែលដើរ តួនាទីយ៉ាងសំខាន់នៅក្នុងទីផ្សារការងារដែលយុវជនកម្ពុជាត្រូវមាន។បំណិនសតវត្សទី២១គឺជាជំនាញដែលជួយពង្រឹងនិងអភិវឌ្ឍសមត្ថភាពសិស្សានុសិស្សដើម្បីទទួលបានជោគជ័យក្នុងអាជីពការងារនាសម័យបច្ចេកវិទ្យាទំនើបនេះ។

បំណិនសតវត្សទី ២១ មានសមាសភាគ ៣ គឺ៖

- **បំណិនសិក្សារៀនសូត្រ** ៖ ការត្រិះរិះពិចារណា ការគិតដោយមានភាពច្នៃប្រឌិតនិងនវានុវត្តន៍ ការសហការនិងការប្រាស្រ័យទាក់ទង។
- **បំណិនអក្ខរកម្ម** ៖ សិស្សត្រូវមាន អក្ខរកម្មព័ត៌មានវិទ្យា អក្ខរកម្មផ្នែកប្រព័ន្ធផ្សព្វផ្សាយនិងអក្ខរកម្មផ្នែកបច្ចេកវិទ្យា។
- **បំណិនជីវិត** ៖ ភាពទន់ភ្លន់និងសម្របសម្រួល ការចេះផ្តួចផ្តើមគំនិត ភាពជាអ្នកដឹកនាំ ផលិតភាពការងារ និងបំណិនសង្គម។

### ១.២.១. **ការគិតស៊ីជម្រៅ** ( Critical Thinking )

- ការរកឃើញព័ត៌មានថ្មីៗ
- ការបកស្រាយនិងការវិភាគ
- ផ្ដល់ជាមតិយោបល់ដើម្បីកែលម្អ
- ការដោះស្រាយបញ្ហា
- ការគិតជាប្រព័ន្ធ




*រូបភាព 6៖ ជំនាញស.វ.ទី២១*




*រូបភាព 7៖ បំណិនស.វ.ទី២១*

### ១.២.២.**ការសហការ** ( Collaboration )

- ភាពជាអ្នកដឹកនាំនិងគំនិតផ្តួចផ្តើម
- មានកិច្ចសហការប្រតិបត្តិការល្អ
- ការបត់បែនតាមកាលៈទេសៈ
- ទំនួលខុសត្រូវនិងផលិតភាព
- ភាសាដែលប្រើប្រព័ន្ធឌីជីថល
- ការឆ្លើយតបនឹងផ្ដល់ជាមតិត្រឡប់

### ១.២.៣.**ការទំនាក់ទំនង** ( Communication )

- ភាពជាអ្នកដឹកនាំនិងផ្តួចផ្តើម
- មានកិច្ចសហប្រតិបត្តិការល្អ
- ការបត់បែនតាមកាលៈទេសៈ
- ទំនួលខុសត្រូវនិងផលិតភាព
- ភាសាដែលប្រើប្រព័ន្ធឌីជីថល
- ការឆ្លើយតបនិងផ្ដល់ជាមតិត្រឡប់

### ១.២.៤.ការបង្កើតថ្មី (Creativity )

- រចនាគំនិតនិងការកែលម្អ
- ការស្វែងរកដោយមានភាពបើកចំហរនិងក្លាហាន
- ធ្វើការបង្កើតថ្មីជាមួយអ្នកដទៃ (ច្នៃប្រឌិត )
- បង្កើតផលិតផលនឹងនវានុវត្តន៍ ។

ក្រៅពីបំណិន C 4 ខាងលើមានបំណិនផ្សេងមួយចំនួនទៀតដូចជា ៖

## ១.៣.បំណិនទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព

- ការងារក្រុម
- កិច្ចសហការប្រតិបត្តិការ
- ជំនាញអន្តរបុគ្គល
- ទំនាក់ទំនងអន្តរកម្ម
- ជំនាញក្នុងការសម្របខ្លួនទៅគ្រប់មជ្ឈដ្ឋាន

## ១.៤.បំណិនក្នុងការសិក្សានិងច្នៃប្រឌិត




*រូបភាព ៨ ៖ បំណិនច្នៃប្រឌិត*




*រូបភាព ៩៖បំណិនក្នុងការសិក្សា*

## ១.៥ .បំណិនផ្នែកព័ត៌មានមេឌា និងបច្ចេកវិទ្យា




*រូបភាព 10៖ បំណិនព័ត៌មាន*

**បំណិនព័ត៌មាន**

- អក្ខរកម្មព័ត៌មាន
- អក្ខរកម្មមេឌា
- អក្ខរកម្មពហុវប្បធម៌
- អក្ខរកម្មមូលដ្ឋានវិទ្យាសាស្ត្រ សេដ្ឋកិច្ចនិងបច្ចេកវិទ្យា

## ១.៦ .បំណិនជីវិតនិងការងារ

- ភាពប៉ិនប្រសប់ផ្នែកទំនាក់ទំនងជាមួយសង្គមនិងជាមួយមនុស្សដែលមានវប្បធម៌ខុសគ្នា
- ភាពជាអ្នកដឹកនាំនិងទទួលខុសត្រូវ
- មានគំនិតផ្តួចផ្តើមចេះដឹកនាំខ្លួនឯង
- ភាពទន់ភ្លន់និងការសម្របខ្លួន
- ផលិតភាពនិងគណនីយភាព

### ១.៦.១.ចំណេះដឹងនិងជំនាញត្រូវការនៅក្នុងសតវត្សរ៍ទី២១

- អក្សរសាស្ត្រ
- គណិតសាស្ត្រ
- អក្ខរកម្មវិទ្យាសាស្ត្រ
- អក្ខរកម្មបច្ចេកវិទ្យាពត៌មាន
- អក្ខរកម្មហិរញ្ញវត្ថុ
- វប្បធម៌និងពលរដ្ឋ
- សម្បទាដោះស្រាយ បញ្ហា
- ការច្នៃប្រឌិត
- ជំនាញអន្តរកម្មបុគ្គល\ជំនាញសំណេរនិងវោហាសាស្ត្រក្នុងកិច្ចទំនាក់ទំនង
- កិច្ចសហប្រតិបត្តិការនិងការងារក្រុម
- ចម្ងល់ចង់ដឹង
- គំនិតផ្តួចផ្តើម
- តស៊ូ អត់ធ្មត់ជំនាញគ្រប់គ្រងខ្លួនឯង
- ភាពជាអ្នកដឹកនាំ




*រូបភាព 11៖ ចំណេះនិងជំនាញត្រូវការនៅស.វ.២១*

- ចំណេះដឹងលើសង្គមនិងវប្បធម៌

### ១.៦.២.ជំនាញសំខាន់ទាំង ១០ ក្នុងឆ្នាំ ២០១៥ ធៀបនឹងឆ្នាំ ២០២០

| ឆ្នាំ ២០១៥ | ឆ្នាំ ២០២០ |
|---|---|
| ១.ការដោះស្រាយបញ្ហាស៊ាំញ៉ាំ<br>២.កិច្ចសហការជាមួយអ្នកដទៃ<br>៣.ការគ្រប់គ្រងមនុស្ស<br>៤.ការត្រិះរិះកម្រិតខ្ពស់<br>៥.ការចរចារ<br>៦.ការពិនិត្យគុណភាព<br>៧.ការតម្រង់ទិសសេវាកម្ម<br>៨.ការវិនិច្ឆ័យនិងការសម្រេចចិត្ត<br>៩.ការស្តាប់ដោយសកម្ម<br>១០.ការច្នៃប្រឌិត | ១.ការដោះស្រាយបញ្ហាស៊ាំញ៉ាំ<br>២.ការត្រិះរិះកម្រិតខ្ពស់<br>៣.ការច្នៃប្រឌិត<br>៤.ការគ្រប់គ្រងមនុស្ស<br>៥.កិច្ចសហការជាមួយអ្នកដទៃ<br>៦.សមត្ថភាពយល់ដឹងពីអារម្មណ៍ខ្លួនឯងនិងអ្នកដទៃ<br>៧.ការវិនិច្ឆ័យនិងការសម្រេចចិត្ត<br>៨.ការតម្រង់ទិស<br>៩.ការចរចារ<br>១០.ភាពបត់បែន |

### ១.៦.៣.ភាពខុសគ្នារវាងតម្រូវការរបស់សិស្សនិងគ្រូនៅសតវត្សរ៍ទី២១

| តម្រូវការសិស្សនៅសតវត្សរ៍ទី២១ | តម្រូវការគ្រូនៅសតវត្សរ៍ទី២១ |
|---|---|
| • ចូលចិត្តបច្ចេកវិទ្យា<br>• ការរៀនសូត្រឆ្លើយតបទៅនឹងតម្រូវការ និងមានភាពរីករាយ<br>• ត្រូវការរូបភាព វីដេអូ សម្លេងច្រើនជាងអត្ថបទ | • ស្ទាក់ស្ទើរមិនចេះប្រើប្រាស់បច្ចេកវិទ្យា<br>• អ្វីដែលត្រូវធ្វើគឺបង្រៀនចប់តាមកម្មវិធីសិក្សា<br>• អត្ថបទគឺជាប្រភពសំខាន់សម្រាប់ចំណេះដឹង<br>• សាំជាមួយថ្នាក់រៀនជាក់ស្តែង |

| | |
|---|---|
| • សាំជាមួយថ្នាក់រៀនជាក់ស្តែងនិងថ្នាក់រៀនសិប្បនិម្មិត<br>• ចូលចិត្តធ្វើចលនាក្នុងការរៀនសូត្រ | • គិតថាសិស្សគិតតែឃើញនិងស្តាប់ទៅបានហើយ |

### ១.៦.៤.គ្រូបង្រៀននៅសតវត្សរ៍ទី២១




*រូបភាព 12 ៖ គ្រូបង្រៀនស.វទី២១*

## ១.៧ . វិធីបង្រៀននិងរៀនបំណិនសតវត្សរ៍ទី២១

បើសិនជាអ្នកគិតថាខ្លួនអ្នកជាគ្រូបង្រៀនអ្នកក៏ត្រូវគិតថាខ្លួនអ្នកជា៖

- អ្នកបង្រៀនបំណិនជីវិត ជំរុញនិងលើកទឹកចិត្ត អ្នកចរចារ អ្នកពង្រឹងការអនុវត្តច្បាប់ អ្នកធ្វើជាគម្រូល្អ អ្នកពូកែរៀបចំអ្នកតាមដានតថភាពសង្គម អ្នកគៀរគរថវិការ អ្នកឯកទេសITអ្នកប្រឹក្សាយោបល់អ្នកធ្វើឱ្យសុបិន្តក្លាយជាការពិត ជាអាជ្ញាកណ្តាល អ្នកស្វែងរកការពិត អ្នកផ្តល់ភាពរីករាយ អ្នករៀបចំផែនការព្រឹត្តការណ៍ផ្សេងៗ អ្នករៀបចំគម្រោង អ្នកតុបតែងលម្អ អ្នកដឹកនាំនឹងអ្នករៀនពេញមួយជីវិត....។

### ១.៧.១. ធ្វើឱ្យទាក់ទងពាក់ព័ន្ធ ( Make it relevant )

វិធីបង្រៀននឹងរៀនជំនាញសតវត្សន៍ទី២១លើមុខវិជ្ជាវិទ្យាសាស្រ្ត

- ដើម្បីឱ្យមានប្រសិទ្ធភាពកម្មវិធីសិក្សាត្រូវតែទាក់ទងទៅនឹងជីវភាពរស់នៅរបស់សិស្ស។
- ការផ្ទេរនិងការទន្ទេញចាំមាត់អំពីចំណេះដឹងពិតអាចធ្វើឱ្យមុខវិជ្ជាណាមួយគ្មានភាពពាក់ព័ន្ធ។
- ភាពមិនទាក់ទងគ្នានាំឱ្យខ្វះការលើកទឹកចិត្តដែលជាហេតុនាំឱ្យមានការថយចុះការរៀនសូត្រ
- ដើម្បីឱ្យកម្មវិធីសិក្សាពាក់ព័ន្ធគ្នាគ្រូត្រូវចាប់ផ្តើមជាមួយប្រធានបទទូទៅដែលជាកន្លែងសំខាន់មួយនៅក្នុងការសិក្សា។

- គ្រូនិងសិស្សទទួលបានអត្ថប្រយោជន៍ពីការប្រើប្រាស់ប្រធានបទទូទៅនឹងការពង្រឹងភាពពាក់ព័ន្ធ។
- គ្រូចូលចិត្តវិធីសាស្ត្រនេះព្រោះវាអាចឱ្យគ្រូមានសេរីភាពក្នុងការបង្រៀនប្រកបដោយភាពច្នៃប្រឌិត។
- សិស្សចូលចិត្តព្រោះវាធ្វើឱ្យការរៀនសូត្រមានសារៈសំខាន់និងមានការចូលរួមហើយគេយល់ថាការយល់ដឹងគឺជាអ្វីដែលពួកគេអាចប្រើបាននៅក្នុងជីវភាពរស់នៅ។

**១.៧.២.បង្រៀនឱ្យគោរពច្បាប់ ឬបទដ្ឋាន**( Teach through the disciplines )

ការរៀនសូត្របែបនេះមិនត្រឹមតែមានចំណេះដឹងផ្នែកវិន័យប៉ុណ្ណោះទេប៉ុន្តែថែមទាំងមានជំនាញដែលទាក់ទងនឹងការអនុវត្តចំណេះដឹងដោយមានវិន័យផងដែរ។

- តាមរយៈកម្មវិធីសិក្សានិងការណែនាំអំពីវិន័យ សិស្សគួររៀនពីមូលហេតុដែលវិន័យមានសារៈសំខាន់។ឧទាហរណ៍ ៖ តាមរយៈការសិក្សាវិទ្យាសាស្ត្រសិស្សគួរតែរៀនពីមូលហេតុដែលវិទ្យាសាស្ត្រមានទំនាក់ទំនងគ្នារបៀបដែលអ្នកវិទ្យាសាស្ត្រអនុវត្តការពិសោធន៍ របៀបដែលពួកគេឈានដល់ការសន្និដ្ឋាន តើពួកគេធ្វើអ្វីខ្លះជាមួយនឹងចំណេះដឹងដែលទទួលបានពីដំណើរការទាំងនោះនិងវិធីដែលទាក់ទងនឹងរបកគំហើញរបស់គេ។

**១.៧.៣.អភិវឌ្ឍន៍បំណិនការគិតកម្រិតខ្ពស់និងការគិតកម្រិតទាបក្នុងពេលដំណាលគ្នា**

- លំហាត់កម្រិតទាបត្រូវមានជាធម្មតាក្នុងកម្មវិធីសិក្សាចំណែកឯសកម្មភាពនៃការគិតកម្រិតខ្ពស់ជាទូទៅមិនសូវមានទេ។
- ការគិតកម្រិតខ្ពស់មានការលំបាកសម្រាប់សិស្សព្រោះវាតម្រូវឱ្យពួកគេយល់ពីទំនាក់ទំនងរវាងអថេរពីរផ្សេងគ្នានិងអនុវត្តឬផ្ទេរការយល់ដឹងនោះទៅនឹងបរិបទថ្មីដែលមិនមានការផ្លាស់ប្តូរ។

**១.៧.៤ លើកទឹកចិត្តដល់ការផ្ទេរការសិក្សា**

- សិស្សត្រូវអនុវត្តចំណេះដឹង និងបំណិនគេទទួលបានដោយមានវិន័យត្រឹមត្រូវ
- ពួកគេក៏ត្រូវអនុវត្តអ្វីដែលពួកគេបានរៀននៅសាលាទៅក្នុងជីវភាពរស់នៅរបស់ពួកគេផងដែរ
- អនុវត្តឬការផ្ទេរនេះ អាចជាបញ្ហាប្រឈមសម្រាប់សិស្សនិងមនុស្សពេញវ័យផងដែរ
- វិធីដែលជាក់លាក់មួយចំនួនដែលគ្រូអាចលើកទឹកចិត្តដល់ការអនុវត្តឬការផ្ទេរ
- ការរៀបចំបទពិសោធន៍នៃការរៀនដែលមានលក្ខណៈស្រដៀងគ្នានឹងស្ថានភាពដែលសិស្សអាចត្រូវការដើម្បីអនុវត្តចំណេះដឹងនិងបំណិន
- កំណត់ការរំពឹងទុកដោយសិស្សប្រាប់ថា ពួកគេនឹងត្រូវរៀបចំអត្ថបទអំណះអំណាងរបស់ពួកគេតាមរបៀបដែលពួកគេកំពុងអនុវត្តនៅក្នុងថ្នាក់

- ឱ្យសិស្សអនុវត្តការជជែកដេញដោលគ្នាលើប្រធានបទជាលក្ខណៈឯកជន ជាមួយដៃគូរមុនពេលជជែកដេញដោលជាទ្រង់ទ្រាយធំនៅក្នុងថ្នាក់
- រៀបចំការសាកល្បងជជែកពិភាក្សាតាមបែបសភាឬហាត់សម្តែងតួរជាវិធីមួយជួយសិស្សក្នុងការអនុវត្តចូលរួមរបស់ពលរដ្ឋ
- និយាយតាមរយៈការដោះស្រាយបញ្ហាគណិតវិទ្យាជាក់លាក់ដែលនាំឱ្យសិស្សយល់ពីលំនាំនៃការគិតហើយពួកគេអាចអនុវត្តចំពោះបញ្ហាស្រដៀងគ្នា
- អនុវត្តរបកគំហើញនិងប្រើប្រាស់ភស្តុតាងពីប្រភពបឋមបន្ទាប់មកឱ្យសិស្សអនុវត្តកិច្ចការដូចគ្នាដោយប្រើប្រាស់ប្រភពបឋមផ្សេងទៀត។

## ១.៨. តួនាទីរបស់គ្រូក្នុងការធ្វើឱ្យសម្រេចបំណិនសតវត្សរ៍ទី ២១

- ជួយសម្រួលនិងជំរុញការរៀនសូត្រនិងគំនិតច្នៃប្រឌិតរបស់សិស្ស ដើម្បីឱ្យសិស្សសម្រេចកិច្ចការនៅក្នុងសង្គម
- ធ្វើការជាមួយសិស្សដើម្បីរួមបង្កើតឱកាសការរៀនថ្មី
- ប្រើទិន្នន័យដើម្បីគាំទ្រការរៀនសូត្ររបស់សិស្សនិងកែលម្អកម្មវិធីសិក្សា
- ជួយសិស្សដើម្បីបង្កើតសក្តានុពលនៃបទពិសោធន៍ការរៀនសូត្រជាផ្លូវការនិងក្រៅផ្លូវការ
- ធ្វើជាសមាជិកក្រុមសិក្សាប្រកបដោយប្រសិទ្ធភាព
- ប្រើឧបករណ៍បច្ចេកវិទ្យាឌីជីថល ឱ្យបានទូលំទូលាយដើម្បីកែលម្អការចូលរួមនិងសមិទ្ធិផលរបស់សិស្ស
- ធ្វើជាអ្នករៀនពេញមួយជីវិត
- ធ្វើជាអ្នកអប់រំពិភពលោក
- ធ្វើការជាអ្នកដឹកនាំគោលនយោបាយដែលជាភ្នាក់ងារផ្លាស់ប្តូរ។

## ១.៩.តួនាទី៧ចំណុចរបស់គ្រូបង្រៀននៅក្នុងយុគ្គសម័យទំនើប

**ទី១. អ្នកគ្រប់គ្រង** ៖ តាមពិតទៅគ្រូបង្រៀនមានតួនាទីក្នុងការគ្រប់គ្រងសកម្មភាពក្នុងថ្នាក់, លើសពីនេះ គ្រូបង្រៀនក៏ជាអ្នកសម្រេចចិត្តលើកិច្ចការអ្វីមួយដែលសិស្សគួរធ្វើ ក៏ដូចជាការដោះស្រាយសម្ភារៈបណ្តុះបណ្តាល ។ នៅពេលផ្តល់ចំណេះដឹងថ្មីៗដល់សិស្ស គ្រូត្រូវប្រើប្រាស់បទពិសោធន៍ និងសមត្ថភាព ក្នុងជួយជំរុញទឹកចិត្តសិស្ស ក្នុងការរៀនពីអ្វីដែលថ្មីៗ។

**ទី២. អ្នកលើកទឹកចិត្ត** ៖ នៅពេលដែលសិស្សជួបបញ្ហានៅក្នុងការសិក្សា គ្រូបង្រៀនមានតួនាទីសំខាន់ក្នុងការផ្តល់ជំនួយដល់ពួកគេ តាមរយៈការលើកទឹកចិត្ត ឬក៏អាចផ្តល់នូវតម្រុយបន្តិច។ ជាមួយគ្នានេះ នៅពេលសិស្សមិនដឹងថា ត្រូវនិយាយអ្វី ឬធ្វើអ្វីបន្ទាប់ គ្រូបង្រៀនក៏មានតួនាទីក្នុងការប្រាប់ពួកគេពីវិធីដែលត្រូវធ្វើផងដែរ។

**ទី៣. ប្រភពចំណេះដឹង ៖** គ្រូបង្រៀន គឺជាប្រភពចំណេះដឹងសម្រាប់សិស្ស នៅពេលពួកគេត្រូវការជំនួយចាំបាច់ បើទោះបីជាប្រព័ន្ធអ៊ីនធឺណេត ត្រូវបានគេចាត់ទុកថា ជាលំហូរចំណេះដឹងដ៏ធំសម្បើមក៏ដោយ ប៉ុន្តែក៏មិនអាចជំនួសគ្រូនៅក្នុងថ្នាក់នោះទេ។

**ទី៤. អ្នកវាយតម្លៃ ៖** ទិដ្ឋភាពសំខាន់មួយទៀតនៃទំនួលខុសត្រូវរបស់គ្រូបង្រៀន គឺត្រូវវាយតម្លៃស្ថានភាពសិក្សារបស់សិស្សខ្លួនជាប្រចាំ ។ គ្រូបង្រៀន ត្រូវតែផ្តល់មតិកែលម្អ និងផ្តល់ការកែតម្រូវសម្រាប់ភាពល្អរបស់សិស្ស ។ បច្ចេកទេសវាយតម្លៃប្រើដើម្បីយល់ថា តើសិស្សទទួលយកព័ត៌មានបានត្រឹមត្រូវឬអត់? ក្នុងពេលដំណាលគ្នា តួនាទីរបស់អ្នកវាយតម្លៃអនុញ្ញាតឱ្យគ្រូកែកំហុសរបស់សិស្ស។

**ទី៥. អ្នកសម្របសម្រួល ៖** ការសម្របសម្រួល ប្រហែលជាតួនាទីដ៏សំខាន់ និងទាមទារបំផុតដែលគ្រូបង្រៀនត្រូវអនុវត្ត។ ជារឿយៗ ភាពជោគជ័យក្នុងការសិក្សារបស់សិស្ស គឺអាស្រ័យទៅលើការរៀបចំគុណភាពនៃសកម្មភាពបណ្តុះបណ្តាល។ នេះមានសារៈសំខាន់ណាស់សម្រាប់សិស្សចូលរៀននៅសាលា មហាវិទ្យាល័យ និងសាកលវិទ្យាល័យ ដើម្បីដើរតាមគន្លងជាក់លាក់មួយក្នុងការសិក្សារបស់ពួកគេ។ អ្នកសម្របសម្រួលផ្តល់ការណែនាំ និងបង្កើតគោលបំណងសិក្សា។ ហើយគ្រូជាអ្នករៀបចំ និងគ្រប់គ្រងដំណើរការទាំងអស់នៅក្នុងថ្នាក់រៀន។ ដូចនេះ គ្រូបង្រៀន តែងតែប្រមូលកិច្ចការដែលបានបញ្ចប់ និងផ្តល់មតិកែលម្អ។

**ទី៦. អ្នកចូលរួម ៖** បរិយាកាសនៅក្នុងថ្នាក់រៀន ភាគច្រើនអាស្រ័យទៅលើអ្វីដែលគ្រូបង្រៀនធ្វើ និងរបៀបដែលសិស្សធ្វើ។ ជាឧទាហរណ៍ ដើម្បីបង្កើតបរិយាកាសមិត្តភាព និងផាសុកភាព គ្រូបង្រៀនអាចចូលរួមក្នុងសកម្មភាពជាមួយសិស្ស ប៉ុន្តែគ្រូបង្រៀនគួរតែចៀសវាងការបំពេញកិច្ចការបានល្អជាងសិស្សខ្លួន ការធ្វើបែបនេះ គឺដើម្បីអនុញ្ញាតឱ្យសិស្សបានបង្ហាញពីជំនាញ និងចំណេះដឹងរបស់ពួកគេ។

**ទី៧. អ្នកណែនាំ ៖** សិស្សតែងតែត្រូវការដំបូន្មាន និងការណែនាំរបស់គ្រូជាចម្បង នៅពេលដែលពួកគេធ្វើការលើគម្រោងអ្វីមួយ ។ តួនាទីបែបនេះ គឺជាមធ្យោបាយដ៏ល្អបំផុតក្នុងការផ្តល់ឱ្យសិស្សម្នាក់ៗនូវការយកចិត្តទុកដាក់ដោយមិនបែងចែក ។ តាមរយៈការសិក្សាពីតម្រូវការសិក្សារបស់សិស្ស និងគម្លាតចំណេះដឹង គ្រូបង្រៀនអាចកែលម្អដំណើរការបណ្តុះបណ្តាលសម្រាប់ពួកគេបាន។ ទោះជាយ៉ាងណាក៏ដោយ វាជារឿងសំខាន់ដែលមិនត្រូវធ្វើឱ្យអ្នកសិក្សាពឹងផ្អែកខ្លាំងពេកលើជំនួយរបស់គ្រូនោះឡើយ ពោលគឺពួកគេគួរតែស្វ័យភាពដោយខ្លួនឯង។

## សន្និដ្ឋាន

ជំនាញដែលសិស្សត្រូវការដើម្បីរួមចំណែកក្នុងការអភិវឌ្ឍសង្គមមានការផ្លាស់ប្តូរឥតឈប់ឈរប៉ុន្តែប្រព័ន្ធអប់រំរបស់យើងមិនមានការប្រែប្រួលខ្លាំងទេ។ សាលាភាគច្រើនមើលទៅដូចគ្នានឹងសាលាជំនាន់មុនដែរ ហើយគ្រូខ្លួនឯងច្រើនតែមិនអភិវឌ្ឍនូវការអនុវត្តនិងបំណិនដែលត្រូវការដើម្បីបំពេញតម្រូវការ

របស់អ្នកសិក្សានាពេលបច្ចុប្បន្នក្នុងនោះអ្នកសិក្សាត្រូវការបំណិនសតវត្សទី២១ មានដូចជាៈ បំណិនទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព បំណិនក្នុងការសិក្សានិងការច្នៃប្រឌិត បំណិនផ្នែកព័ត៌មាន មេឌា និងបច្ចេកវិទ្យា បំណិនជីវិត និងការងារ។

**សំណួរ**

១. តើបំណិននៅសតវត្សទី២១មានអ្វីខ្លះ?

២. តើយើងអាចអភិវឌ្ឍបំណិនសតវត្សទី២១តាមរយៈការបង្រៀននិងការរៀនដោយរបៀបណា?

៣. តើគ្រូបង្រៀនប្រភេទណាដែលយើងត្រូវការសម្រាប់ថ្នាក់រៀននិងសាលារៀននៅសតវត្សន៍ទី២១?

៤.តើគ្រូត្រូវប្រើវិធីអ្វីខ្លះដើម្បីបង្រៀនជំនាញសតវត្សន៍ទី២១ លើមុខវិជ្ជាសិក្សាសង្គម?

៥.ផ្អែកលើមធ្យោបាយក្នុងការផ្ទេរឬអនុវត្តការសិក្សាកម្រិតទាបដូចបានរៀបរាប់ខាងលើ តើអ្នកត្រូវធ្វើដូចម្តេច ដើម្បីឱ្យសិស្សមានការផ្ទេរឬអនុវត្តការសិក្សាកម្រិតខ្ពស់?

# មេរៀនទី២ គោលដៅអភិវឌ្ឍប្រកបដោយចីរភាព

## វត្ថុបំណង

បន្ទាប់ពីរៀនមេរៀននេះចប់គរុនិស្សិតនឹង៖

-កំណត់បានពីនិយមន័យនៃការអភិវឌ្ឍប្រកបដោយចីរភាព និងបញ្ញត្តិនៃការអប់រំសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព

-រៀបរាប់បានពីបញ្ហាបរិស្ថាន សាវតា និងគោលបំណងនៃការអភិវឌ្ឍប្រកបដោយចីរភាព

-យកចិត្តទុកដាក់លើការបង្រៀននិងរៀនដើម្បីសម្រេចគោលបំណងនៃការអប់រំសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព

## ២.១. សេចក្តីផ្តើម

ការអប់រំជាឧបករណ៍ដ៏សំខាន់សម្រាប់ការធ្វើឱ្យសម្រេចនិរន្តភាព ព្រោះវាធ្វើឱ្យមនុស្សមានការយល់ដឹងពីផលប្រយោជន៍របស់មនុស្សពីជំនាន់មួយទៅជំនាន់មួយ។យោងតាមអង្គការយូណេស្កូ ការអប់រំសម្រាប់ការអភិវឌ្ឍន៍ប្រកបដោយចីរភាពពឹងផ្អែកលើ កម្រិត និងប្រភេទនៃការសិក្សាទាំងអស់ដូចជារៀនដើម្បីដឹង ដើម្បីទទួលបានបំណិន ដើម្បីអាចរស់នៅជាមួយគ្នាបាន និងដើម្បីផ្លាស់ប្តូរខ្លួនឯងនិងសង្គម។

គោលដៅអភិវឌ្ឍប្រកបដោយចីរភាព (ESD) គឺផ្តោតលើការអប់រំ និងការរៀនសូត្រដែលទាមទារឱ្យប្រជាជនចូលរួមគិតពីបញ្ហានៃការអភិវឌ្ឍប្រកបដោយចីរភាពនិរន្តរភាព ដោយអភិវឌ្ឍន៍សមត្ថភាពរបស់ពួកគេតាមរយៈការអប់រំ។

## ២.២. សញ្ញាណទូទៅនៃបរិស្ថាន

បរិស្ថានជាអ្វីដែលនៅព័ទ្ធជុំវិញខ្លួនយើងរួមទាំងខ្លួនយើងមានដូចជា មនុស្ស សត្វ ធម្មជាតិទាំងឡាយរួមទាំងភាវៈមានជីវិត និងគ្មានជីវិតហើយភាវៈទាំងនោះមានទំនាក់ទំនងគ្នាទៅវិញទៅមកដែលជះឥទ្ធិពលមកលើផែនដីនេះ ។

(បរិស្ថានវិទ្យា) environment , environments មជ្ឈដ្ឋានជុំវិញទាំងអស់ (សំណុំរូបសាស្ត្រ សំណុំគីមី សំណុំជីវសាស្ត្រ) ដែលមានឥទ្ធិពលទៅលើជីវិត និងការលូតលាស់របស់មនុស្ស សត្វ និង/ ឬ រុក្ខជាតិ។

ឧ. ការការពារបរិស្ថានជាភារកិច្ចរបស់មនុស្សយើងទាំងអស់គ្នា។

គេចែកបរិស្ថានជា ៣ ផ្នែកគឺ ៖ បរិស្ថានធម្មជាតិ បរិស្ថានសង្គម វប្បធម៌ និងបរិស្ថានមនុស្ស។




*រូបភាព 13៖ បរិស្ថានមនុស្ស ធម្មជាតិ និងសង្គម វប្បធម៌*

### ២.២.១.បរិស្ថានធម្មជាតិ

បរិស្ថានធម្មជាតិ ជាភាវៈទាំងឡាយណាដែលមិនមែនបង្កើតឡើងដោយមនុស្ស ប៉ុន្តែវាត្រូវបានបង្កើតឡើងដោយមនុស្សរួមទាំងភាវៈមានជីវិត និងភាវៈគ្មានជីវិត ។

បរិស្ថានធម្មជាតិនៅប្រទេសកម្ពុជាមានដូចជា បឹងទន្លេសាប ទន្លេមេគង្គ តំបន់ខ្ពង់រាប ព្រៃឈើ សត្វព្រៃ តំបន់ព្រៃភ្នំ និងតំបន់មាត់សមុទ្រ ។ល។






*រូបភាព 14 ៖ បរិស្ថានធម្មជាតិ*

### ២.២.២.បរិស្ថានសង្គមវប្បធម៌

វត្ថុទាំងឡាយណាដែលមានប្រភពចេញពីបរិស្ថានធម្មជាតិ ហើយត្រូវបានកែច្នៃដោយមនុស្ស ដើម្បីជានាតម្រូវការជាមូលដ្ឋានក្នុងជីវភាពរស់នៅផ្នែករូបរាងកាយដូចជា ចំណីអាហារ ថាមពល ទឹកជម្រក សំលៀកបំពាក់ សាលារៀន ផ្លូវគមនាគមន៍ មន្ទីរពេទ្យ ផ្សារលក់ទំនិញ ។

សកម្មភាពនានាដែលមនុស្សរៀបចំឡើងដើម្បីបំពេញតម្រូវការផ្នែកស្មារតី ដូចជារបៀបរស់នៅ ក្នុងគ្រួសារ ជំនឿសាសនា ប្រពៃណី ទំនៀមទំលាប់ សិល្បៈ អក្សរសិល្ប៍ កីឡា និងប្រព័ន្ធរៀបចំសង្គម។

### ២.២.៣.បរិស្ថានមនុស្ស

បរិស្ថានមនុស្សសំដៅលើមនុស្សជាតិទាំងអស់នៅផែនដីមានទំនាក់ទំនងរវាងបរិស្ថានធម្មជាតិ និងបរិស្ថានសង្គមវប្បធម៌ ។

- បរិស្ថានមនុស្សនៅកម្ពុជារួមមាន៖
- កសិករ កម្មករ មន្ត្រីរាជការស៊ីវិល
- កងកម្លាំងប្រដាប់អាវុធ ពាណិជ្ជករ សិប្បករ
- ព្រះសង្ឃ ដូនជី និងជីតា
- ជនជាតិដើមភាគតិច ជនអន្តប្រវេសន៍ដូចជា វៀតណាម ឡាវ ថៃ ចិន និងជាតិសាសន៍ ដទៃទៀត
- ប្រទេសកម្ពុជាមានបញ្ហាបរិស្ថានដូចជា៖
- ការប្រែប្រួលអាកាសធាតុ
- ទឹកជំនន់
- ភាពរាំងស្ងួត
- ការបំពុលខ្យល់
- ការបំពុលទឹក
- ការបំពុលដី
- ការបំពុលដោយសម្លេង
- ការបំពុលសម្រាម
- កំណើនប្រជាជន
- កំណើនកម្ដៅលើភពផែនដី
- ការបំផ្លាញស្រទាប់អូសូន
- កង្វក់ឬការបំពុលដោយភ្លៀងអាស៊ីតនគរូបនីយកម្ម
- ការបំផ្លាញព្រៃឈើ
- ការវិនាសសាបសូន្យនៃសត្វមួយចំនួន
- ការប្រើប្រាស់ផូស៊ីលឥន្ទនៈ និងការកែច្នៃថាមពល ។
- តើបញ្ហាទាំងនេះកើតឡើងដោយមូលហេតុអ្វី ?
- សម្មភាពរបស់មនុស្សដូចជា ៖
- ការកាប់បំផ្លាញព្រៃឈើខុសច្បាប់
- បំផ្លាញជំរកនិងការជួញដូរសត្វព្រៃ
- ទន្ទ្រាននិងការយកដីក្នុងតំបន់អភិរក្ស
- គ្រប់គ្រងប្រព័ន្ធធារាសាស្ត្រនិងទីជម្រាលគ្មានប្រសិទ្ធភាព
- ប្រើប្រាស់ថ្នាំពុលកសិកម្ម និងគីមីឧស្សាហកម្មចូលទៅក្នុងដីនិងទឹក
- នេសាទត្រីហួសប្រមាណជាពិសេសបឹងទន្លេសាប
- បំផ្លាញព្រៃលិចទឹក



*រូបភាព 15 ៖ ការបំផ្លាញព្រៃឈើ*



*រូបភាព 16៖ សកម្មភាពរបស់មនុស្ស*



*រូបភាព 17៖ កង្វក់ឬការបំពុលទឹក*

- ការប្រើប្រាស់ថាមពលកើនឡើង
- បូមដីឬខ្សាច់ពីបាតទន្លេហួសកម្រិត
- ធ្វើអាជីវកម្មរ៉ែ
- ប្រើប្រាស់ថង់ប្លាស្ទិច សម្ភារវេចខ្ចប់ធ្វើពីស្នោឬជ័រច្រើនពេក។

ការអប់រំបរិស្ថាន ជាដំណើរបង្រៀននិងរៀនដើម្បីផ្តល់វិជ្ជាសម្បទា បំណិនសម្បទា និង ចរិយាសម្បទា លើផ្នែក បរិស្ថាន និង បញ្ហាប្រឈមផ្សេងៗដែលកើតមានឡើង។ វាផ្តល់នៅបំណិនចាំបាច់ដើម្បីដោះស្រាយ បញ្ហាប្រឈមនានា និងបណ្តុះឥរិយាបទ ឆន្ទៈ និងការ ប្តេជ្ញាចិត្តដើម្បី ធ្វើការសម្រេចចិត្ត និងសកម្មភាព ប្រកបដោយទំនួលខុសត្រូវខ្ពស់។( UNESCO-UNEP,Tbilisi Declaration,1978 )

## ២.៣. ការអភិវឌ្ឍប្រកបដោយចីរភាពនិងគោលដៅនៃ SDGs

ការអប់រំប្រកបដោយនិរន្តរភាពគឺជាអភិវឌ្ឍដែលបំពេញតម្រូវការបច្ចុប្បន្នដោយមិនធ្វើឱ្យបាត់បង់នូវលទ្ធភាពសម្រាប់អ្នកជំនាន់ក្រោយដើម្បីបំពេញតម្រូវការរបស់គេ។

SDGsជាគោលដៅសកលដែលត្រូវបានអនុម័តដោយរដ្ឋជាសមាជិកអង្គការសហប្រជាជាតិទាំងអស់ក្នុងឆ្នាំ២០១៥ ជាការអំពាវនាវជាសកលឱ្យធ្វើសកម្មភាពដើម្បីបញ្ចប់ភាពក្រីក្រ ការពារភពផែនដី និងធានាថាប្រជាជនទាំងអស់ទទួលបានសន្តិភាពនិងវិបុលភាពនៅឆ្នាំ២០៣០។

កិច្ចការអាចសម្រេចទៅបានដោយការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលលើធុរៈកិច្ចប្រព័ន្ធផ្សព្វផ្សាយស្ថានប័នឧត្តមសិក្សា និងអង្គការក្រៅរាជរដ្ឋាភិបាលដើម្បីលើកកម្ពស់រស់នៅរបស់ ប្រជាជន នៅក្នុងប្រទេសរបស់ពួកគេរស់នៅឆ្នាំ។

### ២.៣.១.គោលដៅនៃការអភិវឌ្ឍប្រកបដោយចីរភាព ៖

- លុបបំបាត់ភាពក្រីក្រនិងអត់ឃ្លាន
- បង្កើតឱ្យមានសុខភាពល្អ និង សុខុមាភាព
- ផ្តល់ការអប់រំប្រកបដោយគុណភាព
- ពង្រឹងសមភាពយេនឌ័រ
- ធ្វើឱ្យប្រសើរឡើងនៅទឹកស្អាតនិងអនាម័យ
- បង្កើនថាមពលសមស្របនិងបរិសុទ្ធ
- បង្កើតឱកាសការងារ និង  កំនើនសេដ្ឋកិច្ច
- បង្កើនឧស្សាហកម្ម ការច្នៃប្រឌិត និងហេដ្ឋារចនាសម្ព័ន្ធ
- កាត់បន្ថយវិសមភាព
- ប្រមូលផ្តុំទីក្រុងនិងសហាគមន៍ប្រកបដោយចីរភាព
- រៀបចំសកម្មភាពអាកាសធាតុ
- ធានានូវសន្តិភាព យុត្តិធម៌និងស្ថាប័នរឹងមាំ

- អភិវឌ្ឍជីវិតនៅក្រោមទឹកនិងលើដី ។
- កសាងភាពជាដៃគូសម្រាប់គោលដៅ។

## ២.៣.២.គោលបំណងសំខាន់ៗចំនួន១៧ចំណុចដូចជា៖

- គ្មាន ភាពក្រីក្រ បញ្ចប់ភាពក្រីក្រគ្រប់ទម្រង់នៅគ្រប់ទីកន្លែង។
- គ្មាន ភាពស្រេកឃ្លាន បញ្ចប់ភាពស្រេកឃ្លាន ហើយសម្រេចឱ្យបាននូវសន្តិសុខស្បៀងអាហារ និងអាហារូបត្ថម្ភដែលមានភាពប្រសើរឡើង ហើយលើកកម្ពស់វិស័យកសិកម្មប្រកបដោយចីរភាព។
- សុខភាព ល្អ ធានាឱ្យបាននូវជីវិតប្រកបដោយសុខភាពល្អ និងលើកកម្ពស់សុខុមាលភាពសម្រាប់មនុស្សគ្រប់រូប
- ការអប់រំ ប្រកបដោយគុណភាព ធានាឱ្យបាននូវការអប់រំប្រកបដោយគុណភាពសមធម៌ គ្រប់ជ្រុងជ្រោយ ហើយលើកកម្ពស់ឱកាសសិក្សារៀនសូត្រពេញមួយជីវិតសម្រាប់មនុស្សគ្រប់រូប។
- សមភាព យេនឌ័រ សម្រេចឱ្យបានសមភាពយេនឌ័រ ហើយផ្តល់អំណាចដល់ស្ត្រីនិងក្មេងស្រីទាំងអស់។
- ទឹកស្អាត និង អនាម័យ ធានាឱ្យបាននូវភាពមាន និងការគ្រប់គ្រងទឹក និងអនាម័យប្រកបដោយចីរភាពសម្រាប់មនុស្សគ្រប់រូប។
- ថាមពល កើតឡើងវិញ និងក្នុងតម្លៃសមរម្យ ធានាឱ្យបាននូវការផ្តល់លទ្ធភាពទទួលបាននូវថាមពលទំនើប ប្រកបដោយចីរភាព អាចជឿទុកចិត្តបាន ហើយក្នុងតម្លៃសមរម្យសម្រាប់ទាំងអស់គ្នា។
- ការងារ និង សេដ្ឋកិច្ចល្អ លើកកម្ពស់វឌ្ឍនភាពសេដ្ឋកិច្ចប្រកបដោយចីរភាព ការងារពេញលេញ និងសមរម្យសម្រាប់ទាំងអស់គ្នា។
- នវានុវត្តន៍ និង ហេដ្ឋារចនាសម្ព័ន្ធល្អ កសាងហេដ្ឋារចនាសម្ព័ន្ធរឹងមាំ លើកកម្ពស់ឧស្សាហូបនីយកម្មយ៉ាងពេញលេញ និងប្រកបដោយចីរភាព ហើយលើកតម្កើននវានុវត្តន៍។
- កាត់បន្ថយវិសមភាព កាត់បន្ថយវិសមភាពពីក្នុង និងក្នុងចំណោមប្រទេសនានា។
- ទីក្រុង និងសហគមន៍ប្រកបដោយចីរភាព ធ្វើឱ្យទីក្រុង និងការតាំងទីលំនៅរបស់មនុស្សមានលក្ខណៈរួមគ្នា មានសុវត្ថិភាព មាំទាំ និងមានចីរភាព។
- ការប្រើប្រាស់ធនធានប្រកបដោយការទទួលខុសត្រូវ ធានាឱ្យបាននូវការប្រើប្រាស់ និងគំរូផលិតកម្មប្រកបដោយចីរភាព។
- វិធានការចំពោះអាកាសធាតុ ចាត់វិធានការជាបន្ទាន់ប្រយុទ្ធប្រឆាំងនឹងបម្រែបម្រួលអាកាសធាតុ និងផលប៉ះពាល់ទាំងឡាយរបស់វា។
- មហាសមុទ្រប្រកបដោយចីរភាព អភិរក្ស ហើយប្រើប្រាស់មហាសមុទ្រ សមុទ្រ និងធនធានសមុទ្រសម្រាប់ការអភិវឌ្ឍន៍ប្រកបដោយចីរភាព។

- ការប្រើប្រាស់ដីប្រកបដោយចីរភាព ការពារ ស្តារឡើងវិញ និងលើកកម្ពស់ការប្រើប្រាស់ប្រកបដោយចីរភាពនូវប្រព័ន្ធអេកូសាស្ត្រនៅលើផែនដី គ្រប់គ្រងដោយចីរភាពនូវព្រៃឈើ ប្រយុទ្ធប្រឆាំងនឹងការធ្វើឱ្យក្លាយទៅជាវាលខ្សាច់ ហើយបញ្ឈប់ការធ្វើឱ្យអន់គុណភាពដី និងកែច្នៃវាឡើងវិញ ហើយបញ្ឈប់ការធ្វើឱ្យបាត់បង់នូវជីវៈចម្រុះ។
- សន្តិភាព និង យុត្តិធម៌... លើកកម្ពស់សង្គមជាតិនានាឱ្យមានសន្តិភាព និងរួមរស់ជាមួយគ្នាសម្រាប់ការអភិវឌ្ឍន៍ប្រកបដោយចីរភាព ផ្តល់ភាពយុត្តិធម៌សម្រាប់ទាំងអស់គ្នា ហើយបង្កើតស្ថាប័ន នានាដែលប្រសិទ្ធភាព មានការទទួលខុសត្រូវរួមគ្នា នៅគ្រប់លំដាប់ថ្នាក់។
- ដៃគូសម្រាប់ ការអភិវឌ្ឍន៍ប្រកបដោយចីរភាព ពង្រឹងមធ្យោបាយអនុវត្ត ហើយធ្វើឱ្យរស់ឡើងវិញ នូវដៃគូជាសាកលដើម្បីការអភិវឌ្ឍន៍ប្រកបដោយចីរភាព។

## ២.៤. សាវតារ នៃការអភិវឌ្ឍប្រកបដោយនិរន្តរភាព

- ១៩៦៨ ៖ សន្និសីទអន្តររដ្ឋាភិបាលរៀបចំដោយអង្គការ UNESCO ស្តីអំពីបរិស្ថាននិងការអភិវឌ្ឍដែលបច្ចុប្បន្នយើងហៅថាការអភិវឌ្ឍប្រកបដោយនិរន្តរភាព ។
- ១៩៧២ ៖ សន្និសីទលើកដំបូងនៃអង្គការសហប្រជាជាតិអំពីបរិស្ថានមនុស្សត្រូវបានធ្វើឡើងនៅទីក្រុងស្តុកហូម( Stockholm) ប្រទេសស៊ុយអែត ។
- ១៨៨៧ ៖ គណៈកម្មការពិភពលោកលើបរិស្ថាននិងការអភិវឌ្ឍបានប្រើប្រាស់ការអភិវឌ្ឍប្រកបដោយនិរន្តរភាពជាលើកដំបូងក្នុងរបាយការណ៍របស់ខ្លួនដែលមានចំណងជើងថា «Our Common Future »
- ១៩៩២ ៖ សន្និសិទអង្គការសហប្រជាជាតិស្តីពីបរិស្ថាននិងការអភិវឌ្ឍ(ប្រេស៊ីល)
- ២០០២៖ សន្និសិទអង្គការសហប្រជាជាតិស្តីពីអភិវឌ្ឍប្រកបដោយនិរន្តរភាព
- ២០០៥៖ ទសវត្សរ៍ អង្គការ សហប្រជាជាតិសម្រាប់សម្រាប់ការអប់រំសម្រាប់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព
- គោលដៅចុងក្រោយនៃUN-ESD គឺជាការលើកកម្ពស់និងធ្វើឱ្យប្រសើរឡើងនៃការបញ្ជ្រាប ការអប់រំដើម្បីការអភិវឌ្ឍប្រកបដោយនិរន្តរភាពក្នុងយុទ្ធសាស្ត្រអប់រំនិងផែនការសកម្មភាពនៅគ្រប់កម្រិតនិងវិស័យអប់រំនៅគ្រប់ប្រទេសទាំងអស់ ។
- ២០១២៖សន្និសិទអង្គការសហប្រជាជាតិស្តីពីការអភិវឌ្ឍប្រកបដោយនិរន្តរភាព(អនាគតដែលយើងចង់បាន)

ការអភិវឌ្ឍប្រកបដោយនិរន្តរភាព

- ដំណាក់កាលដំបូងគ្រាន់តែបញ្ចូលផ្នែកបរិស្ថានទៅក្នុងការអភិវឌ្ឍគោលនយោបាយ
- ចាប់តាំងពីកិច្ចប្រជុំកំពូលJohannesburg( អាហ្វ្រិក ខាងត្បូង ) ក្នុងឆ្នាំ ២០០២បានដាក់បញ្ចូលបន្ថែមនូវផ្នែកសង្គម ផ្នែកសេដ្ឋកិច្ច

- រហូតមកដល់បច្ចុប្បន្នបានដាក់បញ្ចូលផ្នែកផ្សេងៗទៀតដូចជាអប់រំនិងវប្បធម៌៖ បច្ចុប្បន្នត្រូវបានគេទទួលស្គាល់ថាជាប្រភពពេញលេញនៃការអភិវឌ្ឍដោយសេចក្តីប្រកាសជា សកលនៃវប្បធម៌សម្បូរបែប ( The Universal Declaration of Culture Diversity )។

ការអប់រំសម្រាប់ការអភិវឌ្ឍប្រកបដោយនិរន្តភាពគឺ៖

- ការអប់រំដែលធ្វើឱ្យអ្នកសិក្សាទទួលបាន បំណិន សមត្ថភាប តម្លៃ និងចំណេះដឹងដែលត្រូវការចាំបាច់ដើម្បីធានាបាននៅការអភិវឌ្ឍប្រកបដោយនិរន្តភាព
- ការអប់រំដែលផ្តល់ជូនដល់គ្រប់កម្រិតនិងបរិបទសង្គម (គ្រួសារ សាលារៀន កន្លែង ធ្វើការ សហគមន៍)
- ការអប់រំដែលជំរុញឱ្យប្រជាជនមានទំនួលខុសត្រូវនិងលើកកម្ពស់ប្រជាធិបតេយ្យដោយអនុញ្ញាតឱ្យប្រជាជនម្នាក់ៗនិងសហគមន៍រីករាយនិងសិទ្ធិនិងទទួលខុសត្រូវពេញលេញ
- ការអប់រំដែលឈរលើគោលការណ៍រៀនពេញមួយជីវិត
- ការអប់រំដែលជំរុញអភិវឌ្ឍន៍ដល់ប្រជាពលរដ្ឋម្នាក់ៗ

## ២.៥. ការអប់រំដើម្បីអភិវឌ្ឍប្រកបដោយនិរន្តរភាព

ការអប់រំដើម្បីអភិវឌ្ឍប្រកបដោយនិរន្តរភាពគឺជាទស្សនៈវិស័យមួយនៃការអប់រំដែលរិះរកតុល្យភាពមនុស្សនិងភាពរីកចម្រើនផ្នែកសេដ្ឋកិច្ចជាមួយនិងប្រពៃណី វប្បធម៌ជាតិ និងការថែរក្សាធនធាន ធម្មជាតិដែលមាននៅលើផែនដី ។ វាអាចអនុវត្ត បានតាមរយៈការរួមបញ្ចូលគ្នានៃមុខវិជ្ជាផ្សេងៗ ដើម្បី បង្កើតបាននូវចរិយាមាយាទមួយសម្រាប់ដំណើរ ការរៀនសូត្ររយៈពេលវែង លើកតម្កើងការគោរពគ្នា ចំពោះតម្រូវការមនុស្សដែលយកចិត្តទុកដាក់ចំពោះការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយ និរន្តភាពសេចក្តីត្រូវការផែនដី និងគំនិតអប់រំអំពីសាមគ្គីភាពជាសកល ។

គោលបំណងនៃការអប់រំដើម្បីការអភិវឌ្ឍប្រកបដោយនិរន្តរភាព

- ជួយមនុស្សអភិវឌ្ឍ(ឥរិយាបថ ជំនាញ ទស្សនៈនិងចំណេះដឹង) ដើម្បីធ្វើការសម្រេចចិត្ត និងធ្វើសកម្មភាពជាប្រយោជន៍ដល់ខ្លួនឯង និងអ្នកដទៃនាពេលបច្ចុប្បន្ន និងពេលអនាគត
- ជួយពលរដ្ឋលើពិភពលោកឱ្យរៀនសូត្រឆ្ពោះទៅរកអនាគតប្រកបដោយចីរភាព
- លើកទឹកចិត្តឱ្យមានការផ្លាស់ប្តូរចំណេះដឹង ជំនាញ គុណតម្លៃ និងឥរិយាបថ ដើម្បីធ្វើឱ្យសង្គមមាននិរន្តភាពនិងយុត្តិធម៌សម្រាប់មនុស្សទាំងអស់(Wikipedia)
- ដើម្បីសម្រេចបានការអប់រំសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព យើងត្រូវមានវិធីសាស្ត្រគរុកោសល្យសម្រាប់ការអប់រំប្រកបដោយចីរភាពដូចជា ការគិតពីអនាគតកាលរៀនផ្លាស់ប្តូរ មានការគិតជាប្រព័ន្ធ មានការចូលរួមពីអ្នកពាក់ព័ន្ធ មានការគិតត្រិះរិះពិចារណាស៊ីជម្រៅ និងមានការចូលរួមក្នុងសកម្មភាពរៀនសូត្រ។

## សន្និដ្ឋាន

គោលបំណងនៃការអប់រំដើម្បីការអភិវឌ្ឍប្រកបដោយនិរន្តរភាពជួយមនុស្សអភិវឌ្ឍ( ឥរិយាបថ ជំនាញ ទស្សនៈ និង ចំណេះដឹង ) ដើម្បីធ្វើការសម្រេចចិត្ត និង ធ្វើសកម្មភាពជាប្រយោជន៍ដល់ខ្លួនឯង និងអ្នកដទៃនាពេលបច្ចុប្បន្ន និងពេលអនាគត ជួយពលរដ្ឋលើពិភពលោកឱ្យរៀនសូត្រឆ្ពោះទៅរកអនាគតប្រកបដោយចីរភាពលើកទឹកចិត្តឱ្យមានការផ្លាស់ប្តូរចំណេះដឹង ជំនាញ គុណតម្លៃ និង ឥរិយាបថដើម្បីធ្វើឱ្យសង្គម មាននិរន្តភាពនិងយុត្តិធម៌សម្រាប់មនុស្សទាំងអស់ដើម្បីសម្រេចបានការអប់រំសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព យើងត្រូវមានវិធីសាស្រ្ត គរុកោសល្យសម្រាប់ការអប់រំប្រកបដោយចីរភាពដូចជា ការគិតពីអនាគតកាល រៀន ផ្លាស់ប្តូរមានការគិតតាមប្រព័ន្ធ មានការគិតត្រិះរិះពិចារណាស៊ីជម្រៅ និងការចូលរួមក្នុងសកម្មភាពរៀនសូត្រ ។

## សំណួរ

១.តើបរិស្ថានជាអ្វី? តើបរិស្ថានមានប៉ុន្មានប្រភេទ? តើប្រទេសកម្ពុជាមានបញ្ហាបរិស្ថានអ្វីខ្លះ?
២.តើការអភិវឌ្ឍប្រកបដោយចីរភាពជា( និរន្តរភាព )អ្វី? ហើយមានគោលបំណងដូចម្តេច?
៣.ចូររៀបរាប់ពីសារតានៃការអភិវឌ្ឍប្រកបដោយចីរភាព?
៤.តើការអប់រំសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពជាអ្វី? ហើយមានគោលបំណងដូចម្តេច?

# មេរៀនទី៣ បញ្ញាត្តិនៃការអប់រំសម្រាប់ការអភិវឌ្ឍ ប្រកបដោយចីរភាព

## វត្ថុបំណង

បន្ទាប់ពីរៀនមេរៀននេះចប់គរុនិស្សិតនឹង៖

-រៀបរាប់បានពីនិយមន័យ គោលបំណង និងវិធីសាស្រ្តគរុកោសល្យសម្រាប់ការអប់រំប្រកបដោយចីរភាព

-ពន្យល់បានពីទំនាក់ទំនងរវាងធាតុសំខាន់ៗនៃការអប់រំដើម្បីសម្រេចគោលដៅអប់រំឆ្នាំ២០៣០

-យកចិត្តទុកដាក់លើការបង្រៀននិងរៀនដើម្បីធានាបាននូវការអប់រំដែលមានគុណភាព។

## ៣.១. ការអប់រំសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព

ការអប់រំសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព ESD = Education for Sustainable Development.Education for sustainable development ( ESD ) is the use of education as a tool to achieve sustainability: Giving people knowledge and skills for lifelong learning to help them find new solutions to their environmental, economic and social issues.

For example, Driver Education seeks to make roads safer for travelers; Fire Safety Education seeks to prevent fires and loss of lives and property.

Similarly, ESD promises to make the world more livable for this and future generations. ការអប់រំដែលលើកទឹកចិត្តឱ្យមានការផ្លាស់ប្តូរចំណេះដឹង ជំនាញគុណតម្លៃ និងឥរិយាបថ ដើម្បីធ្វើឱ្យសង្គមមាននិរន្តភាព និងយុត្តិធម៌សម្រាប់មនុស្សទាំងអស់ ( Wikipedia ).






*រូបភាព 18 ៖ ការអប់រំសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព*

ការអប់រំដែលលើកទឹកចិត្តឱ្យមានការផ្លាស់ប្តូរចំណេះដឹង ជំនាញ គុណតម្លៃ និងឥរិយាបថ ដើម្បីធ្វើឱ្យសង្គមមាននិរន្តភាព និងយុត្តិធម៌ សម្រាប់មនុស្សទាំងអស់។

**៣.១.១.គោលចំណងខ** ESD (Global concept)

- ជួយមនុស្សអភិវឌ្ឍ (ឥរិយាបថ ជំនាញ ទស្សនៈ និងចំណេះដឹង) ដើម្បីធ្វើការសម្រេចចិត្ត និងធ្វើសកម្មភាពជាប្រយោជន៍ដល់ខ្លួនឯង និងអ្នកដទៃនាពេលបច្ចុប្បន្ន និងពេលអនាគត។
- ជួយពលរដ្ឋលើពិភពលោកឱ្យរៀនសូត្រឆ្ពោះទៅរកអនាគតប្រកបដោយចីរភាព។
- **តម្រូវការរបស់មនុស្ស**




*រូបភាព 19 ៖ តម្រូវការមនុស្ស*

**៣.១.២.វិធីសាស្ត្រគរុកោសល្យសម្រាប់ការអប់រំប្រកបដោយចីរភាព ៖**

- ការគិតពីអនាគតកាល
- រៀនផ្លាស់ប្តូរ នូវអ្វីដែលទម្លាប់
- មិនល្អឱ្យទៅជាទម្លាប់ល្អ
- ការគិតជាប្រព័ន្ធ
- ការចូលរួមពីអ្នកពាក់ព័ន្ធ
- ការគិតត្រិះរិះពិចារណា
- ចូលរួមក្នុងសកម្មភាពរៀនសូត្រ




*រូបភាព 20 ៖ ការចូលរួមពីអ្នកពាក់ព័ន្ធ*

**២.២. តើចក្ខុវិស័យថ្មីសម្រាប់វិស័យអប់រំឆ្ពោះទៅរកឆ្នាំ២០៣០ផ្តោតលើចំណុចអ្វីខ្លះ?**



*រូបភាព 21 ៖ ការអប់រំបរិយាបន្ន*

ចក្ខុវិស័យថ្មីសម្រាប់ការអប់រំឆ្ពោះទៅរកឆ្នាំ២០៣០គឺ ៖

- ធានាបាននូវការអប់រំមានគុណភាព
- បរិយាបន្ន
- សមធម៌
- លើកកម្ពស់ឱកាសសិក្សាមួយពេញមួយជីវិត
- សម្រាប់ទាំងអស់គ្នា។

## ២.៣. ធាតុសំខាន់ៗនៃការអប់រំសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព

ការអភិវឌ្ឍប្រកបដោយចីរភាពជាទូទៅត្រូវមានសមាសធាតុចូលរួម៣យ៉ាងគឺ

- សង្គម
- បរិស្ថាន
- សេដ្ឋកិច្ច

### ២.៣.១.សង្គម ( Society )

- សិទ្ធមនុស្ស
- សន្តិភាព និងសន្តិសុខ
- សមភាពយេនឌ័រ
- សុខភាព និងសុខមាលភាព
- អភិបាលកិច្ចល្អ

### ២.៣.២.សិទ្ធិមនុស្ស

- ការអប់រំ
- ការជួបជុំ
- មានជំនឿដោយសេរី
- សុំឱ្យច្បាប់ការពារខ្លួន
- មានសេរីភាព
- សម្បត្តិកម្មសិទ្ធិ
- មានការងារធ្វើ
- កាតព្វកិច្ចចំពោះសហគមន៍
- ជីវភាពសមរម្យ




*រូបភាព 22 ៖ សិទ្ធិមនុស្ស*

### ២.៣.៣.សន្តិភាព និងសន្តិសុខ

សន្តិភាពគឺជាកត្តាកំណត់លើការអភិវឌ្ឍ ការរីកចម្រើន និងការរស់នៅប្រកបដោយសេចក្តីសុខរបស់ប្រជាជនខ្មែរ។

សន្តិសុខ មានន័យថាភាពផុតពីគ្រោះថ្នាក់ (literary) និរភ័យ financial ភាពមិនខ្វះខាត measures សន្តិសុខ ។




*រូបភាព 23៖ សន្តិសុខ និងសន្តិភាព*

### ២.៣.៤.សមភាពយេនឌ័រ

សមភាពយេនឌ័រ គឺមកពីពាក្យ " សមភាព+យេនឌ័រ" សមភាពមានន័យថាភាពស្មើគ្នាចំណែកឯពាក្យយេនឌ័រ មានន័យថា លក្ខណៈនៃភាពជាស្ត្រី និងបុរស ។ ដូចនេះ សមភាពយេនឌ័រ គឺជាភាពស្មើគ្នារវាងបុរស និងស្ត្រី ។



*រូបភាព 24៖ សមភាពយេនឌ័រ*



*រូបភាព 25៖ វិសមភាពយេនឌ័រ*

### ង.សុខភាព និងសុខមាលភាព

- សុខភាពផ្លូវចិត្ត
- សុខភាពរាងកាយ
- សុខភាពសង្គម




*រូបភាព 26៖ សុខភាពនិងសុខមាលភាព*

## ២.៣.៥.អភិបាលកិច្ចល្អ

- លំនឹង
- ការអនុវត្តតាមគោលការណ៍
- តម្លាភាព
- សមធម៌និងរួមបញ្ចូល
- ប្រសិទ្ធភាព
- ការយល់ព្រម




*រូបភាព 27៖ អភិបាលកិច្ចល្អ*

## ២.៣.៦.សេដ្ឋកិច្ច( Economy )

- ទំនួលខុសត្រូវ និងគណនីយភាពសាជីវកម្ម




*រូបភាព 28៖ ទំនួលខុសត្រូវ*

- ការកាត់បន្ថយភាពក្រីក្រ




*រូបភាព 29៖ ការកាត់បន្ថយភាពក្រីក្រ*

- សេដ្ឋកិច្ចទីផ្សារ




*រូបភាព 30៖ សេដ្ឋកិច្ចទីផ្សារ*

**២.៣.៧.បរិស្ថាន** ( Environment )

- ធនធានធម្មជាតិ ( ទឹក ថាមពល កសិកម្ម ជីវសាស្ត្រចម្រុះ )
- បម្រែបម្រួលអាកាសធាតុ
- អភិវឌ្ឍជនបទ
- នគរូបនីយកម្មប្រកបដោយចីរភាព
- ការពារនិងកាត់បន្ថយគ្រោះមហន្តរាយ

"បំពេញសេចក្តីត្រូវការរបស់មនុស្សបច្ចុប្បន្នដោយមិនធ្វើឱ្យប៉ះពាល់ដល់សមត្ថភាពក្នុងការបំពេញសេចក្តីត្រូវការរបស់មនុស្សជំនាន់ក្រោយ"

ការអភិវឌ្ឍប្រកបដោយចីរភាពពាក់ព័ន្ធនឹងដំណើរការរៀនតាមរយៈការដែលយើងអាចរៀនបង្កើនសមត្ថភាពដើម្បីរស់នៅប្រកបដោយនិរន្តរភាព។

**សន្និដ្ឋាន**

ការអប់រំប្រកបដោយចីរភាព"បំពេញសេចក្តីត្រូវការរបស់មនុស្សបចុប្បន្នដោយមិនធ្វើឱ្យប៉ះពាល់ដល់

សមត្ថភាពក្នុងការបំពេញសេចក្តីត្រូវការរបស់មនុស្សជំនាន់ក្រោយ។

ការអភិវឌ្ឍប្រកបដោយចីរភាពពាក់ព័ន្ធនឹងដំណើរការរៀនតាមរយៈការដែលយើងអាចរៀនបង្កើតសមត្ថភាពដើម្បីរស់នៅប្រកបដោយនិរន្តរភាព។

**សំណួរ**

១.តើការអប់រំសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពជាអ្វី ?ហើយមានគោលបំណងដូចម្តេចខ្លះ ?

២.តើចក្ខុវិស័យថ្មីសម្រាប់វិស័យអប់រំឆ្ពោះទៅរកឆ្នាំ២០៣០ ផ្តោតលើចំណុចអ្វីខ្លះ ?

៣.តើជាតុសំខាន់ៗអ្វីខ្លះដែលធ្វើឱ្យសម្រេចចក្ខុវិស័យថ្មីឆ្ពោះទៅរកគោលដៅអប់រំឆ្នាំ២០៣០ ?

# មេរៀនទី៤ គោលការណ៍ចម្បងនៃការអប់រំសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព

## ៤.១.សេចក្តីផ្តើម

-ប្រជាពលរដ្ឋទូទាំងពិភពលោកស្មើ ៧ ពាន់លាននាក់ចំណែកធនធានធម្មជាតិមានកំណត់។

-បុគ្គលម្នាក់ៗក្នុងសង្គមត្រូវសិក្សាពីវិធីរស់នៅប្រកបដោយចីរភាព។ ទាំងអស់គ្នាត្រូវចូលរួមអនុវត្តនិងទទួលខុសត្រូវលើជីវិតរបស់ពលរដ្ឋលើពិភពលោក។

-ESD ៖ លើកកម្ពស់ប្រជាជនដើម្បីផ្លាស់ប្តូរវិធីគិតនិងអនុវត្តរបស់ប្រជាពលរដ្ឋឆ្ពោះទៅរកអនាគតប្រកបដោយនិរន្តភាព(អង្គការសហប្រជាជាតិ)។

## ៤.២.និយមន័យ

-ESD គឺជាការអប់រំផ្សារភ្ជាប់ជាមួយនឹងរបៀបវារៈនៃការផ្លាស់ប្តូរឆ្ពោះទៅរកការរស់នៅប្រកបដោយចីរភាព។

-ESD ផ្តោតទៅលើការអភិវឌ្ឍការយល់ដឹងផ្នែកបរិស្ថាននិងព័តមានស្តីអំពីវប្បធម៌ចម្រុះ។

## ៤.៣.គោលការណ៍នៃការអប់រំសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព

-ការផ្លាស់ប្តូរនិងការផ្លាស់ប្តូរ

-ការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា

-ការគិតជាប្រព័ន្ធ

-អនាគតល្អប្រសើរ

-ការត្រិះរិះពិចារណា

-ការចូលរួម

-ភាពជាដៃគូរសម្រាប់ការផ្លាស់ប្តូរ



*រូបភាព 31៖ការផ្លាស់ប្តូរ*

### ៤.៣.១. ការផ្លាស់ប្តូរនិងការផ្លាស់ប្តូរ

-មនុស្សម្នាក់ៗគួរតែត្រូវបានផ្តល់អំណាចឱ្យធ្វើការផ្លាស់ប្តូរជីវិតរបស់ខ្លួនសាលារៀននិងសហគមន៍រស់នៅ។

### ៤.៣.២. ការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា

-ការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា គឺសម្រាប់មនុស្សគ្រប់វ័យជាពិសេសយុវជន វ័យកណ្តាលនិងវ័យចំណាស់ ហើយការសិក្សាពុំមានដែនកំណត់។

### ៤.៣.៣.ការគិតជាប្រព័ន្ធ

-ជាវិធីដែលជួយឱ្យមនុស្សម្នាក់ៗមានទស្សនៈជាប្រព័ន្ធដោយផ្តើមចេញពីទស្សនៈទូលំទូលាយរួមមានរចនាសម្ព័ន្ធទូទៅ លំនាំនិងវដ្តនៃប្រព័ន្ធជាជាងការមើលឃើញតែព្រឹត្តិការណ៍ជាក់លាក់។

### ៤.៣.៤. អនាគតល្អប្រសើរ

-មនុស្សគួរតែធ្វើការឆ្ពោះទៅរកអនាគតដែលអាចរស់នៅប្រកបដោយគុណភាពនិងសុខដុមរម្យនាជាមួយបរិស្ថានរបស់ខ្លួន។

### ៤.៣.៥. ការត្រិះរិះពិចារណា

- អ្វីទាំងអស់ពុំមានគុណភាពនិងពុំទាន់មានដំណើរការល្អទេ ហើយពិភពលិកកំពុងស្ថិតនៅលើផ្លូវឆ្ពោះទៅរកមហន្តរាយអាកាសធាតុ។
- ដូច្នេះយើងចាំបាច់ត្រូវអប់រំមនុស្សឱ្យចេះគិតពិចារណាស្វែងរកវិធីនិងដំណោះស្រាយថ្មីដើម្បីឈានទៅរកសន្តិភាព។

### ៤.៣.៦. ការចូលរួម

- យើងទាំងអស់គ្នាមាននាទីចូលរួមធ្វើឱ្យពិភពលោកមាននិរន្តភាពជាងនេះ។

### ៤.៣.៧. ភាពជាដៃគូរសម្រាប់ការផ្លាស់ប្តូរ

- មនុស្សគ្រប់រូបត្រូវតែធ្វើការរួមគ្នាដើម្បីបង្កើតការផ្លាស់ប្តូរ។

## ៤.៤.វិធីបង្រៀនការអប់រំដើម្បីការអភិវឌ្ឍន៍ប្រកបដោយចីរភាព

### ៤.៤.១.ការឆ្លុះបញ្ចាំង

- ឱ្យសិស្សគិតឱ្យបានម៉ត់ចត់ដើម្បីធ្វើឱ្យពិភពលោកមានគុណភាពបរិស្ថាននិងសង្គម។

### ៤.៤.២.ការគិតជាប្រព័ន្ធ

- ប្រការគិតជាប្រព័ន្ធនៅក្នុងថ្នាក់រៀនការសិក្សាត្រូវសង្កត់ធ្ងន់លើភាពទាក់ទងគ្នានៃអ្វីៗដែលនៅជុំវិញយើង

### ៤.៤.៣. ការរៀនសូត្រដែលមានការចូលរួម

- សិស្សរៀនដោយតាមការសហការគ្នា។

### ៤.៤.៤.ការគិតប្រកបដោយច្នៃប្រឌិត

- លើកទឹកចិត្តសិស្សឱ្យគិតពីអនាគតប្រកបដោយនិរន្តភាពនិងបង្កើតយុទ្ធសាស្រ្តដើម្បីឆ្ពោះទៅរកគោលដៅ។

### ៤.៤.៥.ការសិក្សារួមគ្នា

- លើកទឹកចិត្តសិស្សឱ្យចេះធ្វើការជាក្រុម សហការគ្នាដើម្បីសម្រេចលទ្ធផលការងារដែលគ្រូដាក់ឱ្យ។

## ៤.៥.ឱកាសនិងបញ្ហាប្រឈមនៃESD

### ៤.៥.១. អត្ថប្រយោជន៍និងឱកាស

- បង្កើតការផ្លាស់ប្តូរជាប្រព័ន្ធនៅក្នុងសាលារៀន
- ជួយយុវជនអភិវឌ្ឍន៍ស្រលាញ់និងថែរក្សាបរិស្ថាន

- ផ្សារភ្ជាប់រវាងកម្មវិធីសិក្សាទៅនឹងមេរៀនគណិតវិទ្យា ប្រវិត្តសាស្ត្រនិងវិទ្យាសាស្ត្រ។
- អភិវឌ្ឍន៍បំណិនស.តទី២១
- អភិវឌ្ឍភាពជាពលរដ្ឋសកល។

### ៤.៥.២.បញ្ហាប្រឈម

- ឪពុកម្តាយឬអាណាព្យាបាលសិស្សអាចនឹងមិនយល់ស្រប
- សិស្សអាចនឹងចំណាយពេលសិក្សាច្រើនដោយកម្មវិធីសិក្សាច្រើនមុខវិជ្ជា
- ចំណាយថវិកាច្រើនតាមគំនិតផ្តួចផ្តើមថ្មី។

## ៤.៦.សាវតាបរិស្ថាន

- ក្រោយពី WWII: បដិវត្តន៍បៃតង និង បញ្ហាបរិស្ថាន
- កិច្ចព្រមព្រៀងអន្តរជាតិស្តីពី បរិស្ថាន
- ១៩៧២ ការបង្កើត កម្មវិធីបរិស្ថានសហប្រជាជាតិ( UNEP )
- ១៩៧២ សន្ធិសញ្ញា Stockholm ស្តីពី មនុស្ស និង ការអភិវឌ្ឍ
- ១៩៧៧ សន្ធិសញ្ញា Tbilisi ស្តីពី ការអប់រំបរិស្ថាន ដោយផ្តោតលើៈ
- ការយល់ដឹង ( Awareness )
- ចំណេះសម្បទា/ចំណេះដឹង ( Knowledge )
- បំណិនសម្បទា/បំណិន/ជំនាញ ( Skills )
- ចរិយាសម្បទា/ឥរិយាបថ ( Attitude )
- ការចូលរួម ( Participation )។
- ១៩៩២ សន្និសីទសហប្រជាជាតិ ស្តីពី បរិស្ថាន និង ការអភិវឌ្ឍ ( UNCED/The របៀបវារៈ ២១ )
- ២០០២ សន្និសីទសហប្រជាជាតិ ស្តីពី ការអភិវឌ្ឍប្រកបដោយចីរភាព (ឬសន្និសីទកំពូលពិភពលោកសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព -WSSD ) ឬRio+10
- ២០០៥ ទសវត្សរ៍សហប្រជាជាតិ ស្តីពី ការអប់រំសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពគោលបំណងចុងក្រោយរបស់ UN-ESD គឺដើម្បីលើកកម្ពស់នឹងកែលំអការបញ្ជ្រាប ESD ទៅក្នុងយុទ្ធសាស្ត្រអប់រំនិងផែនការសកម្មភាពនៅគ្រប់កម្រិតនិងវិស័យអប់រំនៅក្នុងប្រទេសទាំងអស់
- ២០១២ សន្និសីទសហប្រជាជាតិ ស្តីពី ការអភិវឌ្ឍប្រកបដោយចីរភាព( ប្រធានបទៈអនាគតដែលយើងចង់បាន( future we want )/ការរីកចំរើនបៃតង( Green Growth )ឬRio+20

## ៤.៧.ការបញ្ជ្រាប ESD នៅក្នុងកម្មវិធីសិក្សាអប់រំគ្រូបង្រៀន

ការបញ្ជ្រាបតាមរយៈវត្ថុបំណងអប់រំ

**ចរិយាសម្បទា និង តម្លៃៈ**

- ថែរក្សាសហគមន៍ ( Care for the community )

- គោរពជំនឿនិងយោបល់របស់អ្នកដទៃ (Respect for the beliefs and opinions of others)
- គោរពភស្តុតាងនិងអំណះអំណាងដែលសមហេតុផល (Respect for evidence and rational argument)
- ភាពអត់ធ្មត់និងការបើកចំហចិត្ត (Tolerance and open-mindedness)

**បំណិនសម្បទា៖**

- ជំនាញទំនាក់ទំនង (Communication skills)
- ជំនាញខាងលេខនពន្ធ (Numeracy skills)
- ជំនាញក្នុងការសិក្សា (Study skills)
- ជំនាញដោះស្រាយបញ្ហា (Problem solving skills)
- ជំនាញផ្ទាល់ខ្លួននិងសង្គម (Personal and social skills)
- ជំនាញបច្ចេកវិទ្យាព័ត៌មាន (Information technology skills)

**ការលាយចូលតាមរយៈបទពិសោធន៍នៃការរៀនទៅក្នុងមុខវិជ្ជាទាំងអស់៖**

- សិក្សាកសិកម្ម (Agricultural Studies)
- គេហ-សេដ្ឋកិច្ច (Home Economics)
- សិល្បៈ (The Arts)
- គណិតវិទ្យា (Mathematics)
- ពាណិជ្ជសាស្ត្រនិងសិក្សាពាណិជ្ជកម្ម (Commerce and Business Studies)
- សិល្បៈហត្ថកម្ម និងបច្ចេកវិទ្យា (Manual Arts and Technology)
- ការសិក្សាភាសាទី១ (First Language Studies)
- ការអប់រំអំពីសាសនា (Religious Education)
- ការសិក្សាភាសាទី២ (Second Language Studies)
- វិទ្យាសាស្ត្រ (Science)
- ការអប់រំសុខភាពនិងរាងកាយ (Health and physical Education)
- សិក្សាសង្គម (Social Studies)
- ការបង្រៀនអំពីធម្មនុញ្ញផែនដី៖ ធម្មនុញ្ញផែនដីគឺជាការប្រកាសអំពីភាពអាស្រ័យគ្នារវាងភាវៈរស់និងឥតជីវិតទាំងអស់នៅលើផែនដី។
- វាក៏ជាសេចក្តីថ្លែងការណ៍អំពីគោលការណ៍និងគុណតម្លៃដែលត្រូវការដើម្បី

**កសាងភាពជាដៃគូសកលសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព៖**

សិល្បៈ (The Arts) សិក្សាភាសា ( Language Studies) គណិតវិទ្យា (Mathematics)វិទ្យាសាស្ត្រ (Science) បច្ចេកវិទ្យា ( Technology)។

**ការប្រារព្ធពិធីនៅក្នុងប្រតិទិនសាលារៀន៖ ព្រឹត្តិការណ៍អន្តរជាតិ**

- ២ កុម្ភៈ ទិវាសើមពិភពលោក
- ២៣ មីនា ទិវាឧតុនិយមពិភពលោក
- ៧ មេសា ទិវាសុខភាពពិភពលោក
- ១ ឧសភា ទិវាកម្មករ
- ១៥ ឧសភា ទិវាគ្រួសារអន្តរជាតិ
- ១៨ ឧសភា ទិវាសារមន្ទីរអន្តរជាតិ
- ៥ មិថុនា ទិវាបរិស្ថានពិភពលោក
- ១៧ មិថុនា ទិវាពិភពលោកប្រយុទ្ធប្រឆាំងនឹងវាលខ្សាច់
- ១១ កក្កដា ទិវាប្រជាជាតិពិភពលោក
- ៩ សីហា ទិវាអន្តរជាតិនៃជនជាតិដើមនៅលើពិភពលោក
- ៨ កញ្ញា ទិវាអក្ខរកម្មអន្តរជាតិ
- ១៦ កញ្ញា ទិវាអន្តរជាតិសម្រាប់ការអភិរក្សស្រទាប់អូហ្សូន
- ១៧-១៩ កញ្ញា ទិវាសម្អាតពិភពលោក
- ២១ កញ្ញា ទិវាសន្តិភាពអន្តរជាតិ
- ៥ តុលា ទិវារបស់គ្រូបង្រៀនពិភពលោក
- ១៦ តុលា ទិវាម្ហូបអាហារពិភពលោក
- ២៤-៣០ តុលា សប្តាហ៍សម្រាប់ការរំសាយអាវុធនិងការអភិវឌ្ឍន៍
- ២០ វិច្ឆិកា ទិវារបស់កុមារសាកល
- ១០ ធ្នូ ទិវាសិទ្ធិមនុស្ស

**ការឆ្លុះបញ្ចាំង**

ការបញ្ច្រាបការអប់រំតម្រូវឱ្យមានគោលការណ៍សាលាទូលំទូលាយនិងមានកិច្ចសហការពីសំណាក់គ្រូបង្រៀនទាំងអស់នៅក្នុងសាលារៀនក៏ដូចជាសិស្ស ឪពុកម្តាយ និងសហគមន៍ទូទៅផងដែរ។ជំហានចំនួន ៦ អាចត្រូវបានអនុវត្តតាមដំណើរការអភិវឌ្ឍគោលនយោបាយ៖

- តែងតាំងអ្នកសម្របសម្រួល ( Appoint a coordinator )
- ផ្សព្វផ្សាយសេចក្តីព្រាងគោលនយោបាយ ( Publish draft policy )
- សម្របសម្រួលគណៈកម្មាធិការគោលនយោបាយ ( convene a policy committee )
- អនុវត្តផែនការសកម្មភាព ( Implement action plans )
- អនុវត្តដំណើរការសវនកម្មសាលារៀន ( Undertake a school audit process )
- វាយតម្លៃនិងពិនិត្យឡើងវិញ ( Evaluate and review )

ឧទាហរណ៍ : នៃការរៀនសូត្រសម្រាប់អនាគតប្រកបដោយចីរភាពនៅក្នុងមុខវិជ្ជាដែលមានស្រាប់

**៤.៧.១.សិក្សាកសិកម្ម** ( Agricultural Studies )

ការអប់កសិកម្មផ្តល់នូវឱកាសដ៏ល្អដើម្បីបង្រៀនអំពីបញ្ហានិងចីរភាពធ្ងន់ធ្ងរមួយចំនួន រួមមានៈ

- សុវត្ថិភាពចំណីអាហារ
- អហាររូបត្ថម្ភនិងសុខភាព
- ការចម្លងរោគទឹកក្រោមដីពីសារជាតុគីមីកសិកម្ម
- ការន្លឿនការសឹករិចរិលដី
- ការគំរាមកំហែងនិងការជិតផុតពូជនៃរុក្ខជាតិនិងសត្វព្រៃ
- ការការពារដីនិងទឹក។

ឱកាសជាច្រើនអាចរកបានសម្រាប់និស្សិតមានបទពិសោធផ្ទាល់ក្នុងការដោះស្រាយបញ្ហាទាំងនេះ។

**សិល្បៈ** ( The Arts )

- សិល្បៈសម្តែងនិងមើលឃើញ អាចអភិវឌ្ឍការយល់ដឹងនិងសោភ័ណភាពទាំងបែបធម្មជាតិនិងបរិស្ថានដែលមានស្រាប់
- កម្មវិធីសិល្បៈគួរតែបញ្ចូលជាតុផ្សំនៃបរិស្ថានដែលមានស្រាប់និងធម្មជាតិដែលបង្កើតឡើងទៅក្នុងបទពិសោធន៍រៀនសូត្រដែលផ្តល់ជូនដល់និស្សិត។
- តួនាទីនៃសិល្បៈជាមធ្យោបាយនៃការប្រាស្រ័យទាក់ទងសារអំពីអនាគតប្រកបដោយចីរភាពដល់អ្នកដទៃគួរតែត្រូវបានរាប់បញ្ចូលផងដែរ។
- សិល្បៈគឺជាឧទាបករណ៍ផ្ទុកដ៏មានអានុភាពតាមរយៈការបង្ហាញគំនិតនិងអារម្មណ៍អំពីចីរភាពហើយអាចជាឧបករណ៍ផ្ទុកតាមរយៈការពង្រឹងចំណងរវាងមនុស្សនិងផែនដី។សិក្សាពាណិជ្ជកម្មនិងអាជីវកម្ម

- ពាណិជ្ជកម្មផ្តល់នូវឱកាសសម្រាប់ការស៊ើបអង្កេតទំនាក់ទំនងរវាងអាជីវកម្ម ឧស្សាហកម្ម និងចីរភាព។
- ពាណិជ្ជកម្មក៏អាចជួយសិស្សឱ្យរៀនពីៈ
  -របៀបគ្រប់គ្រងធនធានដោយប្រុងប្រយ័ត្ន
  -របៀបរៀបចំផែនការសម្រាប់ពេលអនាគត និងរបៀបអនុវត្តលក្ខណៈវិនិច្ឆ័យប្រកបដោយសីលធម៌ក្នុងការសម្រេចចិត្តផ្នែកហិរញ្ញវត្ថុ។

**សិក្សាភាសាទី១** ( First Language Studies )

- គ្រប់ផ្នែកសិល្បៈភាសាមានតួនាទីសំខាន់ក្នុងការអប់រំដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព
- ជាតុជាច្រើននៃអនាគតប្រកបដោយចីរភាពអាចដើរតួជាប្រធានបទដ៏ប្រសើរសម្រាប់ការសរសេរដោយច្នៃប្រឌិត។

- មានអក្សរសិល្ប៍ជាតិជាច្រើនផងដែរដូចជា កំណាព្យ ការបកស្រាយរឿងល្ខោន និងរឿងរ៉ាវផ្សេងៗទៀត ដែលទាក់ទងនឹងទំនាក់ទំនងរបស់មនុស្សជាមួយវប្បធម៌ដទៃទៀតនិងជាមួយភពផែនដីតាមរបៀប ផ្សេងៗគ្នាដែលគួរឱ្យចាប់អារម្មណ៍រស៊ើប និងគិត។

**សិក្សាភាសាទី២** (Second Language Studies)

- កម្មវិធីក្នុងការរៀនសូត្រភាសាទី២ ផ្តល់នូវឱកាសដ៏ល្អដើម្បីអភិវឌ្ឍការតម្រង់ទិសជាសកលដើម្បីសិក្សាពីចីរភាព។
- នេះជាការពិតជាពិសេសនៅកម្រិតថ្នាក់ខ្ពស់នៅពេលដែលការបោះពុម្ពផ្សាយជាភាសាទី២អាចត្រូវបានប្រើជាសម្ភារៈប្រភព។

**ការអប់រំសុខភាពនិងរាងកាយ** (Health and physical Education)

- ការអប់រំសុខភាពគឺជាផ្នែកមួយនៃមុខវិជ្ជាសំខាន់បំផុតដែលត្រូវដោះស្រាយជាមួយផ្នែកផ្សេងៗនៃចីរភាព។
- ទាំងសុខភាពផ្លូវកាយនិងផ្លូវចិត្តគឺពឹងផ្អែកទៅបរិស្ថាននិងធម្មជាតិដែលមានគុណភាពខ្ពស់។
- ប្រធានបទដូចជាសារធាតុគីមីដែលមានគ្រោះថ្នាក់នៅក្នុងផ្ទះនិងនៅកន្លែងធ្វើការ ការបំពុលខ្យល់និងទឹក តម្រូវការសម្រាប់សកម្មភាពកម្សាន្តដែលមានសុខភាពល្អទាំងក្នុងនិងក្រៅផ្ទះ និងទំនាក់ទំនងរវាងសំឡេងរំខាននិងសុខភាពគឺចាំបាច់ត្រូវពិចារណានៅពេលគ្រោងកម្មវិធីសិក្សាអប់រំសុខភាព។
- ការអភិវឌ្ឍជំនាញកំសាន្តបានក្លាយជាផ្នែកសំខាន់មួយនៃកម្មវិធីសិក្សាអប់រំកាយក្នុងប៉ុន្មានឆ្នាំថ្មីៗនេះរួមមាន ការប្រណាំងទូក ការស្ពាយការបូបដើរ ការបោះជំរុំការនេសាទ និងសកម្មភាពក្រៅផ្សេងទៀត។
- កម្មវិធីអប់រំកាយបានក្លាយជាមធ្យោបាយដោះស្រាយជាមួយប្រធានបទដូចជាក្រមសីលធម៌ខាងក្រៅផ្ទះ គុណសម្បត្តិនិងគុណវិបត្តិនៃការបរបាញ់ សកម្មភាពក្រៅផ្ទះដែលស៊ីចង្វាក់គ្នានឹងមិនស៊ីចង្វាក់គ្នានិងទំនាក់ទំនងបរិស្ថានប្រកបដោយគុណភាពដល់សុខភាពរាងកាយនិងផ្លូវចិត្ត។
- គេហ-សេដ្ឋកិច្ច (Home Economics)
- គេហ-សេដ្ឋកិច្ចផ្តល់នូវឱកាសដើម្បីពិនិត្យមើលបញ្ហាដូចជា៖
  - ការប្រើប្រាស់និងការអភិរក្សថាមពល
  - ការវេចខ្ចប់លើសនិងការចោលកាកសំណល់រឹងលើស
  - ការកែច្នៃឡើងវិញ
  - ការបន្ថែមសារធាតុគីមីទៅក្នុងចំណីអាហារ

- សារធាតុគីមីដែលមានគ្រោះថ្នាក់នៅក្នុងផ្ទះ
- ប្រធានបទទាក់ទងនឹងរបៀបរស់នៅផ្សេងទៀត។

**គណិតវិទ្យា** (Mathematics)

- ដំណោះស្រាយបញ្ហាចីរភាពជារឿយៗពឹងផ្អែកលើការប្រមូលនិងវិភាគទិន្នន័យនិងការទំនាក់ទំនង លទ្ធផល។
- គណិតវិទ្យាគឺជាឧបករណ៍សំខាន់មួយសម្រាប់បញ្ហានេះ។
- គំនិតគណិតវិទ្យាជាច្រើនអាចត្រូវបានបង្ហាញដោយបទពិសោធន៍និងឧទាហរណ៍ពីបរិស្ថានធម្មជាតិ បរិយាកាសសង្គម បរិយាកាស សេដ្ឋកិច្ច និងបរិយាកាសនយោបាយ។

**សិល្បៈហត្ថកម្ម និងបច្ចេកវិទ្យា** (Manual Arts and Technology)

- ការអប់រំសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពមានការព្រួយបារម្ភជាមួយនឹងការរុករកផលវិបាកនៃអន្តរកម្មរវាងបច្ចេកវិទ្យានិងធនធាន។
- វាក៏ពាក់ព័ន្ធនឹងការរុកបញ្ហាជុំវិញការប្រើប្រាស់បច្ចេកវិទ្យាថ្មីផងដែរ។

**ការអប់រំអំពីសាសនា** (Religious Education)

- ការអប់រំសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពផ្តល់នូវឱកាសសម្រាប់ស្វែងយល់ទំនាក់ទំនងខាងវិញ្ញាណរវាងមនុស្សនិងមនុស្ស រវាងមនុស្សនិងធម្មជាតិ និងរវាងធម្មជាតិនិងធម្មជាតិ។
- វាក៏ពាក់ព័ន្ធជាមួយនឹងសាសនា សីលធម៌ និងក្រមសីលធម៌នៃការសម្រេចចិត្តដែលប៉ះពាល់ដល់ចីរភាពផងដែរ។

**វិទ្យាសាស្ត្រ** (Science)

- ការសិក្សាវិទ្យាសាស្ត្របង្ហាញពីឱកាសជាច្រើនដើម្បីដោះស្រាយជាមួយប្រធានបទប្រកបដោយចីរភាព។
- ផ្នែកសំខាន់មួយនៃខ្លឹមសារនៃការអប់រំដើម្បីការអភិវឌ្ឍប្រកបដោយចីរភាពពាក់ព័ន្ធនឹងវិទ្យាសាស្ត្រ។

ឧទាហរណ៍៖ ការសង្កត់ធ្ងន់លើការអភិវឌ្ឍជំនាញដោះស្រាយបញ្ហានិងការ សិក្សាទំនាក់ទំនងរវាងវិទ្យាសាស្ត្របច្ចេកវិទ្យា និងសង្គមមានសារៈសំខាន់ណាស់។ទោះយ៉ាងណា ការអប់រំសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពនិងវិទ្យាសាស្ត្រអាចមិនស្មើគ្នា នៅពេលដែលមនុស្ស វិទ្យាសាស្ត្រសង្គម សិល្បៈនិងគ្រប់ទិដ្ឋភាពផ្សេងទៀតនៃកម្មវិធីសិក្សាក៏មានតួនាទីសំខាន់ផងដែរ។

**សិក្សាសង្គម** (Social Studies)

ចាប់តាំងពីការសម្រេចចិត្តគោលនយោបាយនៅថ្នាក់មូលដ្ឋាន ថ្នាក់រដ្ឋ ថ្នាក់ជាតិ និងថ្នាក់សកលត្រូវបានបង្កើតឡើងនៅក្នុងបរិបទនៃស្ថាប័នសង្គមនិងតម្លៃមនុស្ស ការសិក្សាសង្គមឬវិទ្យាសាស្ត្រសង្គមផ្សេងៗគ្នា(ដូចជាភូមិវិទ្យា ប្រវត្តិវិទ្យា វិទ្យាសាស្ត្រនយោបាយ នរវិទ្យា សង្គមវិទ្យា ចិត្តវិទ្យា ជាដើម)

អាចចូលរួមចំណែកយ៉ាងច្រើនដល់ការសិក្សាអំពីវិធីដែលផែនការនិងសកម្មភាពជំនាសបាន អាចជះឥទ្ធិពលដល់អនាគតប្រកបដោយចីរភាព។

- គំរូនៃបទពិសោធន៍រៀនសូត្រ

**សិក្សាកសិកម្ម** (Agricultural Studies)

- ជួយកសិករដាំដើមឈើដើម្បីការពារការហូរច្រោះដី
- ចូលរួមនិងឬបង្កើតក្រុមថែរក្សាដី
- បង្កើតនិងថែរក្សាកសិដ្ឋានសាលារៀន ជ្រើសរើសប្រភេទសត្វសមស្របនឹងលក្ខខណ្ឌក្នុងតំបន់
- ស្រាវជ្រាវបញ្ហាដែលបាក់ព័ន្ធនឹងការធ្វើកសិកម្មសត្វដើម
- ពិនិត្យមើលភាពពាក់ព័ន្ធនៃច្រករបៀបសត្វព្រៃដើម្បីការគ្រប់គ្រងកសិកម្មប្រកបដោយចីរភាព
- ពិភាក្សាអំពីទំនាក់ទំនងរវាងអតិថិជននិងអ្នកផលិតបឋម។

**សិល្បៈ** (The Arts)

- ការគូរូបនិងការផាត់ព័ណ៌គំនូរដើម្បីធ្វើឱ្យសិស្សចាប់អារម្មណ៍នឹងវប្បធម៌នៃគ្រួសារចំណាកស្រុក
- ដោះស្រាយទំនាស់តាមរយៈសិល្បៈសម្តែងនិងសិល្បៈមើលឃើញ។
- កសាងការគោរពខ្លួនឯង ភាពជឿជាក់ និងការច្នៃប្រឌិត ជាមធ្យោបាយនៃការផ្តល់សិទ្ធិអំណាចដល់និស្សិតឱ្យតម្លៃការចូលរួមរបស់ពួកគេចំពោះសហគមន៍។
- ការអភិវឌ្ឍជំនាញញាណនិងអំណាចនៃការសង្កេត។
- តែង បកស្រាយ និងសម្តែងតន្ត្រីលើប្រធានបទសកល។

**សិក្សាពាណិជ្ជកម្មនិងអាជីវកម្ម**

- ស៊ើបអង្កេតអំពីការប្រើប្រាស់ប្រកបដោយចីរភាព
- ពិនិត្យមើលផលប៉ះពាល់នៃការអភិវឌ្ឍប្រកបដោយចីរភាពសម្រាប់ឧស្សាហកម្មមួយ
- ស៊ើបអង្កេតអាជីវកម្ម និងឧស្សាហកម្ម«បៃតង»
- ប្រៀបធៀបថ្លៃដើមនៃការវេចខ្ចប់អាហារ ឧ.ក្រដាសនិងប្លាស្ទិច
- ស៊ើបអង្កេតអំពី ការចង់បាន និងតម្រូវការ (របស់បុគ្គល គ្រួសារ សហគមន៍សាលារៀន សង្គមទាំងមូល)
- ស៊ើបអង្កេតអំពីអាជីវកម្មក្នុងស្រុកដើម្បីប្រៀបធៀបកម្រិត«ការប្រើប្រាស់»និង«សំណល់» បន្ទាប់មកបង្កើតផែនការគ្រប់គ្រងដើម្បីកាត់បន្ថយកម្រិតទាំងនេះ
- វាយតំលៃប្រតិបត្តិការនៃឧស្សាហកម្មក្នុងស្រុកទាក់ទងនឹង«ការចំណាយ»នៃការបំពុល។

**សិក្សាភាសាទី១** (First Language Studies)

- ប្រើការពិភាក្សារឿងល្ខោន សម្តែងរឿង និងដោះស្រាយបញ្ហា ដើម្បីបង្ហាញឥរិយាបទនិងទស្សនៈលើបញ្ហាមូលដ្ឋាន

- ស្រាវជ្រាវ សរសេរ និងបោះពុម្ពអត្ថបទសម្រាប់ឯកសារ ទស្សនាវដ្ដីកុមារ សៀវភៅខិតប័ណ្ណ ព្រឹត្តិប័ត្រ ទិនានុប្បវត្តិ កំណត់ហេតុប្រចាំថ្ងៃ
- ពិភាក្សានិងជជែកវែកញែកអំពីបញ្ហាចីរភាពដើម្បីអភិវឌ្ឍជំនាញភាសា
- រីករាយនឹងរឿងរ៉ាវ ប្រលោមលោក ល្ខោននិងកំណាព្យមកពីជុំវិញពិភពលោកលើប្រធានបទវប្បធម៌
- ប្រើកម្មវិធីសិក្សាបែបប្រព័ន្ធផ្សព្វផ្សាយដើម្បីស៊ើបអង្កេតខ្សែភាពយន្តដែលបង្ហាញពីយុត្តិធម៌សង្គម។

**សិក្សាភាសាទី២** (Second Language Studies)

- ប្រើប្រាស់សម្ភារៈលើបញ្ហាសង្គមសម្រាប់ការអនុវត្តនិងអភិវឌ្ឍជំនាញភាសា។
- ធ្វើការសន្ទនាតាមរចនាសម្ព័ន្ធសាមញ្ញជុំវិញរូបថតដែលបង្ហាញពីអាហារមកពីប្រទេសផ្សេងៗ។
- សិក្សាបញ្ហាសហគមន៍ក្នុងតំបន់ដែលជាផ្នែកមួយនៃកម្មវិធីផ្លាស់ប្ដូរភាសា។
- ស៊ើបអង្កេតភាពខុសគ្នានៃវិធីដែលវប្បធម៌ផ្សេងគ្នាឆ្លើយតបនិងផ្ដល់តម្លៃដល់បរិស្ថាន។

**ការអប់រំសុខភាពនិងរាងកាយ** (Health and physical Education)

- អនុវត្តកម្មវិធីបង្រួមសំណល់ជាអប្បបរមានៅសាលារៀន និងស៊ើបអង្កេតផលប៉ះពាល់នៃបញ្ហាសំណល់មកលើសុខភាពមនុស្សនិងសុខភាពបរិស្ថាន។
- ស៊ើបអង្កេតផ្ទះបាយសាលារៀនឬហាងលក់ទំនិញ( ឧ. ការវេចខ្ចប់គ្រឿងបន្ថែមក្នុងអាហារ ថ្នាំសំលាប់សត្វល្អិតលើអាហារ ផលិតផលសរីរាង្គ តម្លៃអាហាររូបត្ថម្ភ) និងរៀបចំផែនការ/អនុវត្តសកម្មភាពសមស្របដើម្បីលើកកម្ពស់ផ្ទះបាយសាលារៀនឬហាងលក់ទំនិញ។
- ពិនិត្យមើលស្រទាប់អូហ្សូននិងបញ្ហាផ្ទះកញ្ចក់ និងភ្ជាប់បញ្ហាទាំងនេះទៅនឹងបញ្ហាសុខភាពមនុស្សនិងបញ្ហាបរិស្ថានធម្មជាតិ។
- ដោះស្រាយបញ្ហាមូលដ្ឋានដែលអាចមានផលវិបាកដល់សុខភាពមនុស្ស (ឧ.សំណល់គ្រោះថ្នាក់ ការគ្រប់គ្រងសំណល់មន្ទីរពេទ្យ/ការដុតសំណល់។
- ស៊ើបអង្កេតសារធាតុគីមីនៅក្នុងការផ្គត់ផ្គង់ទឹកក្នុងស្រុក។តើកម្រិតមានសុវត្ថិភាពទេ ?តើមានកម្រិតមួយដែលសុខភាពមនុស្សអាចរងផលប៉ះពាល់ដែរឬទេ ?

**គេហ-សេដ្ឋកិច្ច** (Home Economics)

- ស៊ើបអង្កេតមីក្រូអាកាសសធាតុ ការរចនាផ្ទះការរៀបចំផែនការទេសភាព និងការអភិវឌ្ឍន៍បរិស្ថានផ្ទាល់ខ្លួន។
- ស៊ើបអង្កេតពីទំនាក់ទំនងរវាងសុខភាពបុគ្គលនិងសុខភាពបរិស្ថាន។
- ស៊ើបអង្កេតប្រភពដើមនិងបច្ចេកទេសផលិតកម្មចំណីអាហារ( ឧ.ផលិតផលសរីរាង្គ, ផលិតផលក្នុងស្រុក និងផលិតផលនាំចូល-ថ្លៃដើម គុណភាព ផលវិបាកនៃសាច់ប្រាក់ផលិតកម្មដំណាំ។
- ស៊ើបអង្កេតការវេចខ្ចប់លើការកែច្នៃ ការអភិរក្សថាមពល និងការចោលសំណល់។

**គណិតវិទ្យា (Mathematics)**

- យល់ដឹង ប៉ាន់ប្រមាណ និងគណនាប្រូបាប៊ីលីតេដោយប្រើទិន្នន័យប្រជាសាស្ត្រ។
- គណនាចម្ងាយ ប្រវែង និងមុំ ដោយប្រើបរិស្ថានធម្មជាតិនិងសង្គម។
- ប្រមូលនិងតាងទិន្នន័យស្តីពីការប្រើប្រាស់ទឹកសម្រាប់គោលបំណងអភិរក្សទឹក។
- អភិវឌ្ឍជំនាញគណិតវិទ្យាមូលដ្ឋានតាមរយៈករណីសិក្សាការងារលើសហគមន៍មូលដ្ឋាន។
- សវនកម្មការប្រើប្រាស់ថាមពលដោយឧបករណ៍វាយតម្លៃអានបញ្ហា គណនាការចំណាយនិងការសន្សំ។
- ពិនិត្យមើលថ្លៃដើម/អត្ថប្រយោជន៍នៃការអនុវត្តថាមពលដែលមានប្រសិទ្ធភាព។
- បកស្រាយស្ថិតិអំពីនិន្នាការសង្គមនិងការអភិវឌ្ឍ។

**សិល្បៈហត្ថកម្ម និងបច្ចេកវិទ្យា (Manual Arts and Technology)**

- បង្កើតគោលការណ៍ណែនាំសម្រាប់សិល្បៈហត្ថកម្ម/បច្ចេកទេស

ឧ.ការបោលនូវសារធាតុពុល ការទិញ/ការប្រើប្រាស់គ្រឿង បន្ទាប់/ផលិតផលកែច្នៃឡើងវិញមិនទិញឈើពីព្រៃ បច្ចេកទេសកាត់បន្ថយសំណល់។

- ស៊ើបអង្កេតប្រភពឈើ ការប្រើប្រាស់និងផលប៉ះពាស់នៃប្រភពឈើសម្រាប់ការអភិរក្សនិងការអភិវឌ្ឍ។
- ពិនិត្យគុណសម្បត្តិនិងគុណវិបត្តិនៃធនធានកកើតឡើងវិញនិងធនធានសម្ភារៈសំយោគ។
- ស៊ើបអង្កេតគំនិតដូចជា៖ ការអភិរក្ស ការបង្រួមសំណល់ជាអប្បបរមា ការធ្វើរចនាម៉ូដបរិស្ថាន បច្ចេកវិទ្យាបរិស្ថានមេត្រី ធនធានកកើតឡើងវិញនិងធនធានមិនកកើតឡើងវិញ។

**សិក្សាសាសនា (Religious Education)**

- ពិចារណាការទទួលខុសត្រូវផ្ទាល់ខ្លួនចំពោះភាវៈមានជីវិតទាំងអស់។
- រុករកមេរៀនអំពីក្រមសីលធម៌ក្នុងរឿងរ៉ាវជនជាតិដើម។
- សើបអង្កេតទស្សនវិស្ស័យនៃសាសនាពិភពលោកផ្សេងៗគ្នាលើបញ្ហាដូចជា ធម្មជាតិសន្តិភាព ។ល។
- រុករកខាងសីលធម៌និងក្រមសីលធម៌នៃការសម្រេចចិត្តនយោបាយសង្គមនិងសេដ្ឋកិច្ច
- រុករក"ភាពខាងវិញ្ញាណធម្មជាតិ"។

**វិទ្យាសាស្ត្រ (Science)**

- ស៊ើបអង្កេតការប្រែប្រួលសារធាតុគីមីក្នុងបរិយាកាសដែលបង្កដោយសកម្មភាពមនុស្សនិងឧស្សាហកម្ម។
- ពិនិត្យគុណភាពទឹកនិងសិក្សាឥទ្ធិពលនៃកម្រិតអុកស៊ីសែនមកលើគ្រប់ទម្រង់ជីវិត។
- ប្រមូលគ្រាប់ពូជ ដាំដុះ និងប្រមូលផល។
- ស៊ើបអង្កេតផលិតផលថាមពលរូបវិទ្យាដែលផលិតចេញធនធានកកើតឡើងវិញនិងធនធានមិនកកើតឡើងវិញនិងប៉ះពាល់នៃផលិតផលថាមពលរូបវិទ្យាទៅលើបរិស្ថាន

- សិក្សាបណ្ដាញអាហារនិងស្ថានប្រព័ន្ធនានានិងផលប៉ះពាល់នៃជីអសរីរាង្គ ថ្នាំសម្លាប់សត្វល្អិត និងផលសំណល់។
- ស៊ើបអង្កេតវិទ្យាសាស្ត្រអំពីការកើនកម្ដៅពិភពលោក។
- អញ្ជើញមនុស្សធនធានសហគមន៍ដើម្បីជជែកវែកញែកអំពីបញ្ហាវិទ្យាសាស្ត្រ។

**សិក្សាសង្គម**( social studies )

- ស៊ើបអង្កេតវិធីផ្សេងៗគ្នាដែលសង្គមផ្សេងគ្នាឆ្លើយតបទៅនឹងតម្លៃបរិស្ថាន
- ប្រើប្រាស់ការសម្ដែង/ជីវចលដើម្បីកំណត់ចំណាប់អារម្មណ៍ផ្សេងគ្នានៅក្នុងបញ្ហាអភិវឌ្ឍ
- ផ្ដល់គុណតម្លៃតួនាទីនៃតម្លៃក្នុងទំនាស់អំពីអនាគត
- ដឹកនាំការសិក្សាអំពីតំបន់មូលដ្ឋានដើម្បីពិនិត្យមើលទំនាក់ទំនងរវាងបរិស្ថានសាងសង់ថ្មីនិងបរិស្ថានធម្មជាតិ
- ស៊ើបអង្កេតការប្រមូលឡើងវិញនៃការប្រើប្រាស់ដីចាស់ៗរបស់មនុស្សដោយប្រើប្រាស់ជំនាញប្រវត្តិសាស្ត្រផ្ទាល់មាត់។
- ប្រើប្រាស់ផ្ដល់គុណតម្លៃនៃគោលគំនិតនៃការអភិវឌ្ឍប្រកបដោយចីរភាពការកាន់ទ្រព្យសម្បត្តិនិងការអភិរក្ស។
- ពិនិត្យសិទ្ធិកាតព្វកិច្ចនៃបុគ្គលរដ្ឋាភិបាល អង្គការអាជីវកម្ម និងសង្គមនៅក្នុងសកម្មភាពអន្តរជាតិ។

## ៤.៨.ការអភិវឌ្ឍខ្លួនឯងប្រកបដោយចីរភាព( The Sustaninable Self )

"អ្នកអាចរៀបចំជីវិតដែលមានសុខភាពល្អ និងប្រកបដោយចីរភាព ព្រមទាំងមានតុល្យភាពក្នុងទំនាក់ទំនងរបស់អ្នកជាមួយនឹងធម្មជាតិ និងបច្ចេកវិទ្យា" Dr.Thomas Doherty

ការអប់រំជាគន្លឹះនៃការចូលរួមចំណែកដោះស្រាយបញ្ហានានានៅក្នុងសង្គមជាតិ( តើត្រូវអប់រំនរណាហើយអប់រំយ៉ាងដូចម្ដេច ?

ការផ្ដួចផ្ដើមចេញពីមនុស្សម្នាក់ៗ គឺអាចរួមចំណែកក្នុងការអភិវឌ្ឍប្រកបដោយចីរភាពឱ្យមានឥទ្ធិពលកាន់តែខ្លាំងឡើងៗតាមរយៈវិធីសាស្ត្រផ្ទាល់ខ្លួនក្នុងការអប់រំប្រកបដោយចីរភាពនិងឈានទៅដល់ភាពជាអ្នកដឹកនាំដល់មនុស្សដែលនៅជុំវិញនៃបុគ្គលម្នាក់ៗ។

លោកMurray បានលើកឡើងពីគោលការណ៍មួយចំនួនរបស់បុគ្គលចំពោះការអប់រំប្រកបដោយចីរភាពដែលមានដូចជា ការយល់ដឹងចំពោះខ្លួនឯងការលើកទឹកចិត្ត ការផ្ដល់អំណាចឱ្យខ្លួនឯងចំណេះដឹង បំណិននិងការអនុវត្ត។




**ការយល់ដឹងខ្លួនឯង** ( Self awareness )

- ចងចាំរូបភាពសំខាន់៖ ហេតុផលសម្រាប់ការផ្លាស់ប្តូរវិជ្ជមាន
- ចងចាំតួនាទីរបស់យើង៖ ផលប៉ះពាល់នៃសកម្មភាពរបស់យើង
- ផ្តើមចេញពីការយល់ដឹងខ្លួនឯង យើងអាចដឹងពីបញ្ហាប្រឈមនៅក្នុងគ្រួសារក្នុងសហគមន៍ នៅកន្លែងការងារ និងនៅក្នុងសង្គម ហើយចាប់ផ្តើមគិតពីរបៀបដោះស្រាយបញ្ហារបស់យើង ដោយផ្អែកលើការវិនិច្ឆ័យ ការកំណត់ និងការយល់ឃើញរបស់ខ្លួនឯង ដែលនេះគ្រាន់តែជាការយល់ឃើញដំបូងប៉ុណ្ណោះ។

**ការជំរុញទឹកចិត្ត** ( Motivation )

- ចងចាំតម្លៃរបស់យើង៖ បែបផែនជីវិត និងគុណតម្លៃស្នូលនៃសកម្មភាពរបស់យើង
- ចូលរួមអាកប្បកិរិយារបស់យើង៖ សម្របខ្លួនក្នុងន័យស្ថាបនានិងបើកចំហឥរិយាបថដើម្បីឆ្លើយតបទៅនឹងគុណតម្លៃស្នូល
- ផ្តោតលើបែបផែនជីវិត និងគុណតម្លៃស្នូល ថាតើគុណតម្លៃរបស់យើងជាអ្វី ( life style and core values in our actions. )
- រៀបចំឥរិយាបថដើម្បីឆ្លើយតបចំពោះគុណតម្លៃ ( open attitudes in response to core values )
- ចំពោះគុណតម្លៃ អ្នកខ្លះឱ្យតម្លៃលើភាពស្មោះត្រង់ ខ្លះឱ្យតម្លៃលើការជឿទុកចិត្តគ្នានិងគោរពគ្នាទៅវិញទៅមក ឬការចេះផ្តល់ក្តីស្រឡាញ់ដល់អ្នកដទៃជាដើម។
- យើងម្នាក់ៗត្រូវរកឱ្យឃើញនូវគុណតម្លៃរបស់យើងជាអ្វី រួចហើយចាប់ផ្តើមរៀបចំឥរិយាបថ ដោយការយកចិត្តទុកដាក់លើអ្នកដទៃ បើកចំហឬស្វែងយល់ពីអ្នកដទៃផ្សេងទៀត។ ពេលយើងជួបបញ្ហា យើងធ្វើការប្រៀបធៀបគ្នាជាមួយនឹងគុណតម្លៃ នោះយើងចាប់ផ្តើមជំរុញទឹកចិត្តយើង។ មនុស្សយើងកាលណាមានគុណតម្លៃវាអាចបណ្តាលចិត្តយើងឱ្យមានការផ្លាស់ប្តូរហើយ។

**បង្កើនអំណាចសមត្ថភាព** ( Empowerment )

- ប្រឈមនឹងជំនឿដែលគ្មានប្រយោជន៍៖ ដកចេញនូវការដាក់កម្រិតលើជំនឿខ្លួនឯង

- កែប្រែជំនឿរបស់យើង៖ ផ្តល់អំណាចដល់ខ្លួនឯងឡើងវិញ
- បង្កើនអំណាចខ្លួនឯងដោយបញ្ចៀសឧបសគ្គ
- យើងតែងជួបឧបសគ្គ ថាយើងមិនអាចធ្វើបាន
- ដូច្នេះគេឱ្យយើងចាប់ផ្តើមជឿលើខ្លួនឯងដោយគិតថាយើងអាចធ្វើបាន ហើយយើងឱ្យសិទ្ធិអំណាចមកលើខ្លួនឯងនៅក្នុងការចាប់ផ្តើមធ្វើសកម្មភាព។ ដូច្នេះយើងចាប់ផ្តើមជឿជាក់ និងចាប់ផ្តើមបើកចំហនិងធ្វើសកម្មភាពតែម្តង។

**ចំណេះដឹង (Knowledge)**

- អនុវត្តចំណេះដឹងរបស់យើង៖ ប្រែក្លាយការយល់ដឹងពីនិរន្តរភាពឱ្យទៅជាសកម្មភាព
- អភិវឌ្ឍមូលដ្ឋាននៃចំណេះដឹងរបស់យើង៖ ផ្តល់ឱកាសដល់ខ្លួនយើងសម្រាប់ការទទួលបានចំណេះដឹងនៃនិរន្តរភាព
- នៅពេលដែលយើងផ្តល់អំណាចឱ្យខ្លួនឯងរួចហើយ យើងនឹងទៅរកទិន្នន័យបន្ថែម គឺទៅរកចំណេះដឹងដែលទាក់ទងទៅនឹងការអភិវឌ្ឍប្រកបដោយចីរភាព

**បំណិនចាំបាច់**

- អនុវត្តការគិតប្រកបដោយញាណ៖ រាល់សកម្មភាពនិងការដោះស្រាយបញ្ហាភ្ជាប់ជាមួយនឹងអនាគតកាល ការពិចារណាស៊ីជម្រៅ ការស្រាវជ្រាវនិងការគិតជាប្រព័ន្ធ
- ការប្រាស្រ័យទាក់ទងល្អ៖ ទំនាក់ទំនងទូលំទូលាយ និងភាពជាអ្នកដឹកនាំប្រកបដោយប្រសិទ្ធភាពនិងការងារក្រុម
- ត្រូវចាត់វិធានការដែលដំបូងវិធានការលើខ្លួនឯងដោយមើលទៅលើសក្តានុពលរបស់ខ្លួនឯង។

**ការអនុវត្តន៍ (Practice)**

- ការអនុវត្តន៍ត្រូវផ្តើមចេញពីយើងខ្លួនឯង
- ជះឥទ្ធិពលដល់អ្នកដែលនៅជុំវិញយើង ពេលនោះគេនឹងរៀនសូត្រ គេនឹងអនុវត្តតាមយើង ហើយ ចំណុចទាំងនេះធ្វើឱ្យយើងដឹកនាំខ្លួនឯងផង និងដឹកនាំអ្នកដទៃផងក្នុងការពង្រឹងគុណភាពជីវិតរបស់យើងម្នាក់ៗ។

សរុបសេចក្តីទៅគោលការណ៍ទាំងនេះត្រូវជាមួយនឹងទ្រឹស្តីរបស់ទស្សនវិទូ និងពុទ្ធសាសនាដែលយើងត្រូវចាប់ផ្តើមស្វែងយល់ពីហេតុ និងផល និងរកដំណោះស្រាយដោយធ្វើសកម្មភាពនានាដែលសកម្មភាពទាំងនោះត្រូវធ្វើឡើងដោយប្រយ័ត្នថាតើវាប៉ះពាល់ដល់នរណាខ្លះ ហើយត្រូវកាត់បន្ថយផលប៉ះពាល់នោះយ៉ាងដូចម្តេចដើម្បីឱ្យមានការអភិវឌ្ឍប្រកបដោយចីរភាព។

**សន្និដ្ឋាន**

ការបញ្ជ្រាបការអប់រំតម្រូវឱ្យមានគោលការណ៍សាលាទូលំទូលាយនិងមានកិច្ចសហការពីសំណាក់គ្រូបង្រៀនទាំងអស់នៅក្នុងសាលារៀនក៏ដូចជាសិស្ស ឪពុកម្ដាយ និងសហគមន៍ទូទៅផងដែរ គោលការណ៍ចម្បងនៃការអប់រំសម្រាប់ការអភិវឌ្ឍន៍ប្រកបដោយចីរភាពលើកកម្ពស់ប្រជាជនដើម្បីផ្លាស់ប្ដូរវិធីគិតនិងអនុវត្តរបស់ប្រជាពលរដ្ឋឆ្ពោះទៅរកអនាគតប្រកបដោយនិរន្តភាព។

**សំណួរ**

១.តើអ្នកចាប់អារម្មណ៍បញ្ហាសង្គម-វប្បធម៌ បរិស្ថាន សេដ្ឋកិច្ច និងអប់រំអ្វីខ្លះនៅក្នុងថ្នាក់រៀន ឬសាលារៀនរបស់អ្នក?

២.ក្នុងនាមជាគ្រូបង្រៀនតើអ្នកជួយសិស្សក្នុងការបង្កើតទម្លាប់ស្រលាញ់និងថែរក្សាបរិស្ថានយ៉ាងដូចម្ដេច?

៣. ដូចម្ដេចដែលហៅថាពលរដ្ឋសាកល? ហេតុអ្វីបានជាវាមានសារៈសំខាន់?

# មេរៀនទី ៥ ទ្រឹស្ដីនៃការអប់រំ

## វត្ថុបំណង

បន្ទាប់ពីសិក្សាមេរៀននេះចប់គរុនិស្សិតនឹង៖

- ពន្យល់បានពីទ្រឹស្ដីនៃអាកប្បកិរិយា ទ្រឹស្ដីនៃការយល់ដឹង ទ្រឹស្ដីស្ថាបនានិយម និងទ្រឹស្ដីមនុស្សនិយម។
- កំណត់បានពីបញ្ញត្តិនៃទ្រឹស្ដីនៃការសិក្សានិងបង្ហាញពីភាពខុសគ្នារវាងទ្រឹស្ដីទាំងនោះ
- ជ្រើសរើសនិងផ្ដល់តម្លៃដល់ទ្រឹស្ដីដែលអាចយកមកប្រើប្រាស់បានក្នុងការរៀននិងបង្រៀន។

## ៥.១.សេចក្ដីផ្ដើម

មេរៀននេះផ្ដោតលើទ្រឹស្ដីនៃការរៀនផ្សេងៗគ្នាដែលត្រូវបានប្រើប្រាស់រហូតមកដល់សព្វថ្ងៃ។ ការសិក្សា និងការស្រាវជ្រាវពីទ្រឹស្ដីនៃការរៀនផ្ដល់នូវការយល់ដឹងស៊ីជម្រៅនិងមានសារៈសំខាន់ចំពោះប្រសិទ្ធភាពនៃការរៀនរបស់សិស្ស។ ពេលដែលយើងពង្រីកចំណេះដឹងអំពីទ្រឹស្ដីអប់រំ យើងផ្ដោតសំខាន់ទៅលើមូលដ្ឋានគ្រឹះនៃទ្រឹស្ដីការអប់រំមួយចំនួនដូចជា៖ ទ្រឹស្ដីអាកប្បកិរិយា ទ្រឹស្ដីនៃការយល់ដឹង ទ្រឹស្ដីស្ថាបនានិយម និងការលើកទឹកចិត្ត ឬទ្រឹស្ដីមនុស្សនិយម។

## ៥.២ . និយមន័យ

ទ្រឹស្ដីនៃការរៀនគឺជាសំណុំនៃការសាកល្បងអត្ថន័យដែលមានលក្ខណៈប្រាស្រ័យទាក់ទងគ្នាជាប្រព័ន្ធតាមរយៈការពន្យល់។

ផ្អែកទៅលើការយល់ពីរបៀបរៀនរបស់សិស្ស វិទ្យាសាស្ត្រនៃការបង្រៀនត្រូវពិចារណាម៉ត់ចត់ដើម្បីរៀបចំផែនការបង្រៀន។

ការរៀបចំផែនការបង្រៀនបានល្អអាចជួយឱ្យអ្នកសិក្សាអភិវឌ្ឍបំណិនគិតដែលនាំទៅសម្រេចលទ្ធផលសិក្សាប្រកបដោយជោគជ័យ។

## ៥.៣. របៀបនៃការរៀន

**តើការរៀនមានអត្ថន័យយ៉ាងណា?**

- ការរៀនជាដំណើរការនៃការផ្លាស់ប្ដូរចំណេះដឹង បំណិន ចរិយា គុណតម្លៃ អត្តចរិក និងចំណង់ចំណូលចិត្តថ្មីៗតាមរយៈការប្រាស្រ័យទាក់ទងជាមួយបរិស្ថានជុំវិញឬតាមបទពិសោធ។

តើទាំងនេះមានការវិវត្តយ៉ាងណាខ្លះសម្រាប់អ្នកណា?

- រៀនពេញមួយជីវិត រៀនតាំងពីចាប់កំណើតរហូតដល់ស្លាប់តាមរយៈប្រាស្រ័យទាក់ទងជាប់ជាបន្តរវាងខ្លួនឯង មនុស្ស និងបរិស្ថាន។

**តើការរៀនជាអ្វី?**

ការរៀនមានន័យថា ការជះឥទ្ធិពលអចិន្ត្រៃយ៍ទៅលើអាកប្បកិរិយា ចំណេះដឹង និងបំណិនការគិតដែលជាលទ្ធផលនៃបទពិសោធន៍ ឆ្លងកាត់។

ឧទាហរណ៍៖ ការរៀន(ប្រើកុំព្យូទ័រ បើកឡាន ...)មិនមែនការរៀន(សមត្ថភាពពីកំណើត ៖ លេបបាយ ញោចខ្លួន ព្រិចភ្នែក...)។

**តើវិធីរៀនជាអ្វី?**

វិធីបង្រៀន គឺជាការគួបផ្សំរវាងរបៀបរបបធ្វើការងាររបស់គ្រូ និងសិស្ស ក្រោមការដឹកនាំរបស់គ្រូ សំដៅអនុវត្តឱ្យបានសម្រេចគ្រប់ភារកិច្ចនៃការបង្រៀន ។

របៀបរបបធ្វើការរបស់គ្រូមានការចាត់តាំងសកម្មភាព ការដឹកនាំសកម្មភាព និងការគ្រប់គ្រងសកម្មភាព...។ របៀបរបបធ្វើការរបស់សិស្សមាន ការភ្ញាក់រឭកដោយខ្លួនឯង ស្វ័យចាត់តាំងសកម្មភាព ស្វ័យគ្រប់គ្រងសកម្មភាព ... ។

**ដូចម្តេចដែលហៅថា លំនាំនៃការបង្រៀន?**

លំនាំនៃការបង្រៀន គឺជាលំនាំនៃការផ្សព្វផ្សាយចំណេះដឹងនិងគ្រប់គ្រង ព្រមទាំងស្វ័យគ្រប់គ្រង ការរៀនសូត្ររបស់សិស្ស ។

## ៥.៤. ទ្រឹស្តីនៃការរៀន

### ៥.៤.១. ទ្រឹស្តីនៃអាកប្បកិរិយា(Behaviorism)

- ជាគំនិតដែលយល់ថាអាកប្បកិរិយាទទួលបានតាមរយៈការដាក់លក្ខខណ្ឌ
- យើងអាចវាស់អាកប្បកិរិយាដោយការឆ្លើយតបរបស់អ្នកសិក្សាចំពោះវត្ថុភ្ញោច
- ការឆ្លើយតបរបស់អ្នកសិក្សាចំពោះវត្ថុភ្ញោចអាចត្រូវបានពង្រឹងដោយការប្រើព័ត៌មានត្រឡប់វិជ្ជមានឬ អវិជ្ជមាន។
- មានលក្ខខណ្ឌ២ប្រភេទគឺ លក្ខខណ្ឌក្លាសិច និងលក្ខខណ្ឌប្រតិបត្តិ

Classical conditoning/pavlovian conditioning

ជាការរៀនតាមរយៈការផ្សារភ្ជាប់ហើយត្រូវបានរកឃើញដោយសារលោកប៉ាវឡូវដែលជាអ្នកជំនាញខាងសរីរវិទ្យាជនជាតិរុស្ស៊ី។ក្នុងន័យសាមញ្ញ គឺវត្ថុភ្ញោចពីត្រូវបានភ្ជាប់ជាមួយគ្នាដើម្បីបង្កើតការឆ្លើយតបថ្មីរបស់មនុស្សឬសត្វ។







*រូបភាព 32៖*

**ឧទាហរណ៍៖**

- សិស្សមានទាំងបទពិសោធល្អនិងអាក្រក់នៅក្នុងថ្នាក់។
- បើសិនជាគេមានអារម្មណ៍ថាក្នុងថ្នាក់រៀនមានភាពសប្បាយរីករាយឬគ្រូមានភាពកក់ក្តៅគេចង់មករៀន ពោលគឺក្នុងការរៀនបានផ្សារភ្ជាប់ទៅនឹងភាពកក់ក្តៅ។
- តែបើគេធ្វើតេស្តមិនបាន ហើយគ្រូស្តីឱ្យគេរៀនផ្សារភ្ជាប់តេស្តទៅនិងការភ័យព្រួយទៅវិញ។គេមិនមករៀន បើគេផ្សារភ្ជាប់ថ្នាក់រៀនទៅនឹងការស្តីឱ្យពីគ្រូ។
- សំណួរអនុវត្ត តើ Classical conditoning មានប្រយោជន៍ដូចម្តេចនៅពេលលោកគ្រូអ្នកគ្រូបង្រៀនសិស្ស?
- លក្ខខណ្ឌប្រតិបត្ត

តើការលើកទឹកចិត្តនិងទណ្ឌកម្មកំណត់អាកប្បកិរិយាយ៉ាងដូចម្តេច?

ការលើកទឹកចិត្តនិងទណ្ឌកម្មកំណត់អាកប្បកិរិយាគឺជាវិធីសាស្ត្រនៃការរៀនដែលប្រើប្រាស់រង្វាន់និងដាក់ទណ្ឌកម្មចំពោះអាកប្បកិរិយា

- តាមរយៈលក្ខខណ្ឌប្រតិបត្តិទំនាក់ទំនងរវាងអាកប្បកិរិយានិងផលវិបាកត្រូវបានបង្កើតឡើង (មិនថាវិជ្ជមានឬអវិជ្ជមាន)ចំពោះអាកប្បកិរិយានោះ។

ឧទាហរណ៍ ៖ គ្រូពោលប្រសើរណាស់

- អ្នកគ្រូមានមោទកភាពណាស់ចំពោះសាច់រឿងដែលកូនបានសរសេរ សិស្សសរសេរកាន់តែល្អ។ នេះហៅថាការពង្រឹង(ឬរង្វាន់)។
- តែបើគ្រូជ្រួញចិញ្ចើមដាក់សិស្សម្នាក់ដែលនិយាយក្នុងថ្នាក់រៀនវាបានកាត់បន្ថយការនិយាយរបស់សិស្ស នោះគេហៅថា ការដាក់ពិន័យ។
- ការពង្រឹងបន្ថែមមានពីរបែប positive and negative reinforcement

ឧទាហរណ៍ ៖ ពុកម្តាយស្តីឱ្យកូននៅពេលធ្វើលំហាត់ដែលគ្រូដាក់ឱ្យ កូនក៏ចាប់ផ្តើមធ្វើ។ នៅពេលកូនធ្វើពុកម្តាយលែងថាឱ្យហើយ នេះហៅថា Negative Reinforcement.

### ៥.៤.២ ទ្រឹស្តីនៃការយល់ដឹង(Cognitivism)

- ជាទ្រឹស្តីនៃការរៀនដែលផ្តោតលើដំណើរការពាក់ព័ន្ធនិងការរៀនសូត្រជាងការសង្កេតលើអាកប្បកិរិយា។
- ផ្ទុយពីទ្រឹស្តីអាកប្បកិរិយា
- ទ្រឹស្តីនៃការយល់ដឹងមិនតម្រូវឱ្យបង្ហាញមកខាងក្រៅប៉ុន្តែវាផ្តោតលើលំនាំខាងក្នុងនិងការភ្ជាប់ដែលកើតឡើងក្នុងអំឡុងពេលសិក្សា។

ឧទាហរណ៍ ៖ ឱ្យសិស្សឆ្លុះបញ្ចាំងពីបទពិសោធរបស់គេ។ ជួយឱ្យសិស្សស្វែងរកដំណោះស្រាយភាពត្រឹមត្រូវនិងពន្យល់ពីការគិតរបស់ពួកគេ ។ល។

### ៥.៤.៣ ទ្រឹស្តីស្ថាបនានិយម(Constructivism)

ទ្រឹស្តីស្ថាបនានិយមចាត់ទុកថា អ្នកសិក្សាមិនមែនជាអ្នកអកម្មក្នុងការទទួលចំណេះដឹងទេ ប៉ុន្តែជាអ្នកដែលសកម្មខ្លាំងក្នុងដំណើរការរៀន។

ពួកគេផ្អែកលើបទពិសោធន៍ពីមុនដើម្បីស្វែងយល់ពីអ្វីដែលគេកំពុងរៀន។ពួកគេកាន់តែសកម្មក្នុងការបង្កើតអត្ថន័យនិងចំណេះដឹង។



*រូបភាព 33*

## សន្និដ្ឋាន

មេរៀននេះអាចជួយឱ្យយើងចេះរៀបចំជីវិតដែលមានសុខភាពល្អ និងប្រកបដោយចីរភាព ព្រមទាំងមានតុល្យភាពក្នុងទំនាក់ទំនងរបស់អ្នកជាមួយ នឹងវប្បធម៌ជាតិ និងបច្ចេកវិទ្យា។ ការអប់រំជាគន្លិះនៃការចូលរួមចំណែកដោះស្រាយបញ្ហានានានៅក្នុងសង្គមជាតិ។ ការផ្តួចផ្តើមចេញពីមនុស្សម្នាក់ៗគឺរួមចំណែកក្នុងការអភិវឌ្ឍប្រកបដោយចីរភាពឱ្យមានឥទ្ធិពលកាន់តែខ្លាំងឡើងៗតាមរយៈវិធីសាស្ត្រផ្ទាល់ខ្លួនក្នុងការអប់រំប្រកប
ដោយចីរភាពនិងឈានទៅដល់ ភាពជាអ្នកដឹកនាំដល់មនុស្សដែលនៅជុំវិញខ្លួននៃបុគ្គលម្នាក់ៗ។
គោលការណ៍មួយចំនួនរបស់បុគ្គលចំពោះការអប់រំប្រកបដោយចីរភាពដែលមានដូចជា ការយល់ដឹងចំពោះខ្លួនឯង ចំណេះដឹង បំណិន និងការអនុវត្ត។ រៀនពេញមួយជីវិត រៀនតាំងពីចាប់កំណើតរហូតដល់ស្លាប់តាមរយៈប្រាស្រ័យទាក់ទងជាប់ជាបន្តរវាងខ្លួនឯង មនុស្ស និងបរិស្ថាន។

## សំណួរ

១.តើអ្វីជាការលើកទឹកចិត្ត និងទ្រឹស្តីមនុស្សនិយម? ហេតុអ្វីគ្រូត្រូវប្រើវា?

២.ចូរបង្ហាញពីគុណសម្បត្តិនិងគុណវិបត្តិនៃទ្រឹស្តីនៃការរៀនសូត្រ?

៣.តើទ្រឹស្តីទាំងនេះត្រូវបានអនុវត្តយ៉ាងដូចម្តេចនៅក្នុងថ្នាក់រៀន?

# មេរៀនទី៦ ការប្រៀបធៀបការអប់រំអន្តរជាតិ

## វត្ថុបំណង

បន្ទាប់ពីរៀនមេរៀននេះចប់គរុនិស្សិតនឹងៈ

- កំណត់បានពីបញ្ញត្តិនៃការប្រៀបធៀបការអប់រំ
- ពន្យល់បានពីមូលហេតុនៃការប្រៀបធៀបការអប់រំដែលមានសារៈសំខាន់ចំពោះគ្រូ
- ប្រៀបធៀបប្រព័ន្ធអប់រំនៃប្រទេសអភិវឌ្ឍន៍និងប្រទេសកំពុងអភិវឌ្ឍ
- កំណត់បញ្ហាប្រឈមមួយចំនួនដែលអ្នកសិក្សាប្រៀបធៀបបានជួបនៅក្នុងដំណើរការប្រើប្រាស់ព័ត៌មានពីប្រទេសដទៃទៀតក្នុងសតវត្សរ៍ទី ២១ ។

## ៦.១.សេចក្តីផ្តើម

មេរៀននេះផ្តោតលើការប្រៀបធៀបការអប់រំអន្តរជាតិ។ ប្រព័ន្ធអប់រំនៅក្នុងប្រទេសមិនអាចឃ្លាតឆ្ងាយពីប្រព័ន្ធអប់រំនៃប្រទេសដទៃទៀតបានទេ។ ដោយមើលឃើញពីតម្រូវការនៃភាពស្មើគ្នានៅក្នុងពិភពលោកវាមានសារៈសំខាន់ណាស់ក្នុងការប្រៀបធៀបប្រព័ន្ធអប់រំរបស់ប្រទេសកម្ពុជាជាមួយនិងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍និងប្រទេសដទៃទៀត។ ប្រៀបធៀបប្រព័ន្ធអប់រំរវាងប្រទេសកំពុងអភិវឌ្ឍនិងប្រទេសអភិវឌ្ឍដូចជាៈ កម្មវិធីសិក្សា ការអប់រំគ្រូ និងលក្ខខ័ណ្ឌនៃការជ្រើសរើស។ ចំណេះដឹងអំពីប្រព័ន្ធអប់រំនៃប្រទេសផ្សេងៗ ជួយដល់អ្នកធ្វើគោលនយោបាយក្នុងការឆ្លុះបញ្ចាំងពី ការអប់រំនៅក្នុងបរិបទនៃការប្រកួតប្រជែងនិងឧត្តមភាព។ ដូច្នេះវាមាន សារៈសំខាន់ណាស់សម្រាប់គ្រូឧទ្ទេសត្រូវដឹងអំពីគោលបំណងនៃកម្មវិធីសិក្សា ការអប់រំគ្រូ លក្ខខណ្ឌនៃការចូលរៀន និងតម្រូវការជ្រើសរើសបុគ្គលិកនៃប្រព័ន្ធអប់រំរបស់ប្រទេសអភិវឌ្ឍន៍និងប្រទេសកំពុងអភិវឌ្ឍន៍ផ្សេងទៀត។

## ៦.២. និយមន័យ

ការប្រៀបធៀបការអប់រំអន្តរជាតិគឺជាវិស័យអប់រំដែលវិភាគលើប្រព័ន្ធអប់រំនៃប្រទេសមួយដោយប្រើទិន្នន័យនិងប្រព័ន្ធពីប្រទេសដទៃទៀតនិងរៀបចំគោលបយោបាយដើម្បីលើកកម្ពស់ការអប់រំ។

យោងតាមហ្វ្រេស (១៩៦២ ដូចដែលបានដកស្រង់នៅក្នុងច្បាប់ ២០០៤) វាទាក់ទងនឹងការសិក្សាទាក់ទងនឹងការប្រៀបធៀបទ្រឹស្តីការអប់រំនិងការអនុវត្តបច្ចុប្បន្ន នៅក្នុងប្រទេសផ្សេងៗគ្នាសម្រាប់គោលបំណងពង្រីកនិងស្វែងយល់ឱ្យកាន់តែស៊ីជម្រៅពីបញ្ហាអប់រំលើសពីព្រំដែននៃប្រទេសផ្ទាល់ខ្លួន។

Getao (ឆ្នាំ ១៩៩៦) បានកំណត់និយមន័យការអប់រំប្រៀបធៀប ជាវិន័យការសិក្សា ប្រព័ន្ធអប់រំដែលមនុស្សម្នាក់ស្វែងយល់ពីភាពដូចគ្នា និងភាពខុសគ្នារវាងប្រព័ន្ធអប់រំ។ វិស័យអប់រំប្រៀបធៀបត្រូវបានកំណត់ថាជាចំណុចប្រសព្វគ្នានៃវិទ្យាសាស្ត្រសង្គមការអប់រំ និងការសិក្សាឆ្លងប្រទេស។

បើតាមលោក Adeyinka(ឆ្នាំ១៩៩៤) ផ្តល់នូវនិយមន័យដូចខាងក្រោមៈ

- ការសិក្សាអំពីទស្សនវិជ្ជាគោលបំណងនិងគោលនយោបាយនិងការអនុវត្តជាក់ស្តែង
- ការសិក្សាអំពីប្រព័ន្ធអប់រំពីរឬច្រើន

- ការអប់រំក្នុងប្រទេសដទៃទៀតដែលមានសក្តានុពលដល់កាអភិវឌ្ឍន៍
- ការសិក្សាអំពីរបៀបនៃការអភិវឌ្ឍការអប់រំក្នុងអតីតកាលគ្រប់ជំនាន់និងទិ្វបដល់ការអភិវឌ្ឍការអប់រំក្នុងប្រទេស។
- ការសិក្សាអំពីប្រព័ន្ធសាលារៀននៃប្រទេសពីរឬច្រើនដើម្បីអនុវត្តឬត្រួតពិនិត្យការអនុវត្តរបស់រដ្ឋាភិបាល គោលនយោបាយនៅកម្រិតផ្សេងៗនៃប្រព័ន្ធអប់រំ ព្រមទាំងដើម្បីឱ្យមានការយល់ដឹងកាន់តែច្បាស់អំពីប្រព័ន្ធអប់រំនៅខាងក្រៅប្រទេសរបស់ខ្លួន ដឹងអំពីតំរូវការនៃភាពស្មើគ្នាជាសកល។
- វាជាការសំខាន់ដើម្បីប្រៀបធៀបប្រព័ន្ធអប់រំនៃប្រទេសណាមួយជាមួយ ប្រព័ន្ធនៃប្រទេសផ្សេងទៀត។

## ៦.៣. គោលបំណងនៃការសិក្សាប្រៀបធៀបការអប់រំ

- ស្វែងយល់ការអប់រំពីស្ថាប័នរបស់ខ្លួននិងរបស់គេ
- ស្វែងយល់ពីកត្តាដែលជានាចំពោះការផ្លាស់ប្តូរការអប់រំ
- អប់រំគ្រូនិងសិស្សអំពីនិតិវិធីដែលនាំឱ្យមានការផ្លាស់ប្តូរការអប់រំ
- រួមចំណែកក្នុងការអភិឌ្ឍន៍វិស័យអប់រំនិងជួយដល់ការអភិវឌ្ឍន៍ទូទៅ
- ជួយដោះស្រាយបញ្ហាអប់រំ
- ជួយគ្រូនិងសិស្សក្នុងការប្រមូលព័ត៌មាន
- លើកកម្ពស់ទំនាក់ទំនងអន្តរជាតិ
- ជាចំណែកក្នុងការបង្កើតប្រព័ន្ធអប់រំរបស់ប្រទេស។

## ៦.៤. សារៈសំខាន់នៃការប្រៀបធៀបអប់រំ

- ការអប់រំផ្តល់ឱ្យកុមារនូវផ្លូវចាកចេញពីភាពក្រីក្រនិងឆ្ពោះទៅរកអនាគតដែលមានស្ថិរភាពនិងក្តីសង្ឃឹម
- ជាឯកសារយោងសម្រាប់កំណែទម្រង់។ ការសិក្សាជួយសិស្សឱ្យកែលម្អការអប់រំក្នុងប្រទេសរបស់ពួកគេ
- ជួយសិស្សយល់ដឹងកាន់តែច្បាស់ពីប្រព័ន្ធអប់រំនៃប្រទេសដទៃនិងខ្ចីនូវទិដ្ឋភាពមួយចំនួនសម្រាប់កែលម្អការអប់រំក្នុងប្រព័ន្ធអប់រំក្នុងប្រទេស។




https://prezi.com/p/j7s_nxqkyb2a/importance-of-comparative-education-for-transnational-students/

*រូបភាព 34*

## ៦.៥. វិសាលភាពនៃការប្រៀបធៀបអប់រំ

វិសាលភាពនៃការប្រៀបធៀបអប់រំធ្វើឡើងដោយផ្អែកលើទស្សនៈវិស័យ ៥៖

- ប្រធានបទនិងខ្លឹមសារ(រចនាសម្ព័ន្ធ គោលបំណង ខ្លឹមសារឬកម្មវិធីសិក្សា)
- ភូមិសាស្ត្រនៃការសិក្សា(ការសិក្សាថ្នាក់ជាតិ ថ្នាក់តំបន់និងអន្តរជាតិ)
- វិសាលភាពមនោគមវិជ្ជា(ការប្រៀបធៀប្រទេសមួយដោយផ្អែកលើភាពខុសគ្នានៃនយោបាយនិងសេដ្ឋកិច្ច)
- វិសាលភាពតាមវិស័យ(ផ្តោតលើប្រធានបទអប់រំ បញ្ហាប្រធានបទហើយប្រៀបធៀបក្នុងភូមិសាស្ត្រ។
  ឧទាហរណ៍៖ ការអប់រំបឋមសិក្សានិងមធ្យមសិក្សាឥតគិតថ្លៃការអប់រំទាំងអស់គ្នា។
- វិសាលភាពប្រវត្តិសាស្ត្រ៖ ទាក់ទងនិងការសិក្សាអំពីការអភិវឌ្ឍជាប្រវត្តិសាស្ត្រនៃក្រិត្យក្រមចាប់ពីដំណាក់កាលដំបូង ទៅដំណាក់ទំនើប។

## ៦.៦. បញ្ហាប្រឈម

- ការអប់រំមានគម្លាតដ៍ធំរវាងគុណភាពនៃការអប់រំក្នុងទីក្រុងនិងជនបទជាពិសេសបើប្រៀបធៀបជាមួយបណ្តាលប្រទេសអភិវឌ្ឍ
- តំបន់ដាច់ស្រយាលនៅខ្វះហេដ្ឋារចនាសម្ព័ន្ធដូចជា ផ្លូវថ្នល់ សម្ភារៈ សាលារៀន គ្របង្រៀននិងធនធាននានានៅមានកម្រិត។
- គ្រូបង្រៀនបញ្ចប់ក្រោយការសិក្សាមានភាពស្ទាក់ស្ទើរដែលធ្វើការតាមខេត្ត
- ការផ្តល់ការគាំទ្រដល់ការរៀនសូត្ររបស់កុមារ មានសារៈសំខាន់យ៉ាងខ្លាំង ដើម្បីឱ្យពួកគេអាចអភិវឌ្ឍខ្លួនឈានទៅសម្រេចបានសក្តានុពលរបស់ពួកគេ។
- នៅក្នុងប្រទេសកម្ពុជាមានកុមារជាច្រើនពុំបានរៀនសូត្រគ្រប់គ្រាន់ជាពិសេសកុមារដែលរស់នៅជនបទនិងទីប្រជុំជន
- ប្រទេសកម្ពុជាបានសម្រេចនូវវឌ្ឍនភាពយ៉ាងគាប់ប្រសើរចាប់តាំងពីឆ្នាំ២០០៧

- ទោះជាយ៉ាងនេះក៏ដោយ នៅប្រទេសកម្ពុជា មានកុមារជាច្រើនពុំបានរៀនសូត្រគ្រប់គ្រាន់ ជាពិសេសកុមារដែលរស់នៅក្នុងតំបន់ក្រីក្រនៅជនបទ និងទីប្រជុំជន។
- ប្រទេសកម្ពុជា បានសម្រេចនូវវឌ្ឍនភាពយ៉ាងគាប់ប្រសើរ ក្នុងការផ្តល់ការអប់រំដល់កុមាររបស់ខ្លួន។ ចាប់តាំងពីឆ្នាំ២០០៧ ចំនួនកុមារដែលបានចុះឈ្មោះចូលរៀនក្នុងកម្មវិធីអប់រំកម្រិតមត្តេយ្យសិក្សាកើនឡើងទ្វេដង។ ចំនួនកុមារដែលចុះឈ្មោះចូលរៀនក្នុងកម្រិតអប់រំបឋមសិក្សាកើនឡើងពី ៨២ ភាគរយក្នុងឆ្នាំ១៩៩៧ ដល់ជាង ៩៧ ភាគរយក្នុងឆ្នាំសិក្សា ២០១៧ - ២០១៨។
- ទោះជាមានវឌ្ឍនភាពបែបនេះក៏ដោយ កុមារនៅកម្ពុជានៅពុំទាន់រៀនទាន់ស្តង់ដានៃការរៀនសូត្រដែលអាចទទួលយកបាន ស្របទៅតាមអាយុរបស់ពួកគេឡើយ។ នៅកម្រិតបឋមសិក្សាមានកុមាររៀនថ្នាក់ទី៣ ជិត២៥ភាគរយពុំចេះសរសេរសូម្បីតែពាក្យមួយម៉ាត់នៅក្នុងតេស្តសរសេរតាមអាន។ កុមារអាយុពី ៣ ទៅ៥ឆ្នាំ ត្រឹមតែ ២៧ ភាគរយតែប៉ុណ្ណោះ ដែលមានការអភិវឌ្ឍចំណេះដឹងអក្សរ និងលេខនព្វន្តស្របទៅតាមអាយុរបស់ពួកគេ ហើយមានក្មេងជំទង់ ៥៥ ភាគរយបោះបង់ចោលការសិក្សា មុនពេលពួកគេមានអាយុ ១៧ឆ្នាំ។

## ៦.៧.ដំណោះស្រាយ

- ពង្រឹងគុណភាពជាអ្នកដឹកនាំ គុណភាពនៃការបង្រៀននិងការកសាងបរិស្ថានសាលារៀនដែលធ្វើឱ្យកុមារមានសុខភាពល្អ ជួយជំរុញទឹកចិត្តឪពុកម្តាយឱ្យបញ្ជូនកូនៗទៅរៀននិងលើកទឹកចិត្តសិស្សឱ្យបន្តរៀនសូត្រ យូនីសេហ្វ បន្តកិច្ចសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា និងដៃគូដទៃទៀត ដើម្បីធានាយ៉ាងណាឱ្យកុមារ អាចទៅរៀន និងបន្តរៀនបាន ហើយសំខាន់ជាងនេះទៀតគឺដើម្បីធានាថាពួកគេអាចរៀនសូត្រប្រកបដោយគុណភាព។
- យុទ្ធសាស្ត្រអភិវឌ្ឍរបស់ប្រទេសអភិវឌ្ឍគឺការផ្តោតលើការយកចិត្តទុកដាក់លើប្រជាជនវ័យក្មេង ពេញលេញដោយភាពស្វាហាប់និងចល័តភាពដោយចាត់ទុកពួកគេជាអ្នកចូលរួមចំនែកដ៏សំខាន់ដល់ការអភិវឌ្ឍនិងកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព
- ដើម្បីធានាថាកុមារគ្រប់រូបអាចរៀនសូត្របានយើងត្រូវផ្តោតការយកចិត្តទុកដាក់លើការលើកកម្ពស់លទ្ធភាពទទួលបានការអប់រំប្រកបដោយសមធម៌និងបរិយាបន្នសម្រាប់កុមារពិការ កុមារជនជាតិភាគតិចនិងកុមារដែលរស់នៅតំបន់ក្រីក្រនៅជនបទនិងទីប្រជុំជន។




*រូបភាព 35*

## ករណីសិក្សា

### ការអប់រំនៅប្រទេសកម្ពុជា

ការអប់រំប្រកបដោយគុណភាព និងបំណិនជីវិតសម្រាប់កុមារគ្រប់រូប



*រូបភាព 36*

### បញ្ហាប្រឈម

កុមារគ្រប់រូបមានសិទ្ធិរៀនសូត្រ មិនថាពួកគេស្ថិតនៅក្នុងកាលៈទេសៈបែបណានោះឡើយ។ ការផ្តល់ការគាំទ្រគ្រប់គ្រាន់ដល់ការរៀនសូត្ររបស់កុមារ មានសារៈសំខាន់យ៉ាងខ្លាំងដើម្បីឱ្យពួកគេអាចអភិវឌ្ឍខ្លួនឈានទៅសម្រេចបានសក្តានុពលរបស់ពួកគេ។ ទោះជាយ៉ាងនេះក៏ដោយ នៅប្រទេសកម្ពុជា មានកុមារី និងកុមារាជាច្រើននាក់ ពុំបានរៀនសូត្រគ្រប់គ្រាន់ ជាពិសេសកុមារដែលរស់នៅក្នុងតំបន់ក្រីក្រនៅជនបទ និងទីប្រជុំជន។ប្រទេសកម្ពុជាបានសម្រេចនូវវឌ្ឍនភាពយ៉ាងគាប់ប្រសើរ ក្នុងការផ្តល់ការអប់រំដល់កុមាររបស់ខ្លួន។ ចាប់តាំងពីឆ្នាំ២០០៧មក ចំនួនកុមារដែលបានចុះឈ្មោះចូលរៀនក្នុងកម្មវិធីអប់រំកម្រិតមត្តេយ្យសិក្សាកើនឡើងទ្វេដង។ ចំនួនកុមារដែលចុះឈ្មោះចូលរៀនក្នុងកម្រិតអប់រំបឋមសិក្សាកើនឡើងពី ៨២ ភាគរយក្នុងឆ្នាំ១៩៩៧ ដល់ជាង ៩៧ ភាគរយក្នុងឆ្នាំសិក្សា ២០១៧/១៨។ទោះជាមានវឌ្ឍនភាពបែបនេះក៏ដោយ កុមារនៅកម្ពុជា នៅពុំទាន់រៀនទាន់ស្តង់ដានៃការរៀនសូត្រដែលអាចទទួលយកបាន ស្របទៅតាមអាយុរបស់ពួកគេឡើយ។ នៅកម្រិតបឋមសិក្សា មានកុមារ

រៀនថ្នាក់ទី៣ ជិត ២៥ ភាគរយពុំចេះសរសេរសូម្បីតែពាក្យមួយម៉ាត់នៅក្នុងតេស្តសរសេរតាមអាន។ កុមារអាយុពី ៣ ទៅ ៥ឆ្នាំ ត្រឹមតែ ២៧ ភាគរយតែប៉ុណ្ណោះ ដែលមានការអភិវឌ្ឍចំណេះដឹងអក្សរ និងលេខនព្វន្តស្របទៅតាមអាយុរបស់ពួកគេ ហើយមានក្មេងជំទង់ ៥៥ ភាគរយបោះបង់ចោលការសិក្សា មុនពេលពួកគេមានអាយុ ១៧ឆ្នាំ។កុមារអាយុពី ៣ ទៅ ៥ឆ្នាំ ចំនួន ៤៣ភាគរយបានចុះឈ្មោះចូលរៀនក្នុងកម្មវិធីអប់រំកុមារតូច(២០១៧/១៨)



*រូបភាព 37*

កុមារនៅកម្ពុជា នៅបន្តរៀនយឺត ដោយសារមូលហេតុជាច្រើន ដូចជាការពុំបានត្រៀមខ្លួនឱ្យបានគ្រប់គ្រាន់សម្រាប់ចូលរៀន គុណភាពទាបនៃការរៀន និងបង្រៀនដែលកុមារទទួលបាន និងការមករៀនមិនទៀងទាត់។ បញ្ហាទាំងអស់នេះ ទីបំផុតបានធ្វើឱ្យកុមារជាច្រើននាក់បោះបង់ចោលការសិក្សា។

ការរៀនសូត្រមិនគ្រប់គ្រាន់នៅឆ្នាំដំបូងៗ គួបផ្សំនឹងការពុំទទួលបាអាហារូបត្ថម្ភឱ្យបានគ្រប់គ្រាន់ផង ធ្វើឱ្យកុមារជាច្រើននាក់អភិវឌ្ឍខ្លួនយឺតយ៉ាវ។ ចំនួនគ្រូមានសមត្ថភាពមិនគ្រប់គ្រាន់ ហើយគុណភាពនៃបរិស្ថានរៀនសូត្រនៅមានកម្រិតទាប។ លើសពីនេះ ហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋាន ដូចជាបរិក្ខារ អនាម័យ និងទឹកស្អាត នៅខ្វះខាតនៅឡើយ ដែលបង្កផលប៉ះពាល់ជាពិសេសដល់ក្មេងស្រីជំទង់ និងកុមារពិការ។ អំពើហិង្សា ក៏ជាបញ្ហាមួយនៅតាមសាលារៀនផងដែរ ដោយសារតែគ្រូនៅប្រើប្រាស់ការដាក់ទណ្ឌកម្មរាងកាយលើសិស្ស។ កុមារពិការ នៅប្រឈមនឹងការរើសអើង។ ឪពុកម្ដាយជាច្រើននាក់ នៅមិនយល់ពីតម្លៃនៃការអប់រំ ហើយភាគ

ច្រើនពុំមានលទ្ធភាពបញ្ជូនកូនទៅរៀនឡើយ ជាពិសេសនៅតាមតំបន់ជនបទ និងតំបន់ជួបការលំបាក។

ការអប់រំគឺជាការវិនិយោគលើអនាគតកុមារ និងប្រទេសជាតិជារួម មានកុមារី និងកុមារាជាច្រើននាក់ បន្តនៅក្រៅសាលានៅគ្រប់កម្រិតភូមិសិក្សាទាំងអស់ ចាប់ពីកុមារតូច រហូតដល់វ័យជំទង់។ កុមារភាគច្រើន បោះបង់ចោលការសិក្សាមុនពេលឡើងដល់កម្រិតមធ្យមសិក្សា។ កុមារី និងកុមារាមកពីមកគ្រួសារ និងសហគមន៍ងាយរងគ្រោះ នៅមានការលំបាកក្នុងការសម្រេចសក្តានុពលខ្លួន ដោយពួកគេជួបនឹងការប្រឈមជាច្រើនដើម្បីទៅរៀន និងបន្តរៀន។ជាការចាំបាច់ណាស់ ត្រូវមានកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីជួយឱ្យកុមារទៅរៀននិងបន្តរៀនបាន។

**ដំណោះស្រាយ**

ការពង្រឹងភាពជាអ្នកដឹកនាំ គុណភាព និងការបង្រៀន និងការកសាងបរិស្ថានសាលារៀនដែលធ្វើឱ្យកុមារមានសុខភាពល្អ ជួយជំរុញទឹកចិត្តឪពុកម្តាយឱ្យបញ្ជូនកូនៗពួកគេទៅសាលារៀន និងលើកទឹកចិត្តសិស្សឱ្យបន្តរៀនសូត្រ។ យូនីសេហ្វ បន្តកិច្ចសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា និងដៃគូដទៃទៀត ដើម្បីធានាយ៉ាងណាឱ្យកុមារ អាចទៅរៀន និងបន្តរៀនបាន ហើយសំខាន់ជាងនេះទៀតគឺដើម្បីធានាថាពួកគេអាចរៀនសូត្រប្រកបដោយគុណភាព។

ការអប់រំមានសារៈសំខាន់ចំពោះការអភិវឌ្ឍរបស់ប្រទេសកម្ពុជា។ យុទ្ធសាស្ត្រអភិវឌ្ឍន៍របស់ប្រទេសនេះ ផ្តោតការយកចិត្តទុកដាក់លើប្រជាពលរដ្ឋវ័យក្មេង ពោរពេញដោយភាពស្វាហាប់ និងចល័តភាព ដោយចាត់ទុកពួកគេជាអ្នកចូលរួមចំណែកដ៏សំខាន់ដល់ការអភិវឌ្ឍ និងកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព។ រដ្ឋាភិបាលបន្តវិភាជន៍ថវិការដ្ឋ ក្នុងចំនួនមួយដ៏ច្រើនសម្រាប់វិស័យអប់រំ ហើយយូនីសេហ្វ កំពុងប្រើប្រាស់ឱកាសបច្ចុប្បន្ននេះ ដើម្បីធ្វើកំណែទម្រង់វិស័យអប់រំ។

ដើម្បីធានាថាកុមារគ្រប់រូបអាចរៀនសូត្របាន យើងត្រូវផ្តោតការយកចិត្តទុកដាក់លើការលើកកម្ពស់លទ្ធភាពទទួលបានការអប់រំប្រកបដោយសមធម៌ និងបរិយាបន្ន សម្រាប់កុមារពិការ កុមារជនជាតិដើមភាគតិច និងកុមារដែលរស់នៅតំបន់ក្រីក្រនៅជនបទ និងទីប្រជុំជន។

ការអប់រំ ផ្តល់ឱ្យកុមារនូវផ្លូវចាកចេញពីភាពក្រីក្រ និងឆ្ពោះទៅរកអនាគតដែលពោរពេញដោយស្ថិរភាព និងក្តីសង្ឃឹម។



*រូបភាព 38៖ UNICEF Cambodia/2018/Todd Brown*

## លុបបំបាត់ឧបសគ្គរាំងដល់ការទទួលបានការអប់រំ

យូនីសេហ្វ សហការជាមួយរាជរដ្ឋាភិបាល និងដៃគូដទៃទៀត ដើម្បីផ្តល់ឱ្យកុមារគ្រប់រូបនូវលទ្ធភាពទទួលបានការអប់រំប្រកបដោយសមធម៌ និងបរិយាបន្ន។ នេះមានន័យថាយើងលុបបំបាត់នូវឧបសគ្គដែលរាំងមិនឱ្យកុមារអាចទៅរៀនបាន ដូចជាភាពក្រីក្រ ភាពនៅដាច់ស្រយាល ការមាក់ងាយ និងការរើសអើងជាដើម។កាន់តែជាក់លាក់ទៅទៀតនោះ យើងគាំទ្ររាជរដ្ឋាភិបាលដើម្បីផ្តល់៖ អាហារូបករណ៍ដល់កុមារមកពីគ្រួសារក្រីក្រ ដើម្បីឱ្យពួកគេអាចបន្តទៅរៀនបាន ជាជាងបោះបង់ចោលការសិក្សាទៅរកការងារធ្វើ ទទួលបានសេវាអប់រំកុមារតូចប្រកបដោយគុណភាព ជាពិសេសនៅតាមតំបន់ជនបទដាច់ស្រយាល ផ្តល់នូវសម្ភាររូបវន្តក្នុងសាលារៀនដែលកុមារី និងកុមារាទាំងមានពិការភាព ទាំងគ្មានពិការភាព ងាយស្រួលប្រើប្រាស់ សាលារៀនដែលមានបរិក្ខារអនាម័យ និងទឹកស្អាតគ្រប់គ្រាន់ ដើម្បីកុំឱ្យកុមារឈឺដោយសារប្រើប្រាស់ទឹកកខ្វក់ ឬអនុវត្តទម្លាប់គ្មានអនាម័យ ហើយក្មេងស្រីជំទង់មិនបោះបង់ចោលការសិក្សាដោយតែពួកគេពុំអាចរក្សាអនាម័យពេលមករដូវឱ្យបានត្រឹមត្រូវនៅក្នុងសាលារៀន គ្រូអប់រំពហុភាសាដែលមានសមត្ថភាពសម្រាប់សិស្សជនជាតិដើមភាគតិចជាពិសេសនៅខេត្តភាគឦសាន និងគ្រូបង្រៀនដែលមានជំនាញបង្រៀនកុមារពិការ។

ការយកចិត្តទុកដាក់ចំពោះគុណភាពបង្រៀន និងរៀនរួមគ្នាជាមួយរាជរដ្ឋាភិបាល និងដៃគូដទៃទៀត យើងធ្វើការងារដើម្បីបង្កើនគុណភាពអប់រំ ដើម្បីឱ្យកុមារកម្ពុជាអាចចាប់ផ្តើមដំណើរផ្លូវរៀនសូត្រពេញមួយជីវិតបាន។ យើងស្វែងរកការគាំទ្រ ដើម្បីឱ្យមានការវិនិយោគផ្នែកហិរញ្ញវត្ថុដើម្បីឱ្យមានការផ្តល់ការបណ្តុះបណ្តាលកាន់តែល្អប្រសើរដល់គ្រូបង្រៀន ចាប់ពីកម្រិតអប់រំកុមារតូច រហូតដល់កម្រិតមធ្យមសិក្សា។ យុទ្ធនាការកៀងគរ និងការបណ្តុះបណ្តាលរបស់

យើង ជួយជំរុញឱ្យមានការដាក់វិន័យបែបវិជ្ជមាននៅក្នុងថ្នាក់រៀន ដោយពុំចាំបាច់ប្រើប្រាស់ការដាក់ទណ្ឌកម្មលើរាងកាយ ហើយយើងលើកទឹកចិត្តឱ្យអ្នកគ្រប់គ្រងសាលា និងគ្រូបង្រៀនប្រើប្រាស់ការដាក់វិន័យបែបវិជ្ជមានជំនួសឱ្យការប្រើប្រាស់ការដាក់វិន័យបែបហិង្សា។ យើងក៏ជំរុញឱ្យមានការចិញ្ចឹមបីបាច់កូនបែបវិជ្ជមាននៅក្នុងសហគមន៍ផងដែរ។

យើងគាំទ្រក្រសួងអប់រំ យុវជន និងកីឡា ក្នុងការកែសម្រួលកម្មវិធីសិក្សាជាតិ រួមទាំងកម្មវិធីសិក្សាលម្អិត ស្តង់ដានៃការរៀនសូត្រ ការបណ្តុះបណ្តាលគ្រូ និងសៀវភៅសិក្សា ដើម្បីឱ្យមានការបញ្ចូលបំណិនសតវត្សរ៍ទី២១ ទៅក្នុងប្រព័ន្ធអប់រំរបស់កម្ពុជា។ អាទិភាពមួយ ក្នុងចំណោមអាទិភាពសំខាន់ៗរបស់យើង គឺបញ្ចូលសុខភាព អាហារូបត្ថម្ភ និងបំណិនជីវិតទៅក្នុងកម្មវិធីសិក្សា ដើម្បីឱ្យក្មេងជំទង់អាចរៀនសូត្រពីរបៀបក្លាយខ្លួនទៅជាមនុស្សពេញវ័យ ដែលមានសុខភាពល្អ មានសមត្ថភាព និងប្រកបដោយការទទួលខុសត្រូវ។

ការសាងភាពជាអ្នកដឹកនាំ និងផ្តល់ការគាំទ្រចាប់ពីកម្រិតរដ្ឋាភិបាល រហូតដល់កម្រិតសហគមន៍ បរិយាកាសអំណោយផលដែលផ្តល់នូវការជួយជ្រោមជ្រែង មានសារៈសំខាន់យ៉ាងខ្លាំង ដើម្បីបង្កើតជំនាន់យុវវ័យកម្ពុជាមួយដែលអាចក្លាយទៅជាសមាជិកដ៏សកម្មនៅក្នុងសហគមន៍។ដោយមានការចូលរួមពីដៃគូរបស់យើង យើងធ្វើការងារដើម្បីកសាងភាពជាអ្នកដឹកនាំ និងគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពដល់មន្ត្រីរាជរដ្ឋាភិបាល និងមន្ត្រីអប់រំ។ យើងផ្តល់ការបណ្តុះបណ្តាលបច្ចេកទេស ដើម្បីឱ្យមន្ត្រីអាចរៀបចំថវិកា និងរៀបចំផែនការ ដើម្បីបង្កើតនូវសេវាអប់រំដែលមានគុណភាព បរិយាបន្ន សមធម៌ និងឆ្លើយតប ហើយយើងគាំទ្រឱ្យអ្នកគ្រប់គ្រងសាលារៀន និងគ្រូបង្រៀនចេះរៀបចំផែនការ និងបែងចែកធនធានរបស់ពួកគេឱ្យកាន់តែមានប្រសិទ្ធភាព។ប៉ុន្តែយើងក៏ដឹងផងដែរថា វឌ្ឍនភាពពិតប្រាកដកើតចេញពីការជំរុញឱ្យមានការចូលរួមពីគ្រួសារ និងសហគមន៍ ដូច្នេះហើយបានជាយើងធ្វើការងារជាមួយនឹងសមាជិកនៃគណៈកម្មការទ្រទ្រង់សាលារៀន ដើម្បីជំរុញឱ្យមានការផ្តល់ការអប់រំដល់គ្រួសារ និងគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់សហគមន៍ ដើម្បីលើកទឹកចិត្តដល់ឪពុកម្តាយឱ្យផ្តល់តម្លៃដល់ការអប់រំ។ យើងធ្វើបែបនេះ ក្នុងគោលបំណងជំរុញឱ្យមានតម្រូវការសេវាអប់រំ ដើម្បីឱ្យកុមារី និងកុមារាកាន់តែទទួលបានការជួយជ្រោមជ្រែងពីឪពុកម្តាយ និងសហគមន៍របស់ពួកគេ ដែលអាចឱ្យពួកគេអាចចូលរៀននិងបញ្ចប់ការអប់រំកុមារតូចនិងការអប់រំកម្រិតបឋមសិក្សាបាន។

## ប្រព័ន្ធអប់រំនៅប្រទេសសិង្ហបុរី

ប្រព័ន្ធអប់រំនៅសិង្ហបុរីត្រូវបានគ្រប់គ្រងទាំងស្រុងដោយក្រសួងអប់រំសិង្ហបុរី ដែលមានតួនាទីគ្រប់គ្រងនូវការអភិវឌ្ឍសាលារបស់រដ្ឋនិងទទួលហិរញ្ញប្បទានពីរដ្ឋាភិបាល។ លើសពីនេះទៅទៀត ក្រសួងអប់រំក៏នៅមានតួនាទីជាទីប្រឹក្សានិងតាមដានសាលាឯកជនដទៃទៀតផងដែរ។



*រូបភាព 39*

ប្រព័ន្ធអប់រំចែកចេញជា ៣កម្រិត កម្រិតបឋមសិក្សា (ចាំបាច់) កម្រិតមធ្យមសិក្សា និងកម្រិតត្រៀមមហាវិទ្យាល័យ។ សិស្សចូលសាលាបឋមនៅអាយុ៦ឆ្នាំ បឋមសិក្សាមានរយៈពេល៦ឆ្នាំ ចែកចេញជា២ផ្នែកៈ ៤ឆ្នាំដំបូងជាថ្នាក់មូលដ្ឋាន និង ២ឆ្នាំទៀតជាថ្នាក់តំរង់ទិស។ កម្មវិធីសិក្សាសង្កត់ធ្ងន់លើមុខវិជ្ជាស្តង់ដា ៤គឺ ភាសាអង់គ្លេស ភាសាកំណើត គណិតវិទ្យា និងវិទ្យាសាស្ត្រ។

កម្រិតមធ្យមសិក្សាមានរយៈពេលពី៤ទៅ៥ឆ្នាំ ដោយចែកចេញជា៤ប្រភេទ (តាមកំរិតសមត្ថភាពរបស់សិស្ស)៖ ជាពិសេស "អិចស្រ្ពេស" ធម្មតា(សិក្សាធិកា) និងធម្មតា (បច្ចេកទេស)។ កម្រិតត្រៀមមហាវិទ្យាល័យមានរយៈពេលពី ២ទៅ៣ឆ្នាំ។

ខាងក្រោមនេះជាមូលហេតុមួយចំនួនដែលប្រព័ន្ធអប់រំនៅប្រទេសសិង្ហបុរីល្អជាងប្រទេសដទៃ។

**សិស្សខ្សោយ៖** សិង្ហបុរីមានប្រព័ន្ធអប់រំមួយហៅថា "តម្រូវការពិសេស" ដែលមានន័យថាការផ្តល់ជំនួយបន្ថែមដល់សិស្សទាំងឡាយណាដែលតាមមិនទាន់មេរៀនឬតាមមិនទាន់នឹងមិត្តភក្តិរបស់ពួកគេ និងសិស្សដែលមានការលំបាកក្នុងការស្តាប់ និយាយ និងគណនាលេខជាដើម។ គ្មានសិស្សណាម្នាក់ត្រូវបានបោះបង់ប្រសិនជាពួកគេមិនបោះបង់ខ្លួនឯង។

**សិស្សខ្លាំង៖** សម្រាប់សិស្សដែលខ្លាំងវិញ សិង្ហបុរីមានប្រព័ន្ធអប់រំមួយហៅថា "ថ្នាក់សម្រាប់សិស្សដែលមានទេពកោសល្យ" ដែលផ្តល់ឱ្យដល់សិស្សដែលពូកែដែលមានសមត្ថភាព និងបង្រៀនពួកគេឱ្យចេះប្រើប្រាស់សមត្ថភាពឱ្យដល់កម្រិតកំពូល។

**ការប្រលងចេញពីសាលាបឋមសិក្សា៖** ក្រោមសិស្សបញ្ចប់កម្រិតបឋម សិស្សទាំងអស់តម្រូវឱ្យប្រលងវិញ្ញាសារមួយហៅថា PSLE (primary school leaving examination) មុនពេលពួកគេអាចទៅរៀននៅថ្នាក់អនុវិទ្យាល័យបាន។ សិស្សជាច្រើនមានសម្ពាធ និងខិតខំប្រឹងប្រែងណាស់សម្រាប់ការប្រលងមួយនេះ៕



*រូបភាព 40*

## សន្និដ្ឋាន

ប្រៀបធៀបការអប់រំអន្តរជាតិ គឺជាវិស័យអប់រំដែលវិភាគលើប្រព័ន្ធអប់រំ នៃប្រទេសមួយដោយប្រើទិន្នន័យនិងប្រព័ន្ធពីប្រទេសដទៃទៀតនិងរៀបចំគោលនយោបាយ ដើម្បីលើកម្ពស់ការអប់រំ។

ប្រៀបធៀបប្រព័ន្ធអប់រំនៃប្រទេសអភិវឌ្ឍន៍និងប្រទេសកំពុងអភិវឌ្ឍដើម្បីកំណត់បញ្ហាប្រឈមមួយចំនួនដែលអ្នកសិក្សាប្រៀបធៀបបានជួបនៅក្នុងដំណើរការនៃវិស័យអប់រំអំពីប្រទេសដទៃទៀតរួចឆ្លុះបញ្ចាំងមកប្រទេសរបស់ខ្លួនចូលរួមជួយអភិវឌ្ឍឱ្យដើរទាន់គ្នាក្នុងសតវត្សរ៍ទី ២១ ។

## សំណួរ

១.តើការប្រៀបធៀបការអប់រំគឺជាអ្វី ?ហើយមានគោលបំណងដូចម្តេច ?

២.ចូររៀបរាប់ពីសារៈសំខាន់នៃការប្រៀបធៀបការអប់រំអន្តរជាតិ។

៣.តើប្រៀបធៀបការអប់រំអន្តរជាតិមានបញ្ហាប្រឈមអ្វីខ្លះ ?

## មេរៀនទី៧ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០១៩-២០២៣(ផ្នែក១)

### ចំណុចបំណង

- កំណត់បានពីវិស័យសំខាន់ៗសម្រាប់ផែនការយុទ្ធសាស្ត្រអប់រំឆ្នាំ២០១៩-២០២៣
- តម្រឹមការអនុវត្តការបង្រៀននិងទសន្សវិជ្ជារបស់ពួកគេតាមផែនការយុទ្ធសាស្ត្របច្ចុប្បន្ន

### ៧.១. សេចក្តីផ្តើម

ផែនការយុទ្ធសាស្ត្រអប់រំ២០១៩-២០២៣ ត្រូវបានរៀបចំឡើងក្នុងគោលដៅបន្តអនុវត្តកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា និងបង្កើតមូលដ្ឋានរឹងមាំសម្រាប់ឆ្ពោះទៅឆ្នាំ២០២៣ស្តីពីការអប់រំនៅកម្ពុជា។ ដើម្បីឆ្លើយតបទៅនឹងចក្ខុវិស័យអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា និងកម្មវិធីកំណែទម្រង់រៀននិងបង្រៀន។

### ៧.២. និយមន័យ

ផែនការយុទ្ធសាស្ត្រវិស៧យអប់រំឆ្នាំ២០១៩-២០២៣គឺជាផែនការដែលរៀបចំដោយក្រសួងអប់ក្នុងគោលបំណងដើម្បីធានាបាននូវការលើការអភិវឌ្ឍវិស័យអប់រំឱ្យកាន់តែមានភាពសុក្រិត និងជឿទុកចិត្តបាន ជាពិសេសមានមូលដ្ឋានដ៏រឹងមាំ គ្រប់ជ្រុងជ្រោយ ច្បាស់លាស់ ត្រឹមត្រូវនិងមានភាពប្រទាក់ប្រឡាគ្នារវាងគោលនយោបាយអប់រំជាតិនិងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០ស្តីពីការអប់រំនៅកម្ពុជា។(ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួនណារ៉ុន ២០១៨)

### ៧.៣.គោលបំណងនៃការសិក្សា

ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ ត្រូវបានរៀបចំឡើងក្នុងគោលដៅបន្តអនុវត្តកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា និងបង្កើតមូលដ្ឋានរឹងមាំសម្រាប់ឆ្ពោះទៅឆ្នាំ២០៣០ ស្តីពីការអប់រំនៅកម្ពុជា។

ដើម្បីឆ្លើយតបទៅនឹងចក្ខុវិស័យអភិវឌ្ឍ សេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា និងកម្មវិធីកំណែទម្រង់នានារបស់រដ្ឋាភិបាលកម្ពុជា។

### ៧.៤.កំណែទម្រង់សំខាន់ៗនៅក្នុងផែនការយុទ្ធសាស្ត្រអប់រំសម្រាប់ឆ្នាំ២០១៩-២០២៣

ការធានាបាននូវសន្តិភាពនៃកំណែទម្រង់គោលនយោបាយអប់រំថ្នាក់ជាតិ កំណែទម្រង់ការបណ្តុះបណ្តាលគ្រូ និងកំណែទម្រង់កម្រិតសាលារៀន(ការអនុវត្តនូវគោលនយោបាយអប់រំកម្រិតជាតិការងនុវត្តកំណែទម្រង់គ្រូតាមសាលាគរុកោសល្យនិងការអនុវត្តកំណែទម្រង់សាលារៀន)

អទិភាពកំណែទម្រង់គោលនយោបាយក្នុងក្របខណ្ឌសរសរស្តម្ភទាំង៥ ការអនុវត្តផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន ការពិនិត្យឡើងវិញកម្មវិធីសិក្សា សៀវភៅសិក្សាគោល កែកម្មបរិស្ថានសិក្សា ការដាក់ឱ្យអនុវត្តអធិការកិច្ច ការពង្រឹងវង្វាយតម្លៃសិក្សាដូចជា ការប្រលង វង្វាយតម្លៃថ្នាក់ជាតិ តំបន់និងអន្តរជាតិ និងការកែតម្រង់ឧត្តមសិក្សា។

យុទ្ធសាស្ត្រកំណែទម្រង់គ្រប់គ្រងអប់រំ ការគ្រប់គ្រងការសិក្សា ការគ្រប់គ្រងរដ្ឋបាល ការគ្រប់គ្រងហិរញ្ញវត្ថុ និងការគ្រប់គ្រងធនធានមនុស្ស។

កំណែទម្រង់ការអប់រំគ្រូនៅតាមសាលាគរុកោសល្យ(ការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀននិងមជ្ឈមណ្ឌលអប់រំគ្រូបង្រៀន)។

កំណែទម្រង់សាលារៀន(បង្កើតសាលាជំនាន់ថ្មី បង្កើតសាលាគម្រូ និងការលើកទឹកចិត្តឱ្យអនុវត្តការគ្រប់គ្រងសាលាតាមគ្រឹះស្ថានសិក្សាដែលមានលក្ខខណ្ឌសមស្រប)។

កំណែទម្រង់ការអភិវឌ្ឍយុវជន(ផ្តល់ឱកាស លើកទឹកចិត្តឱ្យចូលរួមគ្រប់សកម្មភាព)។

កំណែទម្រង់ការអភិវឌ្ឍវិស័យអប់រំកាយនិងកីឡា(ការអភិវឌ្ឍវិស័យអប់រំកាយនិងកីឡានៅគ្រឹះស្ថានសិក្សាគ្រប់កម្រិត និងសហគមន៍ អភិរក្ស និងអភិវឌ្ឍន៍វិស័យកីឡា គ្រប់ប្រភេទ)។

ការលើកកម្ពស់ការអប់រំតាមបែបឌីជីថលបញ្ច្រៀបបច្ចេកវិទ្យាព័ត៌មាននិងសហគមន៍ប្រើប្រាស់ការរៀនសូត្រតាមប្រព័ន្ធអេឡិចត្រូនិច(E-Learning)...។

ការបញ្ជ្រៀបយេនឌ័រក្នុងវិស័យអប់រំ(ផ្តល់សេវាអប់រំ និងគ្រប់គ្រងដឹកនាំដោយផ្តោតលើការយកចិត្តទុកដាក់ជានាឱ្យកុមារា និងកុមារី បានទទួលលទ្ធចូលរៀនដោយពេញលេញនិងស្មើរភាពគ្នា...)។

កំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ(ពង្រឹងស្វ័យភាពនិងការទទួលខុសត្រូវ ឱ្យរបស់រដ្ឋបាលថ្នាក់ជាតិ និងគ្រឹះស្ថានសាធារណៈតាមរយៈការផ្ទេរនូវមុខងារនិងធនធាននានាដល់ពួកគេសំដៅធ្វើឱ្យប្រសើរឡើងនូវគុណភាព តម្លាភាព សមធម៌និងគណនេយ្យភាពក្នុងការផ្តល់សេវាដែលមានគុណភាពជូនប្រជាជន)

**សន្និដ្ឋាន**

ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០១៩ ដល់ ២០២៣ គឺជាផែនការដែលរៀបចំដោយក្រសួងអប់រំក្នុងគោលបំណងដើម្បីធានាបាននូវ លើការអភិវឌ្ឍវិស័យអប់រំឱ្យកាន់តែមានភាពសុក្រឹតនិងជឿទុកចិត្តជាពិសេសមានមូលដ្ឋានដ៏រឹងមាំ គ្រប់ជ្រុងជ្រោយ ច្បាស់លាស់ ត្រឹមត្រូវ និងមានភាពប្រទាក់ក្រឡាគ្នារវាងគោលនយោបាយអប់រំជាតិនិងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០២៣ស្តីពីការអប់រំនៅកម្ពុជា ។

មេរៀននេះផ្តោតលើផែនការយុទ្ធសាស្ត្រអប់រំរបស់កម្ពុជាសម្រាប់ឆ្នាំ ២០១៩-២០២៣ ។ បន្ទាប់ពីសិក្សាមេរៀនទាំងនេះគរុនិស្សិតនឹងដឹងថាតើសកម្មភាពសំខាន់ៗអ្វីខ្លះនៅក្នុងកំណែទម្រង់វិស័យអប់រំនៅក្នុងអាណត្តិរដ្ឋាភិបាលបច្ចុប្បន្ន។ មេរៀននេះនឹងជួយផ្តល់នូវចំណេះដឹងដល់គរុនិស្សិតនូវក្របខណ្ឌសម្រាប់ការអនុវត្តការបង្រៀន និងរៀនរបស់សិស្ស។

**សំណួរ**

១.តើកំណែទម្រង់សំខាន់ៗនៅក្នុងផែនការយុទ្ធសាស្ត្រអប់រំសម្រាប់ឆ្នាំ ២០១៩-២០២៣ មានអ្វីខ្លះ?

## មេរៀនទី៨ ផែនការយុទ្ធសាស្ត្រចក្ខុវិស័យអប់រំឆ្នាំ២០១៩_២០២៣(ផ្នែកទី២)

### វត្ថុបំណង

បន្ទាប់ពីរៀនមេរៀននេះចប់គរុនិស្សិតនឹងៈ

- កំណត់បានពីវិស័យសំខាន់ៗសម្រាប់ផែនការយុទ្ធសាស្ត្រអប់រំសម្រាប់ឆ្នាំ ២០១៩-២០២៣ ។
- រៀបរាប់បានពីគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០ ស្តីការអប់រំនៅកម្ពុជា
- ការអនុវត្តការបង្រៀននិងទស្សនវិជ្ជារបស់ពួកគេតាមផែនការយុទ្ធសាស្ត្របច្ចុប្បន្ន

### ៨.១.សេចក្តីផ្តើម

ផែនការយុទ្ធសាស្ត្រអប់រំរបស់កម្ពុជាសម្រាប់ឆ្នាំ ២០១៩-២០២៣ ។ បន្ទាប់ពីសិក្សាមេរៀនទាំងនេះគរុនិស្សិតនឹងដឹងថាតើសកម្មភាពសំខាន់ៗអ្វីខ្លះនៅក្នុងកំណែទម្រង់វិស័យអប់រំនៅក្នុងអាណត្តិរដ្ឋាភិបាលបច្ចុប្បន្ន។ មេរៀននេះនឹងជួយផ្តល់នូវចំណេះដឹងដល់សិស្ស និង ក្របខ័ណ្ឌសម្រាប់ការអនុវត្តការបង្រៀននិងការអនុវត្តការរៀនរបស់សិស្ស។

*រូបភាព 41*

### ៨.២.គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពសម្រាប់ឆ្នាំ២០៣០

ដើម្បីសម្រេចតាមគោលដៅនេះ ក្រសួងអបរំ យុវជន និងកីឡា បានអនុម័តផែនទីបង្ហាញផ្លូវគោលដៅអភិវឌ្ឍន៍ប្រ កបដោយចីរភាព ស្តីពីការអបរំនៅកម្ពុជានៅដើមឆ្នាំ២០១៩ ដើម្បីធានាឱ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា។

ផែនទីបង្ហាញផ្លូវនេះបានកំណត់អទិភាពគោលនយោយអប់រំធំៗចំនួនប្រាំគឺៈ

- កុមារគ្រប់រូបទទួលបានការគាំពារ និងការអភិវឌ្ឍន៍កុមារតូច ការអប់រំកម្រិតមតេយ្យសិក្សា ការបញ្ចប់ការអប់រំកម្រិត មូលដ្ឋានដោយឥតបង់ថ្លៃនៅកម្រិតបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ ដោយទទួលបានលទ្ធផលសិក្សាប្រកប ដោយគុណភាព ប្រសិទ្ធភាព សមធម៌ និង ភាពឆ្លើយតប។

- កុមារគ្រប់រូបទទួលបានការគាំពារ ការអប់រំកុមារតូចតាមរយៈ ការចូលរៀននៅកម្រិតបឋម កម្រិតមូលដ្ឋានដោយឥតបង់ថ្លៃសេវា
- កុមារនិងយុវជនគ្រប់រូបបញ្ចប់ការសិក្សាត្រឹមកម្រិតមធ្យមសិក្សាទុតិយភូមិ ការអប់រំបច្ចេកទេស និងវិជ្ជាជីវៈនិងឧត្តមសិក្សាចំណេះជំនាញបច្ចេកទេសប្រកបដោយគុណភាព និងអាចឆ្លើយតប បាន។
- ធានាឱ្យអ្នកសិក្សាគ្រប់រូបមានលទ្ធភាពស្មើគ្នា ក្នុងការទទួលបានការអប់រំជំនាញ បច្ចេកទេស វិជ្ជាជីវៈ និងកម្រិតឧត្តមសិក្សាប្រកបដោយគុណភាព
- យុវជន និងមនុស្សពេញវ័យត្រូវតែមានចំណេះដឹង លើអក្ខរកម្ម គណនាលេខនព្វន្តនិងមាន ឱកាសកាន់តែច្រើនក្នុងការសិក្សាពេញមួយជីវិត។
- អភិបាលកិច្ច និងការគ្រប់គ្រងវិស័យអប់រំមានភាពប្រសើរជាងមុននិងធានាបាននូវគុណភាព អប់រំ។

ការអប់រំសម្រាប់ទាំងអស់គ្នាជាគោលដៅរួមរបស់ពិភពលោកក្នុងការលុបបំបាត់អនក្ខរភាពនៅ សហវត្សថ្មីនិងដើម្បីធានាបាននូវការអប់រំប្រកបដោយនិរន្តរភាព(គោលដៅអភិវឌ្ឍសហសវត្ស របស់អង្គការសហប្រជាជាតិ ក្រោយឆ្នាំ២០១៥)។ ជាមួយគ្នានេះសហគមន៍អាស៊ាន(២០១៥) បានផ្តោតទៅលើសហគមន៍សេដ្ឋកិច្ចក្នុងនោះរួមមាន លំហូរ សេវាកម្ម កម្លាំងពលកម្ម និងធនធាន មនុស្ស(យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ដើម្បីរីកចម្រើន ការងារ សមធម៌ និងប្រសិទ្ធភាព រាជរដ្ឋាភិបាលកម្ពុជាឆ្នាំ២០១៣)។ ដូច្នេះរាជរដ្ឋាភិបាលបានដាក់ចេញនូវគោលដៅអភិវឌ្ឍជាតិ ឆ្នាំ២០៣០ និង២០៥០ និងយុទ្ធសាស្ត្រ ចតុកោណ ដំណាក់កាលទី៤ ដើម្បីឆ្ពោះទៅឆ្នាំ២០៣០ និង២០៥០ ជាមួយនឹងយុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា ឆ្នាំ២០១៨-២០២៣ ក្នុងគោលដៅចូលរួមអភិវឌ្ឍវិស័យអាទិភាពនានារបស់ប្រទេសកម្ពុជា។ដើម្បីឆ្លើយតបនិន្នាការអប់រំ ពិភពលោក និងតំបន់ រាជរដ្ឋាភិបាលកម្ពុជាដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណដែលក្នុងនោះមុំទី៤ បានផ្តោតទៅលើការកសាងសមត្ថភាព និងអភិវឌ្ឍធនធានមនុស្ស ជាពិសេសយុវជន ឱ្យក្លាយ ទៅ ជាពលរដ្ឋពេញលេញមានជំនាញវិជ្ជាជីវៈច្បាស់លាស់ សម្រាប់រួមចំណែកលើកកម្ពស់សេដ្ឋកិច្ច ជាតិពីប្រទេសដែលមានចំណូលមធ្យមកម្រិតទាបនាពេលបច្ចុប្បន្នទៅជាប្រទេសដែលមាន ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ (ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៩-២០២៣ ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០១៩)។

លើសនេះទៅទៀតត្រឹមឆ្នាំ២០៥០ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវគោលដៅអភិវឌ្ឍ ជាតិ ដើម្បី កំណើនការងារ សមធម៌ និងប្រសិទ្ធភាព ក្នុងន័យកសាងមូលដ្ឋានឆ្ពោះទៅសម្រេច ចក្ខុវិស័យកម្ពុជាក្នុងគោលបំណង ប្រែក្លាយប្រទេស ឱ្យក្លាយជាប្រទេសដែល មានចំណូលខ្ពស់ និង ជាប្រទេសអភិវឌ្ឍ។ដើម្បីសម្រេចបាននូវគោលដៅអភិវឌ្ឍជាតិនេះបាន ចតុកោណទី១នៃយុទ្ធ សាស្ត្រចតុកោណដំណាក់កាលទី៤ ផ្តោតលើការអភិវឌ្ឍធនធានមនុស្ស ត្រូវបានចាត់ទុកជាអាទិ ភាពនៃការអនុវត្ត យុទ្ធសាស្ត្រចតុកោណនៅគ្រប់ដំណាក់កាល, ពិសេសបានក្លាយជាអាទិភាពទី ១

នៅក្នុងដំណាក់កាលទី ៣ និង ទី ៤ នេះ,សំដៅលើកកម្ពស់ចំណេះដឹងជំនាញ វិជ្ជាជីវៈ សមត្ថភាព សហគ្រិនភាព ការច្នៃប្រឌិត នវានុវត្តន៍ គុណធម៌ សីលធម៌ មនសិការស្នេហាជាតិ និង ស្មារតី ទទួលខុសត្រូវ , សុខភាពល្អ និង កាយសម្បទា រឹងមាំ, តួនាទីស្ត្រី និង កិច្ចគាំពារសង្គម។ ក្នុងន័យនេះ, ការអភិវឌ្ឍធនធានមនុស្ស ក្នុងនីតិកាលទី ៦ នឹងបន្តផ្តោតលើ : ១). ការពង្រឹងគុណភាពវិស័យអប់រំ វិទ្យាសាស្ត្រ និង បច្ចេកវិទ្យា;២). ការបណ្តុះបណ្តាលជំនាញបច្ចេកទេស ៣). ការលើកកម្ពស់សេវាសុខភាពសាធារណៈ និង អាហារូបត្ថម្ភ និង ៤). ការពង្រឹង សមភាពយេនឌ័រនិងការគាំពារសង្គម។ ក្នុងន័យនេះក្រសួងអប់រំយុវជន និងកីឡា បានផ្តោតសំខាន់ លើមុំទី១ ស្តីពីការពង្រឹងគុណភាពវិស័យអប់រំ វិទ្យាសាស្ត្រនិងបច្ចេកវិទ្យានិងមុំទី២ស្តីពីការ បណ្តុះបណ្តាលជំនាញបច្ចេកទេសដើម្បីសម្រេចបានយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ឆ្នាំ២០៥០ក្នុងការប្រែក្លាយប្រទេសកម្ពុជាឱ្យទៅជាប្រទេសអភិវឌ្ឍ(យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដើម្បីកំណើនការងារសមធម៌ និងប្រសិទ្ធភាពកសាងមូលដ្ឋានឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ រាជរដ្ឋាភិបាលកម្ពុជាឆ្នាំ២០១៨)។

យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៤របស់រាជរដ្ឋាភិបាលនីតិកាលទី៦នៃរដ្ឋសភា បានចាត់ទុកថា កាអភិវឌ្ឍធនធានមនុស្សជាអាទិភាពទី១។ រាជរដ្ឋាភិបាលកម្ពុជានឹងធ្វើឱ្យប្រទេសកាន់របបប្រជាធិបតេយ្យសេរីពហុបក្ស គោរពសិទ្ធិនិងសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ ជាសង្គមមួយមានមនុស្ស ប្រកបដោយចំណេះដឹង បទពិសោធ មានជីវភាពសមរម្យមានសុខភាពល្អ។ រាជរដ្ឋាភិបាលនឹងធ្វើឱ្យប្រទេសកម្ពុជាសម្រេចបានជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់ត្រឹមឆ្នាំ២០៣០ និងជាប្រទេសដែលមានចំណូលខ្ពស់និងជាប្រទេសអភិវឌ្ឍត្រឹមឆ្នាំ ២០៥០នេះ។ក្នុងរយៈពេល ៥ ឆ្នាំនៃការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៤-២០១៨ក្រសួងនិងដៃគូអភិវឌ្ឍបានរួមគ្នាសម្រេចកិច្ចការធំៗគួរឱ្យកត់សម្គាល់តាមរយៈការអនុវត្តវិធានការកំណែទម្រង់ ៨ចំណុចនៅឆ្នាំ ២០១៤ និងវិធានការកែទម្រង់ ១៥ ចំណុចពីឆ្នាំ២០១៥ ដល់ ២០១៨ ជាពិសេសសិស្សខិតខំរៀនសូត្រជាងមុន និងគ្រូបង្រៀនខិតខំបំពេញការងារល្អប្រសើរជាងមុន។ ដំណាក់កាលបន្ទាប់គឺបន្តពង្រឹងការគ្រប់គ្រងសាលារៀននិងសមិទ្ធកម្មនៃការអនុវត្តកម្មវិធីអប់រំគ្រប់រូបភាព។

ក្នុងអាណត្តិទី ៦នេះសម្តេចតេជោនាយករដ្ឋមន្ត្រីបានដាក់ចេញយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាល ទី៤ ដោយបានចាត់ទុកថាការអភិវឌ្ឍធនធានមនុស្សជាអាទិភាពទី១។ ក្រសួងអប់រំយុវជន និង កីឡានឹងប្តេជ្ញាសម្រេច ឱ្យ បាននូវមុំទី១ស្តីពី "ការពង្រឹងគុណភាពអប់រំ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា" ដោយផ្តល់អាទិភាពលើ១.ការយកចិត្តទុកដាក់លើគ្រូបង្រៀន២.ការពង្រីកវិសាលភាពសាលារៀនគ្រប់ កម្រិត ៣.ការពង្រឹងអធិការកិច្ចគ្រប់ជ្រុងជ្រោយ លើការគ្រប់គ្រងសាលារៀន ៤.ការជំរុញការអប់រំបច្ចេកទេសនៅមធ្យមសិក្សាទុតិភូមិ ៥.ការអប់រំបំណិនឱ្យស្របតាមទីផ្សារការងារ៦.ការអភិវឌ្ឍកម្មវិធីសិក្សានិងសៀវភៅសិក្សាគោលគ្រប់ជ្រុងជ្រោយ ៧.ការត្រៀមប្រកួតកីឡាស៊ីហ្គេម ឆ្នាំ ២០២៣ (ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៩-២០២៣ ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ ២០១៩)។ក្រសួងអប់រំ យុវជននិងកីឡាបានធ្វើមូលដ្ឋានីយកម្មគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរ

ភាពស្តីពីការអប់រំ ឆ្នាំ ២០៣០ និងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ ដែលមានគោលនយោបានពីរគឺ ១.ធានាឱ្យការ អប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាបន្ននិងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ ទាំងអស់គ្នានិង២.ធានាភាពសាកសិទ្ធនៃភាពជាអ្នកដឹកនាំនិងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ ។ ដើម្បីគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី ៤ និងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ ក្រសួងអប់រំ យុវជន និងកីឡាបានដាក់ចេញនូវយុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡាចំនួន ៤ រួមមាន៖ យុទ្ធសាស្ត្រកំណែទម្រង់ការគ្រប់គ្រងអប់រំ យុទ្ធសាស្ត្រកំណែទម្រង់ឧត្តមសិក្សា យុទ្ធសាស្ត្រកំណែទម្រង់ការអភិវឌ្ឍយុវជន និងយុទ្ធសាស្ត្រកំណែទម្រង់ការអភិវឌ្ឍវិស័យអប់រំកាយនិងកីឡា។ ដើម្បីសម្រេចបាននូវការអភិវឌ្ឍធនធានមនុស្ស ក្រសួងអប់រំ យុវជន និងកីឡា បានជ្រើសរើសយកយុទ្ធសាស្ត្រទី១អំពីកំណែទម្រង់ការគ្រប់គ្រងអប់រំជាមួយនឹងសកម្មភាពកំណែទម្រង់ ៤ យ៉ាងដូចខាងក្រោម៖

- កំណែទម្រង់ការគ្រប់គ្រងការសិក្សា ផ្តោតលើរង្វាយតម្លៃការសិក្សារបស់សិស្សជាប្រចាំការកែលម្អ វិធីសាស្ត្របង្រៀននិងការដាក់បញ្ចូលភាពជាពលរដ្ឋមានគុណភាពក្នុងកម្មវិធីសិក្សានិងសៀវភៅសិក្សាគោល
- កំណែទម្រង់ការគ្រប់គ្រងរដ្ឋបាល ផ្តោតលើការធានាការចូលរួមរបស់មាតាបិតាសិស្ស និងសហគមន៍មូលដ្ឋានការអនុវត្តការគ្រប់គ្រងតាមសាលារៀននិងការអនុវត្តគោលនយោបាយការអប់រំនិងផែនការយុទ្ធសាស្ត្រវិស័យអប់រំ
- កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុផ្តោតលើការបង្កើនស្វ័យភាពគណនេយ្យភាពហិរញ្ញវត្ថុនៅសាលារៀន ការធ្វើសវនកម្មពីការអប់រំជាទៀងទាត់ និងការបង្កើនការបែងចែកថវិកាផ្សារភ្ជាប់និងគោលនយោបាយអប់រំ
- កំណែទម្រង់ការគ្រប់គ្រងធនធានមនុស្ស ផ្តោតលើការបណ្តុះបណ្តាលដោយផ្តោតលើ វិធីសាស្ត្របង្រៀន និងកម្មវិធីបំប៉ននៅនឹងកន្លែង ការបង្កើនការបណ្តុះបណ្តាលគ្រូបង្រៀន និងការអនុវត្តការវាយតម្លៃការបំពេញការងាររបស់បុគ្គលិកអប់រំ។

ដើម្បីគាំទ្រដល់ការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣និងយុទ្ធសាស្ត្រកំណែទម្រង់ការគ្រប់គ្រងអប់រំ យុវជន និងកីឡារាជរដ្ឋាភិបាលនឹងបង្កើនការគាំទ្រលើក្រសួងអប់រំ យុវជន និងកីឡាតាមរយៈការផ្តល់ហិរញ្ញប្បទានដៃគូអភិវឌ្ឍធំៗចំនួន៧ដូចជា៖កម្មវិធីអភិវឌ្ឍវិស័យអប់រំនៅមធ្យមសិក្សាទុតិយភូមិគម្រោងកែលម្អការអប់រំនៅមធ្យមសិក្សាមូលនិធិភាពជាដៃគូអប់រំសកលទី៣ មូលនិធិភាពជាដៃគូសម្រាប់អភិវឌ្ឍសមត្ថភាព ដំណាក់កាលទី ៣ គម្រោងកែលម្អបរិស្ថានសាលារៀននិងការផ្គត់ផ្គង់សម្ភារៈបរិក្ខារអប់រំ នៅកម្ពុជា គម្រោងកែលម្អការអប់រំនៅឧត្តមសិក្សា ។រាជរដ្ឋាភិបាលកម្ពុជា មានចក្ខុវិស័យប្រែក្លាយកម្ពុជាឱ្យទៅជាប្រទេសដែលមានចំណូលមធ្យម កម្រិត ខ្ពស់នៅឆ្នាំ២០៣០ និងចំណូលខ្ពស់នៅឆ្នាំ២០៥០។ ការធានាសម្រេចចក្ខុវិស័យនេះ ទាមទារ ឱ្យមានកម្លាំង ពលកម្មប្រកបដោយគុណសម្បទាកម្រិត

ខ្ពស់ រួមមានវិជ្ជាសម្បទា បំណិនសម្បទា និង ចរិយាសម្បទាដែល ឆ្លើយតបទៅនឹងទីផ្សារការងារក្នុងសតវត្សរ៍ទី២១។ គ្រូបង្រៀន គណៈគ្រប់គ្រង សាលារៀន និងអ្នកឯកទេសអប់រំ ជាកម្លាំងចលករជួរមុខ មិនអាចខ្វះបាន ក្នុងការផលិតមូលធនមនុស្សដែលជាកម្លាំងពលកម្មសកម្ម និងមាន ផលិតភាពសេដ្ឋកិច្ចខ្ពស់ សម្រាប់ជានាកំណើនសេដ្ឋកិច្ចនិងការអភិវឌ្ឍប្រកបដោយចីរភាព។ការស្រាវជ្រាវជាសកលបញ្ជាក់ថា កំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍរបស់ជាតិមួយ គឺពឹងផ្អែកជាចម្បងលើគុណភាពនៃកម្មវិធីសិក្សា និងគ្រូបង្រៀន។ ដូច្នេះ ជោគជ័យនៃការជានាឱ្យមានកំណើន សេដ្ឋកិច្ចនិងការអភិវឌ្ឍ ប្រកបដោយចីរភាព ត្រូវផ្សាភ្ជាប់ជាមួយនឹងការអភិវឌ្ឍវិជ្ជាជីវៈ អាជីព និងការលើកទឹកចិត្តដល់គ្រូបង្រៀនគណៈ គ្រប់គ្រងសាលារៀន និងអ្នកឯកទេសអប់រំ។ ក្របខណ្ឌគន្លងអាជីពគ្រូបង្រៀនជាឯកសារគតិយុត្តដែលគ្រប់ភាគីពាក់ព័ន្ធត្រូវចូលរួម ដើម្បីអភិវឌ្ឍគុណតម្លៃរបស់ គ្រូបង្រៀនគណៈគ្រប់គ្រងសាលារៀននិងអ្នកឯកទេសអប់រំ។ ក្នុងក្របខណ្ឌគោលនយោបាយស្តីពីគ្រូបង្រៀននិងផែនការសកម្មភាពអនុវត្តគោលនយោបាយស្តីពីគ្រូបង្រៀន តម្រូវឱ្យរៀបចំបង្កើតក្របខណ្ឌគន្លងអាជីពគ្រូបង្រៀនក្នុងគោលដៅទាក់ទាញនិងលើកទឹកចិត្តពលរដ្ឋពូកែៗឱ្យចាប់យកអាជីពគ្រូបង្រៀននិងរក្សាគ្រូបង្រៀនល្អ នាយកល្អ និងអ្នកឯកទេសអប់រំពូកែៗ បម្រើការងារក្នុង ប្រព័ន្ធអប់រំ (ក្របខណ្ឌគន្លងអាជីពគ្រូបង្រៀន ក្រសួងអប់រំ យុវជន និងកីឡា២០១៨)។ដើម្បីគាំទ្រដល់ការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣និងយុទ្ធសាស្ត្រកំណែទម្រង់ការគ្រប់គ្រងអប់រំ យុវជន និងកីឡាគម្រោងកែលម្អការអប់រំ នៅមធ្យមសិក្សាត្រូវបាន បង្កើតឡើងដែលមានរយៈពេលអនុវត្ត ៥ឆ្នាំពីឆ្នាំ២០១៧ដល់ ២០២២។ គោលបំណងនៃការអភិវឌ្ឍគម្រោងនៃគម្រោងកែលម្អការអប់រំនៅមធ្យមសិក្សាគឺដើម្បីពង្រីកការអប់រំមធ្យមសិក្សាដើម្បីទទួលបានស្តង់ដារអប្បបរមានៅក្នុងតំបន់គោលដៅនិងដើម្បីផ្តល់ការឆ្លើយតបភ្លាមៗនិងមានប្រសិទ្ធភាពក្នុងករណីមានវិបត្តិឬភាពអាសន្ន។ផ្នែកទី១នៃគោលបំណងអភិវឌ្ឍន៍គម្រោងនឹងត្រូវបានសម្រេចតាមរយៈសមាសធាតុសំខាន់ពីរគឺៈ (១)ការកែលម្អការអប់រំមធ្យមសិក្សាទុតិយភូមិឱ្យបានអប្បបរមាស្តង់ដារ (ឧទាហរណ៍ការសំរេចបានពិន្ទុអប្បបរមា ៦៥ លើ ១០០ ក្នុងចំណោមអនុវិទ្យាល័យរបស់គម្រោងទាំង១៣០) តាមរយៈការផ្តល់មូលនិធិកែលំអសាលារៀនការលើកកម្ពស់គុណវុឌ្ឍិរបស់គ្រូអនុវិទ្យាល័យដល់បរិញ្ញាបត្រនិងការកែលម្អកន្លែងសិក្សានៅតាមតំបន់គោលដៅដែលមានចែងក្នុងកថាខណ្ឌខាងក្រោម និង (២) ពង្រឹងការគ្រប់គ្រងគម្រោងការត្រួតពិនិត្យនិងវាយតម្លៃ។ អន្តរាគមន៍របស់គម្រោងត្រូវបានរៀបចំឡើងដើម្បីឱ្យស្របទៅនឹងកម្មវិធីអាទិភាពផែនការយុទ្ធសាស្ត្រវិស័យអប់រំ យុវជន និងកីឡា ។

### ៨.២.១.គោលដៅអប់រំជាតិ

- បណ្តុះមនសិការជាតិ មានស្មារតីទទួលខុសត្រូវ ស្មោះត្រង់ និង មោទកភាពជាតិ។
- ផ្តល់ការអភិវឌ្ឍគ្រប់ជ្រុងជ្រោយដល់អ្នកសិក្សា ដើម្បីទទួលបានតុល្យភាពរវាងការអភិវឌ្ឍកាយ

- សម្បទា បញ្ញា អារម្មណ៍ សោភណ្ឌភាព និងស្មារតី។
- ផលិតធនធានមនុស្សដែលមានចំណេះដឹង បំណិន និងសមត្ថភាព ដែលសមស្របនឹងតម្រូវការទីផ្សារ។
- រៀបចំការសិក្សាពេញមួយជីវិត ដើម្បីឱ្យពួកគេអាចចូលរួមក្នុងពិភពលោក ដែលមានទំនាក់ទំនង ជាមួយគ្នា និងពឹងអាស្រ័យគ្នាទៅវិញទៅមក។
- បណ្ដុះមនសិកាជាតិ និងស្មារតីទទួលខុសត្រូវ សម្បទា បញ្ញា អារម្មណ៍ សោភណភាព
- បង្កើតធនធានមនុស្សដែលមានចំណេះដឹង បំណិន សមត្ថភាពដែលទីផ្សារចង់បាន
- រៀបចំឱ្យមានការសិក្សាពេញមួយជីវិត ដើម្បីឱ្យពួកគេអាចមានទំនាក់ទំនងជាមួយពិភពលោក

### ៨.២.២.គោលដៅយុទ្ធសាស្ត្រសម្រាប់សម្រេចគោលដៅអប់រំឆ្នាំ២០៣០

កម្ពុជាត្រូវមានប្រព័ន្ធអប់រំរឹងមាំ និងមានសមត្ថភាពប្រកួតប្រជែងថ្នាក់តំបន់សម្រាប់សង្គមពុទ្ធិ។ ប្រព័ន្ធអប់រំត្រូវមានធនធានគ្រប់គ្រាន់ មានអភិបាលកិច្ចល្អ និងមានតុល្យភាព។

- សាលារៀនទាំងអស់និងមានស្វ័យភាពផ្នែករដ្ឋបាន គឺហិរញ្ញវត្ថុនិងគណនេយ្យភាព
- គ្រូបង្រៀនត្រូវមានសមត្ថភាពជាគ្រូសតវត្សទី២១ និងទទួលបានការលើកទឹកចិត្ត និងគាំទ្រសម្រាប់អ្នកសិក្សាប្រកបដោយគុណភាព
- សិស្សមានសម្បទារឹងមាំ សុខភាពល្អ នឹងក្លាយជាសរសរទ្រូងអភិវឌ្ឍជាតិ។
- ក្រសួងអប់រំ យុវជន និងកីឡា គឺជាក្រសួងដែលមានឧត្តមភាពក្នុងការផ្ដល់នូវការអប់រំ និងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា ប្រកបដោយគុណភាព ដើម្បីក្លាយជាចលករក្នុងការឈានទៅសម្រេចបាននូវការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច។
- សាលារៀនគឺជាគ្រឹះស្ថានសិក្សា ដែលធានាបាននូវការអប់រំប្រកបដោយគុណភាពសម្រាប់ទាំងអស់គ្នា។ សាលារៀនទាំងអស់នឹងមានស្វ័យភាពផ្នែករដ្ឋបាន និងហិរញ្ញវត្ថុ និងគណនេយ្យភាពក្នុងការសម្រេចបាននូវលទ្ធផលសិក្សាប្រកបដោយគុណភាពខ្ពស់សម្រាប់ទាំងអស់គ្នា។
- គ្រូបង្រៀនកម្ពុជា មានសមត្ថភាព ទទួលបានការលើកទឹកចិត្ត និងទទួលបានការគាំទ្រគ្រប់គ្រាន់ដើម្បីជួយគាំទ្រដល់អ្នកសិក្សាឱ្យទទួលបានការអប់រំប្រកបដោយគុណភាពខ្ពស់។
- បន្ទប់រៀនកម្ពុជា ជាបន្ទប់រៀនវៃឆ្លាត ដែលផ្ដល់ឱ្យសិស្សនូវឱកាសល្អបំផុតសម្រាប់ការរៀនសូត្រ
- សិស្សមានសុខភាពល្អ មានការលើកទឹលចិត្ត និងមានការផ្ដេជ្ជាចិត្តសម្រាប់អនាគត់កម្ពុជា។

## ៨.៣.កំណែទម្រង់សាលារៀន

ដើម្បីធានានូវប្រសិទ្ធភាពនៃការផ្ដល់សេវាអប់រំនៅកម្រិតសាលារៀន ក្រសួងអប់រំ បានដាក់ចេញនូវកម្មវិធីកំណែទម្រង់សាលារៀនដែលមានសមាសភាគដូចតទៅ៖

- បង្កើតឱ្យមានសាលាជំនាន់ថ្មី
- ការបង្កើតសាលាគំរូ១៥០ តាមរយៈការគ្រប់គ្រងរបស់សាលារៀន

- ការលើកទឹកចិត្តឱ្យអនុវត្ត ការគ្រប់គ្រងសាលារៀនតាមគ្រឹះស្ថានសិក្សា ដែលមានលក្ខខណ្ឌសមស្រប។

### ៨.៤.ការលើកកម្ពស់ការអប់រំឌីជីថល

- បញ្ញាបបច្ចេកវិទ្យាព័ត៌មាន និងសាគមនាគមន៍
- បង្កើនប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិនៃការបង្រៀន និងរៀនតាមរយៈការប្រើប្រាស់ឧបករណ៍ ប.ព.សនិងធនធានអេឡិចត្រូនិច(បច្ចេកវិទ្យា,ព័ត៌មានវិទ្យា,សាគមនាគមន៍)
- ប្រើប្រាស់ការរៀនសូត្រតាមប្រពន្ធ័អេឡិចត្រូនិច(E-Learning)
- បង្កើនប្រសិទ្ធភាពក៏ដូចជាសមត្ថភាពរបស់ខ្លួន ក្នុងការធ្វើសេចក្ដីសម្រេចចិត្តផ្អែកតាមភស្តុតាង និង ការចែករំលែកចំណេះដឹង តាមរយៈការប្រើប្រាស់ព័ត៌មាន។
- បង្កើតស្តង់ដារសម្រាប់ហេដ្ឋារចនាសម្ព័ន្ធ ការភ្ជាប់ទំនាក់ទំនងបណ្ដាញអង្គភាពនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិទាំងអស់ទៅក្នុងប្រព័ន្ធតភ្ជាប់ផ្ទៃក្នុង។
- ផ្តល់ធនធានហិរញ្ញវត្ថុចាំបាច់ ដើម្បីគាំទ្រដល់ការប្រើប្រាស់ ប.ព.ស ក្នុងវិស័យអប់រំ។

### ៨.៥.វិធីសាស្ត្របង្រៀនដើម្បីឆ្លើយតបទៅនឹងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០១៩-២០២៣

វិធីសាស្ត្របង្រៀន ដែលអាចជំរុញឱ្យផែនការយុទ្ធសាស្ត្រអប់រំឆ្នាំ២០៣០ ទទួលបានជោគជ័យគឺ

- ការឆ្លុះបញ្ចាំងសំខាន់(Critical reflection) ៖ ឱ្យសិស្សគិតឱ្យបានហ្មត់ចត់អំពីវិធីធ្វើឱ្យពិភពលោកមានតុល្យភាពបរិស្ថាននិងសង្គម
- ការគិតជាប្រព័ន្ធ(systematic thinking) ៖ប្រើការគិតជាប្រព័ន្ធនៅក្នុងថ្នាក់រៀន=ការសិក្សាត្រូវសង្កត់ធ្ងន់លើភាពទាក់ទងគ្នានៃអ្វីៗដែលនៅជុំវិញយើង
- ការរៀនសូត្រដែលមានការចូលរួម ៖ សិស្សរៀនតាមវិធីសហការ
- ការគិតប្រកបដោយការច្នៃប្រឌិត(Thinking creatively) ៖ លើកទឹកចិត្តសិស្សឱ្យគិតពីអនាគតប្រកបដោយនិរន្តរភាពនិងបង្កើតយុទ្ធសាស្ត្រដើម្បីទៅដល់គោលដៅ។
- ការសិក្សារួមគ្នា(Collaborative learning) ៖ លើកទឹកចិត្តសិស្សឱ្យចេះធ្វើការងារក្រុម សហការគ្នាដើម្បីសម្រេចលទ្ធផលការងារដែលគ្រូដាក់ឱ្យ។

### សន្និដ្ឋាន

មេរៀននេះផ្តោតលើផែនការយុទ្ធសាស្ត្រអប់រំរបស់កម្ពុជាសម្រាប់ឆ្នាំ ២០១៩-២០២៣ ។ បន្ទាប់ពីសិក្សាមេរៀនទាំងនេះនិស្សិតនឹងដឹងថាតើសកម្មភាពសំខាន់ៗអ្វីខ្លះនៅក្នុងកំណែទម្រង់វិស័យអប់រំនៅក្នុងអាណត្តិរដ្ឋាភិបាលបច្ចុប្បន្ន។ មេរៀននេះនឹងជួយផ្តល់នូវចំណេះដឹងដល់សិស្ស និង គ្រុបខ័ណ្ឌសម្រាប់ការអនុវត្តការបង្រៀននិងការអនុវត្តការរៀនរបស់សិស្ស។

**សំណួរ**

១. តើអ្វីជាគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០ ស្ដីការអប់រំនៅកម្ពុជា?ចូររៀបរាប់។

២. ចូរបង្ហាញពីគោលដៅអប់រំជាតិ។

៣.តើនៅក្នុងកំណែទម្រង់សាលារៀន គេផ្ដោតលើសមាសភាគណាខ្លះ?

៣. តើការលើកកម្ពស់ការអប់រំតាមបែបឌីជីថលនៅកម្ពុជាមានលក្ខណៈដូចម្ដេចខ្លះ?

៤. តើអ្នកត្រូវធ្វើអ្វីខ្លះ ដើម្បីរៀបចំការបង្រៀនរបស់អ្នកឱ្យស្របជាមួយផែនការយុទ្ធសាស្ត្រអប់រំសម្រាប់ឆ្នាំ ២០១៩-២០២៣?

## មេរៀនទី៩ សាលារៀនជំនាន់ថ្មី (ផ្នែកទី ១)

### វត្ថុបំណង

បន្ទាប់ពីបញ្ចប់ការងារសម្រាប់ថ្នាក់នេះនិស្សិតនឹងអាចៈ

- កំណត់បានពីចក្ខុវិស័យ និងគោលដៅនៃសាលាជំនាន់ថ្មី
- ពន្យល់បានពីគោលបំណងនៃសាលាជំនាន់ថ្មី
- កំណត់យុទ្ធសាស្ត្រសម្រាប់ NGS

### ៩.១.សេចក្តីផ្តើម

គោលនយោបាយបច្ចុប្បន្នត្រូវបានបង្កើតឡើងដើម្បីផ្តល់ការណែនាំដល់អ្នកអប់រំ និងរដ្ឋបាលគ្រប់ជាន់ថ្នាក់ទាក់ទងនឹងការអនុវត្តសាលារៀនជំនាន់ថ្មីទូទាំងព្រះរាជាណាចក្រកម្ពុជា។ ការបង្កើតសាលារៀនជំនាន់ថ្មីគឺជាគោលនយោបាយផ្លូវការរបស់ក្រសួងអប់រំយុវជន និងកីឡា យោងតាមក្របខណ្ឌកំណែទម្រង់វិស័យអប់រំថ្មីដែលប្រកាសដោយក្រសួង។ គោលនយោបាយនេះសមស្រប និងគាំទ្របន្ថែមលើរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់អប់រំជាតិ គោលដៅសហស្សវត្សរ៍ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា។ ការបង្កើតសាលារៀនជំនាន់ថ្មីគឺជាការបន្តកិច្ចខិតខំប្រឹងប្រែងអភិវឌ្ឍសាលាកុមារមេត្រី និងបង្ហាញពីការវិវត្តន៍ជាបន្តបន្ទាប់របស់ពួកគេ។

### ៩.២.បញ្ញត្តិសាលាជំនាន់ថ្មី

តើអ្វីទៅជាសាលារៀនជំនាន់ថ្មី NGS? សាលារៀនជំនាន់ថ្មី គឺជាកម្មវិធីកំណែទម្រង់ប្រព័ន្ធអប់រំរបស់រាជរដ្ឋាភិបាលកម្ពុជាដែលជាមាគ៌ាអភិវឌ្ឍថ្មីមួយនៅក្នុងប្រព័ន្ធអប់រំនាពេលបច្ចុប្បន្នដែលជួយបង្កើតសាលារៀនសាធារណៈស្វយ័ត។

សាលាជំនាន់ថ្មី គឺជាកំណែទម្រង់ថ្មីមួយដែលត្រូវបាន**សម្ភោធ**ដោយក្រសួងអប់រំ យុវជន និងកីឡានៅឆ្នាំ២០១៤ ដើម្បីបង្កើតសាលារៀនរដ្ឋស្វ័យភាពមួយដោយប្រគល់សិទ្ធិឱ្យច្នៃប្រឌិត និងកែលម្អគុណភាពអប់រំ។ ការទទួលបានមូលនិធិវិនិយោគខ្ពស់គឺអាស្រ័យលើស្តង់ដារខ្ពស់នៃអភិបាលកិច្ច និងវិជ្ជាជីវៈ។




*រូបភាព 42*

ឧទាហរណ៍៖សាលារៀនជំនាន់ថ្មីនៃវិទ្យាល័យព្រះស៊ីសុវត្ថិ(NGS)គឺជាគំរូសាលារៀនមួយស្ថិតនៅក្នុងវិទ្យាល័យធំជាងគេនិងមានវ័យចំណាស់ជាងគេនៅក្នុងប្រទេសកម្ពុជាមានអាយុកាលជាង ១១៣ឆ្នាំ។សាលារៀននេះ ជាលទ្ធផល' មួយទៀតនៃការធ្វើកំណែទម្រង់ស៊ីជម្រៅលើវិស័យអប់រំ ដែលបានសម្ពោធដាក់ឱ្យដំណើរការនៅទី២៣ ខែ មិថុនា ឆ្នាំ ២០១៦ មាន២៤ថ្នាក់រៀនចែកជាបន្ទប់រៀនគីមីវិទ្យាបំពាក់ដោយ សម្ភារៈ បរិក្ខារពិសោធ ចំនួន០៣បន្ទប់ បន្ទប់រៀនរូបវិទ្យាបំពាក់ដោយសម្ភារៈបរិក្ខារពិសោធចំនួន០៣បន្ទប់បន្ទប់រៀនជីវវិទ្យាបំពាក់ដោយសម្ភារៈបរិក្ខាពិសោធចំនួន០៣បន្ទប់បន្ទប់រៀនកុំព្យូទ័រ បំពាក់ដោយម៉ាស៊ីនកុំព្យូទ័រទំនើប ចំនួន០២បន្ទប់ស្មើ៦០គ្រឿងបន្ទប់គណិតវិទ្យា ០៤ បន្ទប់រៀនពោពេញដោយសម្ភារឧបទេស ចាប់ពីថ្នាក់ទី ៧ ដល់ថ្នាក់ទី១២ គ្រូបង្រៀន សរុបចំនួន ៥៨ នាក់ក្នុងនោះស្រី ៣០នាក់។

## ៩.៣.មូលហេតុនៃការបង្កើតសាលាជំនាន់ថ្មី

កំណែទម្រង់សាលារៀនជំនាន់ថ្មីនៅកម្ពុជាត្រូវបានបង្កើតឡើងនៅឆ្នាំ២០១៥ ក្នុងគោលបំណង៖

លើកកម្ពស់គុណភាពនៃការអប់រំ ដើម្បីរៀបចំកម្លាំងពលកម្មយុវជនកម្ពុជាឱ្យកាន់តែប្រសើរសម្រាប់សតវត្សរ៍ទី២១។

អភិវឌ្ឍសមត្ថភាពនៃការយល់ដឹងរបស់សិស្សដោយផ្តោតជាពិសេសលើ STEM បច្ចេកវិទ្យាព័ត៌មាននិងបំណិនក្នុងការត្រិះរិះពិចារណា ព្រមទាំងជំនាញក្នុងទំនាក់ទំនងជាមួយអ្នកដទៃនិងជំនាញផ្ទាល់ខ្លួនក្នុងការគ្រប់គ្រងអារម្មណ៍ ដោះស្រាយបញ្ហា និងទទួលព័ត៌មានថ្មីផងដែរ។

ជំរុញការបង្កើតថ្មីនៅក្នុងកម្មវិធីសិក្សា ការបង្រៀន និងការប្រើប្រាស់ធនធានដើម្បីកែលម្អលទ្ធផលនៃការសិក្សា។

ផ្តល់នូវស្តង់ដារអប់រំឈានមុខគេដល់សិស្សមកពីគ្រប់ស្ថានភាពសេដ្ឋកិច្ចសង្គម។





*រូបភាព 43៖ How do we teach 21st century skills in classrooms ?*

*រូបភាព 44៖ 21st century classrooms design*

## ៩.៤.ចក្ខុវិស័យ និងគោលដៅនៃសាលាជំនាន់ថ្មី

**ចក្ខុវិស័យ៖** សាលារៀនជំនាន់ថ្មីនឹងធ្វើឱ្យលេចឡើងនូវក្របខណ្ឌរដ្ឋបាលថ្មីមួយដែលធានាបាននូវលក្ខខណ្ឌចាំបាច់សម្រាប់ការវិនិយោគអប់រំដែលទទួលបានជោគជ័យ។

**គោលដៅ៖** បង្កើតបែបបទអភិវឌ្ឍថ្មីមួយក្នុងប្រព័ន្ធអប់រំសាធារណៈដែលនឹងនាំឱ្យមានការបង្កើតសាលារដ្ឋស្វយ័តដែលទទួលបានការវិនិយោគខ្ពស់ផ្សារភ្ជាប់ទៅនឹងស្តង់ដាថ្មីនៃគណនេយ្យភាព និងអភិបាលកិច្ចក៏ដូចជាស្តង់ដារវិជ្ជាជីវៈសម្រាប់ការសិក្សានៅសតវត្សរ៍ទី២១។




*រូបភាព 45*

## ៩.៥.គោលបំណងរបស់សាលាជំនាន់ថ្មី

គោលបំណងជាក់លាក់របស់សាលាជំនាន់ថ្មីរួមមាន៖

- បង្កើតសាលារដ្ឋស្វយ័ត គ្រប់គ្រងដោយវិន័យតឹងរឹងនៃគណនេយ្យភាព ការអនុវត្តផ្សារភ្ជាប់ទៅនឹងការវិនិយោគខ្ពស់។
- បង្កើតក្រុមប្រឹក្សាអភិបាលកិច្ចថ្មីដែលនឹងធ្វើឱ្យសាលារៀនទទួលខុសត្រូវចំពោះការអនុវត្តការងាររបស់ពួកគេ។
- បង្កើតប្រព័ន្ធទទួលស្គាល់ដែលជួយសម្រួលដល់ការសម្រេចចិត្តរបស់ក្រុមប្រឹក្សាភិបាលអំពីការប្រកាន់ខ្ជាប់របស់សាលាចំពោះគោលការណ៍គ្រឹះរបស់សាលាជំនាន់ថ្មី។
- ផ្តល់សិទ្ធិសេរីភាពដល់ស្ថាប័នថ្មីៗ( ឧទាះប្រតិបត្តិការស្វ័យភាព )ដើម្បីជំរុញការបង្កើតថ្មីតាមមធ្យោបាយសេវាកម្មអប់រំដែលបានរៀបចំនិងចែកចាយ។
- ធ្វើឱ្យប្រព័ន្ធអប់រំមានប្រសិទ្ធភាព និងសមធម៌ក្នុងសង្គមដោយគោរពតាមដំណើរការបង្រៀន និងរៀនដោយបង្កើតប្រព័ន្ធបែងចែកធនធានដែលមានលក្ខណៈសមហេតុផលដែលលើកកម្ពស់សេវាកម្មអប់រំ។
- លើកកម្ពស់ស្តង់ដារបង្រៀនតាមរយៈវិធីសាស្រ្តថ្មីៗដែលរួមមាន ការជ្រើសរើសគ្រូដែលមានការប្រកួតប្រជែង ការលើកទឹកចិត្តផ្អែកលើការអនុវត្ត ការកសាងសមត្ថភាពលើផ្នែកបច្ចេកវិទ្យាអប់រំ STEMនិងវិធីសាស្ត្ររៀនតាមបែបដោះស្រាយបញ្ហា និងគន្លងអាជីពគ្រូបង្រៀនជាក់លាក់ដែលភ្ជាប់ទៅនឹងឱកាសអភិវឌ្ឍវិជ្ជាជីវៈ( ឧទាហរណ៍៖ អាហារូបករណ៍គ្រូសម្រាប់ការសិក្សានាពេលអនាគត )

- ពង្រីកសេវាកម្មអប់រំសម្រាប់យុវជនកម្ពុជាដែលរួមមានសេវាកម្មផ្តល់ប្រឹក្សាអាជីព ការរៀនសូត្រចល័ត និងការអប់រំបំណិនជីវិត។

**សន្និដ្ឋាន**

មូលហេតុនៃការបង្កើតសាលារៀនជំនាន់ថ្មីគឺជាការកសាងប្រព័ន្ធអប់រំដែលមានគុណភាពខ្ពស់ ជាកត្តាគន្លឹះដើម្បីធានាបាននូវកម្រិតជីវភាពខ្ពស់សម្រាប់ប្រទេសមួយ។ ប្រទេសទាំងអស់ត្រូវការធនធានមនុស្សដែលមានសមត្ថភាព មានចំណេះដឹង និងជំនាញខ្ពស់ដើម្បីអភិវឌ្ឍសេដ្ឋកិច្ច និងកម្លាំងទាំងមូលរបស់សង្គម។

ដើម្បីឆ្លើយតបទៅនឹងតម្រូវការដែលបានលើកឡើងខាងលើ ក្រសួងអប់រំ យុវជន និងកីឡាបានបង្កើតគោលនយោបាយថ្មីក្នុងការអភិវឌ្ឍសាលាជំនាន់ថ្មី ក្នុងគោលបំណងលើកកម្ពស់គុណភាពអប់រំទាំងមូល។ បច្ចុប្បន្ននេះក្រសួងអប់រំ យុជន និងកីឡាបាននិងកំពុងដាក់ចេញនូវការអនុវត្តសាលាជំនាន់ថ្មីដែលបន្តពីកម្មវិធីសាលាកុមារមេត្រី ប៉ុន្តែក្នុងកម្រិតស្តង់ដារខ្ពស់។

គោលការណ៍សាលាជំនាន់ថ្មី នឹងផ្តល់ការណែនាំដល់អ្នកអប់រំ និងសិស្ស ឱ្យយល់កាន់តែច្បាស់ពីវិធីសាស្រ្តថ្មីៗនៃការរៀនសូត្រដូចជា ការរៀនតាមបែបស្ថាបនា និងដោះស្រាយបញ្ហា។ តាមរយៈវិធីសាស្រ្តទាំងនេះ សាលាជំនាន់ថ្មីនឹងជួយបង្កើនវត្តមាននៃការអប់រំច្នៃប្រឌិតនៅទូទាំងប្រព័ន្ធសាលារៀន។ សកម្មភាពផ្សេងទៀតរួមមានកិច្ចការគម្រោង ក្លឹបប្រធានបទ និងបច្ចេកវិទ្យាព័ត៌មានក្នុងវិស័យអប់រំក៏ជួយលើកកម្ពស់ការច្នៃប្រឌិតការអប់រំផងដែរ។

ចុងបញ្ចប់គោលការណ៍ណែនាំទាំងនេះ នឹងធ្វើឱ្យក្រសួងនិងដៃគូអភិវឌ្ឍន៍របស់ខ្លួនធ្វើការវិនិយោគនៅតាមសាលារៀនដែលបានជ្រើសរើសតាមរបៀបមួយដែលអាចទទួលបានស្តង់ដារខ្ពស់ចំពោះការសិក្សារបស់កុមារនិងយុវជនកម្ពុជា។ដូច្នេះគំនិតរបស់សាលាជំនាន់ថ្មី នឹងផ្តល់អំណាចដល់ប្រព័ន្ធអប់រំរបស់ព្រះរាជាណាចក្រកម្ពុជា ដើម្បីប្រកួតប្រជែងប្រកបដោយប្រសិទ្ធភាពជាមួយប្រព័ន្ធអប់រំដទៃទៀតនៅក្នុងតំបន់អាស៊ានដែលមានតម្រូវការបន្ទាន់សម្រាប់កម្លាំងការងារដែលមានជំនាញសតវត្សរ៍ទី២១។

**សំណួរ**

១.ដូចម្តេចដែលហៅថាសាលាជំនាន់ថ្មី?

២.ហេតុអ្វីចាំបាច់ត្រូវបង្កើតសាលាជំនាន់ថ្មីនៅកម្ពុជា?

៣.តើសាលារដ្ឋទាំងអស់គួរតែប្តូរទៅជាសាលាជំនាន់ថ្មីដែរឬទេ? ហេតុអ្វី?

៤.ចូរប្អូនបកស្រាយពី ចក្ខុវិស័យ បេសកកម្ម និងគុណតម្លៃ របស់វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ។

# មេរៀនទី១០ សាលារៀនជំនាន់ថ្មី (ផ្នែកទី២)

## វត្ថុបំណង

បន្ទាប់ពីរៀនមេរៀននេះចប់គរុនិស្សិតនឹងៈ

- កំណត់បានពីយុទ្ធសាស្ត្ររបស់សាលាជំនាន់ថ្មី
- រៀបរាប់បានពីផែនការសកម្មភាព និងចូលរួមអនុវត្តដើម្បីធ្វើឱ្យសម្រេចនូវផែនការយុទ្ធសាស្ត្ររបស់សាលាជំនាន់ថ្មី។

## ១០.១.សេចក្តីផ្តើម

ការបង្កើតគោលនយោបាយថ្មីក្នុងការអភិវឌ្ឍសាលាជំនាន់ថ្មី ក្នុងគោលបំណងលើកកម្ពស់គុណភាពអប់រំ។គោលការណ៍សាលាជំនាន់ថ្មី នឹងផ្តល់ការណែនាំដល់អ្នកអប់រំ និងសិស្សឱ្យយល់កាន់តែច្បាស់ពីវិធីសាស្ត្រថ្មីៗដូចជា ការរៀនតាមបែបស្ថាបនា និងដោះស្រាយបញ្ហា។ក្រសួងនិងដៃគូអភិវឌ្ឍន៍ធ្វើការវិនិយោគតាមសាលារៀនដែលបានជ្រើសរើស។

## ១០.២.កំណែទម្រង់ប្រព័ន្ធអប់រំ

គំនិតសម្រាប់ការធ្វើកំណែទម្រង់ប្រព័ន្ធអប់រំត្រូវផ្តួចផ្តើមឡើងដំបូងដោយអង្គការ KAPE ដែលជាអង្គការក្នុងស្រុកធំបំផុតផ្តោតសំខាន់ទៅលើវិស័យអប់រំនៅកម្ពុជា ហើយក្រោយមកអង្គការនេះត្រូវបានអនុម័ត និងត្រូវបានឧបត្ថម្ភថវិកាដោយក្រសួងអប់រំ យុវជន និងកីឡា។ កម្មវិធីសាកល្បងរបស់ពួកគេដែលជាគំនិតផ្តួចផ្តើមសាលា Beacon ត្រូវបានស្ថាបនាឡើងនៅឆ្នាំ២០១៤ នៅខេត្តកំពង់ចាម ហើយនៅពេលដែលកម្មវិធីមានការពង្រីកធំទៅៗ សាលានេះក៏ក្លាយជាសាលារៀនជំនាន់ថ្មីនេះឯង។

គោលបំណងរបស់សាលារៀនជំនាន់ថ្មី គឺការបង្កើតសាលារដ្ឋដែលរក្សាបានស្តង់ដារនៃការអប់រំបានខ្ពង់ខ្ពស់បំផុតតាមរយៈការវិនិយោគថវិកាច្រើន និងផ្តោតទៅលើការពង្រឹងតម្លាភាព និងទទួលខុសត្រូវដោយការផ្លាស់ប្តូរវិធីគ្រប់គ្រងសាលា។ នេះគឺជាការខុសប្លែកពីវិធីសាស្ត្រប្រពៃណីរបស់រដ្ឋាភិបាលដែលរមែងតែងតែបែងចែកមូលនិធិស្មើៗគ្នាទាំងអស់។

ប្រសិនបើមិនមានការទទួលខុសត្រូវក្នុងការគ្រប់គ្រងសាលារៀនទេនោះ សម្ភារៈបរិក្ខារដូចជាបន្ទប់ពិសោធវិទ្យាសាស្ត្រនឹងមិនត្រូវបានប្រើប្រាស់ឱ្យអស់ពីសមត្ថភាពទេពីព្រោះគ្រូបង្រៀនរវល់តែស្ទិតស្ទាញក្នុងការបង្រៀនគួរយកលុយក្រៅម៉ោងវិញ និងមានភាពលម្អៀងទៅលើសិស្សរៀនគួរជាងសិស្សដែលមិនមានលុយរៀនគួរ។

សាលារៀនជំនាន់ថ្មីព្យាយាមដោះស្រាយបញ្ហានេះដោយការលុបបំបាត់ការអនុវត្តបែបនេះទាំងស្រុង។ គ្រូបង្រៀនត្រូវបានជ្រើសរើសយ៉ាងល្អិតល្អន់ និងទទួលបានអត្ថប្រយោជន៍ជាច្រើនដូចជាការផ្តល់អាហារូបករណ៍ដើម្បីពង្រឹងគុណធម៌ក្នុងការបង្រៀន និងសុចរិតភាព។ គេបានសង្កេតឃើញថា នៅក្នុងបរិយាកាសថ្មីនេះគ្រូបង្រៀនលែងមានការប្រកួតប្រជែងជាមួយគ្នាដើម្បីទាក់ទាញអតិថិជនដែលជាសិស្សនោះទេ ហើយវាធ្វើឱ្យការពង្រឹងគុណភាពនេះប្រព្រឹត្តទៅដោយរលូន។

សាលារៀនជំនាន់ថ្មី គឺជាកម្មវិធីសិក្សាថ្មីមួយដែលក្រសួងអប់រំបានដាក់ឱ្យអនុវត្តន៍ក្នុងដំណាក់កាលសាកល្បងនៅឆ្នាំ២០១៥។ ការអនុវត្តន៍នេះ គឺធ្វើទាំងថ្នាក់បឋម និងថ្នាក់មធ្យមសិក្សាផងដែរ ក្នុងបំណងធ្វើឱ្យការអប់រំនៅកម្ពុជាកាន់តែល្អប្រសើរ ដូចទៅនឹងប្រទេសមួយចំនួននៅក្នុងតំបន់ និងលើពិភពលោក។

យោងតាមប្រសាសន៍លោក ឌី ខាំបូលី បច្ចុប្បន្នមានសាលាចំនួន១០ហើយ កំពុងដាក់ឱ្យអនុវត្តកម្មវិធីសិក្សាសាលារៀនជំនាន់ថ្មីនេះ។ ក្នុងនោះសាលាបឋមសិក្សាមានចំនួន៤ និងសាលាមធ្យមសិក្សាមានចំនួន៦។ សាលាទាំងនោះរួមមាន៖ វិទ្យាល័យព្រះស៊ីសុវត្ថិ វិទ្យាល័យហ៊ុនសែនកំពង់ចាម វិទ្យាល័យព្រែកលៀប វិទ្យាល័យសម្តេចជាស៊ីព្រែកអញ្ចាញ វិទ្យាល័យហ៊ុនសែនពាមជីកង អនុវិទ្យាល័យគោកព្រីង សាលាបឋមសិក្សាហ៊ុនសែនកំពង់ចាម សាលាបឋមសិក្សាព្រះរាជអគ្គមហេសី សាលាបឋមសិក្សាអង្គរបាន និងសាលាបឋមសិក្សាព្រហូត។

កម្មវិធីសិក្សាសាលារៀនជំនាន់ថ្មី ត្រូវបានយកចិត្តទុកដាក់ខ្ពស់លើការបញ្ចូលប្រព័ន្ធបច្ចេកវិទ្យាទៅក្នុងការអប់រំទាំងអ្នករៀន និងអ្នកបង្រៀន ព្រមទាំងបំពាក់ឧបករណ៍សិក្សាសម្បូរបែបផងដែរ។ ជាពិសេសម៉ោងសិក្សាមានច្រើនជាងកម្មវិធីសិក្សាចាស់។

អ្វីដែលនាំឱ្យមានការចាប់អារម្មណ៍ខ្ពស់នោះ កម្មវិធីសិក្សាសាលារៀនជំនាន់ថ្មី បានយកចិត្តទុកដាក់ខ្ពស់លើការលុបបំបាត់ការរៀនក្រៅម៉ោង ឬហៅថារៀនគួរ និងការលក់ឯកសារផ្សេងៗ ដែលនាំឱ្យសិស្សចំណាយក្រៅផ្លូវការលើការសិក្សារបស់ពួកគេ។

អ្នកនាំពាក្យក្រសួងអប់រំ យុវជន និងកីឡា ក៏បានឆ្លើយតបនឹងការលើកឡើងថា កម្មវិធីថ្មីនេះតម្រូវឱ្យបង់ការសិក្សាប្រមាណ ៣០០ដុល្លារក្នុងមួយឆ្នាំ ពីសំណាក់គ្រូៗ អាណាព្យាបាល និងសិស្សនៅសាលាព្រះស៊ីសុវត្ថិផងដែរ។ បើតាមលោក ឌី ខាំបូលី ការបង់ថវិកានេះជាការចូលរួមវិភាគទានសម្រាប់ទ្រទ្រង់ដល់ការអនុវត្តកម្មវិធីសិក្សាថ្មីនេះ ហើយឈរលើគោលការស្ម័គ្រចិត្តប៉ុណ្ណោះ ពោលបើអាណាព្យាបាលមានលទ្ធភាពក៏បង់ ហើយអាណាព្យាបាលសិស្សមានជីវភាពខ្សត់ខ្សោយក៏មិនតម្រូវឱ្យបង់នោះទេ។

យោងតាមស្ថិតិនៃការប្រលងបានបង្ហាញឱ្យឃើញថា លទ្ធផលប្រលងបាក់ឌុបកន្លងទៅរវាងសិស្សដែលរៀនតាមកម្មវិធីសិក្សាចាស់ និងសិស្សរៀនតាមកម្មវិធីសិក្សាថ្មីនេះមានការខុសគ្នាច្រើន ពោលសិស្សរៀនតាមកម្មវិធីសិក្សាថ្មីមានអត្រាជាប់ខ្ពស់ជាងសិស្សរៀនតាមកម្មវិធីសិក្សាចាស់។ ការអនុវត្តន៍កម្មវិធីសិក្សាថ្មីនេះ បានធ្វើឱ្យមានការពេញចិត្តពេញថ្លើមខ្លាំងពីសិស្ស និងអាណាព្យាបាលផងដែរ ដោយបានធ្វើឱ្យចំណេះដឹងទទួលបានមានភាពល្អប្រសើរខ្លាំងបើធៀបជាមួយកម្មវិធីសិក្សាចាស់។

ពាក់ព័ន្ធនឹងការបង់វិភាគទានទ្រទ្រង់ការអនុវត្តន៍កម្មវិធីសិក្សាថ្មីប្រមាណ ៣០០ដុល្លារក្នុងមួយឆ្នាំនោះ ត្រូវបានអាណាព្យាបាលមួយចំនួនលើកឡើងថា ចំនួននេះមិនច្រើននោះទេ បើធៀបជាមួយការសិក្សាក្នុងកម្មវិធីសិក្សាចាស់ ព្រោះថាកម្មវិធីសិក្សាចាស់បើមិនបង់លុយប្រចាំតែសិស្សត្រូវចំណាយច្រើនលើការសិក្សាក្រៅម៉ោង និងទិញឯកសារផ្សេងៗ។

តាមការសាកសួរទាំងសិស្ស និងអាណាព្យាបាលបានបង្ហាញថា សាលាជំនាន់ថ្មី ជាកម្មវិធីសិក្សាថ្មីមួយប្រកបដោយភាពល្អប្រសើរក្រោមការប្រឹងប្រែងធ្វើកំណែទម្រង់របស់ក្រសួងអប់រំ ដើម្បីឆ្ពោះទៅរកប្រព័ន្ធអប់រំមួយប្រកបដោយគុណភាព។ តែហេតុអ្វីបានជាគ្រូៗមួយចំនួននៅក្នុងវិទ្យាល័យព្រះស៊ីសុវត្ថិនាំគ្នាមិនពេញចិត្តលើកម្មវិធីអប់រំនេះ ហើយព្យាយាមសាបព្រោះពាក្យអកុសលថាយកសាលារដ្ឋទៅធ្វើជាសាលាឯកជនទៅវិញ?

មានការលើកឡើងថា ការតវ៉ាទាំងនេះធ្វើឡើងដើម្បីប្រយោជន៍ផ្ទាល់ខ្លួនជាជាងប្រយោជន៍រួមរបស់ជាតិ ដោយហេតុថា កម្មវិធីសិក្សាថ្មីនេះ នឹងធ្វើឱ្យគ្រូៗបាត់បង់ចំណូលប្រចាំថ្ងៃរបស់ខ្លួនតាមរយៈការបង្រៀនក្រៅម៉ោង ក៏ដូចជាការលក់ឯកសារនានាទៅឱ្យសិស្សជាដើម។

ដើម្បីធ្វើឱ្យការអនុវត្តកម្មវិធីសិក្សាសាលារៀនជំនាន់ថ្មីនេះទទួលបានជោគជ័យ នៅឆ្នាំ២០១៦ កន្លងទៅនេះ ក្រសួងអប់រំ បានដាក់ចេញគោលនយោបាយស្តីពីសាលារៀនជំនាន់ថ្មីនេះផងដែរ។ ក្នុងគោលនយោបាយនេះបានដាក់ចេញនូវចំណុចជាច្រើនដើម្បីធានាផ្តល់នូវការអប់រំមួយប្រកបដោយគុណភាពនិងប្រសិទ្ធភាពខ្ពស់

**១០.៣.ផែនការសកម្មភាព**

ដើម្បីសម្រេចបានយុទ្ធសាស្ត្រខាងលើ ត្រូវយកចិត្តទុកដាក់លើសកម្មភាពមួយចំនួនដូចជា៖

- ការបង្កើតយន្តការ(ក្រុមប្រឹក្សាភិបាល ថ្នាក់ជាតិនិងអន្តរជាតិ អនុកម្មការសម្រាប់វាយតម្លៃដែលទទួលស្គាល់ដោយសាលាជំនាន់ថ្មី )
- ការបង្កើតក្របខណ្ឌស្តង់ដា គតិយុត្តិ
- ការគាំទ្រហិរញ្ញវត្ថុ
- ការបណ្តុះបណ្តាលធនធានមនុស្ស
- ដំណើរការអនុវត្តគម្រោង
- ក្រសួង អប់រំ យុវជន និង កីឡាបានបង្កើតសាលាជំនាន់ថ្មីចំនួន ១១ ហើយដើម្បីរួមចំណែកពង្រឹងប្រព័ន្ធអប់រំជំរុញការអប់រំតាមបែបឌីជីថលនិងទិសដៅសេដ្ឋកិច្ចឌីជីថលកម្ពុជា ។
- ក្រសួង បានជ្រើសរើសសាលាមួយចំនួនដើម្បីអនុវត្តកម្មវិធីសាលារៀនជំនាន់ថ្មីសំដៅ ពង្រឹងសមត្ថភាពគ្រូបង្រៀនកែលម្អវិធីសាស្ត្របង្រៀនពង្រឹងការគ្រប់គ្រងសាលានិងជា សាលារៀនគំរូដល់គ្រឹះស្ថានសិក្សា។រហូតមកដល់បច្ចុប្បន្នសាលាជំនាន់ថ្មីមាន១១សាលា

  ក្នុងនោះមានសាលាបឋមសិក្សាចំនួន ៤ និងសាលាមធ្យមសិក្សាចំនួន៧ ។ បើតាម អ្នកនាំពាក្យដដែលសាលាបឋមសិក្សាទាំង ៤ មានសាលាបឋមសិក្សា ហ៊ុន សែនកំពង់ចាមទីរួម ខេត្តកំពង់ចាម ។ សាលាបឋមសិក្សា ព្រះរាជអគ្គមហេសីក្នុងស្រុកឧត្តុង ខេត្តកំពង់ស្ពឺ ។ សាលាបឋមសិក្សាអង្គរបាននៅស្រុកកងមាស ខេត្តកំពង់ចាម ។ សាលាបឋមសិក្សា ស្វាយជ្រុំនៅស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង ។ ចំណែកឯសាលាមធ្យមសិក្សាទាំង ៧ រួមមាន វិទ្យាល័យព្រះស៊ីសុវត្ថិនៅខណ្ឌដូនពេញក្នុងរាជធានីភ្នំពេញ ។ វិទ្យាល័យ ហ៊ុន សែន កំពង់ចាម នៅទីរួមខេត្តកំពង់ចាម ។ វិទ្យាល័យព្រែកលៀបនៅជ្រោយចង្វារាជធានីភ្នំពេញ ។ វិទ្យាល័យ សម្តេចជាស៊ីម

ព្រែកអញ្ចាញនៅមុខកំពូលខេត្តកណ្តាល ។ វិទ្យាល័យហ៊ុន សែនពាមជីកង នៅខេត្តកំពង់ចាម និងវិទ្យាល័យព្រះយុគន្ធរនៅរាជធានីភ្នំពេញ ។

## ១០.៤.យុទ្ធសាស្ត្រសំខាន់ៗក្នុងការធ្វើឱ្យសម្រេចគោលដៅ និងគោលបំណងនៃសាលាជំនាន់ថ្មី

### ១០.៤.១.ការជ្រើសរើសសាលាយ៉ាងហ្មត់ចត់

- ជ្រើសរើសសាលារៀនគោលដៅយ៉ាងហ្មត់ចត់
- ជ្រើសរើសយកសាលារៀនដែលមានសក្តានុពលពេញលេញក្នុងការប្រើប្រាស់ការវិនិយោគឱ្យមានប្រសិទ្ធភាពខ្ពស់។

### ១០.៤.២.ភាពជាដៃគូ

- កសាងភាពជាដៃគូជិតស្និទ្ធ ជាមួយតួអង្គមិនមែនរដ្ឋ និងវិស័យឯកជន ដើម្បីជួយក្រសួងអប់រំ យុវជន និងកីឡាក្នុងការអនុវត្ត និងផ្គត់ផ្គង់ធនធានដល់សាលារៀនជំនាន់ថ្មី។




*រូបភាព 46៖ភាពជាដៃគូ*

### ១០.៤.៣.គណនេយ្យភាពសាលារៀន៖

ពង្រឹងការទទួលខុសត្រូវរបស់អ្នកគ្រប់គ្រងសាលារៀនដោយប្រើយុទ្ធសាស្ត្រជាច្រើនដូចជា

- ជ្រើសរើសអ្នកគ្រប់គ្រងសាលាដោយប្រកួតប្រជែង ប្រើការលើកទឹកចិត្តដែលជាប់ទាក់ទងនឹងលទ្ធផលខ្ពស់។
- បង្កើតក្រុមប្រឹក្សាភិបាលថ្នាក់ជាតិថ្មីដែលអនុវត្តយ៉ាងតឹងរឹងនូវលក្ខណៈវិនិច្ឆ័យសម្រាប់ការរចនាសាលាជំនាន់ថ្មី
- ដកការទទួលស្គាល់ និងការវិនិយោគពីសាលាជំនាន់ថ្មីក្នុងករណីដែលសាលារៀនមិនបានបំពេញតាមលក្ខណៈវិនិច្ឆ័យដែលបានព្រមព្រៀង។

### ១០.៤.៤.ការគ្រប់គ្រងដោយផ្ទាល់ពីថ្នាក់ជាតិចំពោះសាលាជំនាន់ថ្មី៖

- សាលារដ្ឋគ្រប់គ្រងដោយឯករាជ្យដែលត្រូវបានចាត់តាំងជាសាលាជំនាន់ថ្មីដោយផ្ទាល់ពីថ្នាក់ជាតិដោយប្រើប្រាស់ក្រុមប្រឹក្សាជាតិគ្រប់គ្រងដោយក្រសួងអប់រំយុវជននិងកីឡា។
- លះបង់ការគ្រប់គ្រងថ្នាក់កណ្តាលទៅក្រុមប្រឹក្សាត្រួតពិនិត្យក្នុងតំបន់នៅឆ្នាំក្រោយនៅពេលចំនួនសាលារៀនជំនាន់ថ្មីកើនឡើង។

### ១០.៤.៦.ការទទួលខុសត្រូវរបស់សាលារៀនជំនាន់ថ្មី

ពង្រឹងការទទួលខុសត្រូវរបស់គណៈគ្រប់គ្រងសាលាដោយប្រើប្រាស់ពហុយុទ្ធសាស្ត្ររួមមាន៖

- ជ្រើសរើសគណៈគ្រប់គ្រងសាលាតាមរយៈការប្រកួតប្រជែង ការលើកទឹកចិត្តផ្សារភ្ជាប់នឹងការបំពេញភារកិច្ចបានល្អ
- បង្កើតក្រុមប្រឹក្សាភិបាលថ្នាក់ជាតិថ្មីមួយដែលពង្រឹងការអនុវត្តលក្ខណៈវិនិច្ឆ័យតឹងរឹងសម្រាប់ការរៀបចំសាលារៀនជំនាន់ថ្មី
- ដកហូតការទទួលស្គាល់ឋានៈជាសាលារៀនជំនាន់ថ្មី និងដកការវិនិយោគមកវិញក្នុងករណីដែលសាលាមិនបានបំពេញលក្ខណៈវិនិច្ឆ័យដូចបានព្រមព្រៀង។




*រូបភាព 47*

### ១០.៤.៧.ការត្រួតពិនិត្យសាលារៀនជំនាន់ថ្មីដោយផ្ទាល់ពីថ្នាក់ជាតិ

- ត្រួតពិនិត្យដោយផ្ទាល់ពីថ្នាក់ជាតិទៅលើសាលារៀនសាធារណៈស្វយ័ត ដែលបានរៀបចំជាសាលារៀនជំនាន់ថ្មី តាមរយៈក្រុមប្រឹក្សាភិបាលថ្នាក់ជាតិ បង្កើតឡើងក្រសួងអប់រំ យុវជន និងកីឡា។
- ប្រគល់អំណាចគ្រប់គ្រងទៅឱ្យក្រុមប្រឹក្សាភិបាលថ្នាក់មូលដ្ឋាន នៅពេលដែលចំនួនសាលារៀនជំនាន់ថ្មីកើនឡើងនៅឆ្នាំបន្តបន្ទាប់។

### ១០.៤.៨.ការលើកទឹកចិត្តគ្រូ

- ផ្តល់ការលើកទឹកចិត្តពិសេសដល់គ្រូដើម្បីធ្វើឱ្យប្រសើរឡើងនូវការអនុវត្តតាមយុទ្ធសាស្ត្រក៏ដូចជាការលុបបំបាត់ការបង្រៀនឯកជនដល់សិស្សផ្ទាល់ខ្លួនដែលធ្វើឱ្យខូចដល់ស្តង់ដារវិជ្ជាជីវៈនិងសេចក្តីថ្លៃថ្នូរក្នុងចំណោមគ្រូ

- ផ្តល់ប្រាក់លើកទឹកចិត្តពិសេសដល់គ្រូបង្រៀន ដើម្បីលើកកម្ពស់ការបំពេញភារកិច្ចឈានទៅលុបបំបាត់ការបង្រៀនឯកជនសិស្សរបស់ខ្លួនដែលប៉ះពាល់ដល់វិជ្ជាជីវៈនិងសេចក្តីថ្លៃថ្នូរគ្រូបង្រៀន។

### ១០.៤.៦.ដំណើរការស្វ័យភាពផ្សារភ្ជាប់នឹងការច្នៃប្រឌិតថ្មី

- អនុញ្ញាតឱ្យប្រតិបត្តិការក្រៅក្របខណ្ឌគោលនយោបាយដែលបានអនុវត្តនៅក្នុងសាលារៀនធម្មតា ដរាបណាសាលានោះអាចបង្ហាញឱ្យឃើញសកម្មភាពដែលបានស្នើសុំលើកកម្ពស់ការប្រឌិតថ្មីដើម្បីបង្កើនគុណភាពអប់រំ មានសិទ្ធិជ្រើសរើសគ្រូមកពីសាលានានា
- កែលម្អកម្មវិធីសិក្សា ការប្រើប្រាស់បច្ចេកវិទ្យាដើម្បីបង្កើនប្រសិទ្ធិភាពអប់រំ ដូចជាការធ្វើកិច្ចតែងការបង្រៀនអេឡិចត្រូនិក ការសិក្សាតាមឧបករណ៍ចល័ត ជាដើម។និងទម្រង់ផ្សេងៗទៀតនៃការច្នៃប្រឌិតថ្មីក្នុងការសិក្សា ព្រមទាំងការផ្តល់ឱ្យដំណើរការស្វ័យភាពនិងផ្អែកលើភស្តុតាងនៃការច្នៃប្រឌិតថ្មីៗ។

### ១០.៤.៧.ការប្រើប្រាស់បច្ចេកវិទ្យាឱ្យបានទូលំទូលាយដើម្បីជំរុញការច្នៃប្រឌិតថ្មី

- ប្រើប្រាស់បច្ចេកវិទ្យាដែលនិងក្លាយជាធាតុគន្លឹះនៅក្នុងសាលារៀនជំនាន់ថ្មីNGS ដោយមិនត្រឹមតែរាប់បញ្ចូលទាំងជំនាញរឹងប៉ុណ្ណោះទេប៉ុន្តែនិស្សិតអាចប្រើប្រាស់ជំនាញទន់ដែលនឹងជួយបង្កើនការបង្រៀន រៀន និងការវាយតម្លៃផងដែរ។
- សិស្សត្រូវចេះប្រើជំនាញទន់ក្នុងការអប់រំទំនើបទៀតផងដែលនឹងជួយពង្រឹងការសិក្សា ការបង្រៀន និងការវាយតម្លៃ។



*រូបភាព 48៖ ការច្នៃប្រឌិតឬបង្កើតថ្មី*

### ១០.៤.៨.ការពង្រឹងសិទ្ធិអំណាចយុវជន

ទម្លាប់សិស្សឱ្យអនុវត្តតួនាទីដ៏សំខាន់លើការគ្រប់គ្រងសម្ភារៈនិងសេវាថ្មីៗរៀបចំឱ្យមានមណ្ឌលយុវជននៅក្នុងសាលា ដែលផ្តល់កន្លែងឱ្យសិស្សធ្វើផែនការសកម្មភាពពិសេសដោយប្រើប្រាស់មូលនិធិវិនិយោគពិសេស ដែលសាលារៀនផ្តល់ឱ្យ ព្រមទាំងទទួលបានសេវាប្រឹក្សាអាជីព និងប្រឹក្សាយោបល់ផ្សេងៗ។

### ១០.៤.៩.ការបង្កើនម៉ោងបង្រៀននិងរៀន

- បង្កើនម៉ោងបង្រៀនដល់ ៣៤ ម៉ោងសិក្សាក្នុងមួយសប្តាហ៍ក្នុងកម្រិតបឋមសិក្សា និង ៤០ ម៉ោងក្នុងមួយសប្តាហ៍កម្រិតមធ្យមសិក្សា
- តម្រូវឱ្យគ្រូប្រកាន់ខ្ជាប់វិន័យតាមសេចក្តីណែនាំផ្លូវការដែលតម្រូវឱ្យគាត់បង្រៀនពេញម៉ោង (១៨ម៉ោងក្នុងមួយសប្តាហ៍សម្រាប់គ្រូបង្រៀនមធ្យមសិក្សាបឋមភូមិ និង១៦ក្នុងមួយសប្តាហ៍សម្រាប់គ្រូបង្រៀនមធ្យមសិក្សាទុតិយភូមិ)។

### ១០.៤.១០.ការដាក់ឱ្យអនុវត្តប្រភេទមុខវិជ្ជា

តម្រូវឱ្យប្រើប្រាស់ម៉ោងបង្រៀនបន្ថែមដើម្បីផ្តល់ការអនុវត្តប្រភេទមុខវិជ្ជាពិសេសដែលអាចផ្តោតទៅលើមុខវិជ្ជា STEM ភាសាបរទេសឬផ្នែកផ្សេងៗទៀតតាមតម្រូវការរបស់សហគមន៍តាមមូលដ្ឋាន។

### ១០.៤.១១.មូលនិធិសមធម៌សង្គម

- តម្រូវឱ្យបង្ហាញការឆ្លើយតបនឹងតម្រូវការសមាជិកសហគមន៍ក្រីក្រ ផ្តល់ការលើកទឹកចិត្តដល់គ្រួសារ ក្រីក្រក្នុងការរក្សាកូនឱ្យមកទទួលការអប់រំ
- បង្កើតមូលនិធិសមធម៌សង្គម ដែលនឹងអាចឱ្យសាលាទទួលបានមូលនិធិបន្ថែមដើម្បីជួយដល់សិស្ស ក្រីក្រ
- លុបបំបាត់ចោលឱ្យបានដាច់ខាត់ការយកតម្លៃក្រៅផ្លូវការដែលប៉ះពាល់ដល់សិស្សក្រីក្រ

### ១០.៤.១២.សាលារៀននៅក្នុងសាលារៀនគំរូ

- ជ្រើសរើសយុទ្ធសាស្ត្រ សាលាក្នុងសាលា ដែលនៅក្នុងនោះមានការបង្កើតរចនាសម្ព័ន្ធថ្មីមួយនៅក្នុងសាលាដែលមានស្រាប់ដើម្បីដោះស្រាយបញ្ហាប្រឈម
- តម្រូវឱ្យមានការជ្រើសរើសនាយកសាលានិងគ្រូបង្រៀនតាមរយៈការប្រកួតប្រជែងការជ្រើសរើសសិស្ស ការបង្កើតកម្មវិធីសិក្សាថ្មីនឹងការរិះរកវិធានការផ្សេងៗដទៃទៀត ដោយសារភ្ជាប់ជាមួយគំរូសាលារៀនជំនាន់ថ្មី។

### ១០.៤.១៣.ការកាត់បន្ថយផលធៀបគ្រូ-សិស្ស

អនុញ្ញាតឱ្យសាលារៀនកាត់បន្ថយផលធៀបគ្រូ សិស្ស ដើម្បីបង្កើនគុណភាពការសិក្សាជាបុគ្គល។

### ១០.៤.១៤.ការផ្លាស់ប្តូរផ្នត់គំនិតជាបុគ្គល

ផ្លាស់ប្តូរឥរិយាបទគ្រប់អ្នកពាក់ព័ន្ធរួមមាន នាយក នាយិការសាលា គ្រូបង្រៀន មន្រ្តីរដ្ឋបាល សិស្ស មាតិបិតា ដើម្បីឆ្លើយតបទៅនៅការសិក្សាសតវត្សរ៍ទី២១។

### ១០.៤.១៥.ការធ្វើទំនើបកម្មបរិស្ថានសិក្សា

ប្រើគំនិតច្នៃប្រឌិតក្នុងស្ថាបត្យកម្មអប់រំ ដើម្បីកែប្រែបន្ទប់រៀននិងបន្ទប់ផ្សេងៗទៀតក្នុងសាលារៀនឱ្យសមស្របទៅនឹងស្តង់ដាសាលារៀនសតវត្សរ៍ទី២១។

## សន្និដ្ឋាន

មូលហេតុនៃការបង្កើតសាលារៀនជំនាន់ថ្មី។ការបង្កើតគោលនយោបាយថ្មីក្នុងការអភិវឌ្ឍសាលាជំនាន់ថ្មី ក្នុងគោលបំណងលើកកម្ពស់គុណភាពអប់រំ។គោលការណ៍សាលាជំនាន់ថ្មី នឹងផ្តល់ការណែនាំដល់អ្នកអប់រំ និងសិស្ស ឱ្យយល់កាន់តែច្បាស់ពីវិធីសាស្រ្តថ្មីៗដូចជា ការរៀនតាមបែបស្ថាបនា និងដោះស្រាយបញ្ហា។ ក្រសួងនិងដៃគូអភិវឌ្ឍន៍ធ្វើការវិនិយោគតាមសាលារៀនដែលបានជ្រើសរើស។

## សំណួរ

១.តើអ្នកអប់រំត្រូវមានផែនការសកម្មភាពអ្វីខ្លះដើម្បីធ្វើឱ្យសម្រេចបាននូវយុទ្ធវិធីសំខាន់ៗនេះ?

២.ដើម្បីត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តន៍គម្រោងសាលាជំនាន់ថ្មីតើអ្នកអប់រំត្រូវប្រើយុទ្ធសាស្រ្តអ្វីខ្លះ?

# មេរៀន១១ ការគ្រប់គ្រងសាលារៀន ( ផ្នែកទី ១ )

## វត្ថុបំណង

- កំណត់ថាការគ្រប់គ្រងសាលាជាអ្វី?
- ពន្យល់ពីមូលហេតុដែលការគ្រប់គ្រងសាលារៀននៅប្រទេសកម្ពុជាត្រូវចាំបាច់
- កំណត់ស្តង់ដារផ្សេងៗគ្នានៅក្នុងការគ្រប់គ្រង

## ១១.១.សេចក្តីផ្តើម

ថ្នាក់ដឹកនាំនៃក្រសួងអប់រំយុវជននិងកីឡានិងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានគោលបំណងបង្កើតសាលាអប់រំទូទៅប្រកបដោយប្រសិទ្ធភាពតាមរយៈការអនុវត្តប្រព័ន្ធគ្រប់គ្រងសាលារៀនដែលត្រូវបានពិពណ៌នានៅក្នុងសៀវភៅណែនាំអេសប៊ីអេស។សៀវភៅណែនាំអេសប៊ីអេសត្រូវបានរៀបចំឡើងដោយផ្អែកលើគោលការណ៍ចំនួន ៣ ដែលត្រូវបានព្រមព្រៀងគ្នា៖

- ពង្រឹងសមត្ថភាពប្រព័ន្ធដើម្បីអនុវត្តការគ្រប់គ្រងសាលាដោយប្រសិទ្ធភាព។
- ការកែលំអប្រសិទ្ធភាពគ្រូតាមរយៈការគ្រប់គ្រងបុគ្គលិកដោយផ្អែកលើការអនុវត្តន៍ការងារ។
- លើកកម្ពស់ការចូលរួមរបស់សហគមន៍ក្នុងស្វ័យភាពសាលានិងគណនេយ្យភាព។

## ១១.២.សាវតានិងនិយមន័យការគ្រប់គ្រងសាលារៀន( SBM)

### ១១.២.១.សាវតាសង្ខេបរបស់SBM

ថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡានិងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានបំណងធ្វើឱ្យសាលារៀនក្លាយជាកន្លែងផ្តល់សេវាអប់រំប្រកបដោយគុណភាព បរិយាប័ន្ន ប្រសិទ្ធភាព និងលើកកម្ពស់ការអប់រំពេញមួយជីវិតសម្រាប់ទាំងអស់គ្នា តាមរយៈការអនុវត្តការគ្រប់គ្រងតាមសាលារៀន ដែលនឹងអធិប្បាយនៅក្នុងសៀវភៅណែនាំប្រតិបត្តិនេះ។សៀវភៅនេះត្រូវបានរៀបចំឡើងដោយផ្អែកលើគោលការណ៍ចំនួនបី៖ ទី១ ការ ពង្រឹងសមត្ថភាពប្រព័ន្ធអប់រំដើម្បីអនុវត្តការគ្រប់គ្រងតាមសាលារៀន ទី២ ការពង្រឹងប្រសិទ្ធភាពគ្រូបង្រៀន តាមរយៈការអនុវត្តការគ្រប់គ្រងការអនុវត្តការងាររបស់គ្រូបង្រៀន និងទី៣ ការលើកកម្ពស់ការចូលរួមរបស់ សហគមន៍ក្នុងស្វ័យភាពនិងគណនេយ្យភាពសាលារៀន។

ការគ្រប់គ្រងតាមសាលារៀនមានគោលបំណងពីរគឺ ១-រៀបចំសាលារៀនឱ្យបំពេញបាននូវស្តង់ដា សាលារៀនមានប្រសិទ្ធភាព ដោយការកសាងសមត្ថភាពដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីថ្នាក់ជាតិ ថ្នាក់ ក្រោមជាតិ និងសាលារៀន ដើម្បីធានាថាការគាំទ្រត្រូវបានផ្តល់ឱ្យសាលារៀនទាន់ពេលវេលា និង ២ កសាងសមត្ថភាពគ្រូបបង្រៀនដើម្បីអនុវត្តកម្មវិធីសិក្សារបស់ជាតិ។ដើម្បីសម្រេចបាននូវគោលបំណង ទាំងពីរខាងលើនេះ មានសកម្មភាពចំនួន៣ ដែលត្រូវអនុវត្ត៖ ១- ពង្រឹងការគ្រប់គ្រងតាមសាលារៀន ២ បំប៉នបន្ថែមនិងផ្តល់ការគាំទ្រផ្ទាល់ដល់គ្រូបង្រៀន និង ៣- សាងសង់និងកែលម្អអគារសិក្សា និងបរិស្ថាន សិក្សា។សៀវភៅណែនាំប្រតិបត្តិនេះរៀបរាប់ពីរបៀបអនុវត្តសកម្មភាពទី១ និងទី២។

ការគ្រប់គ្រងតាមសាលារៀនជាយន្តការដ៏មានប្រសិទ្ធភាពមួយក្នុងការអនុវត្តវិមជ្ឈការនៃការអប់រំ ដើម្បីធានាឱ្យសេវាអប់រំមានប្រសិទ្ធភាពខ្ពស់។ ការគ្រប់គ្រងតាមសាលារៀនត្រូវបានចាត់ទុកជាវិធី (១) ប្រកួតប្រជែងការរក្សា ការពិនិត្យ និងតុល្យភាពផ្ទៃក្នុងរបស់ក្រសួងអប់រំ យុវជន និងកីឡា រួមមានការផ្តល់ ធនធាន សិទ្ធិអំណាច និងការកសាងសមត្ថភាពដើម្បីបង្កើនលទ្ធផលសិក្សារបស់សិស្ស(២) ធ្វើឱ្យក្រសួងអប់រំ យុវជន និងកីឡាអាចឆ្លើយតបបានច្រើនជាងមុន ក្នុងការផ្តល់សេវាអប់រំនៅសាលារៀន និងក្នុងការដោះ ស្រាយបញ្ហាបានទាន់ពេល និងមានប្រសិទ្ធភាពខ្ពស់ (៣)កាត់បន្ថយភាពតានតឹងសង្គម និងនយោបាយ និង ធានាបាននូវស្វ័យភាព និងតម្លាភាពមូលដ្ឋាន ដោយសារតែសាធារណជនបានរួមចំណែកទទួលខុសត្រូវ និងដោះស្រាយបញ្ហាជាមួយរដ្ឋ។ ក្នុងន័យនេះការគ្រប់គ្រងតាមសាលារៀន គឺការផ្តល់ស្វ័យភាពក្នុងការ សម្រេចចិត្តទៅកម្រិតមូលដ្ឋានដោយផ្អែកលើលទ្ធផលនៃការអនុវត្តការងាររបស់សាលារៀន និងលទ្ធផលសិក្សារបស់សិស្ស។ប្រការនេះជាជំហរអនុវត្តនូវការសម្រេចចិត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីឱ្យសាលារៀនទាំងអស់អាចសម្រេចបានស្តង់ដាទាំង ៩ ស្តីពីសាលារៀនមានប្រសិទ្ធភាព(សៀវភៅណែនាំប្រតិបត្តិស្តីពីការគ្រប់គ្រងតាមសាលារៀនគម្រោងកែលម្អការអប់រំនៅមធ្យមសិក្សាឆ្នាំ ២០១៨)។

១១.២.២.និយមន័យផ្សេងៗរបស់ SBM

ការគ្រប់គ្រងតាមសាលារៀន (SBH) គឺជាវិធីសាស្ត្រអនុវត្តវិមជ្ឈការនៃការអប់រំ ដើម្បីឱ្យសេវាអប់រំមានប្រសិទ្ធភាព ដែលបង្ហាញតាមរយៈភ័ស្តុតាងសមិទ្ធកម្មនៃការអនុវត្តគោល នយោបាយអប់រំជំនួសឱ្យការគ្រប់គ្រងតាមបែបមជ្ឈមការពីថ្នាក់កណ្តាល។ការគ្រប់គ្រងតាមសាលារៀនផ្តល់នូវគុណប្រយោជន៍ដូចជា ៖ ណែនាំឱ្យមាននូវការប្រកួតប្រជែង ការរក្សាការពិនិត្យសមិទ្ធកម្មផ្ទៃក្នុងរដ្ឋ និងតុល្យភាពផ្ទៃក្នុងរដ្ឋ (ផ្តល់ធនធាន អំណាចនិងការកសាងសមត្ថភាព)ធ្វើឱ្យរដ្ឋមានការឆ្លើយតបច្រើនជាងមុននិងឱ្យសេវាសាធារណៈមានប្រសិទ្ធភាព (ដោះស្រាយបញ្ហាទានពេល និងមានប្រសិទ្ធភាព) បន្ថយភាពតានតឹងក្នុងសង្គម និងនយោបាយ និងធានានូវស្វ័យភាពមូលដ្ឋាន(សាធារណៈរួមចំណែកទទួលខុសត្រូវនិងដោះស្រាយបញ្ហាជាមួយរដ្ឋ)(កញ្ចប់ឯកសារបណ្តុះបណ្តាលការគ្រប់គ្រងសាលារៀនភ្នំពេញឆ្នាំ២០១៩)។

ការគ្រប់គ្រងតាមសាលារៀន(SBM)ត្រូវបានកំណត់ជាវិមជ្ឈការនៃសិទ្ធិអំណាចពីរដ្ឋាភិបាលកណ្តាល ដល់កំរិតសាលារៀន (Caldwell, 2005)។ នៅក្នុងពាក្យរបស់ Wongs (2003, p.243) បានកំណត់ និយមន័យវិមជ្ឈការនៃការសម្រេចចិត្តពីមន្ទីរអប់រំទៅសាលារៀនទាក់ទងនឹងនីតិវិធីបុគ្គលិក បញ្ហាហិរញ្ញវត្ថុ និងការរចនា និងការផ្តល់កម្មវិធីសិក្សា។ Murphy (១៩៩៧)បានអះអាងថាSBMគឺពាក់ព័ន្ធនឹងការចែកចាយសិទ្ធិអំណាចវិមជ្ឈការ ពីការិយាល័យកណ្តាល និងតំបន់ទៅសាលារៀនមូលដ្ឋាន។ Caldwell & Spinks (១៩៨៨ ទំព័រ ៥) កំណត់និយមន័យSBMថា"ជាកិច្ចការដែលជាវិមជ្ឈការមួយដែលមានសារៈសំខាន់ និងវិមជ្ឈការដល់ថ្នាក់សាលាដើម្បីធ្វើការសម្រេចចិត្តទាក់ទងនឹងការបែងចែកធនធាន (ចំណេះ ដឹង បច្ចេកវិទ្យា ថាមពល សម្ភារៈ មនុស្ស ពេលវេលា និងហិរញ្ញវត្ថុ)។"

Wohlstetter (ឆ្នាំ ១៩៩៣) បាន កំណត់និយមន័យSBMជាយុទ្ធសាស្ត្រមួយដើម្បីកែលំអការអប់រំដោយប្តូរសិទ្ធិអំណាចធ្វើការសម្រេចចិត្ត សំខាន់ៗពីការិយាល័យរដ្ឋនិងស្រុកទៅសាលារៀននីមួយៗ។ SBMផ្តល់ឱ្យនាយកសាលា លោកគ្រូអ្នកគ្រូ សិស្សានុសិស្ស និងឪពុកម្តាយឱ្យគ្រប់គ្រងលើដំណើរការអប់រំដោយផ្តល់ការទទួលខុសត្រូវដល់ពួកគេក្នុង ការសម្រេចចិត្តអំពីថវិកាបុគ្គលិក និងកម្មវិធីសិក្សា។ តាមរយៈការចូលរួមរបស់លោកគ្រូអ្នកគ្រូ ឪពុកម្តាយ និងសមាជិកសហគមន៍ដទៃទៀតក្នុងការសម្រេចចិត្តសំខាន់ៗទាំងនេះSBMអាចបង្កើតបរិយាកាសរៀនសូត្រប្រកបដោយប្រសិទ្ធភាពសម្រាប់សិស្សានុសិស្ស។

ការគ្រប់គ្រងតាមសាលារៀន(SBM) គឺជាវិធីសាស្ត្រអនុវត្តវិមជ្ឈការនៃការអប់រំដើម្បីឱ្យសេវាអប់រំមានប្រសិទ្ធភាពដែលបង្ហាញតាមរយៈភស្តុតាងសមិទ្ធកម្មនៃការអនុវត្តគោលនយោបាយអប់រំជំនួសឱ្យការគ្រប់គ្រងតាមបែបវិមជ្ឈការពីថ្នាក់កណ្តាល។

## ១១.៣.សារៈសំខាន់នៃការគ្រប់គ្រងសាលារៀន

ការគ្រប់គ្រងតាមសាលារៀនផ្តល់គុណប្រយោជន៍ដូចខាងក្រោម៖

- ណែនាំឱ្យមាននូវការប្រកួតប្រជែង ការរក្សាការពិនិត្យសមិទ្ធកម្មផ្ទៃក្នុងរដ្ឋ និងតុល្យភាពផ្ទៃក្នុងរដ្ឋ (ផ្តល់ធនធាន អំណាច និងការកសាងសមត្ថភាព)
- ធ្វើឱ្យរដ្ឋមានការឆ្លើយតបច្រើនជាងមុន និងឱ្យសេវាសាធារណៈមានប្រសិទ្ធភាព(ដោះស្រាយបញ្ហាទាន់ពេល និងមានប្រសិទ្ធភាព)
- បន្ថយភាពតានតឹងក្នុងសង្គម នយោបាយ និងធានានូវស្វ័យភាពមូលដ្ឋាន(សាធារណៈរួមចំណែកទទួលខុសត្រូវ និងដោះស្រាយបញ្ហាជាមួយរដ្ឋ)។
- ការគ្រប់គ្រងសាលារៀនប្រកបដោយនិរន្តភាព

ដើម្បីឱ្យការគ្រប់គ្រងតាមសាលារៀនប្រកបដោយនិរន្តភាពការគ្រប់គ្រងត្រូវមានស្តង់ដាក្នុងការគ្រប់គ្រងដូចជា

- ស្តង់ដាទី១៖ វត្ថុបំណងគោលនយោបាយសាលារៀន
- ស្តង់ដាទី២៖ការបង្រៀននិងរៀន
- ស្តង់ដាទី៣៖មាតាបិតានិងសហគមន៍ជួយដល់ការរៀនសូត្ររបស់សិស្ស
- ស្តង់ដាទី៤៖ កុមារតូច និងសេវាជួយកុមារតូច
- ស្តង់ដាទី៥៖ការដឹកនាំនិងការគ្រប់គ្រង
- ស្តង់ដាទី៦៖ធនធានមនុស្ស
- ស្តង់ដាទី៧៖សម្ភារបង្រៀននិងរៀន និងសៀវភៅសិក្សាគោល
- ស្តង់ដាទី៨៖ហេដ្ឋារចនាសម្ព័ន្ធ សង្ហារឹម សម្ភារលេងក្រៅថ្នាក់ និងបរិស្ថាន
- ស្តង់ដាទី៩៖ហិរញ្ញប្បទាន និងការគ្រប់គ្រងហិរញ្ញវត្ថុ។

## ១១.៤.យុទ្ធសាស្ត្រអនុវត្តកម្មវិធីការគ្រប់គ្រងតាមសាលារៀន ប្រព័ន្ធ៣ អាចិតជិត




*រូបភាព 49*

## សន្និដ្ឋាន

ការគ្រប់គ្រងសាលារៀនមានគោលដៅសំខាន់ពីរគឺ រៀបចំសាលារៀនដើម្បីបំពេញតាមស្តង់ដារសាលារៀនប្រកបដោយប្រសិទ្ធភាពក្នុងការកសាងភាពជាអ្នកដឹកនាំនិងសមត្ថភាពគ្រប់គ្រងមន្ត្រីអប់រំពីថ្នាក់កណ្តាលថ្នាក់ក្រោមជាតិនិងថ្នាក់សាលារៀនដើម្បីអាចផ្តល់ការគាំទ្រដល់សាលារៀនបានទាន់ពេលវេលានិង កសាងសមត្ថភាពគ្រូ អនុវត្តកម្មវិធីសិក្សារបស់រដ្ឋ។

ដើម្បីសម្រេចបាននូវគោលដៅទាំងនេះមានសកម្មភាពសំខាន់ៗចំនួន ៣ គឺៈ (១)ពង្រឹងការគ្រប់គ្រងសាលារៀនតាមរយៈស្វ័យភាពនិងគណនេយ្យភាព (២)ផ្តល់ការបណ្តុះបណ្តាលនិងគាំទ្រដល់គ្រូ។

(៣)សាងសង់និងជួសជុលហេដ្ឋារចនាសម្ព័ន្ធនិងបរិស្ថានសាលារៀន។

## សំណួរ

១.តើការគ្រប់គ្រងសាលារៀនជាអ្វី?

២.ហេតុអ្វីបានជាការគ្រប់គ្រងសាលារៀនមានភាពចាំបាច់?

៣.តើធ្វើដូចម្តេចដើម្បីធ្វើឱ្យការគ្រប់គ្រងសាលារៀនមាននិរន្តរភាព?

# មេរៀនទី ១២ ការគ្រប់គ្រងសាលារៀន ( ផ្នែកទី ២ )

## វត្ថុបំណង

បន្ទាប់ពីសិក្សាមេរៀននេះចប់គរុនិស្សិតនឹង៖

- និយមន័យនៃ ការដឹកនាំ អ្នកដឹកនាំ និងភាពជាអ្នកដឹកនាំ
- ភាពខុសគ្នារវាងការដឹកនាំ និងការគ្រប់គ្រង
- យល់ដឹងអំពីសមាសភាគទាំង៤ នៃការគ្រប់គ្រងតាមសាលារៀន

## ១២.១.និយមន័យ

- **ការដឹកនាំ** គឺជាការបណ្តុះ និង ជំរុញ មនុស្សឱ្យរីកចម្រើន មានការប្រែប្រួល ក្នុងការជឿជាក់នឹងសកម្មភាពរបស់គេដែលអាចឱ្យគេជួយសាលារៀនក្លាយជាកន្លែងមួយកាន់តែល្អប្រសើរឡើងសម្រាប់ សិស្ស។
- **អ្នកដឹកនាំ** គឺជាបុគ្គលដែលទទួលស្គាល់ពីសមាជិក ក្នុងអង្គភាព ដើម្បីឱ្យធ្វើជាតំណាង ក្នុងការដឹកនាំអង្គភាពឱ្យបានសម្រេចគោលដៅ។
- **ភាពជាអ្នកដឹកនាំ** គឺជាសមត្ថភាពនៃការបណ្តុះ និងជំរុញ មនុស្សឱ្យប្រឹងប្រែងធ្វើការកាន់តែប្រសើរឡើងប្រកបដោយភាពច្នៃប្រឌិត ចេះគិតតាមវិធីប្លែកៗ និងហ៊ានប្រថុយសាកល្បងនូវគំនិតថ្មីៗដើម្បីឱ្យកុមារទាំងអស់រៀនបានប្រកបដោយជោគជ័យ។

## ១២.២.ភាពខុសគ្នារវាងការដឹកនាំ និងការគ្រប់គ្រង

| ការដឹកនាំ | ការគ្រប់គ្រង |
|---|---|
| -ផ្តើមគំនិត | -ចម្លង |
| -បង្កើត | -រក្សា |
| -បណ្តុះទំនុកចិត្ត | -ត្រួតត្រា |
| -គិតសម្រាប់រយៈពេលវែង | -គិតសម្រាប់រយៈពេលខ្លី |
| -សួរអំពី អ្វី និង ហេតុអ្វី? | -សួរអំពី ដូចម្តេច និង ពេលណា? |
| -គិតគ្រប់ជ្រុងជ្រោយ | -គិតត្រឹមចំណុចសំខាន់ |

## ១២.៣. យល់ដឹងអំពីសមាសភាគទាំង៤ នៃការគ្រប់គ្រងតាមសាលារៀន

- ការគ្រប់គ្រងការរៀន និងការបង្រៀន
- ការគ្រប់គ្រងរដ្ឋបាល
- ការគ្រប់គ្រងធនធានមនុស្ស
- ការគ្រប់គ្រងហិរញ្ញវត្ថុ

| កិច្ចការ | ក្រសួង អយក | មន្ទីរ អយក | ការិយាល័យ អយក | សាលារៀន |
|---|---|---|---|---|
| **ការគ្រប់គ្រងការរៀន និងបង្រៀន** | | | | |
| កម្មវិធីសិក្សា | ផលិតបណ្តាញចំណេះដឹង សំណួរតេស្តសព្វគ្រប់បំប៉នសមត្ថភាព | បំប៉នសមត្ថភាព | សម្របសម្រួលសាលារៀនក្នុងស្រុកឱ្យរៀននិងធ្វើតេស្ត | ផលិតសំនួរតេស្តបន្ថែម អនុវត្តតេស្ត ប្រើលទ្ធផលតេស្ត កែលម្អការបង្រៀន បង្រៀនបំណិនការងារ |
| សម្ភារៈសិក្សា | ផលិត ផ្តល់សៀវភៅសិក្សាគោល និងឯកសារវិធីសាស្ត្របង្រៀន | បន្តរបញ្ជូនសៀវភៅសិក្សាគោលរំលែកពិសោធន៍ | បន្តរបញ្ជូនសៀវភៅសិក្សាគោលសម្របសម្រួលឱ្យសាលារៀនក្នុងស្រុកអោយប្រើសម្ភារបង្រៀនល្អៗ | ផលិតសម្ភារបង្រៀន ទិញពីផ្សារនូវសៀវភៅគោលខ្វះ |
| ប្រតិទិនសិក្សា | កំណត់បទដ្ឋាន សម្របសម្រួលបន្ថយការរំខានពេលរៀនសូត្រសិស្ស | សម្របសម្រួលបន្ថយការរំខានពេលរៀនសូត្រសិស្ស | សម្របសម្រួលបន្ថយការរំខានពេលរៀនសូត្រសិស្ស | អនុវត្តម៉ោងបង្រៀនពេញលេញតាមកម្មវិធីសិក្សា |
| **ការគ្រប់គ្រងរដ្ឋបាល** | | | | |
| ការធ្វើផែនការ | ធ្វើផែនការក្រសួងបង្កើតសាលារៀនគំរូមួយនៅខេត្ត១ | ធ្វើផែនការខេត្តបង្កើតសាលារៀនគំរូមួយនៅស្រុក១ | ធ្វើផែនការស្រុកពង្រីកសាលារៀនគំរូក្នុងស្រុក | ធ្វើផែនការសាលារៀន |

| | | | | |
|---|---|---|---|---|
| ការពិនិត្យតាមដាន | ពិនិត្យលទ្ធផលផលិតក្នុងឆ្នាំបំប៉នសមត្ថភាពភ្នាក់ងារ និងសាលារៀន | ពិនិត្យលទ្ធផលផលិតក្នុងឆ្នាំបំប៉នសមត្ថភាពភ្នាក់ងារ និងសាលារៀន | ពិនិតលទ្ធផលផលិតក្នុងឆ្នាំបំប៉នសមត្ថភាពសាលារៀន | ពិនិត្យលទ្ធផលត្រីមាសនិងឆ្នាំអធិការកិច្ចផ្ទៃក្នុង |
| ការផ្សព្វផ្សាយ | កំណត់ទិន្នន័យត្រូវផ្សព្វផ្សាយផ្សព្វផ្សាយថ្នាក់ជាតិ | ផ្សព្វផ្សាយថ្នាក់ខេត្ត | ផ្សព្វផ្សាយថ្នាក់ស្រុក | ផ្សព្វផ្សាយនៅសហគមន៍ |
| **ការគ្រប់គ្រងធនធានមនុស្ស** | | | | |
| ការជួលនិងបញ្ឈប់បុគ្គលិក | កំណត់ចំនួនត្រូវការឆ្នាំ | ចាត់តាំងគ្រូបង្រៀនទៅសាលារៀនខ្វះគ្រូបញ្ឈប់គ្រូបង្រៀន | សម្របសម្រួលទំនាក់ទំនងរវាងសាលារៀននិងមន្ទីរអប់រំ | ជ្រើសរើសគ្រូបង្រៀនគ្រប់គ្រងការអនុវត្តការងាររបស់គ្រូបង្រៀនស្នើបញ្ឈប់គ្រូបង្រៀន |
| ការអភិវឌ្ឍវិជ្ជាជីវៈ | បណ្តុះគ្រូបង្រៀនថ្មីបង្កើនគុណវុឌ្ឍិគ្រូបង្រៀន | បន្ថយគ្រូលើសដោយមិនបន្ថែមគ្រូទៅសាលារៀនមានគ្រូលើស និងផ្ទេរគ្រូបង្រៀនទៅសាលាខ្វះគ្រូ | សម្របសម្រួលឱ្យគ្រូបង្រៀនក្នុងស្រុករៀនពីគ្នា | ស្នើសុំគ្រូបន្ថែមបំពេញចំនួនខ្វះគ្រូផ្តល់ឱកាសឱ្យគ្រូរៀននិងរៀនពីគ្នាទៅវិញទៅមក |
| **ការគ្រប់គ្រងហិរញ្ញវត្ថុ** | | | | |

| | | | | |
|---|---|---|---|---|
| ថវិកានិងប្រាក់បៀវត្ស | បំប៉ននិតិវិធីកំណត់ប្រាក់បៀវត្ស | ប្រើមូលនិធិខេត្តជួយស្រុកនិងសាលារៀន | ប្រើមូលនិធិស្រុកជួយសាលារៀន | គ្រោងថវិការក្សាឯកសារចំណាយកំណត់-ផ្តល់ប្រាក់បៀវត្សបុគ្គលិកជំនួយការ |
| មូលនិធិសាលារៀន | គ្រោងមូលនិធិ | ផ្តល់មូលនិធិទាន់ពេល | សម្របសម្រួលការគ្រោងនិងចំណាយ | រកមូលនិធិបន្ថែមគ្រប់គ្រងការចំណាយមានប្រសិទ្ធិភាព រួមជាមួយថវិការដ្ឋ |
| សំណង់ | ផ្តល់មូលនិធិឬសំណង់ | ជួយរកមូលនិធិ | ជួយរកមូលនិធិ | គ្រប់គ្រងការសាងសង់ ថែរក្សាសំណង់ |

## ១២.៤.គោលបំណងនៃការគ្រប់គ្រងសាលារៀន

- ផ្តល់ស្វ័យភាព និងភាពបត់បែនក្នុងការដឹកនាំ និងគ្រប់គ្រងលើការងារ និងធនធានស្របតាមតម្រូវការរបស់សិស្ស
- ទទួលបានធនធានច្រើនពីការចូលរួមរបស់ឪពុកម្តាយសិស្ស និងសហគមន៍
- ពង្រឹងនូវតម្លាភាពនិងគណនេយ្យភាពក្នុងការប្រើប្រាស់នូវធនធាននានាសម្រាប់អភិវឌ្ឍសាលារៀន
- បង្កើតនូវយន្តការនៃការធ្វើសេចក្តីសម្រេចចិត្តដោយមានការចូលរួមពីគ្រប់ភាគីអ្នកពាក់ព័ន្ធ
- លើកកម្ពស់សមិទ្ធផលការសិក្សារបស់សិស្ស កាត់បន្ថយអាត្រាត្រួតថ្នាក់ កាត់បន្ថយអត្រាការបោះបង់ការសិក្សា

## ១២.៥.តួនាទីអាជ្ញាធរចូលរួមក្នុងការគ្រប់គ្រងសាលារៀន

### តួនាទីអាជ្ញាធរឃុំ សង្កាត់

- គាំទ្រកិច្ចការអប់រំនៅក្នុងឃុំសង្កាត់ឱ្យសម្រេចបាននូវការអនុវត្តគោលនយោបាយការគ្រប់គ្រងតាមសាលា

- បញ្ចូលផែនការកែលម្អសាលារៀននៅក្នុងផែនការឃុំ និងសង្កាត់
- ចូលរួមជាសមាជិកនៃគណកម្មការគ្រប់គ្រងសាលារៀននិងផ្សារភ្ជាប់សាលារៀនជាមួយសហគមន៍
- សម្របសម្រួលនិងការលើកកម្ពស់ការចូលរួមរបស់សហគមន៍ក្នុងការអភិវឌ្ឍសាលារៀននិងការសិក្សារបស់សិស្ស

**តួនាទីអាជ្ញាធរក្រុង ស្រុក ខណ្ឌ**

- គាំទ្រកិច្ចការអប់រំនៅក្នុងក្រុង ស្រុក ខណ្ឌឱ្យសម្រេចបាននូវការអនុវត្តយុទ្ធសាស្ត្រស្នូលនៃយុទ្ធសាស្ត្រចតុកោណ និងគោលនយោបាយការគ្រប់គ្រងសាលារៀន
- ចូលក្នុងការផ្តល់ធនធានមូលដ្ឋានដែលសាលារៀនខ្វះខាតដូចជា គ្រូបង្រៀន អគារសិក្សា បរិស្ថានសាលារៀន និងសម្ភារៈសិក្សាផ្សេងៗ។

**សន្និដ្ឋាន**

ដើម្បីអនុវត្តSBMនិងទទួលបានលទ្ធផលល្អនាយកសាលារៀន និងគ្រូបង្រៀនមានស្វ័យភាព និងគណនេយ្យភាព ចំពោះសហគមន៍ មាតាបិតា និងអ្នកអាណាព្យាបាលសិស្សជាពិសេសលទ្ធផលការសិក្សារៀនសូត្រ គឺការជួយសិស្សរៀនចេះ រៀនចប់និងរៀនរកចំណូលបានច្រើន។ត្រូវបានឆ្លុះបញ្ចាំងជាក់ស្តែងនៅតាមសាលារៀននីមួយៗក្នុងប្រទេសកម្ពុជា និងរិះរកវិធានការដោះស្រាយដោយស្វ័យភាព ដូចជានាយកសាលានិងគ្រូបង្រៀនមិនបានធ្វើកិច្ចការ និងបង្រៀនសិស្សជិតដល់ នាំឱ្យមាតាបិតា និងសហគមន៍ព្រួយបារម្ភលើលទ្ធផលសិក្សារបស់កូនចៅគាត់ និងមានអារម្មណ៍មិនពេញចិត្តចំពោះនាយកសាលា និងគ្រូបង្រៀន។

**សំណួរ**

១.ចូរបកស្រាយពីភាពខុសគ្នារវាងការដឹកនាំ និងការគ្រប់គ្រង។

២. ចូរពន្យល់ពីសមាសភាគទាំង៤ នៃការគ្រប់គ្រងតាមសាលារៀន។

## មេរៀនទី១៣ សាលារដ្ឋ និងសាលាឯកជន

**វត្ថុបំណង**

បន្ទាប់ពីរៀនមេរៀននេះចប់គរុនិស្សិតនឹង៖

- ប្រៀបធៀបបានពីភាពខុសគ្នារវាងសាលារដ្ឋ និង សាលាឯកជន
- កំណត់បានពីវិធីដើម្បីធ្វើឱ្យទាំងសាលារដ្ឋ និង សាលាឯកជនផ្តល់អត្ថប្រយោជន៍ដល់ប្រព័ន្ធអប់រំទាំងមូល។

### ១៣.១. សេចក្តីផ្តើម

បច្ចុប្បន្ននេះការអប់រំនៅកម្ពុជាកំពុងមានការអភិវឌ្ឍជាជំហានៗ ទាំងការអប់រំសាធារណៈ និងឯកជន។ទិដ្ឋភាពទាំងពីរនេះចាំបាច់ត្រូវរួបរួមគ្នាដើម្បីអភិវឌ្ឍប្រទេសយើង។កាលពីមុនមានការអប់រំសាធារណៈប៉ុណ្ណោះដែលដើរតួនាទីយ៉ាងសំខាន់ដើម្បីលើកកម្ពស់ចំណេះដឹងសមត្ថភាពនិងអភិវឌ្ឍសេដ្ឋកិច្ច។ទោះយ៉ាងណាទសវស្សចុងក្រោយឃើញថាការអប់រំឯកជនដ៏ពាក់ព័ន្ធក៏ដើរតួរយ៉ាងសំខាន់នៅក្នុងសង្គមកម្ពុជាផងដែរដែលសាលាឯកជនជះឥទ្ធិពលយ៉ាងខ្លាំងដល់ប្រព័ន្ធអប់រំកម្ពុជា។

### ១៣.២. ចំនួនសាលារដ្ឋ និងសាលាឯកជននៅកម្ពុជា

យោងតាមលោក Phun Han Sin អនុប្រធាននាយកដ្ឋានអប់រំមានប្រសាសន៍ថាទោះបីចំនួនសាលាឯកជននៅតែមានការកើនឡើងក៏ដោយក៏ពួកគេមិនអាចប្រៀបធៀបនិងចំនួនសាលារដ្ឋបានដែរ។លោកមានប្រសាសន៍ថាមានអនុវិទ្យាល័យចំនួន១១៨៩ នៅកម្ពុជា។ទោះយ៉ាងណាគាត់មិនដឹងពីចំនួនសាលាឯកជននោះទេ ព្រោះសាលារៀនខ្លះមិនបានចុះឈ្មោះ។

AKP ភ្នំពេញ ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៩ - រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា បានគូសបញ្ជាក់ថា បច្ចុប្បន្នកម្ពុជាមានសាលាមត្តេ យ្យសិក្សា និងសាលារៀនចំណេះទូទៅ ទាំងសាធារណៈ និងឯកជន ប្រមាណជិត១៥.០០០ កន្លែង នៅទូទាំងប្រទេស។

ថ្លែងក្នុងសន្និបាតបូកសរុបការងារអប់រំ យុវជន និងកីឡា ឆ្នាំសិក្សា២០១៧-២០១៨ និងលើកទិសដៅការងារ ឆ្នាំ២០១៨-២០១៩ កាលពីព្រឹកថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៩ នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ ជួនណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡាបានមានប្រសាសន៍ថា ជាលទ្ធផល នៅទូទាំងប្រទេស យើងមានសាលាមត្តេយ្យសិក្សា និងសាលារៀនចំណេះទូទៅទាំងសាធារណៈ និងឯកជន សរុប១៤.៥២២ ក្នុងនោះ សាលាមត្តេយ្យសិក្សាចំនួន៤.៨១០ សាលាបឋមសិក្សាចំនួន៧.៧១៦ អនុវិទ្យាល័យ ចំនួន១.៣២៤ និងវិទ្យាល័យចំនួន៦៧២។ ឯកឧត្តមបញ្ជាក់ថា គិតមកដល់ខែកញ្ញា ឆ្នាំ២០១៨ សំណង់អគារសិក្សា ដែលជាអំណោយរបស់សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន សរុប ចំនួន៤.៣១០ ខ្នង ស្មើ២៦.៥៣៨បន្ទប់។ ឯកឧត្តមរដ្ឋមន្ត្រីបានបន្តថា តាមរយៈការធ្វើយុទ្ធនាការ ប្រមូលកុមារដល់វ័យសិក្សា ការសាងសង់អគារសិក្សា ការផ្តល់គ្រូបង្រៀន ការផ្តល់ថវិកាដំណើរការ

សាលារៀន ការផ្តល់អាហារូបករណ៍ ដល់សិស្សមកពីគ្រួសារក្រីក្រ ជាពិសេស សិស្សនារី ជាដើម បានបង្កលក្ខណៈ ឱ្យកុមារមានលទ្ធភាពកាន់តែច្រើន ក្នុងការទទួលបានការអប់រំ។

ឯកឧត្តមបណ្ឌិតសភាចារ្យបានលើកឡើងថា បច្ចុប្បន្ន កុមារអាយុ៥ឆ្នាំ បានចូលរៀន នៅមត្តេយ្យសិក្សាគ្រប់រូបភាពមានចំនួន៦៣.១ភាគរយ កុមារី៦៣.៦ភាគរយ។ ជាមួយគ្នានេះ អត្រាពិតនៃការសិក្សានៅបឋមសិក្សាសាធារណៈ និងឯកជនមានចំនួន៩៨.០ភាគរយ (ស្រី៩៨.៥ ភាគរយ) ស្ថិតក្នុងស្តង់ដារ និងក្នុងកម្រិតប្រហាក់ប្រហែល ប្រទេសក្នុងតំបន់។

ឯកឧត្តម កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រីបានស្វាគមន៍ចំពោះលទ្ធផលដែលក្រសួងអប់រំ យុវជន និងកីឡាទទួលបាននាពេលកន្លងមក បន្ទាប់ពីកិច្ចខិតខំប្រឹងប្រែងរបស់ក្រសួងអប់រំក្នុងការកែលម្អគុណភាពអប់រំនៅក្នុងប្រទេសកម្ពុជាឱ្យកាន់តែមានភាពល្អពីមួយឆ្នាំទៅមួយឆ្នាំផងដែរ។ ឯកឧត្តមក៏បានជំរុញដល់លោកគ្រូ អ្នកគ្រូត្រូវយកចិត្តទុកដាក់ក្នុងការបង្រៀនទោះ បីមានមជ្ឈដ្ឋានមួយចំនួនថាគុណភាពអប់រំនៅកម្ពុជានៅមានកម្រិតក៏ដោយ។

សូមបញ្ជាក់ថា បច្ចុប្បន្នសិស្សសរុបនៅគ្រប់ភូមិសិក្សាសាធារណៈ និងឯកជន ចាប់ពី មត្តេយ្យសិក្សា ដល់មធ្យមសិក្សា មានចំនួន៣.៥៦៧.១០៥នាក់ ក្នុងនោះ ស្រី១.៧៦៦.៣៧៩ នាក់ ស្មើនឹង ៤៩.៥ភាគរយ។ ចំពោះគ្រឹះស្ថានឧត្តមសិក្សាទូទាំងប្រទេសមានចំនួន១២៥ ក្នុងនោះ គ្រឹះស្ថានឧត្តមសិក្សារដ្ឋចំនួន៤៨ និងឯកជនចំនួន៧៧។ ដោយឡែកនិស្សិតកំពុងសិក្សា នៅថ្នាក់ឧត្តមសិក្សាមានចំនួន២១១.៤៨៤នាក់ ស្រី៩៨.៦៣០នាក់ ស្មើ៤៦.៦៣ភាគរយ ក្នុងនោះ និស្សិតបរទេសអាហារូបករណ៍មានចំនួន១៥៨នាក់ ស្រី៦០នាក់ ស្មើ ៣៧.៩៧ភាគរយ។ ចំណែកបុគ្គលិកអប់រំសរុបនៅទូទាំងប្រទេសមានចំនួន១២០.២៩៩នាក់ ស្រី៥៤.៩៥៨នាក់ (ត្រូវជា៤៥.៧ភាគរយ) ក្នុងនោះ ថ្នាក់ជាតិចំនួន៣.៤១៦នាក់ ស្រី៩៣៩ នាក់ (ត្រូវជា២៧.៥ភាគរយ) និងថ្នាក់ក្រោមជាតិចំនួន១១៦.៨៨៣នាក់ ស្រី៥៤.០១៩នាក់ (ត្រូវជា៤៦.២ភាគរយ)៕

ក្រសួងអប់រំ បានប្រកាសនៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២០នេះថា សាលារៀនសាធារណៈនិងសាលាឯកជនទាំងបីកម្រិតមួយចំនួន នឹងបើកដំណើរការជាថ្មី នៅថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២០ខាងមុខ។ ការបើកដំណើរការសាលារៀនដំណាក់កាលទី២នេះ ពុំអនុវត្តពេញផ្ទៃប្រទេសនោះទេ។ ក្រោយពីមានកិច្ចប្រជុំយ៉ាងម៉ត់ចត់ជុំវិញការងារ បើកសាលារៀនជាថ្មីក្នុងដំណាក់កាលទី២នេះ ក្រសួងអប់រំបានបញ្ជាក់ថា នឹងមានសាលារៀនរដ្ឋមួយចំនួន និងមានសាលារៀនឯកជនមួយចំនួនអាចបើកដំណើរការជាថ្មីសម្រាប់ការចូលរៀនរបស់សិស្សទាំងបីកម្រិត រាប់បញ្ចូលទាំងថ្នាក់មត្តេយ្យសិក្សា ថ្នាក់បឋមសិក្សា និងថ្នាក់មធ្យមសិក្សា។ជុំវិញរឿងបើកសាលារៀនដំណាក់កាលទី ២នេះ លោក រស់ សុវាចា អ្នកនាំពាក្យក្រសួងអប់រំ បានលើកឡើងដែរថា ពុំទាន់អាចអនុវត្ត បានលើផ្ទៃប្រទេសនោះទេ ដោយមានតែសាលា

រៀនសាធារណៈមួយចំនួន និងសាលារៀនឯកជនមួយចំនួនប៉ុណ្ណោះ និងត្រូវរៀនបែបចម្រុះនិងត្រូវគោរពតាមគោលការណ៍ប្រតិបត្តិស្តង់ដារ សម្រាប់ដំណើរការសាលារៀនឡើងវិញក្នុងបរិបទកូវីដ ១៩។ សម្រាប់សាលាដែលទទួលបានការអនុញ្ញាតសម្រាប់ដំណាក់កាលទី២នេះ បើតាមសេចក្តីណែនាំលេខ ៣៧, ៣៨ និង៣៩ ស្តីពីការបើកដំណើរការឡើងវិញគ្រឹះស្ថានមត្តេយ្យសិក្សា និងសេវាអប់រំកុមារតូច គ្រឹះស្ថានបឋមសិក្សា គ្រឹះស្ថានមធ្យមសិក្សាក្នុងដំណាក់កាលទី ២ បញ្ជាក់ថា ក្នុងមួយថ្នាក់អាចផ្ទុកសិស្សបានត្រឹមតែ ១៥នាក់ទៅ២០នាក់ប៉ុណ្ណោះដោយត្រូវមានគម្លាតសុវត្ថិភាពយ៉ាងហោច២ម៉ែត្រ និងត្រូវចាប់ផ្តើមការរៀន និងបង្រៀនជាថ្មីនៅថ្ងៃទី០៧ ខែកញ្ញារហូតដល់ដំណាច់ខែ វិច្ឆិកា។ក្រសួងអប់រំកាលពីម្សិលមិញ បានប្រកាសថា វិទ្យាល័យបាក់ទូក ជាសាលាដំបូងសម្រាប់ការបើកដំណើរការក្នុងខែកញ្ញាខាងមុខ។ចំពោះគោលការណ៍ប្រតិបត្តិស្តង់ដារ សម្រាប់ដំណើរការសាលារៀនឡើងវិញក្នុងបរិបទកូវីដ ១៩ ដែលក្រសួងអប់រំតម្រូវឱ្យសាលាត្រូវគោរពតាមនោះ មានចំណុចសំខាន់ជាច្រើនសម្រាប់ទប់ស្កាត់ការចម្លងជំងឺកូវីដ ១៩។ ក្នុងនោះ រួមមាន ការរៀបចំបរិស្ថានសិក្សាប្រកបដោយសុវត្ថិភាព បរិយាបន្ន ផាសុកភាព និងមេត្រីភាព ការថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់ និងរក្សាគម្លាតសុវត្ថិភាពក្នុងគ្រឹះស្ថានសិក្សា ការលើកកម្ពស់សុខភាពចាំបាច់ដល់អ្នកសិក្សា បុគ្គលិកអប់រំ និងបុគ្គលិកផ្សេងទៀត ការផ្គត់ផ្គង់ទឹកស្អាត និងបរិក្ខារអនាម័យ ការអប់រំសុខភាព និងបណ្តុះបណ្តាលអំពីវិធាននៃការបង្ការជំងឺកូវីដ ១៩ រួមទាំងចំណុចផ្សេងទៀត៕





*រូបភាព 50*

## ១៣.៣. និយមន័យ

### ១៣.៣.១.សាលារដ្ឋ( Public School )

សាលារដ្ឋគឺជាសាលាដែលបង្កើតឡើង និងប្រើប្រាស់ថវិការបស់រដ្ឋាភិបាល ហើយសិស្សទាំងអស់អាចចូលរៀនដោយមិនគិតថ្លៃ។



*រូបភាព 51*

### ១៣.៣.២. សាលាឯកជន ( Private School )

សាលាឯកជន គឺជាសាលាដែលមានលក្ខណៈស្វ័យតហើយបង្កើតថវិកាផ្ទាល់ខ្លួនតាមរយៈប្រភពផ្សេងៗគ្នា ដូចជាការបង់ថ្លៃសិក្សារបស់សិស្ស ជំនួយឯកជន និង អំណោយផ្សេងៗ។



*រូបភាព 52*

## ១៣.៤.ការប្រៀបធៀបពីភាពខុសគ្នារវាងសាលារដ្ឋនិងសាលាឯកជន

### ១៣.៤.១.ការអនុវត្តភាពជាអ្នកដឹកនាំ ( leadership Performance )

ជាទូទៅភាពជាអ្នកដឹកនាំឬការគ្រប់គ្រងរបស់សាលាឯកជនកាន់តែមានទំនោរទៅរកស្វ័យភាពធនធានសម្បូរបែប និង បរិស្ថានល្អស្អាតជាងសាលារដ្ឋ។គោលការណ៍ក្នុងការគ្រប់គ្រងសាលាឯកជនបានរាយការណ៍អំពីសាលារៀនមានស្វ័យភាពកាន់តែច្រើនក្នុងកម្មវិធីសិក្សា និងការវាយតម្លៃច្រើនជាងនាយកសាលានៅសាលារដ្ឋ។លើសពីនេះទៅទៀតពួកគេបានបញ្ជាក់ថាភាពជាអ្នកដឹកនាំនៅក្នុងសាលាឯកជននឹងមានធនធានអប់រំច្រើនជាងនិងមានការប្រកួតប្រជែងជាងសាលារដ្ឋ ( OECD ,2012 ) ។

នៅក្នុងផ្នែកការអនុវត្តភាពជាអ្នកដឹកនាំ ឪពុកម្តាយមានទំនុកចិត្តនឹងសាលាឯកជនហើយពួកគេជឿជាក់ថាកូនៗ របស់ពួកគេបានកសាងចំណេះដឹងនិងជំនាញពិតពីសាលាបឋមសិក្សាឯកជនទាំងនោះ។សាលាឯកជនមានផែនការមេរបស់ខ្លួនពេញមួយឆ្នាំ និងអាចទុកចិត្តបានជាងសាលារដ្ឋ។ដូចយើងបានដឹងហើយថាសាលាឯកជនពួកគេមានថវិកាផ្ទាល់ខ្លួនដើម្បីដំណើរការពីរមួយឆ្នាំទៅមួយឆ្នាំ។ពួកគេខ្លាំងណាស់ ហើយកសាងសក្តានុពលរបស់ពួកគេឱ្យកាន់តែប្រសើរឡើង។ផ្ទុយទៅវិញសាលារដ្ឋ

ពឹងផ្អែកលើគោលការណ៍ណែនាំរបស់រដ្ឋាភិបាលឬក្រសួង។ប្រសិនបើក្រសួងមិនមានថវិកាគ្រប់គ្រាន់ ដូច្នេះពួកគេចាំបាច់ត្រូវពន្យាពេលបេសកកម្ម។សាលារដ្ឋនេះមិនអាចអភិវឌ្ឍខ្លួនឯងឱ្យប្រសើរបានទេ។




*រូបភាព 53*

**១៣.៤.២.កម្មវិធីសិក្សា**( Curriculum )

ទាំងសាលាឯកជននិងសាលារដ្ឋតែងតែធ្វើតាមកម្មវិធីសិក្សាសំខាន់ៗហើយសិស្សក៏ទទួលបានលទ្ធផលខុសគ្នាដែរ។សាលាបឋមសិក្សាឯកជនមានទំនោរទៅនឹងកម្មវិធីសិក្សារឹងមាំនិងប្លែក( ឌីនជ័រ្វូបឺត២០០៣ )ឪពុកម្តាយតែងតែជឿជាក់ថាសាលាបឋមសិក្សាឯកជននឹងរៀបចំកម្មវិធីសិក្សាប្រកបដោយប្រសិទ្ធភាពសម្រាប់បម្រើក្នុងអង្គការ។សាលាបឋមសិក្សាឯកជនបានធ្វើសកម្មភាពបន្ថែមទៀតដើម្បីឱ្យសិស្សរីករាយក្នុងការរៀនសូត្ររបស់ពួកគេ។បន្ថែមពីនេះទៀតការប្រព្រឹត្ត និង កម្មវិធីសិក្សានៅសាលាឯកជនបឋមដើម្បីបំពេញ និងអភិវឌ្ឍសមត្ថភាព និងឱកាសរបស់សិស្ស។

**១៣.៤.៣.ប្រាក់ខែគ្រូបង្រៀន**( Teacher´s Salary )

ប្រាក់ខែនៅសាលារដ្ឋគឺជាហេតុផលដែលធ្វើឱ្យកម្រិតជីវភាពរបស់គ្រូបង្រៀនមានបញ្ហា។គ្រូខ្លះមានការងារ២ឬ៣ដោយសារជីវភាពរបស់ពួកគេ( ខេមបូឌាដេលី, ២០១៤ )។យោងទៅតាមហេតុផលនេះមានគ្រូជាច្រើនបានសម្រេចចិត្តបង្រៀននៅសាលឯកជនពីព្រោះពួកគេទទួលបានប្រាក់ខែច្រើន។នៅពេលពួកគេទទួលបានប្រាក់ខែច្រើនពួកគេតែងតែរៀបចំខ្លួនបានល្អជាមួយនឹងការបង្រៀនរបស់ពួកគេហើយធ្វើតាមការណែនាំនៅសាលាឯកជន។

តាមពិតប្រសិនគ្រូដែលបង្រៀននៅសាលឯកជនគឺជាគ្រូធ្មើមរបស់ពួកគេនឹងមានការលើកទឹកចិត្តឬប្រាក់លើកទឹកចិត្តផ្សេងៗសម្រាប់ប្រចាំខែនិងប្រចាំឆ្នាំ។វាជាប្រភេទនៃការជម្រុញទឹកចិត្តដែលល្អ។ហេតុអ្វីបានជាគ្រូល្អប្តូរទៅសាលាឯកជន និងគ្រូអសកម្មនៅសាលារដ្ឋ ?

### ១៣.៤.៤.លទ្ធផលរំពឹងទុករបស់សិស្ស( Student Outcome )

សាលាឯកជនមានគុណភាព និងមធ្យោបាយងាយស្រួលជាងសាលារដ្ឋ។ឪពុកម្តាយតែងតែយកចិត្តទុកដាក់លើការសិក្សារបស់កូនៗ ហើយពួកគេគិតថាសាលាឯកជនតែងតែប្រសើរសាលារដ្ឋ។ ពួកគេជឿថាប្រសិនបើកូនៗរបស់ពួកគេសិក្សានៅសាលាឯកជន នោះកូនៗរបស់ពួកគេនឹងមានវិន័យ សីលធម៌ កាន់តែមានភាពឯករាជ្យ និង រៀនសូត្រប្រកបដោយប្រសិទ្ធភាព( Bernal 2005 )។ការសិក្សានេះត្រូវបានបង្ហាញថាឪពុកម្តាយភាគច្រើនចូលចិត្តសាលាឯកជនពីព្រោះពួកគេមានទំនុកចិត្តលើសេវាកម្ម និង ការសម្របសម្រួលផ្សេងទៀត។លើសពីនេះសាលាឯកជនផ្តល់ជម្រើសកាន់តែច្រើនសម្រាប់សិស្ស ហើយធ្វើតាមអ្វីដែលសិស្សចង់បាន។

គុណភាពសាលាឯកជន គឺគ្រាន់តែជាកត្តាមួយ ប៉ុណ្ណោះ ប៉ុន្តែត្រូវប្រាកដថាកូនៗរបស់ពួកគេពេញចិត្តនឹងសកម្មភាពរៀនសូត្រ និង បរិយាកាសក្នុងការសិក្សារៀនសូត្រ។ទោះយ៉ាងណាការស្រាវជ្រាវនេះត្រូវបានបង្ហាញថាសាលាបឋមឯកជនបានដើរតួនាទីយ៉ាងសំខាន់ក្នុងការលើកកម្ពស់គុណភាពអប់រំ និងកត្តាដទៃទៀត។សាលាបឋមសិក្សាឯកជនបង្កើតទំនុកចិត្តដល់ឪពុកម្តាយ ហើយពួកគេនឹងបញ្ជូនកូនៗរបស់ពួកគេទៅសាលាបឋមសិក្សាឯកជន។



*រូបភាព 54*

### ១៣.៤.៥.គណនេយ្យភាព( ACCOUNTING )

សាលារៀនសាធារណៈត្រូវតែគោរពតាមច្បាប់នៃរដ្ឋសហព័ន្ធរដ្ឋនិងក្នុងស្រុកដែលរួមមានទាំងកូនក្មេងដែលបោះបង់ចោលមាត្រាទី 1 ។ល។ ចំនួនបទបញ្ជាដែលសាលារៀនសាធារណៈត្រូវគោរពគឺមានច្រើន។ លើសពីនេះទៀតសាលារៀនសាធារណៈក៏ត្រូវតែគោរពតាមអាគាររដ្ឋនិងអគារអគ្គីភ័យនិងអគ្គីសនីដូចជាសាលាឯកជនដែរ។

សាលារៀនឯកជនត្រូវសង្កេតច្បាប់សហព័ន្ធរដ្ឋនិងច្បាប់ក្នុងស្រុកដូចជារបាយការណ៍ប្រចាំឆ្នាំទៅ IRS ការថែរក្សាការចូលរួមរបស់រដ្ឋដែលទាមទារការចងក្រងនិងកំណត់ត្រាសុវត្ថិភាពនិងរបាយការណ៍ការអនុលោមតាមអគារមូលដ្ឋានភ្លើងនិងអនាម័យ។

មានបទបញ្ញាត្រួតពិនិត្យអធិការកិច្ចនិងការពិនិត្យឡើងវិញនៃដំណើរការរបស់សាលាឯកជននិងរដ្ឋ។

**សន្និដ្ឋាន**

ការជ្រើសរើសសាលារៀនសម្រាប់កុមារគឺមានសារៈសំខាន់ណាស់ ព្រោះវានឹង ជះឥទ្ធិពលដល់សិស្សនៅពេលពួកគេចូលរៀននៅឧត្តមសិក្សា។ការអភិវឌ្ឍរបស់សិស្សជាសាលាបឋមសិក្សាលើឥរិយាបថ និងអាកប្បកិរិយា ការយល់ដឹង ការលើកទឹកចិត្ត សកម្មភាពសិក្សារៀន និង សមត្ថភាពត្រូវបានយកចិត្តទុកដាក់ដោយឪពុកម្តាយភាគ ច្រើន(Sylva, 1994)។

**សំណួរ**

១.ដូចម្តេចដែលហៅថាសាលារដ្ឋ?

២.ដូចម្តេចដែលហៅថាសាលាឯកជន?

៣.តើមានសាលារដ្ឋ និង សាលាឯកជនប៉ុន្មាននៅកម្ពុជា?

៤.ចូរប្រៀបធៀបភាពខុសគ្នាសំខាន់ៗរវាងសាលារៀនរដ្ឋ និង សាលារៀនឯកជន?

# មេរៀនទី ១៤ គោលនយោបាយគ្រូបង្រៀន

## វត្ថុបំណង

បន្ទាប់ពីរៀនមេរៀននេះចប់ គរុនិស្សិតនឹងៈ

- រៀបរាប់បានពីនិយមន័យ ចក្ខុវិស័យ និងគោលបំណងនៃគោលនយោបាយគ្រូបង្រៀនតាមរយៈបទបង្ហាញរបស់គ្រូឧទ្ទេសបានត្រឹមត្រូវ
- កំណត់បានពីយុទ្ធសាស្ត្រសំខាន់ៗក្នុងការធ្វើឱ្យសម្រេចគោលដៅនៃគោលនយោបាយគ្រូបង្រៀនតាមរយៈកិច្ចការងារក្រុមបានត្រឹមត្រូវ
- មានគុណតម្លៃខ្ពស់បំពេញតួនាទីនិងភារកិច្ចដ៏សំខាន់ក្នុងការកសាងធនធានមនុស្សតាមរយៈការបង្រៀនប្រចាំថ្ងៃបានត្រឹមត្រូវ

## ១៤.១.សេចក្តីផ្តើម




*រូបភាព 56*

ការរីកចម្រើននៃវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា និងការស្វែងរកឧត្តមភាពនៅលើពិភពលោកបានជំរុញឱ្យប្រទេសនីមួយៗខិតខំធ្វើការប្រកួតប្រជែងផលិតផល និងសេវាកម្មរបស់ខ្លួន។ធនធានមនុស្សជាកម្លាំងចលករក្នុងការសម្រេចបំណងប្រាថ្នានេះ។គ្រូបង្រៀនត្រូវបានគេទទួលស្គាល់និងឱ្យតម្លៃខ្ពស់ថាមានតួនាទី និងភាពរីកចម្រើននៃវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា និងការស្វែងរកឧត្តមភាពនៅលើពិភពលោក បាន ជំរុញឱ្យប្រទេសនីមួយៗខិតខំធ្វើការប្រកួតប្រជែងផលិតផល និងសេវាកម្មរបស់ខ្លួន។ ធនធានមនុស្ស ជាកម្លាំងចលករក្នុងការសម្រេចបំណងប្រាថ្នានេះ។ គ្រូបង្រៀនត្រូវបានគេទទួលស្គាល់ និងឱ្យតម្លៃខ្ពស់ វាមានតួនាទី និងភារកិច្ចដ៏សំខាន់ក្នុងការកសាងធនធានមនុស្ស និងផ្តល់វិភាគទានដល់ការអភិវឌ្ឍ បុគ្គល គ្រួសារ សហគមន៍ សង្គមជាតិ និងសកល លោក។ ការទទួលស្គាល់នេះបាន

ស្តែងចេញតាមរយៈ ការប្រារព្ធទិវាគ្រូបង្រៀនជារៀងរាល់ឆ្នាំ។ ចំណេះដឹង ជំនាញ សីលធម៌ និងលក្ខណៈសម្បត្តិដែលជាតម្រូវការចាំបាច់សម្រាប់គ្រូបង្រៀនមានការប្រែប្រួលទៅតាមតម្រូវការក្នុងការអភិវឌ្ឍសង្គម សេដ្ឋកិច្ច វប្បធម៌ បច្ចេកវិទ្យានៃសង្គមពុទ្ធិ។

សហគមន៍អាស៊ានមានបំណងបណ្ឌិតជីវភាព និងសុខុមាលភាពប្រជាជនតាមរយៈសកម្មភាពជាច្រើនដូចជា ការលើកកម្ពស់ការវិនិយោគ វិស័យអប់រំ ការអភិវឌ្ឍន៍ធនធានមនុស្ស ការសិក្សាពេញ មួយជីវិត ការអនុវត្តវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាក្នុងគ្រប់សកម្មភាពអភិវឌ្ឍសង្គម សេដ្ឋកិច្ច។ ប្រការនេះ ទាមទារឱ្យមានការចូលរួមយ៉ាងសកម្មពីគ្រូបង្រៀន។ការសិក្សាក្នុងកំបន់ដោយប្រព័ន្ធវាយតម្លៃ និងវាស់វែងលទ្ធផលអប់រំ បានកំណត់គោលដៅក្នុងការអភិវឌ្ឍគោលនយោបាយគ្រូបង្រៀនដូចជាការទាក់ទាញបេក្ខជនដែលមានសមត្ថភាពឱ្យចូលប្រកបវិជ្ជាជីវៈជាគ្រូបង្រៀន ការបណ្តុះបណ្តាលនិងអភិវឌ្ឍសមត្ថភាព ការគាំទ្រនិងលើកទឹកចិត្ត និងការទទួលបានការដឹកនាំល្អ។ រាជរដ្ឋាភិបាលបានផ្តល់អាទិភាពក្នុងការកសាងសមត្ថភាព និងអភិវឌ្ឍធនធានមនុស្សតាម រយៈការពង្រឹងគុណភាពវិស័យអប់រំដែលមានចែងក្នុងមុំទី១នៃយុទ្ធសាស្ត្រចតុកោណ។ ច្បាប់ស្តីពីការអប់រំ មានគោលបំណងអភិវឌ្ឍធនធានមនុស្ស លើកកម្ពស់គុណភាពអប់រំ កំណត់សិទ្ធិនិងកាតព្វកិច្ចរបស់បុគ្គលិកអប់រំដូចជា សិទ្ធិទទួលបានតម្លៃជ្ជាជីវៈ សិទ្ធិអភិវឌ្ឍខាងវិជ្ជាជីវៈសិទ្ធិអភិវឌ្ឍស្តង់ដារ អប់រំ សិទ្ធិទទួលសេវាអប់រំផ្សេងៗ ការគោរពក្រមសីលធម៌វិជ្ជាជីវៈ និងការបំពេញកាតព្វកិច្ចផ្សេងទៀត។ ប្រការនេះរួមចំណែកបំពេញសេចក្តីត្រូវការរបស់គ្រូបង្រៀននិងអ្នកសិក្សាឱ្យទទួលបាននូវចំណេះដឹង ជំនាញ សីលធម៌ និងមានលទ្ធភាពចូលរួមក្នុងការអភិឌ្ឍប្រទេសជាតិប្រកបដោយគុណភាព។ ក្រសួងអប់រំ យុវជន និងកីឡាបានរៀបចំគោលនយោបាយ និងលខិតបទដ្ឋានគតិយុត្តជាច្រើន រួមមាន ផែនការយុទ្ធសាស្ត្រវិស័យអប់រំ គោលនយោបាយស្តីពីធនធានមនុស្សក្នុងវិស័យអប់រំ និង គោលខយោបាយផ្សេងៗទៀត ។ដើម្បីឆ្លើយតបនឹងបរិបទនេះ ក្រសួងបានរៀបចំគោលនយោបាយ ស្តីពីគ្រូបង្រៀន ដើម្បីរួមចំណែកអភិវឌ្ឍធនធានមនុស្សឱ្យមានបុគ្គលិកលក្ខណៈពេញលេញ។ គោលនយោបាយស្តីពីគ្រូបង្រៀនមានវិសាលភាពលើការអេប់រំសាធារណៈនិងឯកជនចាប់ពី មត្តេយ្យសិក្សាដល់មធ្យមសិក្សាទុតិយភូមិនិងគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន។

នៅក្នុងមេរៀនទាំងនេះនិស្សិតនឹងពិនិត្យមើលគោលនយោបាយគ្រូបង្រៀននៅកម្ពុជា។ ពួកគេនឹងអាចមើលឃើញអ្វីដែលបានរំពឹងពីពួកគេនិងអ្វីដែលពួកគេអាចធ្វើបានដើម្បីធ្វើឱ្យគោលនយោបាយនេះក្លាយជាការពិត។

សិស្សក៏នឹងទទួលបានការយល់ដឹងពីសិទ្ធិរបស់ពួកគេក្នុងនាមជាគ្រូបង្រៀននិងអនុវត្តសិទ្ធិទាំងនេះដើម្បីធ្វើឱ្យពួកគេក្លាយជាគ្រូដែលមានគុណភាពខ្ពស់បំផុត។

## ១៤.២.គោលនយោបាយគ្រូបង្រៀន

- គ្រូបង្រៀនត្រូវបានគេទទួលស្គាល់និងឱ្យតម្លៃខ្ពស់ថាមានតួនាទីនិងភារកិច្ចដ៏សំខាន់ក្នុងការកសាងធនធានមនុស្សនិងផ្តល់វិភាគទានដល់ការអភិវឌ្ឍបុគ្គល គ្រួសារ សហគមន៍ សង្គមជាតិ និងសកលលោក។

- ការទទួលស្គាល់នេះបានស្តែងចេញតាមរយៈការប្រារព្ធទិវាគ្រូបង្រៀនជារៀងរាល់ឆ្នាំ។
- ចំណេះដឹង ជំនាញ សីលធម៌ និងលក្ខណសម្បត្តិដែលជាតម្រូវការចាំបាច់សម្រាប់គ្រូបង្រៀនមានការប្រែប្រួលទៅតាមតម្រូវការក្នុងការអភិវឌ្ឍសង្គម សេដ្ឋកិច្ច វប្បធម៌ បច្ចេកវិទ្យាសង្គមពុទ្ធិ។
- រាជរដ្ឋាភិបាលបានផ្តល់អាទិភាពក្នុងការកសាងសមត្ថភាព និងអភិវឌ្ឍធនធាន មនុស្សតាមរយៈការពង្រឹងគុណភាពវិស័យអប់រំដែលមានចែងក្នុងមុំទី១នៃយុទ្ធសាស្ត្រចតុកោណ។
- ច្បាស់ស្តីពីការអប់រំមានគោលបំណងអភិវឌ្ឍធនធានមនុស្សលើកកម្ពស់គុណភាពអប់រំ កំណត់សិទ្ធិនិងកាតព្វកិច្ចរបស់បុគ្គលិកអប់រំដូចជា សិទ្ធិទទួលបានតម្លៃវិជ្ជាជីវៈ សិទ្ធិអភិវឌ្ឍវិជ្ជាជីវៈ សិទ្ធិចូលរួមអភិវឌ្ឍស្តង់ដារអប់រំសិទ្ធិទទួលសេវាអប់រំផ្សេងៗការគោរពក្រមសីលធម៌វិជ្ជាជីវៈ និងការបំពេញកាតព្វកិច្ចផ្សេងទៀត។
- ក្រសួងអប់រំ យុវជន និងកីឡាបានរៀបចំគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តជាច្រើនរួមមាន ផែនការយុទ្ធសាស្ត្រវិស័យអប់រំគោលនយោបាយស្តីពីធនធានមនុស្សក្នុងវិស័យអប់រំ និងគោលនយោបាយផ្សេងៗទៀត។ ដើម្បីឆ្លើយតបនឹងបរិបទនេះក្រសួងបានរៀបចំគោលនយោបាយស្តីពីគ្រូបង្រៀនដើម្បីរួមចំណែកអភិវឌ្ឍធនធានមនុស្សឱ្យមានបុគ្គលិកលក្ខណៈពេញលេញ។
- គោលនយោបាយស្តីពីគ្រូបង្រៀនមានវិសាលភាពលើការអប់រំសាធារណៈនិងឯកជនចាប់ពីមត្តេយ្យសិក្សាដល់មធ្យមសិក្សាទុតិយភូមិ និងគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន។

**១៤.៣.ចក្ខុវិស័យ**

គោលនយោបាយគ្រូបង្រៀនមានចក្ខុវិស័យ កសាងគ្រូបង្រៀនឱ្យមានចំណេះដឹង ជំនាញ សីលធម៌ និងមានសមត្ថភាពអនុវត្តវិជ្ជាជីវៈដោយមានការទទួលស្គាល់ពីសង្គម។

**១៤.៤.គោលបំណង និងគោលដៅ**

**១៤.៤.១.គោលបំណង**

គោលនយោបាយនេះមានគោលបំណងអភិវឌ្ឍគ្រូបង្រៀនឱ្យមានគុណភាព សមត្ថភាព ស្មារតីទទួលខុសត្រូវស្របតាមក្រមសីលធម៌វិជ្ជាជីវៈនិងផ្តល់លក្ខខណ្ឌចាំបាច់ក្នុងការបំពេញការងារប្រកបដោយប្រសិទ្ធភាពនិងភាពសក្តិសិទ្ធិ។

**១៤.៤.២.គោលដៅ**

- ទាក់ទាញនិងលើកទឹកចិត្តអ្នកមានសមត្ថភាពឱ្យប្រកបវិជ្ជាជីវៈជាគ្រូបង្រៀន
- ធានាការបណ្តុះបណ្តាលមុនពេលបម្រើការងារជាគ្រូបង្រៀន។
- ធានាការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀនក្នុងការបំពេញការងារជាប់ជាប្រចាំ
- ធានាលក្ខខណ្ឌចាំបាច់ចំពោះគ្រូបង្រៀនក្នុងការបំពេញការងារប្រកបដោយប្រសិទ្ធភាពនិងភាពសក្តិសិទ្ធិ។

## ១៤.៥.យុទ្ធសាស្ត្រសំខាន់ៗក្នុងការធ្វើឱ្យសម្រេចគោលដៅ

ដើម្បីសម្រេចគោលបំណងនិងគោលដៅខាងលើត្រូវមានយុទ្ធសាស្ត្រៈ

- កសាងលិខិតបទដ្ឋានគតិយុត្តនិងយន្តការ
- ទាក់ទាញអ្នកមានសមត្ថភាពឱ្យប្រកបវិជ្ជាជីវៈជាគ្រូបង្រៀន
- កំណត់ស្តង់ដារប្រព័ន្ធបណ្តុះបណ្តាលគ្រូបង្រៀន
- អភិវឌ្ឍគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន
- ធ្វើសនិទានកម្មគ្រូបង្រៀនឱ្យឆ្លើយតបទៅនឹងតម្រូវការរបស់គ្រឹះស្ថានសិក្សា
- អភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈគ្រូបង្រៀនក្នុងពេលបម្រើការងារ
- លើកទឹកចិត្តនិងរក្សាទុកគ្រូបង្រៀន
- ពង្រឹងប្រសិទ្ធភាពភាពជាអ្នកដឹកនាំសាលារៀន
- ពង្រឹងប្រព័ន្ធតាមដានត្រួតពិនិត្យនិងវាយតម្លៃគ្រូបង្រៀន។

**ក.កសាងលិខិតបទដ្ឋានគតិយុត្តនិងយន្តការ**

- ពិនិត្យឡើងវិញ កែលម្អ និងកសាងលិខិតបទដ្ឋានគតិយុត្ត
- កសាងយន្តការចាំបាច់សម្រាប់ផ្សព្វផ្សាយ អនុវត្ត គាំទ្រ ពិនិត្យតាមដាន និងវាយតម្លៃការ អនុវត្តគោលនយោបាយ
- កសាងផែនការសកម្មភាពជាក់លាក់ និងកម្មវិធីលម្អិតដើម្បីអនុវត្តគោលនយោបាយ។

**ខ.ទាក់ទាញអ្នកមានសមត្ថភាពឱ្យប្រកបវិជ្ជាជីវៈជាគ្រូបង្រៀន ជាក់ពីសង្គម**

- លើកកម្ពស់ជីវភាព តម្លៃវិជ្ជាជីវៈ សេចក្តីថ្លៃថ្នូរ និងការយកចិត្តទុក
- លើកកម្ពស់ការអភិវឌ្ឍវិជ្ជាជីវៈរបស់គ្រូបង្រៀន
- កំណត់លក្ខណវិនិច្ឆ័យនិងលក្ខខណ្ឌតម្រូវខាងវិជ្ជាជីវៈសម្រាប់ការជ្រើសរើស
- ធ្វើទំនើបកម្មស្តង់ដារកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនឱ្យឆ្លើយតបទៅនឹងតម្រូវការរបស់ ជាតិ និងការប្រកួតប្រជែងក្នុងតំបន់និងសកលលោក។

**គ.កំណត់ស្តង់ដារប្រព័ន្ធបណ្តុះបណ្តាលគ្រូបង្រៀន**

- ធ្វើបច្ចុប្បន្នភាពប្រព័ន្ធបណ្តុះបណ្តាលគ្រូបង្រៀន
- បង្កើនប្រសិទ្ធភាពកម្មសិក្សាមុនពេលតាំងស៊ប់ក្នុងក្របខ័ណ្ឌ
- កំណត់កម្រិតស្វ័យភាពរបស់គ្រូបង្រៀន។

**ឃ.អភិវឌ្ឍគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន**

- អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន
- ប្រែក្លាយសាលាគរុកោសល្យឱ្យទៅជាមជ្ឈមណ្ឌលអភិវឌ្ឍគ្រូបង្រៀន
- បង្កើនគុណវុឌ្ឍិនិងបទពិសោធបុគ្គលិកអប់រំនៅមជ្ឈមណ្ឌលអភិវឌ្ឍគ្រូបង្រៀន
- ពង្រឹងមុខងាររបស់មជ្ឈមណ្ឌលអភិវឌ្ឍគ្រូបង្រៀន ដើម្បីបន្តអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន។

**ង. ធ្វើសនិទានកម្មគ្រូបង្រៀនឱ្យឆ្លើយតបទៅនឹងតម្រូវការរបស់គ្រឹះស្ថានសិក្សា**

- ធ្វើទំនើបកម្មផែនការតម្រូវការនឹងផ្គត់ផ្គង់គ្រូបង្រៀនសម្រាប់ការបណ្តុះបណ្តាលមុនពេលបម្រើការងារ
- ពង្រឹងប្រសិទ្ធភាពការប្រើប្រាស់គ្រូបង្រៀនតាមនិយាមប្រើប្រាស់និងតាមគោលការណ៍
- លើកកម្ពស់ការគ្រប់គ្រងនិងរៀបចំក្របខ័ណ្ឌគ្រូបង្រៀន
- លើកកម្ពស់ដំណើរការនិងនីតិវិធីនៃការជ្រើសរើសនិងរក្សាទុកគ្រូបង្រៀនដែលមានស្នាដៃ ល្អសម្រាប់ជានាដ៏រន្តរភាពគ្រឹះស្ថានសិក្សា
- ធ្វើប្រតិភូកម្មការជ្រើសរើសនិងការគ្រប់គ្រងគ្រូបង្រៀនទៅថ្នាក់ក្រោមជាតិតាមគោលការណ៍កំណត់
- លើកកម្ពស់ការចូលរួមរបស់គណៈកម្មការទ្រទ្រង់សាលារៀននិងអ្នកពាក់ព័ន្ធក្នុងការបង្កើនសមិទ្ធិផលសិក្សារបស់សិស្ស។

**ច.អភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈគ្រូបង្រៀនក្នុងពេលបម្រើការងារ**

- បណ្តុះវប្បធម៌រៀនពេញមួយជីវិតដោយចេះចែករំលែកចំណេះដឹងនិងបទពិសោធជាមួយបណ្តាញក្រុមអ្នកអប់រំ
- រៀបចំយន្តការប្រកបដោយប្រសិទ្ធភាពដើម្បីគាំទ្រគ្រូបង្រៀននៅនឹងកន្លែងធ្វើការ
- រៀបចំគោលការណ៍ណែនាំស្តីពីតម្រូវការនិងផលប្រយោជន៍នៃការអភិវឌ្ឍវិជ្ជាជីវៈ។

**ឆ.លើកទឹកចិត្តនិងរក្សាទុកគ្រូបង្រៀន**

- លើកកម្ពស់លក្ខខណ្ឌធ្វើការងារនិងរស់នៅរបស់គ្រូបង្រៀនតាមរយៈការផ្តល់បៀវត្ស លាភការសុខុមាលភាពសង្គម អត្ថប្រយោជន៍ទូទៅ និងអត្ថប្រយោជន៍ពេលចូលនិវត្ត ជាពិសេសអ្នកគ្រូនិងគ្រូបង្រៀនបម្រើការងារនៅតំបន់ដាច់ស្រយាលនិងតំបន់ជួបការលំបាក
- ទទួលស្គាល់និងជូនរង្វាន់ដល់គ្រូបង្រៀនដែលមានស្នាដៃល្អ
- លើកកម្ពស់ភាពរីកចម្រើននៃអាជីព ស្វ័យភាព និងការសម្រេចចិត្តក្នុងវិជ្ជាជីវៈរបស់គ្រូបង្រៀនដែលកំណត់ក្នុងច្បាប់សំដៅកែលម្អលទ្ធផលសិក្សារបស់សិស្ស។

**ជ.ពង្រឹងប្រសិទ្ធភាពភាពជាអ្នកដឹកនាំសាលារៀន**

- ពង្រឹងយន្តការភាពជាអ្នកដឹកនាំសាលារៀនឱ្យមានប្រសិទ្ធភាព
- ជានាសិទ្ធិរបស់គ្រូបង្រៀនស្របតាមច្បាប់ស្តីពីការអប់រំ
- ធ្វើឱ្យប្រសើរឡើងលក្ខខណ្ឌតម្រូវខាងវិជ្ជាជីវៈសម្រាប់ជ្រើសរើសបណ្តុះបណ្តាលបំពេញការងារនិងផលប្រយោជន៍សម្រាប់គ្រូឧទ្ទេសនិងគណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាសាធារណៈ
- កំណត់និងអនុវត្តវិធានការរដ្ឋបាលដល់គ្រូបង្រៀន គ្រូឧទ្ទេស និងគណៈគ្រប់គ្រងនៃគ្រឹះស្ថានសិក្សាសាធារណៈក្នុងការធ្វើសេចក្តីសម្រេចលើការគ្រប់គ្រងនិងអភិវឌ្ឍអង្គភាព។

**១៤.៦.ផែនការសកម្មភាព**

- ការបង្កើតយន្តការ

- ការបង្កើតក្របខណ្ឌគតិយុត្ត
- ការគាំទ្រហិរញ្ញវត្ថុ
- ការបណ្តុះបណ្តាលធនធានមនុស្ស
- ដំណើរការអនុវត្តគម្រោង

**ក.ការបង្កើតយន្តការ**

ពង្រឹងយន្តការដែលមានស្រាប់ ឬបង្កើតថ្មីដើម្បីជំរុញការអនុវត្តការពិនិត្យតាមដាន ការវាយតម្លៃនិងការផ្តល់អនុសាសន៍កែលម្អការអនុវត្តគោលនយោបាយស្តីពីគ្រូបង្រៀន៖

- នៅថ្នាក់ជាតិ នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ ជាសេនាធិការឱ្យក្រសួងអប់រំ យុវជន និងកីឡាទទួលបន្ទុកអនុវត្តសម្របសម្រួលពិនិត្យតាមដានវាយតម្លៃ និងលើកសំណើកែលម្អការអនុវត្តគោលនយោបាយដោយសហការជិតស្និទ្ធជាមួយអង្គភាពស្ថាប័នពាក់ព័ន្ធ
- នៅថ្នាក់ក្រោមជាតិ ប្រធានអង្គភាព គ្រឹះស្ថានសិក្សា ជាអ្នកទទួលបន្ទុកសម្របសម្រួលពិនិត្យតាមដានវាយតម្លៃ ណិងអនុវត្តគោលនយោបាយ។

**ខ.ការបង្កើតក្របខណ្ឌគតិយុត្ត**

- ប្រើរចនាសម្ព័ន្ធរដ្ឋបាលដែលមានស្រាប់ក្នុងករណីចាំបាច់អាចបន្ថែមតួនាទីនិងភារកិច្ចឬបង្កើតគណៈកម្មការនីមួយៗត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ក្រសួងអប់រំ យុវជន និងកីឡា
- គណៈកម្មការទាំងនេះត្រូវពិនិត្យឡើងវិញកែសម្រួលឬកសាងលិខិតបទដ្ឋានគតិយុត្តថ្មីចាំបាច់ដើម្បីធានាការអនុវត្តដោយជោគជ័យនូវគោលនយោបាយស្តីពីគ្រូបង្រៀនរួមទាំងកសាងឯកសារសម្រាប់ជាជំនួយដល់ការបណ្តុះបណ្តាល។

**គ.ការគាំទ្រហិរញ្ញវត្ថុ**

ការអនុវត្តគោលនយោបាយស្តីពីគ្រូបង្រៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិត្រូវប្រើប្រាស់ថវិការបស់ក្រសួងអប់រំ យុវជន និងកីឡា និងថវិកាដែលបានមកពីប្រភពផ្សេងៗទៀតសម្រាប់ដំណើរការងាររបស់ខ្លួន។

**ឃ.ការបណ្តុះបណ្តាលធនធានមនុស្ស**

ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយស្តីពីគ្រូបង្រៀន ត្រូវយកចិត្តទុកដាក់កសាងឯកសារសម្រាប់បំប៉នឬឧបករណ៍សម្រាប់ជាជំនួយដល់ការបណ្តុះបណ្តាល ការគ្រប់គ្រង និងការអភិវឌ្ឍគ្រូបង្រៀនឱ្យមានលក្ខណៈស្តង់ដារជាតិឆ្លើយតបស្តង់ដារតំបន់និងស្តង់ដារសកលលោក។ ការបណ្តុះបណ្តាលធនធានមនុស្សត្រូវអនុវត្តតាមមុខសញ្ញានិងខ្លឹមសារដូចខាងក្រោម៖

- នាយកគ្រឹះស្ថានសិក្សាសាធារណៈលើខ្លឹមសារចំណេះដឹង ជំនាញ ការស្រាវជ្រាវ ភាសាបរទេស បច្ចេកវិទ្យាព័ត៌មាន និងសមត្ថភាពទាក់ទងនឹងការងារគ្រប់គ្រង ភាពជាអ្នកដឹកនាំការពិនិត្យតាមដាន វង្វាយតម្លៃការប្រើប្រាស់ ការគ្រប់គ្រង និងអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈគ្រូបង្រៀន
- គ្រូឧទ្ទេសនៅមជ្ឈមណ្ឌលអភិវឌ្ឍគ្រូបង្រៀន លើខ្លឹមសារចំណេះដឹង ជំនាញ ការស្រាវជ្រាវ ភាសាបរទេស បច្ចេកវិទ្យាព័ត៌មាន និងសមត្ថភាពទាក់ទងនឹងមុខវិជ្ជាឯកទេស សមត្ថភាព

សម្របសម្រួល ការពិនិត្យតាមដាន និងវង្វាយតម្លៃបណ្តុះបណ្តាល ការអប់រំ និងការអភិវឌ្ឍគ្រូបង្រៀន

- មន្ត្រីផែនការអប់រំ លើខ្លឹមសារចំណេះដឹង ជំនាញ ការស្រាវជ្រាវ ភាសាបរទេស បច្ចេកវិទ្យាព័ត៌មាន និងសមត្ថភាពទាក់ទងនឹងការរៀបចំផែនការ បុគ្គលិក កាលវិភាគទិន្នន័យតម្រូវការ និងផ្គត់ផ្គង់គ្រូបង្រៀន
- មន្ត្រីអភិវឌ្ឍឬមន្ត្រីបណ្តុះបណ្តាលធនធានមនុស្សលើខ្លឹមសារចំណេះដឹង ជំនាញ ការស្រាវជ្រាវ ភាសាបរទេស បច្ចេកវិទ្យាព័ត៌មាន និងសមត្ថភាពទាក់ទងនឹងការវិភាគការងារ វិភាគតម្រូវឬមុខសញ្ញាដែលត្រូវបណ្តុះបណ្តាលតាមតម្រូវការរបស់គ្រឹះស្ថានសិក្សាតាមលក្ខណៈជាប្រព័ន្ធ និងវិធីផ្តល់ការបណ្តុះបណ្តាលឬអភិវឌ្ឍ
- គ្រូបង្រៀនទាំងអស់ត្រូវអភិវឌ្ឍលើខ្លឹមសារសមត្ថភាពវិជ្ជាជីវៈ ការស្រាវជ្រាវ ភាសាបរទេស បច្ចេកវិទ្យាព័ត៌មាន មានការគ្រប់គ្រងថ្នាក់រៀន គរុកោសល្យ វិធីសាស្ត្របង្រៀន បច្ចេកទេសដែលទាក់ទងនឹងការងារគ្រូបង្រៀន និងផលប្រយោជន៍ដែលទទួលបានពីគោលនយោបាយ។

**ង.ដំណើរការអនុវត្តគម្រោង**

ដើម្បីធានាការអនុវត្តគោលនយោបាយស្តីពីគ្រូបង្រៀនឱ្យបានជោគជ័យ និងមានប្រសិទ្ធភាពត្រូវយកចិត្តទុកដាក់លើ៖

- ការពិគ្រោះយោបល់ពីគ្រប់អ្នកពាក់ព័ន្ធលើការកសាងផែនការសកម្មភាពសម្រាប់អនុវត្តគោលនយោបាយស្តីពីគ្រូបង្រៀនសំដៅធ្វើឱ្យមានសុខដុមនីយកម្មមូលនិធិទ្រទ្រង់សនិទានកម្មការគ្រប់គ្រងនិងអភិវឌ្ឍគ្រូបង្រៀន ការអភិវឌ្ឍស្ថាប័ន ការអនុវត្តការងារវិមជ្ឈការនិងប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយនេះ
- ភាពស៊ីសង្វាក់គ្នារវាងកម្មវិធីនយោបាយនិងយុទ្ធសាស្ត្ររបស់រដ្ឋាភិបាលនិងរបស់ក្រសួងអប់រំ យុវជន និងកីឡា
- ការពិនិត្យឡើងវិញ ការវាយតម្លៃលើប្រសិទ្ធភាពនៃការអនុវត្ត និងអនុសាសន៍កែលម្អគោនយោបាយស្តីពីគ្រូបង្រៀន
- ការរៀបចំផែនការ

## សន្និដ្ឋាន

ក្រសួងអប់រំ យុវជន និងកីឡាបានរៀបចំគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តជាច្រើនរួមមាន ផែនការយុទ្ធសាស្ត្រវិស័យអប់រំគោលនយោបាយស្តីពីធនធានមនុស្សក្នុងវិស័យអប់រំ និងគោលនយោបាយផ្សេងៗទៀត។ដើម្បីឆ្លើយតបនឹងបរិបទនេះក្រសួងបានរៀបចំគោលនយោបាយស្តីពីគ្រូបង្រៀនដើម្បីរួមចំណែកអភិវឌ្ឍធនធានមនុស្សឱ្យមានបុគ្គលិកលក្ខណៈពេញលេញ។

គោលនយោបាយស្តីពីគ្រូបង្រៀនមានវិសាលភាពលើការអប់រំសាធារណៈនិងឯកជនចាប់ពីមត្តេយ្យសិក្សាដល់មធ្យមសិក្សាទុតិយភូមិ និងគ្រឹះស្ថានបណ្តុះបណ្តាល។

**សំណួរ**

១.តើគោលនយោបាយគ្រូបង្រៀនជាអ្វី?

២.ហេតុអ្វីចាំបាច់ត្រូវមានគោលនយោបាយគ្រូបង្រៀន?

៣.តើគោលនយោបាយគ្រូបង្រៀនមានចក្ខុវិស័យ និងគោលដៅដូចម្តេច?

៤.តើគោលនយោបាយគ្រូបង្រៀនមានយុទ្ធសាស្រ្តសំខាន់ៗដូចម្តេចខ្លះ?

៥.ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយស្តីពីគ្រូបង្រៀនតើការបណ្តុះបណ្តាលធនធានមនុស្សត្រូវអនុវត្តតាមមុខសញ្ញានិងខ្លឹមសារដូចម្តេច?

៦.ដើម្បីធានាការអនុវត្តគោលនយោបាយឱ្យបានជោគជ័យនិងមានប្រសិទ្ធភាពតើយើងត្រូវយកចិត្តទុកដាក់លើអ្វីខ្លះ?

## ឯកសារយោង


- Koehler, M. J., Mishra, P., Bouck, E. C., DeSchryver, M., Kereluik, K., Shin, T. S., & Wolf, L. G. (2011). Deep-play: Developing TPACK for 21st century teachers. *International Journal of Learning Technology*, *6*(2), 146-163.
- https://education.ams.com.kh/education-update/national/news/7-roles-of-teachers-in-the-modern-era/
- What is sustainable development? [ONLINE] Available at: https://www.iisd.org/about-iisd/sustainable-development
- What is education for sustainable development? [ONLINE] Available at: https://en.wikipedia.org/wiki/Education_for_sustainable_developmen
- The Three Pillars of Sustainability. 2015. The Three Pillars of Sustainability. [ONLINE] Available at: http://www.thwink.org/sustain/glossary/ThreePillarsOfSustainability.htm. [Accessed 10 October 2015].
- វិស័យអប់រំឆ្នាំ២០៣០ សេចក្តីប្រកាសទីក្រុង Incheon និងក្របខណ្ឌសម្រាប់សកម្មភាពឆ្ពោះទៅរកការអប់រំមានគុណភាព បរិយាបន្ន សមធម៌និងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា(UNESCO).
- https://books.google.com.kh/books?hl=en&lr=&id=T744OwXA3dcC&oi=fnd&pg=PP2&dq=Murray%27s+sustainable+self&ots=G2XyJxqrng&sig=BQnh0Z
- Major education theories
- https://www.leaderinme.org/blog/learning-theories/
- ឯកសារបណ្ឌិត សិត សេង (វិធីសាស្ត្ររៀបចំ និងដឹកនាំការបង្រៀននិងរៀន)
- ឯកសារបណ្ឌិត សុខ សូត្រ(ទ្រឹស្តីនៃការអប់រំ)
- https://hec.gov.pk/english/services/universities/RevisedCurricula/Documents/2011-2012/Education/CompEdu_Sept13.pdf
- UNICEF Cambodia/2018/Todd Brown
- Comparative Education
- New Generation School Policy
- ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០១៩-២០២៣: MoEYS's Strategic Plan 2019-2023
- https://www.moeys.gov.kh/index.php/kh/policies-and-strategies/3206.html#.X-AV2tgzY54
- ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០១៩-២០២៣

- https://www.moeys.gov.kh/index.php/kh/policies-and-strategies/3206.html#.X-AV2tgzY54
- Availableat:http://www.kapekh.org/en/what-we-do/16/?pro_id=20#:~:text=New%20Generation%20Schools%
- 20are%20a, standards%20of% 20governance%20and%20professionalism
- https://link.springer.com/chapter/10.1007/978-981-15-2137-9_6#:~:text=The%20New%2
- New Generation School Policy, Available at https://www.leaderinme.org/blog/learning-theories/
- School-based management manual by MoEYS and WB
- School-based management manual
- ឯកសារបណ្តុះបណ្តាលការគ្រប់គ្រងសាលារៀន(Workshop 2018)
- https://www.phnompenhpost.com/lift/strengthening-quality-and-building-confidence-state-schools?fbclid=IwAR0JXX5IXhCs_pVYCxBlNGQsIYh_P9xcm8-rUsFls8Obg_rWNJROmHz0TJE
- https://cambodiacomment.wordpress.com/2016/07/15/the-impact-of-private-primary-school-into-educational-system-in-cambodia/amp/?fbclid=IwAR3KSgzBUQh6sWXVBPHLEJiEHvSDfF9VxtynVXdlHt0DKGRSUQW-IdFTvTs
- https://pediaa.com/difference-between-government-school-and-private-school/amp/?fbclid=IwAR2VzokZX0NnSpW8gyKkwcWnmZKVwxUtw0PuSl8CzqJ5p0mxOC75fhuBC2Y
- Teacher policy